ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ តាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល







នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ 2012

**ជំពូកទី 1 បំណិនអាន និងសរសេរ**
**ជំពូកទី 2 បំណិនបកស្រាយបែបវិទ្យាសាស្ត្រ**
**ជំពូកទី 3 វិធីវិទ្យាសាស្ត្រ**
**ជំពូកទី 4 ការប្រៀបប្រដូចនិងគំរូតាង**
**ជំពូកទី 5 ល្បែងសិក្សា**
**ជំពូកទី 6 បំណិនឆ្លុះបញ្ចាំងគំនិតភាន់ច្រឡំ**

បោះពុម្ពផ្សាយដោយ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា

បោះពុម្ពនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៣ (បោះពុម្ពលើកទី២)

ឯកសារនេះត្រូវបានចងក្រង និងបោះពុម្ពផ្សាយក្រោមការឧបត្ថម្ភផ្នែកថវិការបស់អគ្គលេខាធិការដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងជំនួយមនុស្សធម៌ (DGD) និងជំនួយផ្នែកបច្ចេកទេសរបស់ការិយាល័យហ្វ្លេមីស៍សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងជំនួយការបច្ចេកទេស (VVOB)។ ខ្លឹមសារនៃការបោះពុម្ពផ្សាយនេះមិនស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋាភិបាលហ្វ្លេមីស៍ និងរដ្ឋាភិបាលបែលហ្សិកឡើយ។

**កំណត់សម្គាល់កម្មសិទ្ធិបញ្ញា**

រាល់ការបោះពុម្ពផ្សាយឯកសារត្រូវបានធ្វើឡើងដោយអនុលោមតាមអាជ្ញាប័ណ្ណ:
Creative Commons Attribution-Non Commercial-Share Alike 3.0 Unported License

លើកលែងតែឯកសារដែលមិនបានរាប់បញ្ចូលនិងបញ្ជីរក្សាសិទ្ធខាងក្រោម។ មានន័យថាអ្នកអាចចែកចាយ ថតចម្លង ប្រែសម្រួល និងយកលំនាំតាមឯកសារនេះក្នុងន័យមិនរកកម្រៃដោយពុំចាំបាច់ស្នើសុំការអនុញ្ញាតជាមុនពីអ្នកបោះពុម្ពផ្សាយឡើយ តែប្រសិនបើអ្នកបង្កើតឬកែប្រែថ្មីអ្នកត្រូវតែសុំអាជ្ញាប័ណ្ណពីម្ចាស់ដើមក្នុងល័ក្ខខ័ណ្ឌដូចគ្នាដែលបានបញ្ជាក់ខាងលើ ។ សម្រាប់ព័ត៌មានបន្ថែមអំពីអាជ្ញាប័ណ្ណខាងលើ សូមចូលទៅកាន់គេហទំព័រ

http://creativecommons.org/licenses/by-nc-sa/3.0/

**ឯកសារមិនរាប់បញ្ចូល និងរក្សាសិទ្ធិ**

ឯកសារមួយចំនួនក្នុងការបោះពុម្ពផ្សាយនេះមិនស្ថិតក្រោមអាជ្ញាប័ណ្ណខាងលើឡើយ។ ទាំងនេះគឺជាឯកសាររបស់ភាគីទី៣ ដែលត្រូវបានប្រើប្រាស់ដោយត្រឹមត្រូវ និងទទួលបានការអនុញ្ញាត។ អ្នកបោះពុម្ពផ្សាយមិនទទួលខុសត្រូវចំពោះល័ក្ខខ័ណ្ឌច្បាប់ណាមួយ (រួមបញ្ចូលទាំងការធ្វេសប្រហែស) ចំពោះការបាត់បង់ ឬខូចខាតដែលកើតមានឡើងដោយសារការប្រើប្រាស់ផ្នែកណាមួយនៃឯកសារដែលទទួលបានពីភាគីទី៣ឡើយ។

# បុព្វកថា

ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្សគឺជាផ្រុងដ៏សំខាន់នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ការអប់រំវិទ្យាសាស្ត្រដែលផ្តោតលើគុណភាពគឺជាកត្តាមួយដ៏សំខាន់ដែលចូលរួមបង្កើតធនធានមនុស្សពោរពេញដោយចំណេះដឹង។ យើងមិនត្រឹមតែត្រូវការធនធានមនុស្សដែលបញ្ចប់ការសិក្សាហើយទទួលបានសញ្ញាប័ត្រមុខវិជ្ជាវិទ្យាសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាធនធានមនុស្សដែលអនុវត្តការអប់រំវិទ្យាសាស្ត្រដើម្បីចូលរួមបណ្តុះបណ្តាលសិស្សានុសិស្សឱ្យក្លាយជាពលរដ្ឋមានចំណេះដឹង មានគំនិតច្នៃប្រឌិតនិងចេះពិចារណាស៊ីជម្រៅ។

ដោយកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការអន្តរជាតិ ក្រសួងអប់រំយុវជននិងកីឡាបានអភិវឌ្ឍសម្ភារឧបទេសដើម្បីបំពេញតម្រូវការបង្រៀននិងរៀន។ ដំណើរការអភិវឌ្ឍសម្ភារឧបទេស និងការកសាងសមត្ថភាពកើតឡើងពីការប្រឹងប្រែងរួមគ្នារវាងជំនាញបច្ចេកទេសរបស់ក្រសួងអប់រំ និងអង្គការ VVOB។ កត្តានេះជំរុញឱ្យយើងអភិវឌ្ឍសម្ភារដោយផ្តោតលើចំណេះដឹងវិទ្យាសាស្ត្រមូលដ្ឋាន និងវិធីសាស្ត្របង្រៀនសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ។

ឯកសារនេះផ្តោតលើទ្រឹស្តីនិងការអនុវត្តនៃការអប់រំវិទ្យាសាស្ត្រ និងការលើកកម្ពស់បំណិនរកដំណោះស្រាយបំណិនបកស្រាយហេតុផល បំណិនអាន ភាពច្នៃប្រឌិត និងចំណេះដឹងវិទ្យាសាស្ត្រកាន់តែស៊ីជម្រៅ។ មិនតែប៉ុណ្ណោះឯកសារនេះក៏ផ្តល់ជូននូវដំណោះស្រាយមួយចំនួនដែលចូលរួមផ្សារភ្ជាប់ខ្លឹមសារមេរៀនវិទ្យាសាស្ត្រទៅនឹងជីវភាពរស់នៅរបស់សិស្ស។

ក្រសួងអប់រំយុវជននិងកីឡាមានក្តីសង្ឃឹមយ៉ាងមុតមាំថាលោកគ្រូអ្នកគ្រូដែលជាគ្រូឧទ្ទេសទាំងអស់ នឹងប្រើឯកសារនេះជាជំនួយក្នុងការបង្រៀននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដើម្បីចូលរួមលើកកម្ពស់គុណភាពនៃការអប់រំវិទ្យាសាស្ត្រនៅកម្ពុជា។

តាងនាមក្រសួងអប់រំយុវជននិងកីឡា ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះចំពោះក្រុមការងារ និងទីប្រឹក្សាអប់រំរបស់ការិយាល័យហ្វ្លេមីស៍សម្រាប់សហប្រតិបត្តិការអភិវឌ្ឍន៍និងជំនួយបច្ចេកទេស (VVOB) ដែលបានយកអស់កម្លាំងកាយចិត្តក្នុងការកសាងឯកសារដ៏មានសារសំខាន់នេះ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ឹម_សិទ្ធី**

# អារម្ភកថា

ឯកសារស្ដីពីការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលត្រូវបានចងក្រងឡើងក្នុងគោលបំណងចូលរួមជាជំនួយសម្រាប់គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនរបស់គាត់។ ក្នុង 6 ជំពូក យើងបង្ហាញជូនសកម្មភាពមួយចំនួនដើម្បីបង្កើនកម្រិតសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀនមេរៀនវិទ្យាសាស្ត្រ។

សកម្មភាពសិស្សមជ្ឈមណ្ឌលមានន័យថា សិស្សជាចំណុចកណ្ដាលនៃលំនាំសិក្សា។ លក្ខណៈសម្បត្តិមួយចំនួននៃវិធីសកម្មភាពសិស្សមជ្ឈមណ្ឌលរួមមាន:

- សិស្សចូលរួមសកម្ម
- សិស្សរៀនពីគ្នាទៅវិញទៅមក មិនត្រឹមតែរៀនពីគ្រូនោះទេ
- សិស្សទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួនកាន់តែច្រើនជាងមុន
- ភាពខុសគ្នារវាងសិស្សម្នាក់ៗត្រូវបានយកមកពិចារណា

សកម្មភាពក្នុងឯកសារនេះត្រូវបានអនុវត្តជាដំបូងនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគហ៊ុនសែនខេត្តកណ្ដាល។ ក្រុមការងារបច្ចេកទេសរួមមានគ្រូឧទ្ទេសនិងគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្របានសាកល្បងអនុវត្តសកម្មភាពទាំងនេះ រួចធ្វើការកែតម្រូវ ព្រមទាំងបញ្ចូលឧទាហរណ៍មួយចំនួនដែលទាក់ទងនឹងកម្មវិធីសិក្សា។

ឯកសារនេះរួមមាន 6 ជំពូកសំខាន់ៗគឺ:

ជំពូកទី1: បំណិនអាននិងសរសេរ បង្ហាញសកម្មភាពសម្រាប់បំផុសបំណិនរបស់សិស្សក្នុងការអាននិងសរសេរក្នុងមេរៀនវិទ្យាសាស្ត្រ។

ជំពូកទី2: បំណិនបកស្រាយបែបវិទ្យាសាស្ត្រ បង្ហាញសកម្មភាពសម្រាប់ពិភាក្សា និងវែកញែកហេតុផលអំពីប្រធានបទវិទ្យាសាស្ត្រ។

## អារម្ភកថា

ជំពូកទី3: វិធីវិទ្យាសាស្ត្រ ណែនាំវិធីដែលអាចជួយឱ្យសិស្សស៊ាំនឹងជំហាននីមួយៗក្នុងវិធីវិទ្យាសាស្ត្រ។

ជំពូកទី4: បំណិនឆ្លុះបញ្ចាំងគំនិតភាន់ច្រលំ ផ្តោតលើសកម្មភាពសម្រាប់បំផុសការគិតអំពីចំណេះដឹងបែបបញ្ញត្តិរបស់សិស្ស។

ជំពូកទី5: ការប្រៀបប្រដូច និងគំរូតាង ណែនាំសកម្មភាព និងឧទាហរណ៍អំពីលំនាំនៃការប្រើប្រាស់គំរូតាងនិងការប្រៀបប្រដូចក្នុងការបង្រៀនមេរៀនវិទ្យាសាស្ត្រ។

ជំពូកទី6: ល្បែងសិក្សា ពន្យល់វិធីបញ្ចូលល្បែងសិក្សាក្នុងការបង្រៀនមេរៀនវិទ្យាសាស្ត្រនិងផ្តល់ជូននូវឧទាហរណ៍មួយចំនួន។

យើងរង់ចាំទទួលនូវគំនិតយោបល់កែលម្អរបស់អ្នកដោយរីករាយ។

សូមជូនពរបុគ្គលិកសិក្សាទាំងអស់ សូមទទួលបាននូវបទពិសោធប្រកបដោយជំនឿចិត្ត និងការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រប្រកបដោយផ្លែផ្កាជាទីគាប់ចិត្ត ជាមួយនឹងការប្រើប្រាស់ឯកសារបំប៉ននេះ។

គណៈកម្មការនិពន្ធ

# គណៈកម្មការរៀបរៀងឯកសារ

**គណៈកម្មការគ្រប់គ្រង**

| | |
|---|---|
| ឯកឧត្តម អ៊ឹម សិទ្ធី | រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា |
| ឯកឧត្តម ណាត ប៊ុនរឿន | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |

**គណៈកម្មការត្រួតពិនិត្យ**

| | |
|---|---|
| លោក លាង សេងហាក់ | ប្រធាន នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| លោក អេង គឹមលី | ប្រធាន នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| លោក អ៊ឹង ម៉ៅហុក | ប្រធាន នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |

**គណៈកម្មការនិពន្ធ**

| | |
|---|---|
| លោក Stefaan Vande Walle | ប្រធានសម្របសម្រួលកម្មវិធីSEAL ប្រចាំ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្តាល |
| កញ្ញា Veerle Cnudde | ប្រធានសម្របសម្រួលកម្មវិធីSEAL ប្រចាំ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្តាល |
| លោក អួន វីរៈ | ទីប្រឹក្សាបច្ចេកទេស VVOB |
| កញ្ញា ង៉ែត សុខានី | មន្ត្រីត្រួតពិនិត្យនិងវាយតម្លៃ VVOB |

**គ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ហ៊ុន សែន ខេត្តកណ្តាល**

| | | |
|---|---|---|
| លោក ម៉ម ផាអុល | លោក ម៉េង ភិរុណ | លោក ចាក់ សុភា |
| លោក បេ ប្រា | លោក សុខ សារឿន | លោកស្រី ឡុង ពន្និនី |
| កញ្ញា ហ៊ូ ច័ន្ទសារា | លោកស្រី សោម ដានី | លោក អឿ សុខម៉េង |
| លោកស្រី ស្រី ច័ន្ទសោភា | កញ្ញា វ៉េង ស្រីមន | លោក សៀង ប៊ុនធឿន |

**គ្រូវិទ្យាល័យ ហ៊ុន សែន សេរីភាព ខេត្តកណ្តាល**

| | |
|---|---|
| លោកស្រី គង់ សុវណ្ណរា | លោក ប៉ាង ស៊ាងហៃ |
| លោកស្រី ស៊ុន ច័ន្ទមូលី | លោកស្រី ប៉ែន រស្មី |

## គណៈកម្មការរៀបរៀងឯកសារ

**គ្រូអនុវិទ្យាល័យអនុវត្ត ខេត្តកណ្ដាល**

| | |
|---|---|
| លោកស្រី ឡុច សុធានី | លោកស្រី ម៉ម ម៉េតបូរាណ |
| លោកស្រី ម៉ន សុខា | លោក ផាន់ នី |

**គ្រូវិទ្យាល័យ ហ៊ុន សែន តាខ្មៅ ខេត្តកណ្ដាល**

| | |
|---|---|
| លោក ព្រំ វណ្ណារា | លោកស្រី ទូន វណ្ណៈ |
| លោកស្រី ផុន សុជាតិ | |

**គ្រូវិទ្យាល័យ ហ៊ុន សែន កំពង់កន្ទួត ខេត្តកណ្ដាល**

| | |
|---|---|
| លោក ម៉ែន និមល | លោកស្រី ឯក អមរា |
| លោកស្រី ជា យ៉េត | កញ្ញា ទឹម ប៊ុនថេន |

**គណៈកម្មការកែលម្អឯកសារ**

| | |
|---|---|
| លោក ម៉ែន វណ្ណារី | មន្ត្រីជំនាញ នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ |
| លោក សុខ សារឿន | មន្ត្រីជំនាញ នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ |
| លោក ស៊ិន វ៉ាត | មន្ត្រីជំនាញ នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ |
| លោក ចាន់ សុភាព | មន្ត្រីជំនាញ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| លោកស្រី អ៊ាន សារិន | មន្ត្រីជំនាញ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |

**អ្នករៀបរៀង**

| | |
|---|---|
| លោក ជា ផុន | អនុប្រធាននាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ |

**អ្នកបកប្រែ**

| | |
|---|---|
| លោក កែវ មនោ | ទីប្រឹក្សាបច្ចេកទេស VVOB |



## មាតិកា


ជំពូកទី1: បំណិនអាននិងបំណិនសរសេរ

សេចក្តីផ្តើម.....1

1. ខ្លឹមសារសំខាន់ៗ.....2

ការអានប្រកបដោយយុទ្ធវិធី.....2

សំណេរវិទ្យាសាស្ត្រ.....3

2. សកម្មភាព.....3

សកម្មភាពទី1: វិធីបង្កើតបណ្ណតូចៗ.....3

សកម្មភាពទី2: វិធីបំពេញសន្លឹកកិច្ចការ 3-2-1.....7

សកម្មភាពទី3: វិធីបំពេញចន្លោះ.....11

សកម្មភាពទី4: វិធីប្រមូលផ្តុំព័ត៌មាន.....13

សកម្មភាពទី5: វិធីកត់ត្រាតាមប្រព័ន្ធខរនែល (Cornell Note Taking).....17

ជំពូកទី2: បំណិនបកស្រាយបែបវិទ្យាសាស្ត្រ

សេចក្តីផ្តើម.....21

1. ខ្លឹមសារសំខាន់ៗ.....22

2. សកម្មភាព.....22

សកម្មភាពទី1: វិធីពិភាក្សាតាមបែបនំកង.....22

សកម្មភាពទី2: វិធីវេទិកាពិភាក្សា.....25



# មាតិកា


ជំពូកទី3: វិធីវិទ្យាសាស្ត្រ

សេចក្តីផ្តើម.....30

1. ខ្លឹមសារសំខាន់ៗ.....31

2. សកម្មផ្សេងៗនៃវិធីវិទ្យាសាស្ត្រ.....34

សកម្មភាពទី1: វិធីប្រើបណ្ណភ្លើងសញ្ញាចរាចរ.....34

សកម្មភាពទី2: វិធីព្យុះគំនិត.....37

សកម្មភាពទី3: វិធីធ្វើចំណែកថ្នាក់ (ចំណាត់ថ្នាក់បណ្ណ).....42

សកម្មភាពទី4: វិធីពិសោធន៍ព្រឹត្តិការណ៍ប្លែកៗ.....46



# មាតិកា

ជំពូកទី4: បំណិនផ្លុះបញ្ចាំងគំនិតភាន់ច្រឡំ
1. សេចក្តីផ្តើម.......50
រូបគំនូរតុក្កតាគំនិត.......52
2. វត្ថុបំណង.......55
3. សម្ភារ.......55
4. ដំណើរការ.......55
4.1. សកម្មភាពទី1: វិធីគិតជាបុគ្គល.......56
4.2. សកម្មភាពទី2: វិធីពិភាក្សាក្រុម.......59
4.3. សកម្មភាពទី3: វិធីអង្កេតពិសោធន៍.......62
4.4. សកម្មភាពទី4: វិធីពិភាក្សាក្រុមរួមជាមួយអង្កេតពិសោធន៍.......64
5. ពេលវេលា.......66
6. កម្មវិធីសិក្សា.......66
6.1. រូបវិទ្យា.......66
6.2. ជីវវិទ្យា.......67
6.3. ផែនដី និងបរិស្ថានវិទ្យា.......67
6.4. គីមីវិទ្យា.......67
7. សំណូមពរ.......67
8. ដំបូន្មានសំខាន់ៗ.......68



# មាតិកា


ឧបសម្ពន្ធ1: គំរូតុក្កតាគំនិតសម្រាប់មុខវិជ្ជារូបវិទ្យា....69
សេចក្តីផ្តើម....69
អុបទិច....70
1. វ៉ែនតាខ្មៅ....72
2. ស្ដូវ្យគ្រាស....72
3. ពិល....73
មេកានិច....74
4. ការធ្លាក់....76
5. បាល់ទាត់....76
6. រ៉ុកកែតអវកាស....77
7. យន្តហោះលឿន....77
កម្តៅ....78
8. ទឹកពុះ....80
9. ប៉ាន់តែ....80
សន្ទនីយ៍....82
10. ប៉ោងប៉ោង....84
អគ្គិសនី....86
11. កុងតាក់....88
12. រំហួរចរន្ត....88
13. ខ្សែចម្លងធំ....89
14. អេឡិចត្រូមេដែក....89



## មាតិកា

ឧបសម្ពន្ធ2: គំរូតុក្កតាគំនិតសម្រាប់មុខវិជ្ជាជីវវិទ្យា....................................90
សេចក្តីផ្តើម....................................................................90
រុក្ខជាតិ......................................................................92
1. ផ្លែប៉ោមរលួយ................................................................94
សារពាង្គកាយមនុស្ស.............................................................96
2. អង់ទីប្យូទិច.................................................................98
ការវិវត្តនិងការបន្តពូជ........................................................100
3. ជីវិតក្នុងត្រពាំង............................................................102

ឧបសម្ពន្ធ3: គំរូតុក្កតាគំនិតសម្រាប់មុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យា....................104
សេចក្តីផ្តើម...................................................................104
ប្រព័ន្ធព្រះអាទិត្យនិងសកល......................................................106
1. ចន្ទគ្រាស...................................................................108
ផែនដី និង បរិស្ថាន...........................................................110
2. ហេតុអ្វីបានជាមួយថ្ងៃមាន24 ម៉ោង ?.............................................112



## មាតិកា


ឧបសម្ពន្ធ4:គំរូតុក្កតាគំនិតសម្រាប់មុខវិជ្ជាគីមីវិទ្យា..........114
សេចក្តីផ្តើម..........114
ល្បាយ សមាសធាតុនិងលក្ខណៈនៃរូបធាតុ..........116
1. អង្គធាតុរាវ..........118
2. ទឹកល្អក់..........119
3. កំណជាញើស..........119
4. ការរលាយ..........120
5. ទឹកកករលាយ..........121
ប្រតិកម្មគីមី..........122
6. ដែកគោលច្រែះ..........124
7. ទៀនកំពុងឆេះ..........124



# មាតិកា


តេស្តគំនិត និងការបង្រៀនទៅវិញទៅមក.....126
1. សេចក្តីផ្តើមៈ តើអ្វីទៅជាតេស្តគំនិត?.....127
2. វត្ថុបំណង.....128
3. សម្ភារ.....128
4. របៀបប្រើសំណួរតេស្តគំនិត.....128
5. ពេលវេលា.....129
ឧទាហរណ៍ទី1: ហេតុអ្វីបានជាពេលយប់ងងឹត?.....130
ឧទាហរណ៍ទី2: រដូវនៅលើផែនដី.....130
ឧទាហរណ៍ទី3: ស្ទូឡូគ្រាស.....130
ឧទាហរណ៍ទី4: វដ្តទឹក/រំហួត.....130
ឧទាហរណ៍ទី5: ដើមកំណើតនៃប្រេង.....131
ឧទាហរណ៍ទី6: រស្មីសំយោគ.....131
ឧទាហរណ៍ទី7: ប្រដាប់រំលាយអាហារ.....132
ឧទាហរណ៍ទី8: ប្រព័ន្ធប្រសាទ.....132
ឧទាហរណ៍ទី9: ការរលាយ.....132
ឧទាហរណ៍ទី10: ទម្រង់អាតូម.....133
ឧទាហរណ៍ទី11: កម្លាំង.....133



## មាតិកា


ឧទាហរណ៍ទី12: សន្ទនីយ៍ស្តាទិច....134
ឧទាហរណ៍ទី13: អគ្គិសនី....134
ឧទាហរណ៍ទី14: បម្រែបម្រួលភាពរូប....134
ឧទាហរណ៍ទី15: មេកានិច....135
ឧទាហរណ៍ទី16: មេកានិច....135
ឧទាហរណ៍ទី17: កើតផ្កាសាយ....135
7. ដំបូន្មានសំខាន់ៗ....136
1. ឧបសម្ពន្ធ: បង្កើតតេស្តគំនិតដោយខ្លួនឯង....136
2. ឧបសម្ពន្ធ: បណ្ណសម្រាប់បោះឆ្នោតរើសចម្លើយ....138



# មាតិកា

ជំពូកទី 5: ការប្រៀបប្រដូចនិងគំរូតាង
សេចក្តីផ្តើម ......142
សកម្មភាព......144
ការសម្តែងតួ......144
សេចក្តីផ្តើម
វត្ថុបំណង
ដំណើរការ
សម្ភារ
ពេលវេលា
កម្មវិធីសិក្សា
1. សកម្មភាពទី1៖ការសម្តែងតួអំពីជំនោរសមុទ្រ......146
2. សកម្មភាពទី2៖ការសម្តែងតួតំណាងប្រតិកម្មគីមី......147



## មាតិកា


ជំពូកទី 6: ល្បែងសិក្សា

សេចក្តីផ្តើម....152

សកម្មភាព....154

1. ល្បែងលូប (loop)....154
2. ល្បែងប៊ីងហ្គោធាតុគីមី(គីមីវិទ្យា)....155
3. ល្បែងថាប៊ូ(Taboo)....157
4. ល្បែងភ្ញាន....160

ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ តាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល

ជំពូកទី 1

## បំណិនអាន និងសរសេរ







នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ 2012











# សេចក្តីផ្តើម



នៅក្នុងជំពូកនេះ យើងបង្ហាញសកម្មភាព 5 ដែលចូលរួមលើកកម្ពស់បំណិនអាននិងសរសេររបស់សិស្ស។ ជាមធ្យម សិស្សចំណាយពេលវេលាច្រើនដើម្បីអានឬសរសេរក្នុងអំឡុងម៉ោងសិក្សាមុខវិជ្ជាវិទ្យាសាស្រ្ត។ សកម្មភាពទាំងនេះនឹងជួយឱ្យគ្រូអាចបំប្លែងពេលវេលានេះទៅជាឱកាសសិក្សាយ៉ាងសកម្មរបស់សិស្ស។

កាន់តែជាក់លាក់ជាងនេះទៅទៀត ឯកសារនេះនឹងជួយឱ្យសិស្ស:

- អានអត្ថបទមួយយ៉ាងសកម្ម គឺមិនឈប់ត្រឹមការបកស្រាយអត្ថន័យរបស់ពាក្យប៉ុណ្ណោះទេ
- ជ្រើសរើសចំណុចខ្លឹមសារសំខាន់ៗនិងពាក្យគន្លឹះចេញពីក្នុងអត្ថបទ
- កត់ត្រាប្រកបដោយយុទ្ធវិធី
- ឆ្លុះបញ្ចាំងការទទួលបានចំណេះដឹងរបស់ពួកគេ ហើយកសាងចំណេះដឹងទាំងនេះ
- សរសេរអំពីវិទ្យាសាស្រ្តដោយប្រើពាក្យសម្តីផ្ទាល់ខ្លួន
- ប្រើភាពច្នៃប្រឌិតរបស់ខ្លួនដើម្បីសរសេរអត្ថបទវិទ្យាសាស្រ្ត

ការអាននិងសរសេរយ៉ាងសកម្មគឺជាសមាសភាពដ៏សំខាន់នៅក្នុងថ្នាក់រៀនមួយដែលមានលក្ខណៈសិស្សមជ្ឈមណ្ឌល។ សកម្មភាពទាំងនេះភ្ជាប់ទំនាក់ទំនងរវាងសិស្សនិងខ្លឹមសារមេរៀនកាន់តែជិតស្និទ និងជួយឱ្យគេអាចឆ្លុះបញ្ចាំងបាននូវលំនាំទទួលបានចំណេះដឹងរបស់ខ្លួន។

យើងខ្ញុំសង្ឃឹមថា ឯកសារនេះនឹងជាជំនួយដ៏មានប្រយោជន៍ដល់លោកគ្រូអ្នកគ្រូ។ យ៉ាងណាមិញ ឯកសារនេះពិតជាមានចំណុចមួយចំនួនដែលត្រូវកែលម្អ។ អាស្រ័យហេតុនេះ យើងខ្ញុំរីករាយស្វាគមន៍នូវគ្រប់មតិយោបល់កែលម្អ និងសំណូមពរផ្សេងៗ។





# I. ខ្លឹមសារសំខាន់ៗ

## ការអានប្រកបដោយយុទ្ធវិធី

សិស្សានុសិស្សជាច្រើនជឿថាពួកគេជាអ្នកអានដ៏ពូកែប៉ុន្តែតាមការពិត ពួកគេគ្រាន់តែជាអ្នក បកស្រាយអត្ថន័យនៃអត្ថបទតែប៉ុណ្ណោះ។ ការយល់ឃើញបែបនេះមានន័យថាសិស្សានុសិស្សទាំងនោះអាចបំប្លែងតួអក្សរទៅជាពាក្យ ប៉ុន្តែការអានអត្ថបទវិទ្យាសាស្ត្រមួយទាមទារលើសពីនេះទៅទៀត។ ដូចនេះ ប្រសិនបើសិស្សមិនសូវយល់ខ្លឹមសារអត្ថបទដែលគេបានអានទេនោះ ពួកគេមិនត្រូវបានចាត់ទុកថាអ្នកអានដ៏ពូកែនោះទេ ទោះបីជាពួកគេស្ទាត់ជំនាញក្នុងការបកស្រាយក៏ដោយ។ ជំពូកនេះនឹងលើកយកសកម្មភាពមួយចំនួនមកពិភាក្សា ដើម្បីជួយសិស្សដែលមិនសូវមានបំណិនក្នុងការអាន ឱ្យក្លាយជាអ្នកអានប្រកបដោយយុទ្ធវិធី។ តារាងខាងក្រោមនេះ ប្រៀបធៀបទម្លាប់អ្នកអានដែលមិនសូវមានបំណិននិងអ្នកអានដ៏ប៉ិនប្រសប់។ គ្រូចាំបាច់ត្រូវមានសមត្ថភាពគ្រប់គ្រាន់ដើម្បីសម្គាល់បុគ្គលិកលក្ខណៈទាំងនេះ ទើបពួកគាត់អាចធ្វើការវិនិច្ឆ័យរកឃើញបញ្ហាក្នុងការអានដែលសិស្សជួបប្រទះ ដើម្បីជួយឱ្យបំណិននៃការអាន របស់សិស្សមានការរីកចម្រើន។

| | | អ្នកអានធម្មតា | អ្នកអានប្រកបដោយយុទ្ធវិធី |
|---|---|---|---|
| មុនពេលអាន | វចនាសម្ព័ន្ធ | មិនយកចិត្តទុកដាក់ពិនិត្យវចនាសម្ព័ន្ធដែលរៀបចំដោយអ្នកនិពន្ធ | ពិនិត្យដោយយកចិត្តទុកដាក់នូវវចនាសម្ព័ន្ធមុនពេលអាន |
| | គោលដៅ | មិនមានគោលដៅជាក់លាក់ដើម្បីសម្រេចឱ្យបានក្រោយការអាន | កំណត់គោលដៅជាក់លាក់រួចទើបចាប់ផ្ដើមអាន |
| ពេលកំពុងអាន | កំណត់ត្រា | មិនកត់ត្រា | កត់ត្រាចំណុចសំខាន់ៗនិងសង្ខេបគំនិតសំខាន់ៗ |
| | ពាក្យគន្លឹះ | រំលងចោលនូវពាក្យដែលមិនយល់ | ព្យាយាមរកនិយមន័យនៃពាក្យថ្មី |
| | អំណានឡើងវិញ | បន្តអានតទៅទៀតទោះជាមិនយល់ចំណុចសំខាន់ៗក៏ដោយ | អានផ្នែកដែលមិនយល់ឡើងវិញ |
| | សំយោគ | មិនផ្សារភ្ជាប់ចំណេះដឹងថ្មីជាមួយចំណេះដឹងមានស្រាប់ | សំយោគចំណេះដឹងថ្មីបញ្ចូលជាមួយចំណេះដឹងដែលមានស្រាប់ |
| | ឆ្លុះបញ្ចាំង | មិនធ្វើការឆ្លុះបញ្ចាំងនូវអ្វីដែលគេបានអាន | បង្កើតសំណួរពីការអាន |
| | គូសចំណាំ | គូសពណ៌ចំណាំនិងគូសបន្ទាត់ពីក្រោមច្រើនពេក ឬមិនគូសទាល់តែសោះ | គូសពណ៌ចំណាំនិងគូសបន្ទាត់ពីក្រោមតែចំណុចសំខាន់ៗ |
| | ត្រួតពិនិត្យ | មិនធ្វើការត្រួតពិនិត្យការយល់ដឹង ឬធ្វើតែនៅចុងបញ្ចប់នៃការអាន | ត្រួតពិនិត្យចំណេះដឹងដោយធ្វើការសង្ខេបចំណុចសំខាន់ៗនិងឆ្លើយសំណួរ |

























| | | | |
|---|---|---|---|
| ក្រោយពេលអាន | វាយតម្លៃ | មិនមានគោលដៅ ដែលត្រូវវាយតម្លៃ | ត្រួតពិនិត្យឡើងវិញដើម្បី បញ្ជាក់ថាបានសម្រេចគោល ដៅដែលកំណត់ខាងដើម |
| | ការចងចាំ | ទន្ទេញពាក្យគ្រប់ម៉ាត់ ឬមិនចាំសោះតែម្តង | បង្ហាញចំណុចសំខាន់ៗដោយ ប្រើពាក្យសម្តីផ្ទាល់ខ្លួន |
| | ការពិភាក្សា | មិនធ្វើការពិចារណា ឬ ពិភាក្សាជាមួយអ្នកដទៃអំពីអ្វី ដែលគាត់អាននោះទេ | ពិភាក្សាជាមួយអ្នកដទៃអំពី អ្វីដែលគាត់បានអាន |
| | រំឭកឡើងវិញ | មិនរំឭកឡើងវិញនូវអ្វីដែល គាត់បានអាន | បញ្ចូលព័ត៌មានថ្មីទៅក្នុង ចំណេះដឹងដែលមានស្រាប់ |

## សំណេរវិទ្យាសាស្ត្រ

ការសរសេរមាននាទីសំខាន់ណាស់ក្នុងការសិក្សាអំពីវិទ្យាសាស្ត្រ។ អ្នកវិទ្យាសាស្ត្រទំនាក់ទំនងជាមួយគ្នាដោយប្រើសំណេរ។ សំណេរវិទ្យាសាស្ត្រជារចនាបថជាក់លាក់មួយ ប្រៀបបីដូចជារឿងប្រលោមលោក ឬអត្ថបទកាសែតដែលមានក្រឹត្យក្រមនិងការប្រើពាក្យពេចន៍ផ្ទាល់សម្គាល់ខ្លួនដូច្នោះដែរ។ ឧទាហរណ៍ អត្ថបទវិទ្យាសាស្ត្រមានរចនាសម្ព័ន្ធត្រឹមត្រូវមួយ ហើយជៀសវាងការប្រើពាក្យពេចន៍ដែលមិនចាំបាច់ ដោយផ្តោតសំខាន់ទៅលើរបៀបចងក្រងជាក់លាក់និងមានក្បួនខ្នាតត្រឹមត្រូវ។ មិនតែប៉ុណ្ណោះ សំណេរជាធាតុដ៏សំខាន់ក្នុងការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ។ សិស្សសរសេរនិយមន័យ កំណត់ត្រា ដំណើរការ សេចក្តីសន្និដ្ឋាន។ យ៉ាងណាមិញ ការកត់ត្រាពេលគ្រូកំពុងបង្រៀនមេរៀនវិទ្យាសាស្ត្រ ជានិច្ចកាល សិស្សត្រឹមតែចម្លងខ្លឹមសារនៅលើក្តារខៀន ដោយមិនភ្ជាប់ជាមួយនូវសកម្មភាពគិតពិចារណាអំពីខ្លឹមសារទាំងនោះទេ។ ឯកសារនេះបង្ហាញជូននូវសកម្មភាពមួយចំនួន ដែលអាចយកទៅអនុវត្តដើម្បីផ្លាស់ប្តូរការចម្លងខ្លឹមសារមេរៀន ទៅជាសកម្មភាពសិក្សាសកម្ម។

# II. សកម្មភាព

## 1. សកម្មភាពទី1: វិធីបង្កើតបណ្ណតូចៗ

### 1.1. សេចក្តីផ្តើម



បណ្ណតូចៗគឺជាបណ្ណដែលផ្ទៃម្ខាងមានសរសេរពាក្យគន្លឹះឬគំនិតវិទ្យាសាស្ត្រ ហើយនៅលើផ្ទៃម្ខាងទៀតមានសរសេរនិយមន័យនៃពាក្យឬគំនិតនោះ។ នេះគឺជាសកម្មភាពមួយ សម្រាប់បំផុសសកម្មភាពអាន និងដើម្បីអភិវឌ្ឍបំណិនអានរបស់សិស្ស។ បណ្ណដែលសិស្សបង្កើតឡើងក្នុងម៉ោងសិក្សាមួយ អាចយកទៅប្រើបានសម្រាប់ម៉ោងសិក្សាក្រោយៗទៀត។ សិស្សក៏អាចប្រើបណ្ណតូចៗនៅផ្ទះដើម្បីសិក្សាផងដែរ។





## 1.2. វត្ថុបំណង



- អានអត្ថបទយ៉ាងសកម្ម
- រកពាក្យគន្លឹះនិងចំណុចខ្លឹមសារសំខាន់ៗពីក្នុងអត្ថបទ
- ប្រាប់និយមន័យពាក្យគន្លឹះវិទ្យាសាស្ត្រថ្មីៗ
- កសាងចំណេះដឹងវិទ្យាសាស្ត្រដោយខ្លួនឯង
- អនុវត្តចំណេះដឹងនិងបទពិសោធន៍ដែលមានស្រាប់ក្នុងការអានរបស់ពួកគេ

## 1.3. ដំណើរការ



- គ្រូចង្អុលបង្ហាញអត្ថបទដែលសិស្សត្រូវអាន និងមូលហេតុដែលត្រូវអានអត្ថបទនេះ។ គ្រូប្រាប់ចំណងជើងអត្ថបទ និងមេរៀន ឬទ្រឹស្តីដែលអត្ថបទនេះស្ថិតនៅ។
- ដំបូងសិស្សអានអត្ថបទនោះរៀងៗខ្លួន។ បន្ទាប់មក ពួកគេអានអត្ថបទនោះម្តងទៀត ដោយល្បឿនយឺតជាងមុន និងផ្តោតទៅលើពាក្យគន្លឹះដែលមាននៅក្នុងអត្ថបទនោះ។ សិស្សគូសចំណាំពាក្យដែលគេគិតថាជាពាក្យគន្លឹះ។
- ដោយធ្វើរៀងៗខ្លួនឬជាក្រុម សិស្សបង្កើតបណ្ណតូចៗនៃពាក្យគន្លឹះទាំងនោះ ដោយប្រើព័ត៌មាននៅក្នុងអត្ថបទនិងចំណេះដឹងមានស្រាប់របស់គេ។ ចំពោះគ្រប់ពាក្យគន្លឹះដែលគេប្រើសិស្សព្យាយាមសរសេរនិយមន័យដ៏ល្អមួយដែលក្តោបអត្ថន័យនៃពាក្យគន្លឹះនោះ។

គ្រូអាចបញ្ជាក់ឱ្យបានច្បាស់ពីចំនួនបណ្ណដែលសិស្សត្រូវបង្កើត។ គ្រូក៏អាចត្រួតពិនិត្យពាក្យគន្លឹះដែលសិស្សបានគូសចំណាំក្រោយការអានលើកទីពីរហើយបើចាំបាច់គ្រូអាចផ្តល់យោបល់ខ្លះៗឱ្យសិស្សកែតម្រូវ។

នៅពេលដែលសិស្សបង្កើតបណ្ណតូចៗរួចរាល់ហើយ គ្រូចែកសិស្សជាក្រុមដើម្បីពិភាក្សាពីបណ្ណដែលពួកគេម្នាក់ៗបានបង្កើតឡើង ឬគ្រូអាចសួរទៅកាន់សិស្សទាំងអស់គ្នាក្នុងថ្នាក់តែម្តងដោយមិនចាំបាច់ចែកក្រុមពិភាក្សាក៏បាន។ នៅពេលដែលគ្រូផ្តល់ឱ្យពួកគេនូវបណ្ណតូចៗដែលត្រឹមត្រូវ សិស្សអាចពិភាក្សា:

- អំពីហេតុផលដែលពាក្យមួយចំនួនត្រូវបានគេប្រើក្នុងនិយមន័យនោះ។
- ផ្ទៀងផ្ទាត់ដើម្បីរកមូលហេតុដែលនិយមន័យមួយចំនួនត្រឹមត្រូវ ឬមិនត្រឹមត្រូវ។

ជាចុងក្រោយគ្រូធ្វើយ៉ាងណាឱ្យសិស្សទាំងអស់គ្នាមានបណ្ណតូចៗមួយឈុតដែលត្រឹមត្រូវ។ ប្រសិនបើសិស្សមានបណ្ណតូចៗដែលត្រឹមត្រូវហើយ គ្រូគួរលើកទឹកចិត្តសិស្សឱ្យប្រើបណ្ណទាំងនេះ។ បើចាំបាច់ ពួកគេត្រូវចម្លងនិយមន័យត្រឹមត្រូវចូលក្នុងសៀវភៅ។

គ្រូគួរផ្តល់ដំបូន្មានឱ្យសិស្សរក្សាទុកបណ្ណតូចៗរបស់គេក្នុងស្រោមសំបុត្រមួយ។ នៅក្នុងជំហានរំឭកមេរៀន គ្រូអាចស្នើឱ្យសិស្សប្រើបណ្ណតូចៗដែលគេបានបង្កើត ដាក់ច្របល់ចូលគ្នាដើម្បីរំឭកមេរៀនជាក្រុម។

## 1.4. សម្ភារ



យើងអាចបង្កើតបណ្ណតូចៗបានដោយកាត់ក្រដាសចតចម្លងទំហំA4ជា6ចំណែក។ដោយប្រើក្រដាសដែលមានកម្រាស់ក្រាស់បន្តិច បណ្ណតូចៗអាចរក្សាទុកសម្រាប់ប្រើប្រាស់បានយូរ។ គប្បីកាត់ក្រដាសធ្វើបណ្ណដែលមានទំហំសមល្មមដើម្បីផ្តល់ចន្លោះគ្រប់គ្រាន់ឱ្យសិស្សសរសេរ។

ប្រសិនបើគ្រូមានគម្រោងនឹងប្រើបណ្ណតូចៗពេញមួយឆ្នាំសិក្សា គប្បីប្រើក្រដាសពណ៌ផ្សេងៗគ្នាសម្រាប់មេរៀនផ្សេងៗគ្នា (ឧទាហរណ៍ បណ្ណពណ៌ខៀវសម្រាប់មេរៀនសន្ទនីយ៍និងសម្ពាធពណ៌លឿងសម្រាប់មេរៀនអុបទិច។ល។)។























## 1.5. ពេលវេលា



សកម្មភាពនេះសក្តិសមបំផុតសម្រាប់អនុវត្តនៅក្នុងជំហានទី3គឺជំហានបង្រៀនខ្លឹមសារ មេរៀនថ្មី។ គេក៏អាចប្រើសកម្មភាពនេះរួមជាមួយសកម្មភាពសន្លឹកកិច្ចការ 3-2-1 ផងដែរ ( សូមមើលសកម្មភាពសន្លឹកកិច្ចការ 3-2-1 ) ។ បណ្ណតូចៗទាំងអស់ អាចប្រើបាននៅក្នុងជំហានទី2 ដើម្បីរំឭកពាក្យគន្លឹះនៅក្នុងមេរៀនចាស់។ គ្រូគួរលើកទឹកចិត្តឱ្យសិស្សប្រើបណ្ណតូចៗដែលគេបានបង្កើតឱ្យ បានញឹកញាប់នៅពេលវេលាផ្សេងៗគ្នាពេញមួយឆ្នាំសិក្សា។ការរំឭកពាក្យគន្លឹះញឹកញាប់ជួយពង្រឹងការយល់ដឹងរបស់សិស្សអំពីខ្លឹមសារសំខាន់ៗនៃមេរៀន។

## 1.6. កម្មវិធីសិក្សា



### ជីវវិទ្យា

- វិធានការចម្រុះថែទាំដំណាំ ( ថ្នាក់ទី8 ជំពូកទី7 មេរៀនទី1, ឆ្នាំ2010 ): បណ្ណតូចៗដែលមានពាក្យគន្លឹះមួយចំនួនដូចជា ថ្នាំសម្លាប់សត្វល្អិតចង្រៃ ជី នីត្រាតកម្ម ដេដេតេ។ល។
- ប្រដាប់រំលាយអាហារ ( ថ្នាក់ទី7 ជំពូកទី4 មេរៀនទី1, ឆ្នាំ2009 ): បណ្ណតូចៗអំពីសរីរាង្គផ្សេងៗនិងមុខងារ។

### គីមីវិទ្យា

- ផលផ្ទះកញ្ចក់ ( ថ្នាក់ទី7 ជំពូកទី3 មេរៀនទី2, ឆ្នាំ2009 ): បណ្ណតូចៗដែលមានពាក្យគន្លឹះមួយចំនួនដូចជាផលផ្ទះកញ្ចក់ ឧស្ម័នផ្ទះកញ្ចក់ CFC បរិយាកាស ការកើនកម្តៅផែនដី។ល។

| ខាងមុខ | ខាងក្រោយ |
|---|---|
| កំហាប់ជាម៉ូល<br>M | $M = \frac{\text{ចំនួនម៉ូលធាតុរលាយ}}{\text{មាឌសូលុយស្យុង}}$ |

### ផែនដី និងបរិស្ថានវិទ្យា

- សំបកផែនដី ( ថ្នាក់ទី8 ជំពូកទី1 មេរៀនទី1, ឆ្នាំ2010 ):ពាក្យគន្លឹះសម្រាប់បង្កើតជាបណ្ណតូចៗរួមមានស្រទាប់លីតូស្វ៊ែរ អាស្តេណូស្វ៊ែរ ម៉ាក់ម៉ា ចរន្តវិលវល់ ភ្នំភ្លើង។ល។

### រូបវិទ្យា

- កម្លាំងទំនាញផែនដី ( ថ្នាក់ទី11 ជំពូកទី1 មេរៀនទី3,ឆ្នាំ2009 ): បណ្ណតូចៗដែលមានពាក្យគន្លឹះមួយចំនួនដូចជាកម្លាំងទំនាញផែនដី ល្បឿនចាកចេញពីកម្លាំងទំនាញ ទន្លាក់សេរី។ល។
- ការបញ្ជូនកម្តៅ ( ថ្នាក់ទី7 ជំពូកទី2 មេរៀនទី1-3, ឆ្នាំ2009 ): ពាក្យគន្លឹះសម្រាប់បង្កើតបណ្ណតូចៗមានដូចជាភាពចម្លងកម្តៅ ចរន្តវិលវល់ ការបញ្ចេញរស្មី កម្តៅ សីតុណ្ហភាព។ល។

| (ខាងមុខ) | (ខាងក្រោយ) |
|---|---|
| ច្បាប់ទីមួយញូតុន | ដោយមិនរងឥទ្ធិពលពីកម្លាំងខាងក្រៅបើសង្កេតពីតម្រុយនិចលភាពមួយ អង្គធាតុមួយដែលនៅនឹងថ្កល់ នឹងរក្សាភាពនឹងថ្កល់ដដែល រីឯអង្គធាតុមួយដែលមានចលនា នឹងរក្សាចលនារបស់ខ្លួនដដែលដោយល្បឿនថេរ (ល្បឿនថេរលើបន្ទាត់ត្រង់មួយ)។ ប្រសិនបើវត្ថុមួយមិនរងអំពើនៃកម្លាំងណាមួយទេនោះ សំទុះរបស់វាស្មើសូន្យ។ |

## 1.7. សំណូមពរ



គ្រូអាចទុកឱ្យសិស្សជាអ្នកសម្រេចចិត្តដោយខ្លួនឯងអំពី ចំនួនបណ្ណដែលសិស្សត្រូវបង្កើត ឬកំណត់ចំនួនជាក់លាក់ឱ្យសិស្សក៏បាន។





## 1.8. ដំបូន្មានសំខាន់ៗ



គ្រូត្រូវធ្វើយ៉ាងណាឱ្យសិស្សមានបណ្ណតូចៗដែលត្រឹមត្រូវនៅចុងបញ្ចប់នៃមេរៀន។ យ៉ាងណាមិញ ប្រសិនបើសិស្សបានដឹងជាមុនថាពួកគេនឹងទទួលបានបណ្ណតូចៗដែលត្រឹមត្រូវ ពួកគេអាចនឹងមិនសូវយកចិត្តទុកដាក់ប្រឹងប្រែងបង្កើតបណ្ណតូចៗឱ្យបានល្អដោយខ្លួនឯងនោះទេ។ ពន្យល់សិស្សពីសារសំខាន់នៃការបង្កើតបណ្ណតូចៗដ៏ល្អដោយខ្លួនឯងជាជាងការចម្លងចម្លើយត្រឹមត្រូវ។

គ្រូត្រូវជ្រើសរើសអត្ថបទដោយប្រុងប្រយ័ត្ន ដើម្បីឱ្យសិស្សអាចរកសេចក្តីពណ៌នាបានច្រើន។

គ្រូគប្បីត្រួតពិនិត្យដោយយកចិត្តទុកដាក់នូវដំណើរការដែលសិស្សជ្រើសរើស និងពន្យល់ពាក្យគន្លឹះ។ វត្ថុបំណងនៃសកម្មភាពនេះ មិនមែនត្រឹមតែចង់បានបណ្ណតូចៗដែលសិស្សធ្វើបាននោះទេ ប៉ុន្តែជាលំនាំដែលសិស្សអានអត្ថបទមួយយ៉ាងសកម្ម ស្វែងរកពាក្យគន្លឹះនិងរៀបចំចងក្រងជានិយមន័យបានល្អ។

នៅចុងបញ្ចប់នៃឆមាស គ្រូអាចរៀបចំពេលវេលារំឭកមេរៀន ដែលសិស្សប្រើបណ្ណរបស់ពួកគេទាំងអស់ដែលគេបានបង្កើត ដើម្បីរំឭកចំណុចសំខាន់ៗដែលគេបានសិក្សា។





















# 2. សកម្មភាពទី2: វិធីបំពេញសន្លឹកកិច្ចការ 3-2-1

## 2.1. សេចក្តីផ្តើម



វិធីបំពេញសន្លឹកកិច្ចការ 3-2-1 ជាសកម្មភាពមួយដ៏គួរឱ្យចាប់អារម្មណ៍និងងាយស្រួលអនុវត្តដែលបំផុសការអានយ៉ាងសកម្មរបស់សិស្ស ។ សិស្សត្រូវស្វែងរកធាតុសំខាន់ៗចំនួន3នៅក្នុងអត្ថបទដែលគេអាន។ ធាតុសំខាន់ទាំងបីនេះចោទសួរសិស្សអំពីខ្លឹមសារអត្ថបទដែលគេអានថែមទាំងចោទសួរពួកគេអំពីបទពិសោធន៍នៃការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេរៀងៗខ្លួន។ ពួកគេត្រូវរកចំណុចបីសម្រាប់ធាតុសំខាន់ទីមួយ ចំណុចពីរសម្រាប់ធាតុសំខាន់ទីពីរ និងចំណុចមួយសម្រាប់ធាតុសំខាន់ទីបី។

| | |
|---|---|
| 3 | ចំណុចដែលអ្នករៀនចេះ |
| 2 | ចំណុចដែលគួរឱ្យចាប់អារម្មណ៍ |
| 1 | សំណួរដែលអ្នកចង់សួរ |

## 2.2. វត្ថុបំណង



- អានអត្ថបទយ៉ាងសកម្ម។
- កំណត់ចំណុចខ្លឹមសារសំខាន់ៗនៅក្នុងអត្ថបទ។
- គិតនិងពិភាក្សាជាក្រុម។
- វាយតម្លៃការយល់ដឹងរបស់ខ្លួន។

## 2.3. ដំណើរការ



- គ្រូចែកសន្លឹកកិច្ចការ 3-2-1 ដែលមិនទាន់បំពេញឱ្យសិស្សមុននឹងឱ្យសិស្សអានអត្ថបទ ឬ សរសេរទម្រង់ 3-2-1 នៅលើក្តារខៀនហើយទុកឱ្យសិស្សចម្លងគំរូនេះ ចូលក្នុងសៀវភៅសរសេររបស់ពួកគេ។
- សិស្សចាប់ផ្តើមអានអត្ថបទវិទ្យាសាស្ត្រ។ បន្ទាប់មកគ្រូឱ្យសិស្សអានអត្ថបទដដែលនោះជាលើកទី2 ដោយផ្តោតទៅលើធាតុសំខាន់ៗនៅក្នុងសន្លឹកកិច្ចការ 3-2-1។ ក្រោយពេលអានចប់គ្រូត្រូវផ្តល់ពេលវេលាឱ្យសិស្សគ្រប់គ្រាន់ដើម្បីបំពេញព័ត៌មានចូលទៅក្នុងសន្លឹកកិច្ចការ 3-2-1។
- សិស្សប្រៀបធៀបសន្លឹកកិច្ចការ 3-2-1 របស់ខ្លួនជាមួយសិស្សដែលអង្គុយក្បែរឬធ្វើជាក្រុម។
- សួរទៅកាន់សិស្សមួយចំនួនក្នុងថ្នាក់ដើម្បីប្រៀបធៀបចម្លើយ។ តាមរយៈការស្តាប់ចម្លើយរបស់សិស្សផ្សេងទៀត សិស្សអាចទទួលបានចំណេះដឹងថ្មី ឬផ្លាស់ប្តូរការយល់ឃើញរបស់ខ្លួនចំពោះអត្ថបទ។

ធាតុដែលគ្រូអាចប្រើប្រាស់ដើម្បីបង្កើតសន្លឹកកិច្ចការ 3-2-1 មានដូចតទៅ:

- ព័ត៌មានដែលអ្នកមិនធ្លាប់ដឹងពីមុនមក
- ចំណុចគួរឱ្យចាប់អារម្មណ៍នៅក្នុងអត្ថបទ
- សំណួរដែលអ្នកចង់សួរ
- ពាក្យគន្លឹះ
- ចំណុចដែលអ្នកយល់ស្រប
- ចំណុចដែលអ្នកមិនយល់ស្រប
- គំនិតពិភាក្សាគាំទ្រ (ប្រឆាំង)
- ចំណុចដែលអ្នកចង់ប្រាប់នរណាម្នាក់
- ចំណុចដែលអ្នកចង់បានព័ត៌មានបន្ថែម
- ចំណុចដែលសំខាន់ចំពោះអ្នក
- ចំណុចដែលអ្នកនៅមិនទាន់យល់ច្បាស់

## 2.4. សម្ភារ



គ្រូអាចផ្តល់ឱ្យសិស្សនូវសន្លឹកកិច្ចការ 3-2-1 មិនទាន់បំពេញ(មានទំហំប៉ុនពាក់កណ្តាល ក្រដាសថតចម្លងទំហំ A4) ឬគាត់អាចគូរទម្រង់សន្លឹកកិច្ចការ 3-2-1 នៅលើក្តារខៀនឱ្យសិស្សចម្លងចូលក្នុងសៀវភៅសរសេររបស់ពួកគេក៏បាន។



## 2.5. ពេលវេលា



សូមអនុវត្តសកម្មភាពនេះនៅក្នុងជំហានទី3។ គ្រូអាចអនុវត្តសកម្មភាពនេះរួមជាមួយសកម្មភាពបណ្ណតូចៗ។

## 2.6. កម្មវិធីសិក្សា



### ផែនដី និងបរិស្ថានវិទ្យា

ផលផ្ទះកញ្ចក់ (ថ្នាក់ទី9 ជំពូកទី3 មេរៀនទី3, ឆ្នាំ2011) បំផុសសិស្សឱ្យគិតអំពីអ្វីដែលគេនៅមិនទាន់យល់អំពីផលផ្ទះកញ្ចក់

### ជីវវិទ្យា

វិធានការចម្រុះថៃទាំដំណាំ(ថ្នាកទី8 ជំពូកទី1 មេរៀនទី2, ឆ្នាំ2010) បំផុសការពិភាក្សាអះអាងរបស់សិស្សគាំទ្រនិងប្រឆាំងវិធានការចម្រុះថៃទាំដំណាំ

**កិច្ចការៈ បំពេញសន្លឹកកិច្ចការ 3-2-1 និងបង្កើតបណ្ណតូចៗ**

**វិធានការចម្រុះថៃទាំដំណាំ**

មុនឆ្នាំ1990 មិនទាន់មានធាតុគីមីកសិកម្មនៅក្នុងប្រទេសកម្ពុជានៅឡើយទេ ប៉ុន្តែនៅពេលដែលប្រទេសនេះចាប់ផ្តើមបើកចំហរទៅកាន់ពិភពលោក ប្រការនេះត្រូវបានផ្លាស់ប្តូរ។ នៅចន្លោះឆ្នាំ1989 និងឆ្នាំ1999 ការនាំចូលថ្នាំសម្លាប់សត្វល្អិតចង្រៃកើនឡើងច្រើនជាងទ្វេដង។ មិនមានគោលការណ៍សម្រាប់គ្រប់គ្រង ត្រូវបានគេបង្កើតឡើងនោះទេ មិនតែប៉ុណ្ណោះ ធាតុគីមីគ្រោះថ្នាក់ដែលហាមឃាត់នៅក្នុងប្រទេសផ្សេងៗទៀតត្រូវបាននាំចូលមកក្នុងប្រទេសកម្ពុជា។ ការសិក្សាមួយដែលត្រូវបានធ្វើឡើងនៅឆ្នាំ1999 អំពីសំណល់ពុលនៅក្នុងសាច់ត្រី បានរកឃើញជាតិដេដេតេក្នុងកម្រិតទាប ដោយទិន្នន័យដែលមានកម្រិតខ្ពស់បំផុតត្រូវបានកត់ត្រាពីខេត្តកំពង់ឆ្នាំង។ អ្នកស្រាវជ្រាវបានសន្និដ្ឋានថា កម្រិតនៃសំណល់ពុលគឺទាបជាងកម្រិត ដែលគេរកឃើញនៅតំបន់ផ្សេងៗទៀតនៃទ្វីបអាស៊ី ហើយកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានអនាម័យបំផុតនៅក្នុងតំបន់។ ប៉ុន្តែកម្ពុជាប្រហែលជាមានការលំបាកក្នុងការថែរក្សានូវល័ក្ខខ័ណ្ឌដ៏ល្អប្រសើរនេះ ព្រោះថាតាមរយៈរបាយការណ៍នាពេលថ្មីៗនេះរបស់អង្គការក្រៅរដ្ឋាភិបាលមួយរបស់ចក្រភពអង់គ្លេសគឺមូលនិធិយុត្តិធម៌បរិស្ថានគេបានរកឃើញថាមានការកើន





























## វិធានការចម្រុះថៃទាំដំណាំ

មុនឆ្នាំ1990 មិនទាន់មានធាតុគីមីកសិកម្មនៅក្នុងប្រទេសកម្ពុជានៅឡើយទេ ប៉ុន្តែនៅពេលដែលប្រទេសនេះចាប់ផ្តើមបើកចំហរទៅកាន់ពិភពលោក ប្រការនេះត្រូវបានផ្លាស់ប្តូរ។ នៅចន្លោះឆ្នាំ1989 និងឆ្នាំ1999 ការនាំចូលថ្នាំសម្លាប់សត្វល្អិតចង្រៃកើនឡើងច្រើនជាងទ្វេដង។ មិនមានគោលការណ៍សម្រាប់គ្រប់គ្រង ត្រូវបានគេបង្កើតឡើងនោះទេ មិនតែប៉ុណ្ណោះ ធាតុគីមីគ្រោះថ្នាក់ដែលហាមឃាត់នៅក្នុងប្រទេសផ្សេងៗទៀតត្រូវបាននាំចូលមកក្នុងប្រទេសកម្ពុជា។ ការសិក្សាមួយដែលត្រូវបានធ្វើឡើងនៅឆ្នាំ1999 អំពីសំណល់ពុលនៅក្នុងសាច់ត្រី បានរកឃើញជាតិដេដេតេក្នុងកម្រិតទាប ដោយទិន្នន័យដែលមានកម្រិតខ្ពស់បំផុតត្រូវបានកត់ត្រាពីខេត្តកំពង់ឆ្នាំង។ អ្នកស្រាវជ្រាវបានសន្និដ្ឋានថា កម្រិតនៃសំណល់ពុលគឺទាបជាងកម្រិត ដែលគេរកឃើញនៅតំបន់ផ្សេងៗទៀតនៃទ្វីបអាស៊ី ហើយកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសដែលមានអនាម័យបំផុតនៅក្នុងតំបន់។ ប៉ុន្តែកម្ពុជាប្រហែលជាមានការលំបាកក្នុងការថែរក្សានូវល័ក្ខខ័ណ្ឌដ៏ល្អប្រសើរនេះ ព្រោះថាតាមរយៈរបាយការណ៍នាពេលថ្មីៗនេះរបស់អង្គការក្រៅរដ្ឋាភិបាលមួយរបស់ចក្រភពអង់គ្លេសគឺមូលនិធិយុត្តិធម៌បរិស្ថានគេបានរកឃើញថាមានការកើនឡើងនៃការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតចង្រៃដែលមានគ្រោះថ្នាក់ ពាសពេញប្រទេស។

ជំហានមួយផ្សេងទៀតដើម្បីឈានឆ្ពោះទៅមុខត្រូវបានផ្តល់ដោយវិធានការចម្រុះថៃទាំដំណាំដែលមានវត្ថុបំណងលើកទឹកចិត្ត ការអនុវត្តការគ្រប់គ្រងសត្វល្អិតចង្រៃតាមវិធីធម្មជាតិ។ កម្មវិធីនេះចូលរួមកាត់បន្ថយជាអប្បបរមានូវការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតចង្រៃដោយការជ្រើសយកវិធីសាស្រ្តនិងអន្តរាគមន៍មួយចំនួនចំពោះការគ្រប់គ្រងសត្វល្អិតចង្រៃធាតុគីមីមួយចំនួនលើកលែងតែសមាសធាតុជីវសាស្រ្តសមាសធាតុដែលទាក់ទងនឹងវប្បធម៌ឬជាសមាសធាតុដែលមិនស្ថិតនៅយូរអង្វែង។ ឧទាហរណ៍មួយ គឺការផ្សព្វផ្សាយពីប្រព័ន្ធនៃការចិញ្ចឹមត្រីក្នុងស្រែព្រោះថាត្រីមានផលប្រយោជន៍ទាំងការគ្រប់គ្រងសត្វល្អិតចង្រៃ និងកំណើនទិន្នផលត្រីដែលជួយលើកស្ទួយជីវភាពកសិករ។

ឯកសារយោង Poole, 2005

- សន្លឹកកិច្ចការ 3-2-1

| | |
|---|---|
| 3 | ចូរសរសេរព័ត៌មាន3ចំណុចដែលអ្នករៀនចេះពីអត្ថបទ:<br>1. នៅចន្លោះឆ្នាំ1989-1999 ការនាំចូលថ្នាំសម្លាប់សត្វល្អិតចង្រៃកើនឡើងច្រើនជាង2ដង។<br>2. នៅឆ្នាំ1999 សំណល់ពុលនៅក្នុងប្រទេសកម្ពុជាមានកម្រិតទាបជាងប្រទេសផ្សេងៗទៀតនៅអាស៊ី។<br>3. អង្គការស្បៀងអាហារនិងកសិកម្ម ចង់ឱ្យប្រទេសកម្ពុជាគ្រប់គ្រងសត្វល្អិតចង្រៃដោយប្រើវិធីធម្មជាតិ។ |
| 2 | ចូរសរសេរពាក្យគន្លឹះចំនួន2ដែលអ្នកបានឃើញក្នុងអត្ថបទ:<br>• ថ្នាំសម្លាប់សត្វល្អិត<br>• វិធានការចម្រុះថៃទាំដំណាំ |
| 1 | ចូរបង្កើតសំណួរមួយទាក់ទងនឹងអត្ថបទ:<br>តើរដ្ឋាភិបាលគប្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនអំពីវិធានការចម្រុះថៃទាំដំណាំដោយរបៀបណា? |

- បណ្ណតូចៗ

| | |
|---|---|
| IPM | វិធានការចម្រុះថៃទាំដំណាំ<br><br>កម្មវិធីនេះមានគោលដៅកាត់បន្ថយការប្រើប្រាស់ធាតុគីមីនិងបង្កើនការប្រើប្រាស់វិធីគ្រប់គ្រងសត្វល្អិតចង្រៃតាមបែបធម្មជាតិវិញ |
| (ខាងមុខ) | (ខាងក្រោយ) |

| | |
|---|---|
| ដេដេតេ | ថ្នាំបំពុលសម្រាប់សម្លាប់សត្វល្អិត<br><br>សារធាតុនេះត្រូវបានហាមឃាត់នៅក្នុងប្រទេសជាច្រើន |
| (ខាងមុខ) | (ខាងក្រោយ) |



## 2.7. សំណូមពរ

គ្រូអាចឱ្យសិស្សបិទសៀវភៅរបស់ពួកគេ ឬទុកអត្ថបទនៅម្ខាងដើម្បីចៀសវាងសិស្សចម្លងនិយមន័យចេញពីក្នុងអត្ថបទ។ វត្ថុបំណងគឺសិស្សបង្កើតនិងបំពេញសន្លឹកកិច្ចការ 3-2-1 ដោយខ្លួនឯង។

គ្រូគួរគូសទម្រង់សន្លឹកកិច្ចការ 3-2-1 នៅលើក្ដារខៀនធំល្មមឱ្យសិស្សអាចបំពេញព័ត៌មានចូលបាន។ ធ្វើបែបនេះសិស្សអាចមើលឃើញដោយងាយនូវគំនិតរបស់សិស្សដទៃនិងចំណុចដែលខ្លួនមិនបានរកឃើញ ដើម្បីជួយសម្រួលការសំយោគក្នុងថ្នាក់ទាំងមូល។



## 2.8. ដំបូន្មានសំខាន់ៗ

លើកទឹកចិត្តសិស្សឱ្យចេះសរសេរដោយខ្លួនឯង ជាជាងការចម្លងតាមពាក្យពេចន៍ក្នុងសៀវភៅសិក្សា។























# 3. សកម្មភាពទី3: វិធីបំពេញចន្លោះ

## 3.1. សេចក្តីផ្តើម



នៅក្នុងរូបភាពខាងក្រោម មនុស្សភាគច្រើនមើលឃើញការេមួយ រង្វង់មួយ និងត្រីកោណមួយ ប៉ុន្តែប្រសិនបើអ្នកពិនិត្យមើលម្តងទៀត អ្នកនិងកត់សម្គាល់ថាមិនមានរូបរាងទាំងបីខាងលើនៅក្នុងដ្យាក្រាមនេះទេ។ ចិត្តរបស់អ្នកមើលឃើញគន្លឹះបន្ទាប់មកក៏ធ្វើសេចក្តីសន្និដ្ឋានអំពីបំណែកនៃរូបភាពដែលវាជួបប្រទះ។ ស្រដៀងគ្នានេះដែរ ចិត្តរបស់អ្នកក៏ធ្វើសេចក្តីសន្និដ្ឋានដែរ នៅពេលដែលអ្នកមិនបាន អានពាក្យគ្រប់ម៉ាត់នៅក្នុងអំនានរបស់អ្នក។ សមត្ថភាពក្នុងការធ្វើសេចក្តីសន្និដ្ឋានគឺជារង្វាស់មួយសម្រាប់កំណត់កម្រិតយល់ដឹងដែលទទួលបានពីការអាន។ សកម្មភាពនេះជួយអភិវឌ្ឍបំណិនក្នុងការធ្វើសេចក្តីសន្និដ្ឋាន។



ឯកសារយោង: Herr, 2008

## 3.2. វត្ថុបំណង



- អានអត្ថបទវិទ្យាសាស្រ្តយ៉ាងសកម្ម
- ទទួលបានចំណេះដឹងកាន់តែប្រសើរពីការអានអត្ថបទវិទ្យាសាស្រ្ត

## 3.3. ដំណើរការ



សិស្សធ្វើការរៀងៗខ្លួន ឬធ្វើជាក្រុម។ សិស្សអានអត្ថបទវិទ្យាសាស្រ្តបណ្តើរព្យាយាមបំពេញចន្លោះបណ្តើរ។ ពួកគេសរសេរពាក្យដែលខ្វះ នៅលើក្រដាសមួយសន្លឹក បន្ទាប់មកប្រៀបធៀបចម្លើយរបស់ពួកគេជាមួយសមាជិកក្រុមផ្សេងទៀត។ ចម្លើយផ្សេងគ្នាក៏អាចជាចម្លើយត្រឹមត្រូវដែរ ដរាបណាពាក្យទាំងនោះគោរពតាមអត្ថន័យរបស់អត្ថបទ។

ជាចុងក្រោយ គ្រូធ្វើការពិភាក្សារកចម្លើយត្រឹមត្រូវ ហើយទុកឱ្យសិស្សបំពេញពាក្យដែល ត្រឹមត្រូវចូលក្នុងចន្លោះ។ នៅក្នុងការពិភាក្សានេះ គ្រូអាចសួរសំណួរទៅកាន់សិស្សដូចខាងក្រោម:

- តើប្អូនៗបំពេញពាក្យបានត្រឹមត្រូវប៉ុន្មានចន្លោះ ?
- តើប្អូនៗបំពេញពាក្យដែលមានន័យដូចគ្នានឹងពាក្យដែលត្រឹមត្រូវបានប៉ុន្មានចន្លោះ ?ដើម្បីឱ្យការពិភាក្សា និងកែតម្រូវមានភាពងាយស្រួល គ្រូគប្បីប្រើលេខសម្គាល់ចន្លោះនីមួយៗ។

## 3.4. សម្ភារ



តើគ្រូអាចបង្កើតលំហាត់បំពេញចន្លោះដោយរបៀបណា ?

1. ជ្រើសរើសអត្ថបទមួយឬពីរកថាខ័ណ្ឌ ពីក្នុងសៀវភៅសិក្សាវិទ្យាសាស្រ្តរបស់ក្រសួងអប់រំ យុវជននិងកីឡា ឬអត្ថបទវិទ្យាសាស្រ្តផ្សេងៗទៀត។
2. ចម្លងប្រយោគទីមួយទាំងស្រុង។
3. ចម្លងប្រយោគទាំងអស់ លើកលែងតែប្រយោគចុងក្រោយ ដោយជំនួសរាល់ពាក្យទី5 ដោយចន្លោះមួយដែលមានប្រវែងប៉ុននឹងពាក្យនោះ។ អ្នកអាចលុបពាក្យប្រភេទណា ក៏បានដូចជាពាក្យគន្លឹះ កិរិយាស័ព្ទ គុណនាម។ល។
4. ចម្លងប្រយោគចុងក្រោយទាំងស្រុង។
5. ធ្វើបញ្ជីមួយដែលមានរាយពាក្យដែលអ្នកបានលុបនៅលើក្រដាសមួយសន្លឹក។



## 3.5. ពេលវេលា



អនុវត្តសកម្មភាពនេះរួមជាមួយសកម្មភាពអាននៅក្នុងជំហានទី3។ គ្រូគប្បីជ្រើសរើសយកអត្ថបទដែលមិនពិបាកយល់ពេកសម្រាប់សិស្ស។

គ្រូអាចបង្ហាញសេចក្ដីសង្ខេបខ្លឹមសារមេរៀនមួយ ក្នុងទម្រង់ជាអត្ថបទបំពេញចន្លោះនៅក្នុងជំហានទី4ផងដែរ។



## 3.6. កម្មវិធីសិក្សា



### ជីវវិទ្យា

- ប្រព័ន្ធទឹករងៃ (ថ្នាក់ទី9 ជំពូកទី3 មេរៀនទី7, ឆ្នាំ2008): សិស្សអានអត្ថបទសង្ខេបស្ដីអំពីលក្ខណៈពិសេសនៃប្រព័ន្ធទឹករងៃ។

### គីមីវិទ្យា

- អុកស៊ីសែន (ថ្នាក់ទី9 ជំពូកទី2 មេរៀនទី2, ឆ្នាំ2011): សិស្សអានអត្ថបទសង្ខេបនៃមេរៀនដែលពិពណ៌នាអំពីលក្ខណៈពិសេសរបស់ឧស្ម័នអុកស៊ីសែន។

### ផែនដី និងបរិស្ថានវិទ្យា

- ជីវិតនៅក្នុងមហាសមុទ្រ (ថ្នាក់ទី11 ជំពូកទី2 មេរៀនទី3, ឆ្នាំ2011): សិស្សអានអត្ថបទបំពេញចន្លោះមួយស្ដីអំពីជីវិតនៅក្នុងមហាសមុទ្រ។

### រូបវិទ្យា

- ច្បាប់ញូតុន (ថ្នាក់ទី8 ជំពូកទី2 មេរៀនទី3, ឆ្នាំ2010): សិស្សអានអត្ថបទបំពេញចន្លោះដែលសង្ខេបច្បាប់ញូតុន។

**ជីវវិទ្យា: បន្សាយ** (ថ្នាក់ទី8 ជំពូកទី3 មេរៀនទី1, ឆ្នាំ2010)
វិធីបំពេញចន្លោះក្នុងមេរៀនបន្សាយ

**បន្សាយ**

តើបន្សាយជាអ្វី ?

នេះជាឧទាហរណ៍មួយចំនួនអំពីបន្សាយ:

យើងអាចធុំក្លិនទឹកអប់របស់មនុស្សម្នាក់ដែលស្ថិតនៅចម្ងាយ 2 ម៉ែត្រពីយើងក្នុងបន្ទប់មួយ។ ក្លិនទឹកអប់បាន......(1)...... ចេញពីមនុស្សនោះ......(2)......ផ្នែកដទៃទៀតនៃបន្ទប់។ ...(3)...យើងដាក់ស្ករមួយ......(4)......ក្នុងកែវទឹកតែ......(5)......នឹងប្រែទៅជា......(6)......ដោយមិនបាច់កូរ។ ស្ករ......(7)......សាយពេញកែវទឹកតែ។ ......(8)...... បន្ទប់ទទួលភ្ញៀវយើង ......(9)...... ធុំក្លិនម្ហូបដែល ......(10)...... ចម្អិននៅក្នុងផ្ទះបាយ។ ......(11)...... ម្ហូបបានភាយចេញ ......(12)...... ផ្ទះបាយទៅដល់បន្ទប់ ......(13)......។ បើយើងបន្តក់ថ្នាំ ...(14)...... ទៅក្នុងកែវទឹក ......(15)...... រយៈពេលក្រោយមក យើង ......(16)......


















ទឹកក្នុងកែវប្តូរជា ...(17)... ក្រហមទាំងអស់។ ម៉ូលេគុល ......(18)...... បានសាយទៅក្នុង ......(19)...... ។

ឧទាហរណ៍នីមួយៗខាងលើនេះ ម៉ូលេគុលនៃសារធាតុមួយ ធ្វើចលនាពីតំបន់ដែលមានម៉ូលេគុលនៃសារធាតុនោះច្រើន (កំហាប់ខ្ពស់) ទៅតំបន់ដែលមានម៉ូលេគុលសារធាតុនោះតិចជាង ឬគ្មានម៉ូលេគុលសារធាតុនោះ (កំហាប់ទាប)។

ចម្លើយ:

| | | | | |
|---|---|---|---|---|
| 1. ភាយ | 2. ទៅ | 3. កាលណា | 4. ដុំ | 5. ទឹកតែ |
| 6. ផ្អែម | 7. ម៉ូលេគុល | 8. នៅក្នុង | 9. អាច | 10. គេ |
| 11. ក្លិន | 12. ពី | 13. ទទួលភ្ញៀវ | 14. ក្រហម | 15. មួយ |
| 16. សង្កេតឃើញ | 17. ពណ៌ | 18. ថ្នាំ | 19. ទឹក | |

## 3.7. សំណួមពរ



សិស្សអាចធ្វើការជាក្រុមដើម្បីបង្កើតសន្លឹកកិច្ចការបំពេញចន្លោះ។ បន្ទាប់មកក្រុមនីមួយៗ ធ្វើការផ្លាស់ប្តូរសន្លឹកកិច្ចការទៅវិញទៅមក ហើយព្យាយាមអាន (និងបំពេញ) សន្លឹកកិច្ចការនោះ។

## 3.8. ដំបូន្មានសំខាន់ៗ



សូមកុំមានការភាន់ច្រឡំរវាងសន្លឹកកិច្ចការបំពេញចន្លោះ និងសន្លឹកកិច្ចការសម្រាប់ប្រឡង។ នៅក្នុងសន្លឹកកិច្ចការប្រឡង សិស្សត្រូវបំពេញតែពាក្យគន្លឹះចូលក្នុងចន្លោះប៉ុណ្ណោះ។ រីឯសន្លឹកកិច្ចការបំពេញចន្លោះ ពាក្យត្រូវបានលុបចេញតាមលំដាប់មួយត្រឹមត្រូវដើម្បីបំផុស ចំណាប់អារម្មណ៍របស់សិស្សក្នុងការអាន។

ទោះជាគ្រូអនុវត្តសកម្មភាពសន្លឹកកិច្ចការបំពេញចន្លោះក្នុងម៉ោងបង្រៀនរបស់គាត់ក៏ដោយក៏គាត់នៅតែត្រូវការសកម្មភាពមួយចំនួនទៀតដូចជាពិសោធន៍ ឬការពិភាក្សាក្រុមដដែល។

# 4. សកម្មភាពទី4: វិធីប្រមូលផ្តុំព័ត៌មាន

## 4.1. សេចក្តីផ្តើម



សុភាសិតមួយពោលថា:

| | |
|---|---|
| “បើអ្នកប្រាប់ខ្ញុំ | ខ្ញុំអាចភ្លេច។ |
| បើអ្នកបង្ហាញខ្ញុំ | ខ្ញុំអាចចងចាំបាន។ |
| ឱ្យខ្ញុំចូលរួមសកម្មភាព | ខ្ញុំនឹងយល់។” |

វិធីមួយក្នុងចំណោមវិធីដ៏មានប្រសិទ្ធិភាពបំផុតដើម្បីចូលរួមក្នុងសកម្មភាពសិក្សាគឺការចែករំលែកការយល់ដឹងរបស់អ្នកជាមួយសិស្សផ្សេងទៀត។ នៅក្នុងលំនាំនៃការពន្យល់អ្នកដទៃ អ្នកកំពុងអភិវឌ្ឍការយល់ដឹងរបស់អ្នកឱ្យកាន់តែស៊ីជម្រៅថែមទៀត។ នៅក្នុងការអនុវត្តសកម្មភាពប្រមូលផ្តុំព័ត៌មាន សិស្សសិក្សាខ្លឹមសារវិទ្យាសាស្ត្រមួយ ហើយ

ពន្យល់សិស្សផ្សេងទៀត។សកម្មភាពនេះមានប្រសិទ្ធិភាពព្រោះទាមទារឱ្យសិស្សអាននិងចូលរួមយ៉ាងសកម្ម។ សកម្មភាពនេះក៏ជាសកម្មភាពមួយដ៏មានប្រជាប្រិយភាពដែលគ្រូបង្រៀននិយមប្រើ។



## 4.2. វត្ថុបំណង



- បង្កើនការយល់ដឹងអំពីមុខវិជ្ជាវិទ្យាសាស្ត្រ
- ចូលរួមយ៉ាងសកម្ម
- ហ្វឹកហាត់បំណិនទំនាក់ទំនងក្នុងការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ
- ចង្អុលបង្ហាញចំណុចពិបាកៗដល់សិស្ស

## 4.3. ដំណើរការ



- គ្រូបែងចែកសិស្សជាក្រុមជំនាញ និងក្រុមគ្រួសារ។
- សិស្សទាំងអស់គ្នាជាសមាជិកក្នុងក្រុមជំនាញ ហើយក៏ជាសមាជិកក្នុងក្រុមគ្រួសារដែរ។
- ដំបូង សិស្សអង្គុយពិភាក្សានៅក្នុងក្រុមជំនាញនីមួយៗ ដោយសិក្សាផ្នែកមួយនៃអត្ថបទវិទ្យាសាស្ត្រដែលគ្រូបានដាក់ឱ្យ។ លំនាំនៃការសិក្សានេះរួមមានការកំណត់ពាក្យគន្លឹះ សង្ខេបខ្លឹមសារ បង្កើតសំណួរនិងរកចម្លើយ។ គ្រូចល័តក្នុងថ្នាក់ដើម្បីជួយពន្យល់ក្រុមនីមួយៗ។
- សិស្សត្រឡប់ទៅក្រុមគ្រួសារវិញ។ សមាជិកម្នាក់ៗនៅក្នុងក្រុមគ្រួសារធ្លាប់ជាសមាជិកនៃក្រុមជំនាញផ្សេងៗគ្នា។ នៅពេលគេត្រឡប់មកក្នុងក្រុមគ្រួសារវិញ ពួកគេពន្យល់សមាជិកក្រុមគ្រួសាររបស់គេអំពីអ្វីដែលពួកគេបានសិក្សានៅក្នុងក្រុមជំនាញ។ នៅក្នុងការពន្យល់នោះ ពួកគេប្រើប្រាស់ពាក្យគន្លឹះ អត្ថបទសង្ខេបនិងសំណួររបស់ពួកគេដើម្បីជួយឱ្យសមាជិកដទៃទៀតនៅក្នុងក្រុមយល់ខ្លឹមសារអត្ថបទវិទ្យាសាស្ត្រដោយមិនចាំបាច់អានអត្ថបទនោះដោយខ្លួនឯង។
- គ្រូត្រួតពិនិត្យការយល់ដឹងរបស់សិស្សដោយសួរសិស្សក្នុងថ្នាក់រៀនទាំងមូល។ គ្រូគប្បីសួរសំណួរទៅកាន់សិស្សដែលមិនបានសិក្សាប្រធានបទដោយខ្លួនឯង ហើយគ្រាន់តែស្តាប់ការពន្យល់ពីសិស្សដទៃ។
- បន្ទាប់មក គ្រូគួរផ្តល់ពេលឱ្យសិស្សប្រាប់នូវបញ្ហាដែលពួកគេជួបប្រទះក្នុងពេលអនុវត្តសកម្មភាពនេះ ឬចំណុចដែលពួកគេគិតថាពិបាកពន្យល់។

តើអ្វីទៅជាក្រុមជំនាញ និងក្រុមគ្រួសារ ?

- នៅក្នុងក្រុមជំនាញ សិស្សអាននិងសិក្សាផ្នែកមួយនៃមេរៀនវិទ្យាសាស្ត្រ។
- នៅក្នុងក្រុមគ្រួសារ សិស្សពន្យល់គ្នាទៅវិញទៅមក អំពីផ្នែកនៃមេរៀនដែលពួកគេបានសិក្សានៅក្នុងក្រុមជំនាញ។
- មេរៀនវិទ្យាសាស្ត្រត្រូវបានបែងចែកជាផ្នែកតូចៗទៅតាមចំនួននៃក្រុមជំនាញ។

សកម្មភាពរបស់សិស្សនៅក្នុងក្រុមគ្រួសារ និងក្រុមជំនាញ:

| នៅក្នុងក្រុមជំនាញ | នៅក្នុងក្រុមគ្រួសារ |
|---|---|
| អានអត្ថបទ | ពន្យល់សិស្សនៅក្នុងក្រុមគ្រួសារដោយប្រើសម្ភារដែលបានរៀបចំនៅក្នុងក្រុមជំនាញ |
| សង្ខេបខ្លឹមសារ | |
| ធ្វើបញ្ជីពាក្យគន្លឹះ | |
| បង្កើតសំណួរ | |
| ឆ្លើយសំណួរទាំងនេះ | |

របៀបបែងចែកក្រុមគ្រួសារនិងក្រុមជំនាញ:

- ដំបូងគ្រូត្រូវធ្វើការសម្រេចចិត្តថាតើគាត់ចង់បែងចែកអត្ថបទជាប៉ុន្មានផ្នែក ?
- គ្រូកំណត់ចំនួនក្រុមជំនាញ។ ចំនួនក្រុមជំនាញយ៉ាងហោចណាស់គប្បីស្មើគ្នានឹងចំនួន អត្ថបទដែលបានបែងចែក។ ចំពោះថ្នាក់រៀនដែលមានសិស្សច្រើន គ្រូអាចកំណត់ចំនួនក្រុមជំនាញស្មើនឹងពីរដងនៃចំនួនអត្ថបទ។ ឧទាហរណ៍ គ្រូបែងចែកមេរៀនជា3ផ្នែកតូចៗ ហើយថ្នាក់រៀននេះមានសិស្ស 25នាក់។ គ្រូអាចបែងចែកសិស្សជា5 ក្រុមជំនាញដែលមួយក្រុមមានគ្នា4នាក់ ហើយមួយក្រុមចុងក្រោយមានគ្នា5នាក់។ ផ្នែកនីមួយៗនៃមេរៀន ត្រូវសិក្សាដោយក្រុមជំនាញ2ក្រុម។ ថ្នាក់រៀននេះ អាចបែងចែកជា4ក្រុមគ្រួសារដែល3ក្រុមមានសមាជិក6នាក់ក្នុងមួយក្រុមៗនិងមួយក្រុមមានសមាជិក 7នាក់។























របៀបបែងចែកក្រុមគ្រួសារនិងក្រុមជំនាញៈ

- ដំបូងគ្រូត្រូវធ្វើការសម្រេចចិត្តថាតើគាត់ចង់បែងចែកអត្ថបទជាប៉ុន្មានផ្នែក ?
- គ្រូកំណត់ចំនួនក្រុមជំនាញ។ ចំនួនក្រុមជំនាញយ៉ាងហោចណាស់គប្បីស្មើគ្នានឹងចំនួន អត្ថបទដែលបានបែងចែក។ ចំពោះថ្នាក់រៀនដែលមានសិស្សច្រើន គ្រូអាចកំណត់ចំនួនក្រុមជំនាញស្មើនឹងពីរដងនៃចំនួនអត្ថបទ។ ឧទាហរណ៍ គ្រូបែងចែកមេរៀនជា3ផ្នែកតូចៗ ហើយថ្នាក់រៀននេះមានសិស្ស 25នាក់។ គ្រូអាចបែងចែកសិស្សជា5 ក្រុមជំនាញដែលមួយក្រុមមានគ្នា4នាក់ ហើយមួយក្រុមចុងក្រោយមានគ្នា5នាក់។ ផ្នែកនីមួយៗនៃមេរៀន ត្រូវសិក្សាដោយក្រុមជំនាញ2ក្រុម។ ថ្នាក់រៀននេះ អាចបែងចែកជា4ក្រុមគ្រួសារដែល3ក្រុមមានសមាជិក6នាក់ក្នុងមួយក្រុមៗនិងមួយក្រុមមានសមាជិក 7នាក់។
- កំណត់ចំនួនក្រុមគ្រួសារ។ ក្រុមគ្រួសារនីមួយៗគប្បីមានសមាជិកយ៉ាងហោចណាស់1នាក់ ឬជួនកាល2នាក់មកពីក្រុមជំនាញនីមួយៗ។ ក្នុងករណីនេះ ផ្នែកនីមួយៗនៃមេរៀនវិទ្យាសាស្ត្រត្រូវបានពន្យល់ដោយអ្នកជំនាញម្នាក់ឬពីរនាក់។
- ដើម្បីឱ្យសមាជិកក្រុមនីមួយៗមានឱកាសចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា ក្រុមនីមួយៗ គប្បីមានសមាជិកមិនលើសពី6នាក់ឡើយ។
- សមាជិកក្រុមជំនាញ ត្រូវមានលេខសម្គាល់ (1, 2, 3,......) រីឯសមាជិកក្រុមគ្រួសារវិញត្រូវមានអក្សរសម្គាល់ (ក, ខ, គ,.....)។ សិស្សម្នាក់ៗមានលេខកូដសម្គាល់មួយ (ឧទាហរណ៍ ក1) ដែលបញ្ជាក់ពីក្រុមជំនាញនិងក្រុមគ្រួសារដែលគាត់ស្ថិតនៅ។ជំនួសការសម្គាល់ដោយអក្សរនិងលេខ គ្រូក៏អាចប្រើគំនិតវិទ្យាសាស្ត្រ ឬរូបភាពដែលទាក់ទង ទៅនឹងខ្លឹមសារមេរៀនផងដែរ។ ឧទាហរណ៍ ក្រុមជំនាញអាចសម្គាល់ដោយសរីរាង្គសំខាន់ណាមួយនៃរុក្ខជាតិ។
- គ្រូដាក់លេខកូដសម្គាល់ឱ្យសិស្សម្នាក់ៗ។ កន្លែងសិស្សអង្គុយរាល់ថ្ងៃ អាចប្រើជាក្រុម ជំនាញ ធ្វើដូចនេះសិស្សប្តូរកន្លែងអង្គុយតែមួយលើកប៉ុណ្ណោះ។




## 4.4. សម្ភារ



- ក្រុមជំនាញនីមួយៗ គប្បីមានក្រដាសសម្រាប់សរសេរពាក្យគន្លឹះនិងសង្ខេបមេរៀន។ល។ នៅពេលដែលសមាជិកក្រុមទាំងអស់យល់ស្របជារួមចំពោះលទ្ធផលហើយ សិស្សទាំងអស់នៅក្នុងក្រុមអាចចម្លងពាក្យគន្លឹះនិងខ្លឹមសារសង្ខេបចូលទៅក្នុងសៀវភៅកត់ត្រារៀងៗខ្លួនសម្រាប់ប្រើប្រាស់នៅក្នុងក្រុមគ្រួសារ។
- គ្រូអាចប្រើក្រដាសតូចៗដែលមានលេខសម្គាល់ ពាក្យគន្លឹះ ឬរូបភាពសម្រាប់បែងចែកក្រុមជំនាញនិងក្រុមគ្រួសារ។
- ប្រសិនបើល័ក្ខខ័ណ្ឌអនុគ្រោះ សិស្សអាចប្រើសៀវភៅអត្ថបទវិទ្យាសាស្ត្រ ឬប្រព័ន្ធអ៊ីនធើណែតដើម្បីស្វែងរកព័ត៌មានបន្ថែម។



## 4.5. ពេលវេលា



- គ្រូគប្បីអនុវត្តសកម្មភាពនេះនៅក្នុងជំហានទី3 ។ ពេលអនុវត្តសកម្មភាពនេះជាលើកទីមួយ គ្រូគប្បីរំពឹងទុកជាមុនថានឹងត្រូវចំណាយពេលវេលាឱ្យបានគ្រប់គ្រាន់ដើម្បីពន្យល់សិស្សអំពីរបៀបអនុវត្ត។
- គ្រូអាចអនុវត្តសកម្មភាពនេះនៅក្នុងមេរៀនរយៈពេល2ម៉ោងផ្សេងគ្នាដោយអនុវត្តសកម្មភាពក្រុមជំនាញនៅក្នុងម៉ោងទីមួយនិងសកម្មភាពក្រុមគ្រួសារនៅក្នុងម៉ោងមេរៀនបន្ទាប់ ភ្ជាប់ជាមួយការសំយោគដោយគ្រូនិងសិស្សទាំងអស់គ្នា។
- គ្រូគប្បីជ្រើសរើសប្រធានបទដែលមិនពិបាកពេកសម្រាប់សិស្សនិងអាចឱ្យពួកគេសិក្សាដោយខ្លួនឯងបាន។

| | | មេរៀន1ម៉ោង | មេរៀន2ម៉ោង |
|---|---|---|---|
| • ក្នុងជំហានទី3 | | | |
| | ក្រុមជំនាញ | 15នាទី | 30នាទី |
| | ក្រុមគ្រួសារ | 20នាទី | 40នាទី |
| • ក្នុងជំហានទី4 | សំយោគរួម | 7នាទី | 15នាទី |

## 4.6. កម្មវិធីសិក្សា



### ជីវវិទ្យា

- ប្រដាប់ដង្ហើម (ថ្នាក់ទី8 ជំពូកទី4 មេរៀនទី1, ឆ្នាំ2010)

### គីមីវិទ្យា

- ល្បឿននៃប្រតិកម្មគីមី (ថ្នាក់ទី12 ជំពូកទី1 មេរៀនទី1, ឆ្នាំ2010)

### ផែនដី និងបរិស្ថានវិទ្យា

- ផ្លាកតិចតូនិច (ថ្នាក់ទី9 ជំពូកទី2 មេរៀនទី1, ឆ្នាំ2011)

### រូបវិទ្យា

- ការបញ្ចេញរស្មីអេឡិចត្រូម៉ាញ៉េទិច (“ពន្លឺមើលឃើញនិងពន្លឺមើលមិនឃើញ”) (ថ្នាក់ទី12 ជំពូកទី5មេរៀនទី5, ឆ្នាំ2011)

## 4.7. សំណូមពរ



គ្រូអាចផ្តល់ជាសំណួរណែនាំដល់ក្រុមជំនាញ (អ្វី?, ហេតុអ្វី?, ដោយរបៀបណា?,.....) ដែលអាចជាជំនួយដល់ពួកគេក្នុងការរៀបចំព័ត៌មាន។

## 4.8. ជំបូន្មានសំខាន់ៗ



ចែកមេរៀនវិទ្យាសាស្ត្រមួយជាផ្នែកតូចៗ ដែលមានប្រវែងប្រហាក់ប្រហែលគ្នា ឬផ្តល់ជាសំណួរបន្ថែមដល់ក្រុមជំនាញ។

ដើម្បីអនុវត្តសកម្មភាពនេះទទួលបានជោគជ័យ ទាមទារគ្រូរៀបចំជាមុនឱ្យបានរួចរាល់។ គ្រូចាំបាច់ត្រូវគិតជាមុនឱ្យបានច្បាស់ពីរបៀបដែលគាត់នឹងដឹកនាំសកម្មភាពក្រុមជំនាញ។ គ្រូគួរត្រៀមជាមុននូវជំបូន្មានមួយចំនួន ដែលគាត់អាចនឹងផ្តល់ឱ្យសិស្សដោយពុំចាំបាច់និយាយពន្យល់វែង។

សកម្មភាពនេះអាចអនុវត្តបានចំពោះតែមេរៀនណាដែលអាចចែកជាផ្នែកតូចៗ ហើយសិស្សអាចសិក្សាផ្នែកនីមួយៗដាច់ដោយឡែកពីគ្នាបាន។ ចំពោះមេរៀនដែលទាមទារឱ្យសិស្សយល់ផ្នែកមួយជាមុនសិនមុននឹងឈានទៅសិក្សាផ្នែកបន្ទាប់ គ្រូមិនអាចអនុវត្តសកម្មភាពប្រមូលផ្តុំព័ត៌មានបានទេ។








# 5. សកម្មភាពទី5: វិធីកត់ត្រាតាមប្រព័ន្ធខរនែល (Cornell Note Taking)











## 5.1. សេចក្ដីផ្ដើម



ការកត់ត្រាជាបំណិនមួយដ៏សំខាន់នៅក្នុងការអប់រំមុខវិជ្ជាវិទ្យាសាស្ត្រ។ ទម្រង់ជាក់លាក់មួយអាចជួយសិស្សឱ្យធ្វើការកត់ត្រាយ៉ាងមានសណ្ដាប់ធ្នាប់និងមានភាពទៀងទាត់។ ប្រព័ន្ធខរនែលផ្ដល់ឱ្យសិស្សនូវទ្រង់ទ្រាយដ៏មានសណ្ដាប់ធ្នាប់បែបនេះ។ សកម្មភាពនេះប្រែក្លាយការបង្រៀនឱ្យទៅជាពេលវេលាសិក្សាដ៏សកម្ម។



## 5.2. វត្ថុបំណង



- កត់ត្រាយ៉ាងមានសណ្ដាប់ធ្នាប់
- ញែកយកចំណុចខ្លឹមសារសំខាន់ៗចេញពីខ្លឹមសារដែលមិនសូវសំខាន់
- បង្កើតសំណួរ កំណត់ពាក្យគន្លឹះឬបង្កើតតារាងនិងគូររូប
- រំឭកមេរៀនឡើងវិញនិងបំពេញព័ត៌មានបន្ថែមទៅក្នុងកំណត់ត្រារបស់ពួកគេក្រោយរៀនមេរៀនមួយចប់
- ប្រើប្រាស់ពាក្យគន្លឹះវិទ្យាសាស្ត្រនិងសរសេរតាមបែបវិទ្យាសាស្ត្រ

## 5.3. ដំណើរការ



គ្រូជ្រើសរើសប្រធានបទមួយសម្រាប់បង្រៀន។ ការបង្រៀននេះគប្បីរៀបចំយ៉ាងមាន របៀបរៀបរយ ហើយការចាប់ផ្ដើមនិងការបញ្ចប់គប្បីប្រាប់សិស្សឱ្យបានច្បាស់។ គ្រូសរសេរពាក្យគន្លឹះមួយចំនួននៅលើក្ដារខៀនក្នុងអំឡុងម៉ោងបង្រៀនដើម្បីឱ្យសិស្សងាយស្រួលកត់ត្រា។ គ្រូគប្បីរំឭកសិស្សកុំសរសេរចូលនូវប្រយោគទាំងមូល គឺគ្រាន់តែកត់ត្រាចូលនូវពាក្យគន្លឹះនិងឃ្លាខ្លីៗ និងបំផុសសិស្សឱ្យកត់ត្រាឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។ រយៈពេលពន្យល់មេរៀនសម្រាប់ឱ្យសិស្សកត់ត្រាដែលល្អបំផុតគឺចន្លោះពី10ទៅ15នាទី។ ប្រសិនបើអនុវត្តសកម្មភាពនេះជាលើកដំបូង គ្រូគប្បីពន្យល់សិស្សឱ្យយល់ពីបែបបទនៃការកត់ត្រានេះជាមុនសិន។

សន្លឹកកិច្ចការត្រូវបានបែងចែកជាបីផ្នែកសំខាន់ៗគឺ:

- គន្លឹះ : សម្រាប់សរសេរគំនិតសំខាន់ៗ ពាក្យគន្លឹះ សំណួរនិងសកម្មភាពដែលត្រូវធ្វើ។
- កត់ត្រា: សម្រាប់កត់ត្រាមេរៀនដូចជាឃ្លាខ្លីៗ ពាក្យនិងដ្យាក្រាម។
- សង្ខេប: សម្រាប់កត់ត្រាចំណុចសំខាន់ៗនៃមេរៀន។

នៅពេលគ្រូកំពុងបង្រៀន សិស្សកត់ត្រាចូលតែក្នុងផ្នែក “កត់ត្រា” លើសន្លឹកកិច្ចការប៉ុណ្ណោះ។

ក្រោយពេលបង្រៀនមេរៀនចប់ គ្រូផ្ដល់ពេលឱ្យសិស្សពី5ទៅ10នាទីដើម្បី កត់ត្រាចូលផ្នែក “គន្លឹះ” និងផ្នែក “សង្ខេប” នៃសន្លឹកកិច្ចការ។ សកម្មភាពរំឭកមេរៀនបែបនេះ ក៏អាចរៀបចំជាកិច្ចការផ្ទះផងដែរ។ ក្នុងអំឡុងសកម្មភាពរំឭកមេរៀននេះ គ្រូគប្បីចល័តក្នុងថ្នាក់រៀន ដើម្បីស្វែងយល់ពីសមត្ថភាពរបស់សិស្សក្នុងការធ្វើកំណត់ត្រា។

បន្ទាប់មក សិស្សអាចធ្វើការត្រួតពិនិត្យកំណត់ត្រារបស់ពួកគេ ជាដៃគូ (មើលចំណុចវិធីកត់ត្រាដោយត្រួតពិនិត្យជាក្រុម) ឬគ្រូអាចលើកជាសំណួរទៅកាន់សិស្សទាំងអស់នៅក្នុងថ្នាក់រៀនទាំងមូលដោយផ្ដោត



ទៅលើប្រធានបទមួយចំនួនដូចជាៈ

- តើខ្លឹមសារគន្លឹះសំខាន់ៗនៅក្នុងមេរៀននេះមានអ្វីខ្លះ?
- តើមានចំណុចណាខ្លះដែលគប្បីបញ្ចូលទៅក្នុងខ្លឹមសារសង្ខេប?
- តើសិស្សសរសេរបានសំណួរអ្វីខ្លះ?
- តើសិស្សយល់ថាការកត់ត្រានេះមានការលំបាកទេ?

កំណត់ត្រានិងការពិភាក្សាក្រោយមេរៀន ជួយឱ្យគ្រូរកឃើញបញ្ហាសំខាន់ៗដែលជាផលវិបាក សម្រាប់សិស្សក្នុងការយល់មេរៀន។



## 5.4. សម្ភារ



សិស្សកត់ត្រានៅក្នុងសៀវភៅសរសេរ ឬនៅលើសន្លឹកកិច្ចការដាច់ដោយឡែក។

## 5.5. ពេលវេលា



ពេលវេលាដែលសក្តិសមបំផុតដើម្បីអនុវត្តសកម្មភាពនេះគឺនៅក្នុងជំហានទី3។ សកម្មភាពនេះជួយបំផុសការគិតរបស់សិស្សពេលគ្រូកំពុងបង្រៀន និងរំឭកការកត់ត្រារបស់ពួកគេក្រោយចប់មេរៀន។ ប្រសិនបើគ្រូអនុវត្តសកម្មភាពនេះរួមជាមួយសកម្មភាពត្រួតពិនិត្យជាក្រុម គាត់អាចបំផុសសកម្មភាពសិស្សឱ្យចូលរួមរំឭកមេរៀនជាមួយសមាជិកក្រុមរបស់ពួកគេ។

## 5.6. កម្មវិធីសិក្សា



### ផែនដី និងបរិស្ថានវិទ្យា

- អូសូននៅក្នុងមណ្ឌលអាកាសស្ងប់ (Stratosphere) (ថ្នាក់ទី12 ជំពូកទី4 មេរៀនទី8, ឆ្នាំ2011)

### ជីវវិទ្យា

- អង់ស៊ីម (ថ្នាក់ទី12 ជំពូកទី4 មេរៀនទី3, ឆ្នាំ2010)

















## គីមីវិទ្យា

- ការអនុវត្តនៃអាស៊ីតនិងជី ( ថ្នាក់ទី9 ជំពូកទី4 មេរៀនទី2, ឆ្នាំ2011 )

## រូបវិទ្យា

- ទ្រឹស្តីស៊ីនេទិចនៃរូបធាតុ ( ថ្នាក់ទី10 ជំពូកទី2 មេរៀនទី2, ឆ្នាំ2009 )

## 5.7. សំណួមពរ



គ្រូក៏អាចអនុវត្តវិធីកត់ត្រាតាមប្រព័ន្ធខវនៃលជាសកម្មភាពអានដ៏សកម្មផងដែរ ដែលសិស្សសង្ខេបអត្ថបទមួយដោយប្រើកំណត់ត្រាខវនៃល។

ដាក់កិច្ចការឱ្យសិស្សកត់ត្រាចូលក្នុងទម្រង់ខវនៃលពេលកំពុងទស្សនាវីដេអូមួយ។

## 5.8. ដំបូន្មានសំខាន់ៗ



គ្រូគួរពន្យល់ឱ្យសិស្សយល់ច្បាស់ពីវត្ថុបំណងនៃមេរៀន មុននឹងអនុវត្តសកម្មភាពកំណត់ត្រា ដើម្បីឱ្យសិស្សដឹងចំណុចដែលត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងពេលកត់ត្រា។ ឧទាហរណ៍ សិស្សមិនចាំបាច់កត់ត្រាដំណើរការពិសោធន៍ទាំងស្រុងនោះទេ គឺគ្រាន់តែយល់សេចក្តីសន្និដ្ឋានគ្រប់គ្រាន់ហើយ។

គ្រូគួរចល័តក្នុងថ្នាក់រៀនដើម្បីត្រួតពិនិត្យការកត់ត្រារបស់សិស្ស។ គ្រូអាចប្រមូលសន្លឹកកិច្ចការរបស់សិស្សនៅចុងម៉ោងបង្រៀនដើម្បីធ្វើការត្រួតពិនិត្យ។



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ
# តាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល

ជំពូកទី 2

## បំណិនបកស្រាយបែបវិទ្យាសាស្ត្រ







នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ 2012











# សេចក្ដីផ្ដើម



នេះជាឯកសារបំប៉នដែលពិភាក្សាអំពីសកម្មភាពមួយចំនួនបម្រើឱ្យគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងការអប់រំមុខវិជ្ជាវិទ្យាសាស្ត្រ។ រាល់សកម្មភាពទាំងឡាយដែលមាននៅក្នុងឯកសារបំប៉ននេះត្រូវបានពិភាក្សាយ៉ាងលម្អិតជាមួយគ្រូឧទ្ទេស និងគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ដើម្បីឱ្យសមស្របនឹងបរិបទប្រទេសកម្ពុជា ហើយសកម្មភាពទាំងអស់នេះក៏ត្រូវបានយកទៅសាកល្បង និងកែតម្រូវឡើងវិញផងដែរ។ សំណួរមួយចំនួនដែលសិក្ខាកាមនិយមលើកឡើងក្នុងសិក្ខាសាលាក៏ត្រូវបានដាក់បញ្ចូលក្នុងឯកសារនេះដែរ។

ជំពូកនេះផ្ដល់ជូននូវសកម្មភាពមួយចំនួនដើម្បីបណ្ដុះបំណិនបកស្រាយហេតុផលរបស់សិស្ស។ សកម្មភាពទាំងនេះជំរុញឱ្យសិស្សស្ដែងចេញនូវចំណេះដឹង និងបញ្ចេញនូវការយល់ឃើញរបស់គេអំពីប្រធានបទវិទ្យាសាស្ត្រផ្សេងៗ។ តាមរយៈសកម្មភាពទាំងនេះនឹងជួយឱ្យសិស្សយល់ខ្លឹមសារវិទ្យាសាស្ត្រកាន់តែស៊ីជម្រៅ។

យើងសង្ឃឹមថា ឯកសារនេះនឹងជាជំនួយដ៏មានប្រយោជន៍ដល់លោកគ្រូអ្នកគ្រូ។ យ៉ាងណាមិញយើងជឿជាក់ថា ឯកសារនេះពិតជាមានចំណុចមួយចំនួនដែលត្រូវកែលម្អ។ អាស្រ័យហេតុនេះ យើងរីករាយស្វាគមន៍នូវគ្រប់មតិយោបល់កែលម្អ និងសំណូមពរក្នុងគោលបំណងកែលម្អឯកសារនេះឱ្យកាន់តែប្រសើរឡើង។

# I. ខ្លឹមសារសំខាន់ៗ

## បំណិនបកស្រាយបែបវិទ្យាសាស្ត្រ



ការបកស្រាយហេតុផលក្នុងមេរៀនវិទ្យាសាស្ត្ររួមបញ្ចូលសកម្មភាពដែលមានគោលបំណងជំរុញឱ្យសិស្សបង្កើនការយល់ដឹងអំពីមេរៀនវិទ្យាសាស្ត្រតាមរយៈការចូលរួមក្នុងការជជែកវែកញែករកហេតុផលអំពីវិទ្យាសាស្ត្រ ។ តាមរយៈសកម្មភាពនេះ សិស្សប្រើប្រាស់ចំណេះដឹងរបស់ខ្លួនតាមវិធីមួយថ្មី ដោយប្រើពាក្យសម្ដីរបស់ខ្លួន។ តាមរយៈការផ្ដល់ឱកាសឱ្យសិស្ស ប្រាប់ហេតុផលអំពីប្រធានបទវិទ្យាសាស្ត្រ គ្រូអាចរកឃើញនូវគំនិតភាន់ច្រឡំរបស់សិស្សជួយឱ្យគាត់អាចបង្រៀនកាន់តែមានប្រសិទ្ធិភាព។ នៅដើមមេរៀន សកម្មភាពបកស្រាយហេតុផលអាចជួយឱ្យគ្រូត្រួតពិនិត្យចំណេះដឹងមានស្រាប់របស់សិស្ស ហើយសិស្ស ក៏អាចរំឭកឡើងវិញនូវចំណេះដឹងមានស្រាប់របស់ខ្លួន។

# II. សកម្មភាព

## 1. សកម្មភាពទី1: វិធីពិភាក្សាតាមបែបនិកង

### 1.1. សេចក្ដីផ្ដើម



សកម្មភាពនេះជាសកម្មភាពមួយដែលងាយអនុវត្ត ហើយជួយបំផុសការគិតនិងការបកស្រាយហេតុផលរបស់សិស្ស តាមរយៈការពិភាក្សាខ្លីៗអំពីប្រធានបទវិទ្យាសាស្ត្រជាមួយមនុស្សផ្សេងៗគ្នា។ ការផ្ដល់រយៈពេលខ្លីសម្រាប់ពិភាក្សាជំរុញឱ្យសិស្សហាត់រៀនសង្ខេបខ្លឹមសារនៃអំណះអំណាងរបស់ខ្លួន។



### 1.2. វត្ថុបំណង



- បកស្រាយគំនិតបែបវិទ្យាសាស្ត្រ និងស្ដាប់គំនិតគ្នាទៅវិញទៅមក
- បង្កើនការយល់ដឹងអំពីមេរៀនវិទ្យាសាស្ត្រ និងទំនាក់ទំនងរវាងវិទ្យាសាស្ត្រ និងសង្គម
- ទំលាប់ពិនិត្យតាមដានចំណេះដឹងមានស្រាប់និងការយល់ឃើញរបស់សិស្ស




















## 1.3. ដំណើរការ



- សិស្សឈរតម្រៀបគ្នាជារង្វង់ពីរ គឺរង្វង់តូចមួយនៅខាងក្នុងរង្វង់ធំ ដែលសិស្សនៅរង្វង់ខាងក្នុងឈរទល់មុខជាមួយសិស្សនៅរង្វង់ខាងក្រៅ។ គ្រូអានប្រយោគឬសំណួរវិទ្យាសាស្ត្រឮៗ។
- ទុកពេល 1 នាទីឱ្យសិស្សពិភាក្សាគ្នាអំពីប្រយោគឬសំណួរខាងលើជាមួយដៃគូរៀងៗខ្លួន។
- ក្រោយរយៈពេល 1 នាទី ( ផ្តល់ពេលវេលាខ្លីសម្រាប់ការពិភាក្សា ) ឱ្យសិស្សក្នុងរង្វង់តែមួយ ( រង្វង់ណាមួយក៏បាន ) ឈានទៅឆ្វេងឬស្តាំដោយរំលង2នាក់ដើម្បីជួបនឹងដៃគូពិភាក្សាថ្មី។ សិស្សចាប់ផ្តើមពិភាក្សាអំពីប្រយោគឬសំណួរដដែលជាមួយដៃគូថ្មី។ បន្ទាប់មកគ្រូអាចឱ្យសិស្សធ្វើការប្តូរដៃគូមួយលើកទៀត ដើម្បីឱ្យសិស្សបានពិភាក្សាអំពីប្រយោគឬសំណួរដដែលចំនួន3លើក។
- ក្រោយអនុវត្តសកម្មភាពនេះចប់ គ្រូអាចសួរសិស្សក្នុងថ្នាក់រៀនទាំងមូលដោយផ្តោតទៅលើចំណុចមួយចំនួនដូចជា:
  - តើសិស្សបានប្រើប្រាស់ហេតុផលយល់ស្របនិងមិនយល់ស្របដូចម្តេចខ្លះ ?
  - តើសិស្សបានប្រើប្រាស់ពាក្យបច្ចេកទេស និងខ្លឹមសារត្រឹមត្រូវដែរឬទេ ?
  - នៅក្នុងការពិភាក្សាជាមួយដៃគូទី 2 និង ទី 3 តើសិស្សបានផ្លាស់ប្តូរការយល់ឃើញ ឬហេតុផលដើម្បីគាំទ្រគំនិតរបស់ខ្លួនដែរឬទេ ?

នៅពេលសិស្សកំពុងពិភាក្សាគ្នា គ្រូគប្បីចល័តដើម្បីស្តាប់ការពិភាក្សា និងធ្វើការកត់ចំណាំមួយចំនួន ដែលគាត់អាចនឹងលើកយកហេតុផលមួយចំនួនរបស់សិស្សមកពិភាក្សានៅពេលដែលគាត់សួរសិស្សទាំងអស់នៅក្នុងថ្នាក់ ( ពន្យល់ថាហេតុអ្វីគំនិតនោះមិនត្រឹមត្រូវ និងរបៀបដែលសិស្សអាចកែតម្រូវហេតុផលនោះ។ល។ )។

ក្រោយសិស្សពិភាក្សាចប់ គ្រូអាចសរសេរហេតុផលយល់ស្រប ឬមិនយល់ស្របនៅលើក្តារខៀនដើម្បីឱ្យសិស្សចម្លងចូលក្នុងសៀវភៅកត់ត្រារបស់គេ។

## 1.4. សម្ភារ



សកម្មភាពនេះ មិនទាមទារការប្រើសម្ភារអ្វីទេ។ គ្រូអាចអនុវត្តសកម្មភាពនេះនៅខាងក្រៅថ្នាក់ដើម្បីមានទីកន្លែងគ្រប់គ្រាន់។

## 1.5. ពេលវេលា



គ្រូអាចប្រើសកម្មភាពនេះដើម្បីចាប់ផ្តើមមេរៀនដែលមានទាក់ទងនឹងក្រមសីលធម៌។ គ្រូក៏អាចអនុវត្តសកម្មភាពនេះដើម្បីសន្និដ្ឋានបញ្ចប់មេរៀនទាក់ទងនឹងប្រធានបទជាក់លាក់។

ពេលវេលាសមស្របសម្រាប់អនុវត្តសកម្មភាពនេះ គឺនៅដើមជំហានទី៣។

## 1.6. កម្មវិធីសិក្សា



### ជីវវិទ្យា

- តើសត្វមានសិទ្ធិឬទេ ?
- តើយើងគួរយកសត្វរស់ទៅពិសោធឬទេ ?
- តើអ្នកនឹងបរិភោគផលិតផលអាហារដែលត្រូវបានធ្វើឱ្យមានបម្រែបម្រួលក្រមសេនេទិចឬទេ ? ( ថ្នាក់ទី12 ជំពូកទី5 មេរៀនទី1 ) និង ( ថ្នាក់ទី11 ជំពូកទី3 មេរៀនទី2 ឆ្នាំ2009 )
- តើអ្នកជម្ងឺគួរដឹងការពិតអំពីជម្ងឺរបស់ខ្លួន និងលទ្ធផលនៃជម្ងឺនោះគ្រប់ពេលដែរឬទេ ?
- តើមានភាពខុសប្លែកគ្នារវាងថ្នាំល្អ និងថ្នាំអាក្រក់ដែរឬទេ ? ( ថ្នាក់ទី9 ជំពូកទី8 មេរៀនទី18 ឆ្នាំ2008 ) ( ថ្នាក់ទី7 ជំពូកទី5 មេរៀនទី1 ឆ្នាំ2009 )



## ផែនដី និងបរិស្ថានវិទ្យា

- តើយើងគួរវិនិយោគថវិកា ទៅលើបេសកកម្មអវកាសមានមនុស្សជិះទៅកាន់ភពអង្គារដែរឬទេ ?
- តើយើងគួរសាងសង់ទំនប់វារីអគ្គិសនីនៅលើទន្លេមេគង្គដែរឬទេ ?
- តើវដ្តសិលាអាចបញ្ចប់ដែរឬទេ ?

## រូបវិទ្យា

- តើការសង្កេតរបស់យើងរងឥទ្ធិពលនៃចំណេះដឹងមានស្រាប់របស់យើងដែរឬទេ ?
- តើយើងអាចប្រើប្រាស់បច្ចេកវិទ្យាដើម្បីដោះស្រាយបញ្ហាថាមពលផូស៊ីលរបស់យើងដែរឬទេ ?
- តើយើងធ្វើយ៉ាងណា ទើបអាចអះអាងថាច្បាប់រូបវិទ្យាមួយត្រឹមត្រូវ ?

## គីមីវិទ្យា

- តើយើងគួរបំផ្លាញគ្រាប់បែកបរមាណូចោលឱ្យអស់ឬទេ ?
- តើយើងគួរប្រើជីគីមី ដើម្បីបង្កើនទិន្នផលដំណាំដែរឬទេ ?

*( ថ្នាក់ទី10 ជំពូក4 មេរៀនទី5, ឆ្នាំ2008 )*

## 1.7. សំណួមពរ



ប្រសិនបើមិនមានទីកន្លែងធំល្មមទេ គ្រូអាចឱ្យសិស្សឈរជា 2 ជួរទល់មុខគ្នានៅកន្លែងណាក៏បាន ( ឧទាហរណ៍ នៅខាងមុខថ្នាក់ ឬនៅផ្លូវដើរចន្លោះតុ )។

គ្រូអាចចាត់តាំងអ្នកសង្កេតម្នាក់ដែលត្រូវតាមសង្កេតសិស្សណាម្នាក់ជាប់ជានិច្ច រាល់គ្រប់ការពិភាក្សា។ អ្នកសង្កេតពុំគប្បីចូលរួមក្នុងការពិភាក្សាទេគាត់គ្រាន់តែកត់ត្រានូវហេតុផលយល់ស្របឬមិនយល់ស្របដែលសិស្សម្នាក់នោះប្រើប៉ុណ្ណោះ។ ក្រោយពីអនុវត្តសកម្មភាពចប់គ្រូអាចសួរទាំងអ្នកសង្កេត និងសិស្សដែលត្រូវបានសង្កេត អំពីបម្លាស់ប្តូរនៃការយល់ឃើញរបស់សិស្សម្នាក់នោះ ពីដើមដល់ចប់សកម្មភាព។

គ្រូគប្បីចៀសវាងគូពិភាក្សានីមួយៗឈរនៅកៀកៗគ្នាពេក ដែលអាចនាំឱ្យរំខានដល់ការពិភាក្សារបស់គ្នាទៅវិញទៅមក។

ប្រសិនបើសិស្សមានចំនួនសេស គ្រូអាចបង្កើតក្រុមមួយដែលមានសិស្ស2នាក់ ដែលក្នុងនោះ សិស្សម្នាក់មានតួនាទីជាអ្នកសង្កេត ( សូមមើលចំនុចខាងលើ )។

## 1.8. ដំបូន្មានសំខាន់ៗ



គ្រូគប្បីសួរសំណួរពិភាក្សាដែលមានលក្ខណៈទូលាយ ហើយជាប់ទាក់ទងនឹងជីវភាពរស់នៅជាក់ស្តែង។ សំណួរទាំងនោះគប្បីបំផុសឱ្យសិស្ស សួរសំណួរអំពីទំនាក់ទំនងរវាងវិទ្យាសាស្ត្រនឹងសង្គម។ សូមកុំធ្វើអន្តរាគមន៍ពេលសិស្សកំពុងពិភាក្សា ទោះជាអ្នកបានឮសិស្សប្រើអំណះអំណាងខុសក៏ដោយ។ គ្រូអាចកត់ចំណាំចំណុចនោះនៅក្នុងចិត្ត រួចពន្យល់សិស្សទាំងអស់ក្នុងថ្នាក់ជាក្រោយ ព្រោះសិស្សផ្សេងៗទៀតនៅក្នុងថ្នាក់ ក៏អាចនឹងមានគំនិតភាន់ច្រឡំដូចគ្នានេះដែរ។ ប្រសិនបើសិស្សមួយចំនួនធំនៅតែមានការភាន់ច្រឡំនៅចុងបញ្ចប់នៃសកម្មភាព គ្រូចាំបាច់ត្រូវពន្យល់បន្ថែម អំពីមេរៀនដដែលនេះ។













# 2.សកម្មភាពទី2: វិធីវេទិកាពិភាក្សា

## 2.1. សេចក្តីផ្តើម



សកម្មភាពនេះផ្តល់ឱកាសឱ្យសិស្សបានស្តាប់ការជជែកវែកញែកហេតុផលរបស់សិស្សមួយក្រុមនៅក្នុងថ្នាក់។



## 2.2. វត្ថុបំណង



- ទំលាប់ស្តាប់ហេតុផលគ្នាទៅវិញទៅមក
- បកស្រាយគាំទ្រហេតុផលតាមបែបវិទ្យាសាស្ត្រ (ប្រើប្រាស់ភស្តុតាងនិងការពន្យល់)
- ចង្អុលបង្ហាញភាពមិនត្រឹមត្រូវ និងវែកញែកប្រយោគដែលជំទាស់នឹងការយល់ឃើញរបស់ខ្លួន
- ឆ្លុះបញ្ចាំងគំនិតរបស់ខ្លួន

## 2.3. ដំណើរការ



- ជ្រើសរើសសិស្សពី4ទៅ6នាក់ដែលជាតំណាងនៃថ្នាក់រៀនទាំងមូល( សូមមើលដំបូន្មានសំខាន់ៗ)។
- ឱ្យពួកគេឈរនៅខាងមុខ ដើម្បីឱ្យសិស្សទាំងអស់នៅក្នុងថ្នាក់អាចមើលពួកគេឃើញ។
- រំឭកសិស្សទាំងអស់គ្នាថា មានតែសិស្សនៅក្នុង«វេទិកាពិភាក្សា» ប៉ុណ្ណោះដែលអាចចូលរួមការពិភាក្សាបាន។ សិស្សផ្សេងៗទៀតត្រូវស្តាប់ការពិភាក្សា និងសរសេរនូវ យោបល់ឬសំណួរដែលគេចង់លើកឡើងនៅពេលពិភាក្សាចប់។
- អានប្រយោគមួយដែលមានលក្ខណៈបើក ដើម្បីចាប់ផ្តើមការពិភាក្សា។
- សិស្សម្នាក់ចាប់ផ្តើមការពិភាក្សា ដោយប្រាប់ពីចម្លើយរបស់គាត់ និងហេតុផលដែលនាំឱ្យគាត់យល់ឃើញបែបនោះ ។ បន្ទាប់មក សិស្សផ្សេងទៀតនៅក្នុងវេទិកាពិភាក្សាចូលរួមដោយបង្ហាញការយល់ស្រប ឬ មិនយល់ស្របផ្អែកលើហេតុផលរៀងៗខ្លួន ។ គ្រូអាចសម្របសម្រួលការពិភាក្សានេះបានប្រសិនបើចាំបាច់( សូមមើលដំបូន្មានសំខាន់ៗ)។
- លើកទឹកចិត្តសិស្សទាំងអស់គ្នានៅក្នុង «វេទិកាពិភាក្សា» ឱ្យចូលរួមពិភាក្សា និងផ្តោតការយកចិត្តទុកដាក់ស្តាប់មតិគ្នាទៅវិញទៅមកតែនៅក្នុង «វេទិកាពិភាក្សា» ប៉ុណ្ណោះមិនមែនទៅលើសិស្សផ្សេងៗទៀតនៅក្នុងថ្នាក់នោះទេ។
- ក្រោយការពិភាក្សាចប់គ្រូផ្តល់ឱកាសឱ្យសិស្សដែលបានស្តាប់នៅខាងក្រៅ «វេទិកាពិភាក្សា» បង្ហាញការយល់ឃើញផ្ទាល់ខ្លួនរបស់ពួកគេ ថាគេយល់ស្របឬមិនយល់ស្របទៅនឹងគំនិតដែលត្រូវបានពិភាក្សា។
- បន្ទាប់មក គ្រូអាចធ្វើការសំយោគខ្លឹមសារនៃការពិភាក្សាឡើងវិញ។ ប្រសិនបើប្រទះឃើញមានហេតុផលលើកឡើងដែលមិនត្រឹមត្រូវ ឬមានគំនិតភាន់ច្រឡំ គ្រូគប្បីចង្អុលបង្ហាញចំណុចដែលមិនត្រឹមត្រូវ និងការកែតម្រូវចំណុចទាំងនោះ។



## 2.4. សម្ភារ



តើយើងអាចបង្កើតប្រយោគដ៏ល្អមួយបានដោយរបៀបណា? គប្បីបង្កើតប្រយោគឬសំណួរដែលមិនស្រួលពេក និងមិនពិបាកពេកជាប្រយោគដែលបំផុសការពិភាក្សាខ្លីៗ។ គ្រូចាំបាច់ត្រូវឱ្យសិស្សយល់បានច្បាស់អំពីប្រយោគឬសំណួរដែលគ្រូលើកឡើង។

## 2.5. ពេលវេលា



គ្រូគប្បីអនុវត្តសកម្មភាពនេះ នៅក្នុងជំហានទី3 ដើម្បីឱ្យសិស្សមានឱកាសប្រើប្រាស់ចំណេះដឹងរបស់គេ និងដើម្បីពង្រឹងការយល់ដឹងរបស់គេអោយកាន់តែរឹងមាំថែមទៀតទៅលើមេរៀន។

## 2.6. កម្មវិធីសិក្សា



### រូបវិទ្យា

1. *តើវត្ថុមានរបស់ខ្យល់ចាំបាច់ឬទេ ដើម្បីឱ្យកម្លាំងទំនាញអាចមានអំពើទៅលើវត្ថុមួយ?*
   *(ថ្នាក់ទី8 ជំពូកទី2 មេរៀនទី3 ឆ្នាំ2008)*
   *(ថ្នាក់ទី10 ជំពូកទី1 មេរៀនទី3 ឆ្នាំ2009)* និង
   *(ថ្នាក់ទី8 ជំពូកទី3 មេរៀនទី1 ឆ្នាំ 2010)*

   កម្លាំងទំនាញមិនត្រូវការខ្យល់ដើម្បីមានអំពើលើវត្ថុមួយនោះទេ។ យើងអាចគិតដល់ព្រះចន្ទវិលជុំវិញផែនដីឬ ផែនដីវិលជុំវិញព្រះអាទិត្យ។ កម្លាំងទំនាញគឺជាកម្លាំងមួយដែលមិនត្រូវការមជ្ឈដ្ឋានទើបអាចមានអំពើនោះឡើយ។
2. *តើខ្យល់មានថាមពលឬទេ? (ថ្នាក់ទី8 ជំពូកទី3 មេរៀនទី1 ឆ្នាំ2008)*

   *ខ្យល់គឺជាល្បាយឧស្ម័នដែលមានចលនា។ ម៉ូលេគុលឧស្ម័នមានថាមពលស៊ីនេទិច ប៉ុន្តែក៏មានថាមពលប៉ូតង់ស្យែលនិងថាមពលកម្ដៅផងដែរ។*
3. *តើអ្នកចូលចិត្តយួរទឹកដោយប្រើធុងមួយ ឬធុងពីរ? ហេតុអ្វី?*
   *(ថ្នាក់ទី11 ជំពូកទី1 មេរៀនទី6 ឆ្នាំ2009)*

   ការយួរធុងពីរងាយស្រួលជាងយួរធុងមួយ ព្រោះអ្នកឈរត្រង់ពេលអ្នកយួរទឹកក្នុងធុងដោយដៃទាំងពីរ។ ពេលអ្នកយួរធុងពីរទីប្រជុំទម្ងន់ស្ថិតនៅចំចំណុចកណ្ដាលនៃចំណុចទម្រដែលផ្ដល់ដោយជើងរបស់យើង។ ភាពងាយស្រួលដូចគ្នានេះដែរ កើតមានឡើងនៅពេលដែលអ្នកទូលធុងទឹកមួយនៅលើក្បាលរបស់អ្នក។





### ផែនដី និងបរិស្ថានវិទ្យា

1. *ជីវិតមិនអាចប្រព្រឹត្តទៅបានទេ ប្រសិនបើមិនមានផលផ្ទះកញ្ចក់។*
   *(ថ្នាក់ទី12 ជំពូកទី4មេរៀនទី5 ឆ្នាំ2011)*

   ផលផ្ទះកញ្ចក់ចាំបាច់ចំពោះជីវិត (ដូចដែលយើងធ្លាប់ដឹងរួចមកហើយ) នៅលើផែនដី។ ប្រសិនបើមិនមានផលផ្ទះកញ្ចក់ទេនោះផែនដីអាចនឹងមានសីតុណ្ហភាព20អង្សារសេទាបជាងបច្ចុប្បន្ន។



2. *តើមនុស្សអាចមានសមត្ថភាពរៀបចំបេសកកម្មអវកាសមានមនុស្សជិះ ទៅកាន់ភពក្រៅបានដែរឬទេ? (ថ្នាក់ទី7 ជំពូកទី3 មេរៀនទី4)* និង *(ថ្នាក់ទី7 ជំពូកទី1 មេរៀនទី4 ឆ្នាំ2009)*ទេ ព្រោះថា:
   1. ការធ្វើដំណើរចំណាយពេលច្រើនឆ្នាំ
   2. យើងមិនមានកាំជ្រួច ដែលអាចផ្ទុកថាមពលគ្រប់គ្រាន់សម្រាប់គេចចេញពីកម្លាំងទំនាញដ៏ខ្លាំងរបស់ភពក្រៅ ដើម្បីត្រលប់មកវិញបានទេ។
   3. ភពក្រៅមិនមានផ្ទៃរឹងដែលអាចឱ្យយានចុះចតបាននោះទេ។



3. *ចូរអ្នកពន្យល់មនុស្សមកពីពិភពផ្សេងម្នាក់ឱ្យជឿថាផែនដីពិតជាវិលជុំវិញព្រះអាទិត្យមែន។ (ថ្នាក់ទី7 ជំពូកទី3* មេរៀនទី3 *ឆ្នាំ2008)* និង *(ថ្នាក់ទី7 ជំពូកទី1* មេរៀនទី3 *ឆ្នាំ2009)*

   ក្នុងមួយឆ្នាំៗ នៅខែផ្សេងៗគ្នា ប្រសិនបើអ្នកសម្លឹងមើលទៅលើទីតាំងតែមួយនៅលើមេឃនៅម៉ោងតែមួយរៀងរាល់ថ្ងៃ អ្នកនឹងឃើញតារាផ្សេងៗគ្នា។ ព្រះអាទិត្យមានម៉ាសធំជាងផែនដីច្រើនដង ដូចនេះបើតាមច្បាប់នៃកម្លាំងទំនាញ ផែនដីត្រូវវិលជុំវិញព្រះអាទិត្យ។















### គីមីវិទ្យា

1. *ហេតុអ្វីបានជាប្រេងមិនរលាយចូលទឹក? (សូមមើលពិសោធគីមីវិទ្យាទី17 ក្នុងឯកសារពិសោធន៍គីមីវិទ្យា )*
2. តើប្រតិកម្មគីមីនឹងបន្តរហូតដល់អស់អង្គធាតុប្រតិករដែរឬទេ?

### ជីវវិទ្យា

1. តើយើងគួរអនុញ្ញាតឱ្យយកសត្វរស់ទៅពិសោធដែរឬទេ?
2. តើយើងគួរផ្តល់ថវិកាដល់ប្រជាជនដើម្បីឱ្យពួកគាត់ថែរក្សាព្រៃឈើក្នុងតំបន់របស់គាត់ដែរឬទេ?
3. តើយើងអាចបញ្ឈប់សកម្មភាពបំផ្លាញព្រៃឈើដោយរបៀបណា?

## 3.7. សំណួមពរ



គ្រូអាចអនុវត្តសកម្មភាពនេះច្រើនដង  ដោយផ្លាស់ប្តូរសិស្សនៅក្នុងវេទិកាពិភាក្សា។

ដើម្បីដឹកនាំសកម្មភាពពិភាក្សានៅក្នុងវេទិកាពិភាក្សា គ្រូអាចអនុវត្តតាមទម្រង់សកម្មភាពដូចខាងក្រោម។ សិស្សម្នាក់ចាប់ផ្តើមដោយបង្ហាញការយល់ឃើញរបស់គាត់ចំពោះប្រយោគដែលគ្រូបានអាន។ បន្ទាប់មកសិស្សផ្សេងៗទៀតអាចចូលរួមដោយប្រើឃ្លាដូចជា ខ្ញុំយល់ស្រប (ឬខ្ញុំមិនយល់ស្រប) ជាមួយសិស្សទី......ព្រោះ.........(ដែលពួកគេត្រូវបំពេញហេតុផលនៅទីនេះ)។ ការធ្វើបែបនេះសិស្សត្រូវបានតម្រូវឱ្យបង្ហាញហេតុផលសមស្រប និងមានតួនាទីចូលរួមពិភាក្សាយ៉ាងសកម្មដោយប្រើហេតុផលទាំងនេះ។ គ្រូអាចបញ្ចប់ការពិភាក្សានៅពេលដែលហេតុផលទាំងឡាយមានភាពមិនច្បាស់លាស់។ គ្រូអាចជួយសិស្សក្នុងការបង្កើតហេតុផលច្បាស់លាស់សម្រាប់ចូលរួមក្នុងការជជែកវែកញែក។

## 3.8. ដំបូន្មានសំខាន់ៗ



គ្រូត្រូវធ្វើឱ្យសិស្សដែលចូលរួមក្នុង «វេទិកាពិភាក្សា» មានអារម្មណ៍ថាមានទំនុកចិត្តមុននឹងចាប់ផ្តើមការពិភាក្សា។ គ្រូត្រូវពន្យល់សិស្សឱ្យយល់ថា មិនមានគំនិតណាមួយខុសឬត្រូវនៅក្នុងការពិភាក្សានេះឡើយ។ (គ្រប់គំនិតទាំងអស់ សុទ្ធតែអាចទទួលយកបាន ដរាបណាមានហេតុផលគ្រប់គ្រាន់)។

ពេលគ្រូអនុវត្តសកម្មភាពនេះ ជាលើកដំបូង គាត់គួរជ្រើសរើសសិស្សដែលមានបំណិនក្នុងកាសន្ទនា។ ការពិភាក្សារបស់ពួកគេ អាចជាឧទាហរណ៍សម្រាប់សិស្សផ្សេងៗទៀត។

នៅពេលពិភាក្សា គ្រូគប្បីកត់ត្រាបញ្ហា និងគំនិតភាន់ច្រឡំដែលចាំបាច់ត្រូវធ្វើការកែតម្រូវនៅពេលបង្រៀនបន្ទាប់ទៀត។ ប្រសិនបើសិស្សមួយចំនួនធំនៅតែមានការភាន់ច្រលំនៅចុងបញ្ចប់នៃសកម្មភាព គ្រូចាំបាច់ត្រូវពន្យល់បន្ថែមអំពីមេរៀនដដែលនេះ។

គ្រូគួររៀបចំសំណួរបន្ថែម និងដំបូន្មានដែលគាត់អាចនឹងប្រើនៅពេលដែលការពិភាក្សាជាប់គាំងមិនអាចឈានទៅមុខបាន។ សំណួរទាំងនេះ គប្បីជាសំណួរដែលមិនសូវពិបាកពេក ក៏មិនសូវស្រួលពេក ហើយជាសំណួរដែលបំផុសការពិភាក្សាវែកញែក។ ក្រោយពេលអនុវត្តសកម្មភាពគ្រូអាចវាយតម្លៃប្រសិទ្ធិភាពនៃសំណួរឬប្រយោគរបស់គាត់បាន ថាតើសំណួរឬប្រយោគទាំងនោះ មានភាពងាយស្រួលឬពិបាកសមល្មមហើយឬនៅ?





ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ
# តាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល

## ជំពូកទី 3
## វិធីវិទ្យាសាស្ត្រ







នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ 2012

# សេចក្ដីផ្ដើម



វិធីវិទ្យាសាស្ត្រជាបណ្ដុំសកម្មភាពសម្រាប់អង្កេតបាតុភូតនិងទទួលយកចំណេះដឹងថ្មី ក៏ដើម្បីកែតម្រូវនិងពង្រឹងចំណេះដឹងដែលមានស្រាប់។ វត្ថុបំណងសំខាន់មួយក្នុងការអប់រំវិទ្យាសាស្ត្រគឺការបញ្ចូលនូវវិធីវិទ្យាសាស្ត្រទៅក្នុងការបង្រៀនប្រកបដោយប្រសិទ្ធិភាព។

សិស្សស្វែងយល់ថាចំណេះដឹងវិទ្យាសាស្ត្រមិនមែនជាការប្រមូលផ្ដុំនៃការពិតដែលមិនប្រែប្រួលនោះទេ ប៉ុន្តែជាបណ្ដាញមួយដែលសកម្មនិងរីកចម្រើនជានិច្ច ដែលក្នុងនោះទំនាក់ទំនងថ្មីៗត្រូវបានបង្កើត សាកល្បង ពង្រឹងឬបដិសេធចោល។ ពួកគេឈ្វេងយល់ថា វិទ្យាសាស្ត្រគឺជាមធ្យោបាយរៀនសូត្រអំពីពិភពលោក។

ជាក់ស្ដែង ការងាររបស់អ្នកវិទ្យាសាស្ត្រមានភាពសាំញ៉ាំ ពិបាកនិងចំណាយពេលវេលាច្រើន។ ការអង្កេតបែបវិទ្យាសាស្ត្រក្នុងការបង្រៀនមេរៀនវិទ្យាសាស្ត្រតែងត្រូវបានអនុវត្តតាមវិធីសាមញ្ញនិងគោរពតាមគោលការណ៍គរុកោសល្យ។ តាមរយៈការអនុវត្តបែបនេះ គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្របំផុសសណ្ដាប់ធ្នាប់របៀបរៀបរយនិងបំណិនក្នុងការដោះស្រាយបញ្ហា។

ថ្វីបើពាក្យមួយចំនួនដូចជាការសង្កេត ការពិសោធន៍ សំណួរស្រាវជ្រាវ សម្មតិកម្ម។ល។ ត្រូវបានប្រើក្នុងកម្មវិធីសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រក៏ពិតមែន ក៏ពាក្យទាំងនេះហាក់ដូចជាបណ្ដាលឱ្យមានការភាន់ច្រឡំមិនត្រឹមតែចំពោះសិស្សប៉ុណ្ណោះទេ ចំពោះគ្រូក៏ដូច្នោះដែរ។ ដោយមូលហេតុ នេះហើយទើបយើងត្រូវការបែបផែនទូទៅមួយសម្រាប់ការបង្រៀនអំពីវិធីវិទ្យាសាស្ត្រ។





















# 1. ខ្លឹមសារសំខាន់ៗ

## 1. វិធីវិទ្យាសាស្ត្រ

ថ្វីបើមិនមានវិធីវិទ្យាសាស្ត្ររួមជាទូទៅមួយដែលត្រូវគេអនុវត្តតាមក៏ដោយ (សូមមើលកំណត់សម្គាល់សំខាន់ៗបន្ថែមទៀតនៅក្នុងអត្ថបទ) ក៏ការបង្រៀនមេរៀននិងគម្រោងវិទ្យាសាស្ត្រជាច្រើននៅតាមសាលារៀនប្រើប្រាស់លំដាប់នៃជំហានមួយចំនួនក្នុងលំនាំសកម្មភាពនេះ។ ជំហាននៃវិធីវិទ្យាសាស្ត្រអាចនឹងខុសប្លែកគ្នាពីឯកសារមួយទៅឯកសារមួយទៀត ប៉ុន្តែជានិច្ចកាលឯកសារទាំងនោះរួមមានជំហានដូចតទៅ:




ក) សួរសំណួរនិងកំណត់បញ្ហា: មុខវិជ្ជាសិក្សាអំពីវិទ្យាសាស្ត្រធម្មជាតិគឺធម្មជាតិខ្លួនឯង។ ក្នុងចំណោមការសង្កេតរាប់លាន ការសង្កេតមួយឬច្រើនគួរទទួលបានការយកចិត្តទុកដាក់ពីអ្នកសិក្សា។ វាធ្វើឱ្យពួកគេគិត និងបង្កើតសំណួរកាន់តែច្រើនជុំវិញបញ្ហានោះ។ ជាចុងក្រោយ បញ្ហានេះគួរត្រូវបានបំប្លែងជាសំណួរស្រាវជ្រាវច្បាស់លាស់មួយចំនួន។

ខ) ស្រាវជ្រាវរកព័ត៌មានមូលដ្ឋាន: ជាដំណាក់កាលដ៏លំបាកបំផុត (ជាពិសេសសិស្សក្មេងៗ) ហើយជានិច្ចកាលត្រូវបានមើលរំលងគឺតម្រូវការព័ត៌មានបន្ថែមនិងការស្រាវជ្រាវ។ ចំណេះដឹងមានស្រាប់របស់អ្នកស្រាវជ្រាវ និងលទ្ធភាពចូលទៅកាន់ប្រភពឯកសារមួយចំនួនមានសារសំខាន់ណាស់។

គ) បង្កើតសម្មតិកម្ម: ជានិច្ចកាល ពាក្យនេះត្រូវគេប្រើថាសម្មតិកម្មឬការទស្សន៍ទាយដោយចំណេះដឹង[1] ។ តាមការពិត យើងព្យាយាមពន្យល់បាតុភូតមួយចំនួនដែលយើងសម្គាល់ឃើញក្នុងជំហានទីមួយនៃវិធីវិទ្យាសាស្ត្រ។ ដូចនេះយើងត្រូវការបង្កើតសម្មតិកម្មសម្រាប់ស្រាវជ្រាវ ដោយផ្អែកលើចំណេះដឹងមានស្រាប់និងការស្រាវជ្រាវរបស់យើង។ សម្មតិកម្មទាំងនេះគួរតែផ្ទៀងផ្ទាត់នៅក្នុងជំហានបន្ទាប់។

ឃ) ផ្ទៀតផ្ទាត់ដោយការចងក្រងនិងអនុវត្តពិសោធន៍: ដំណាក់កាលមួយដ៏លំបាកដែលមានកិច្ចការជាច្រើនត្រូវពិចារណាគឺការចងក្រងពិសោធន៍។ តាមរយៈការធ្វើត្រាប់តាមបាតុភូតនានាក្នុងសកម្មភាពសិក្សា សិស្សអាចអង្កេតការសន្មតរបស់ពួកគេបាន។ យើងចាំបាច់ត្រូវត្រួតពិនិត្យអថេរឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន។ ពិសោធន៍ដ៏ល្អមួយចាំបាច់ត្រូវតែអាចអនុវត្តសារឡើងវិញបានហើយត្រូវបានវាស់វែងយ៉ាងច្បាស់លាស់ដោយប្រើឧបករណ៍ ដើម្បីអាចបញ្ជាក់ថាលទ្ធផលនៃការធ្វើពិសោធន៍ជាច្រើនដងនោះដូចគ្នា។

ង) វិភាគនិងទាញសន្និដ្ឋាន: ដោយផ្អែកលើការសង្កេតនិងទិន្នន័យដែលមាន យើងអាចទាញសេចក្តីសន្និដ្ឋានអំពីសម្មតិកម្មបាន។ សេចក្តីសន្និដ្ឋានទាំងនេះអាចផ្តោតទៅលើបរិមាណឬគុណភាពអាស្រ័យលើឧបករណ៍វាស់វែងដែលប្រើក្នុងពេលពិសោធន៍។ បើអាចធ្វើបាន អ្នកអាចបកស្រាយលទ្ធផលរបស់អ្នកជារូបមន្ត ឬសេចក្តីសន្និដ្ឋានបែបគុណភាពផ្សេងៗទៀត។

ក្នុងជំហាននេះ ការយល់ឃើញនិងបញ្ហាថ្មីៗអាចកើតមានឡើង ដែលទាមទារការធ្វើពិសោធន៍បន្ថែម។ អាស្រ័យលើលទ្ធផល យើងអាចត្រូវធ្វើការកែសម្រួលមួយចំនួននៅក្នុងជំហានមុនៗ (សំណួរថ្មីៗ ការស្រាវជ្រាវថ្មី និងទ្រឹស្តីថ្មីនៃការពិសោធន៍ថ្មី)។

1 សូមមើល Myth 2: សម្មតិកម្មមួយគឺជាការទស្សន៍ទាយដោយចំណេះដឹង McComas, W., 1996, Ten Myths of Science: Reexamining what we think we know…, Vol.96, School Science & Mathematics, p 10.





ច) រាយការណ៍លទ្ធផលៈ អ្នកវិទ្យាសាស្ត្រចេញផ្សាយរបាយការណ៍ចុងក្រោយរបស់គេនៅក្នុងព្រឹត្តិបត្រវិទ្យាសាស្ត្រមួយដើម្បីទំនាក់ទំនងជាមួយអ្នកវិទ្យាសាស្ត្រផ្សេងៗទៀត។ នៅក្នុងថ្នាក់រៀន ពេលដែលសិស្សបង្ហាញនិងពិភាក្សាសេចក្ដីសន្និដ្ឋាន សកម្មភាពនិងពិសោធន៍របស់ពួកគេ គេអាចអភិវឌ្ឍបំណិនដ៏មានប្រយោជន៍ជាច្រើន។

## 2. ឧទាហរណ៍

### ការហាលសម្លៀកបំពាក់

ក) អ្នកអាចកត់សម្គាល់ឃើញគេហាលសម្លៀកបំពាក់។ អ្នកអាចនឹងកើតមានចម្ងល់មួយចំនួនដូចជាៈ "ហេតុអ្វីបានជាគេហាលសម្លៀកបំពាក់នៅពេលនេះ? តើហាលនៅពេលណាទើបវាឆាប់ស្ងួត? ហេតុអ្វីបានជាសម្លៀកបំពាក់នោះត្រូវប្រើកន្លែងហាលច្រើនម្ល៉េះ?។ល។ ការសង្កេតទាំងនេះ ធ្វើឱ្យអ្នកគិត។



ខ) ជាការពិតណាស់ ផ្អែកលើអ្វីដែលអ្នកធ្លាប់ដឹងនិងធ្លាប់បានឃើញពីមុន អ្នកអាចរៀបរាប់បាននូវកត្តាមួយចំនួនដែលមានឥទ្ធិពលលើការសម្ងួតសម្លៀកបំពាក់ដូចជាសីតុណ្ហភាព ពន្លឺព្រះអាទិត្យ ខ្យល់និងក្រឡាផ្ទៃ។ អ្នកក៏ស្វែងរកព័ត៌មានបន្ថែមអំពីការសម្ងួតសម្លៀកបំពាក់ដែរ។ ប្រហែលជានៅមានកត្តាផ្សេងៗទៀតដែលអ្នកនៅមិនទាន់ដឹងនៅឡើយ។ ចម្ងល់ថ្មីៗអាចកើតមានឡើងដូចជាៈ តើកត្តាមួយណាដែលសំខាន់ជាងគេបំផុតៈ ជាខ្យល់ឬកម្ដៅ?

គ) យើងបង្កើតសម្មតិកម្មៈ ខ្យល់បក់កាន់តែខ្លាំងសម្លៀកបំពាក់កាន់តែឆាប់ស្ងួត ឬសីតុណ្ហភាពកាន់តែខ្ពស់ សម្លៀកបំពាក់កាន់តែឆាប់ស្ងួត។

ឃ) ដើម្បីផ្ទៀងផ្ទាត់សម្មតិកម្មឬការសន្មតរបស់អ្នកដោយប្រើពិសោធន៍ អ្នកត្រូវជួបនឹងការលំបាកមួយចំនួន។ ជាក់ស្ដែងអ្នកមិនអាចអង្កេតបាតុភូតក្នុងលក្ខខ័ណ្ឌដូចគ្នាបេះបិទនោះទេព្រោះមានអថេរជាច្រើនដែលមានឥទ្ធិពលលើលំនាំសម្ងួតសម្លៀកបំពាក់។ ដូចនេះអ្នកចាំបាច់ត្រូវ "ចម្លងតាម"បាតុភូតទាំងនេះនៅក្នុងថ្នាក់រៀនដើម្បីអាចគ្រប់គ្រងលើអថេរទាំងឡាយបាន។ យើងអាចប្រើក្រដាសប្រោះមួយចម្រៀកតូចជំនួសសម្លៀកបំពាក់ហើយជ្រលក់វាក្នុងទឹក។ ចម្រៀកក្រដាសប្រោះទាំងនេះអាចយកទៅសម្ងួតបាន។ យើងត្រូវការឱ្យលំនាំនេះអាចវាស់វែងបាន។ ដូចនេះអ្នកត្រូវកំណត់ល្បឿនរំហួតនិងគិតរកវិធីដែលអ្នកអាចវាស់វាបាន។ ក្នុងពេលកំពុងអង្កេត អ្នកអាចជ្រលក់ចម្រៀកក្រដាសប្រោះពីរចម្រៀកដូចគ្នាបេះបិទក្នុងអង្គធាតុរាវតែមួយនៅក្នុងពេលតែមួយ។ បន្ទាប់មកអ្នកដាក់ចម្រៀកក្រដាសប្រោះមួយចម្រៀកនៅមុខកង្ហារមួយ និងមួយចម្រៀកទៀត នៅក្នុងថ្នាក់(មិនមានកង្ហារ)។
វិធីមួយទៀតគឺដាក់ក្រដាសប្រោះមួយចម្រៀកហាលថ្ងៃនិងមួយចម្រៀកទៀតក្នុងម្លប់ឬក្នុងប្រអប់មួយត្រជាក់។

ង) ទាញសន្និដ្ឋានដោយផ្អែកលើការសង្កេតរបស់អ្នក។ព្រោះអ្នកមិនអាចកំណត់ល្បឿនខ្យល់ជាតួលេខបាន (ត្រឹមតែកម្លាំងនៃកង្ហារ) អ្នកចាំបាច់ត្រូវសន្និដ្ឋានដោយប្រើប្រយោគបែបគុណភាពវិញ ឧទាហរណ៍ ពេលដែលល្បឿនខ្យល់កាន់តែធំ ចម្រៀកក្រដាសប្រោះកាន់តែឆាប់ស្ងួត។

















ច ) នៅចុងបញ្ចប់ អ្នកបង្ហាញលទ្ធផលទៅសិស្សផ្សេងៗទៀតនៅក្នុងថ្នាក់។ មិនត្រឹមតែបង្ហាញលទ្ធផលរបស់អ្នកប៉ុណ្ណោះទេ អ្នកក៏ត្រូវបង្ហាញដំណើរការដែលអ្នកអង្កេតបញ្ហា វិធីប្រមូលទិន្នន័យនិងសម្មតិកម្មដែលអ្នកបានបង្កើតផងដែរ។ ប្រហែលជាមានសិស្សផ្សេងៗទៀតដែលមិនបានប្រើចម្រៀកក្រដាសប្រោះឬកង្ហារទេ? តើគេមានសេចក្តីសន្និដ្ឋានដូចអ្នកដែរឬទេ? តើពួកគេគាំទ្រឬការពារសម្មតិកម្មដូចអ្នកដែរឬទេ? ការប្រមូលផ្តុំព័ត៌មានដ៏មានប្រយោជន៍ទាំងនេះអាចនាំឆ្ពោះទៅរកចំណេះដឹងវិទ្យាសាស្ត្រ ដូចក្នុងការងារវិទ្យាសាស្ត្រជាក់ស្តែងដែរ។

ខាងក្រោមនេះ ជាឧទាហរណ៍ផ្សេងៗទៀតដែលអាចជួយឱ្យសិស្សរបស់អ្នករៀបចំផែនការការងារស្រាវជ្រាវមួយបាន:

- ឥទ្ធិពលនៃលក្ខណៈរបស់ដីចំពោះលំហូរលើផ្ទៃ
  ផែនដី និងបរិស្ថានវិទ្យា ថ្នាក់ទី12 ជំពូកទី1 មេរៀនទី3 ( ឆ្នាំ2011 )
  ជីវវិទ្យា ថ្នាក់ទី8 ជំពូកទី2 មេរៀនទី1 ( ឆ្នាំ2010 )

តើលក្ខណៈរបស់ដីណាខ្លះដែលមានឥទ្ធិពលទៅលើសម្រូបទឹករបស់ដី? កត្តាដែលអាចអង្កេតបានមានដូចជាប្រភេទដី សមាសធាតុរបស់ដី សំណើមរបស់ដី និងរុក្ខជាតិដែលដុះនៅលើដីនោះ។ គេអាចធ្វើការអង្កេតកត្តាទាំងឡាយខាងលើដោយរៀបចំសំណាកដីផ្សេងៗគ្នានៅលើប្លង់ទេរមួយ។



- កត្តាដែលមានឥទ្ធិពលទៅលើល្បឿនរលាយនៃស្ករនៅក្នុងទឹក
  គីមីវិទ្យា ថ្នាក់ទី8 ជំពូកទី3 មេរៀនទី3 ( ឆ្នាំ2010 )

តើកត្តាអ្វីខ្លះដែលមានឥទ្ធិពលលើល្បឿនរលាយនៃស្ករ ( ឬអំបិល )នៅក្នុងទឹក? កត្តាផ្សេងៗដែលយើងអាចអង្កេតបានមានដូចជាទំហំគ្រាប់ស្ករ សីតុណ្ហភាពទឹក ចំនួននៃការកូរ និងបរិមាណទឹក។ ការអង្កេតនេះនឹងពិភាក្សាលម្អិតនៅក្នុងឯកសារបំប៉នសម្រាប់មុខវិជ្ជាគីមីវិទ្យា។



- កត្តាដែលមានឥទ្ធិពលលើការដឹងរសជាតិ
  ជីវវិទ្យា ថ្នាក់ទី12 ជំពូកទី3 មេរៀនទី2 ( ឆ្នាំ2010 )

តើកត្តាអ្វីខ្លះដែលមានឥទ្ធិពលលើការដឹងរសជាតិរបស់យើង? កត្តាដែលយើងអាចអង្កេតបានរួមមានបរិមាណទឹក ទំហំភាគល្អិតនិងប្រភេទនៃអាហារ។ ការអង្កេតនេះនឹងពិភាក្សាលម្អិតនៅក្នុងឯកសារបំប៉នសម្រាប់មុខវិជ្ជាជីវវិទ្យា។





## 3. កំណត់សម្គាល់សំខាន់ៗ

ថ្វីបើជំហានទាំងនេះច្បាស់លាស់ និងអាចអនុវត្តក្នុងថ្នាក់រៀនបានក៏ពិតមែន ក៏នៅមានកំណត់សម្គាល់មួយចំនួនត្រូវលើកឡើងដែរ។

ចំណុចទីមួយគឺនៅក្នុងការងារវិទ្យាសាស្ត្រជាក់ស្តែងមិនមានវិធីវិទ្យាសាស្ត្រដែលត្រូវបានអនុវត្តដូចគ្នាជាទូទៅទេ[2]។ គំនិតដែលគិតថាមានវិធីវិទ្យាសាស្ត្ររួមតែមួយ ត្រូវបានមនុស្សទទួលយកយ៉ាងទូលំទូលាយ ដែលអាចបណ្តាលឱ្យសិស្សជាច្រើនកើតមានភាពមិនប្រាកដក្នុងចិត្តប្រសិនបើគេដឹងថាអ្នកវិទ្យាសាស្ត្រមិនមែនគោរពតាមជំហាននីមួយៗយ៉ាងម៉ត់ចត់គ្រប់ពេលវេលាទេនោះ។

វិធីបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រជាច្រើន បង្អាក់ភាពច្នៃប្រឌិតក្នុងវិទ្យាសាស្ត្រ។ ឧទាហរណ៍ដូចជាសកម្មភាពក្នុងទីពិសោធន៍មួយភាគធំគឺជាសកម្មភាពផ្ទៀងផ្ទាត់។ មានន័យថា គ្រូពិភាក្សាអំពីហេតុការណ៍ដែលនឹងកើតមានឡើងក្នុងទីពិសោធន៍ ឯកសារពន្យល់ជំហាននីមួយៗក្នុងដំណើរការពិសោធន៍ សិស្សត្រូវបានរំពឹងទុកថានឹងទទួលបានលទ្ធផលដូចលទ្ធផលដែលបានកំណត់។ ផ្ទុយទៅវិញ វិទ្យាសាស្ត្រគួរតែជាកិច្ចការមួយដ៏រំភើបនិងប្រកបដោយភាពច្នៃប្រឌិត។ មិនមានវិធីជាក់លាក់ណាមួយ ដែលត្រូវកំណត់ថាជាសកម្មភាពដ៏ត្រឹមត្រូវដែលត្រូវអនុវត្តតាមក្នុងសកម្មភាពអង្កេតវិទ្យាសាស្ត្រនោះទេ។

ជារួម អ្នកវិទ្យាសាស្ត្រសិក្សានិងដោះស្រាយបញ្ហាដោយប្រើការស្រមៃ ភាពច្នៃប្រឌិត ចំណេះដឹងមានស្រាប់ និងការព្យាយាម។ ជាការពិតណាស់ ទាំងនេះជាសកម្មភាពដែលមនុស្សគ្រប់គ្នាប្រើដើម្បីដោះស្រាយបញ្ហា។ ដូចនេះ ឯកសារសម្រាប់បញ្ចូលវិធីវិទ្យាសាស្ត្រក្នុងការបង្រៀនសង្កត់ធ្ងន់ទៅលើបំណិនទាំងឡាយដែលចាំបាច់សម្រាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ ជាជាងការអនុវត្តយ៉ាងម៉ត់ចត់តាមជំហាននីមួយៗក្នុងវិធីវិទ្យាសាស្ត្រ។

គ្រប់សកម្មភាពអាចអនុវត្តដាច់ដោយឡែកពីគ្នាឬអាចអនុវត្តជាជំហាននៅក្នុងវិធីវិទ្យាសាស្ត្រទាំងមូល។ ធ្វើបែបនេះ គ្រូមានភាពបត់បែនច្រើន ហើយគាត់អាចជ្រើសរើសសកម្មភាពមកអនុវត្តអាស្រ័យលើសម្ភារដែលមាន តម្រូវការនិងពេលវេលា។

សកម្មភាពទាំងនេះត្រូវបានបង្ហាញដោយសកម្មភាពប្រើសំណួរបើកនិងវិធីរិះរកអំពីផ្លាស្មា (ស្ទៃរ)។

2. McComas, W., 1996, Ten myths of science: Reexamining what we think we know...., Vol. 96, School Science & Mathematics, p 10. ( http://amasci.com/miscon/myths10.html )

# 2. សកម្មភាពផ្សេងៗនៃវិធីវិទ្យាសាស្ត្រ

## 1. សកម្មភាពទី1: វិធីប្រើបណ្តាភ្លើងសញ្ញាចរាចរ

### 1.1. សេចក្តីផ្តើម



“បណ្តាភ្លើងសញ្ញាចរាចរ” គឺជាសកម្មភាពបម្រើគោលវិធីសិស្សមជ្ឈមណ្ឌលដ៏សប្បាយរីករាយមួយដែល ផ្តល់ព័ត៌មានត្រឡប់ឱ្យគ្រូអំពីកម្រិតយល់ដឹងរបស់សិស្ស។ អ្នកអាចប្រើសកម្មភាពនេះដើម្បីស្វែងយល់ពីអ្វីដែលសិស្សគិតឬដឹងអំពីវិធីវិទ្យាសាស្ត្រ។ ជានិច្ចកាល សិស្សមានការយល់ដឹងមិនត្រឹមត្រូវឬមិនពេញលេញអំពីដំណើរការនៃវិទ្យាសាស្ត្រ។























## 1.2. វត្ថុបំណង



- ឆ្លុះបញ្ចាំងអំពីវិធីវិទ្យាសាស្ត្រក្នុងថ្នាក់រៀន (សកម្មភាពឆ្លុះបញ្ចាំង)
- បញ្ជាក់ហេតុផលក្នុងការពិភាក្សាអំពីវិធីវិទ្យាសាស្ត្រ
- ប្រាប់ពីចំណេះដឹងរបស់សិស្ស

## 1.3. សម្ភារ



សិស្សម្នាក់ត្រូវការបណ្ណបីសន្លឹក ពណ៌ក្រហម ពណ៌លឿងនិងពណ៌បៃតង។ បណ្ណគប្បីមានទំហំធំល្មមដើម្បីឱ្យគ្រូអាចមើលឃើញច្បាស់។ បណ្ណដែលអ៊ុតរឹង ជាប់ធន់បានយូរ។



## 1.4. ពេលវេលា



ដើម្បីប្រើជាល្បែងថាមពលសម្រាប់ចាប់ផ្តើម គួរអនុវត្តសកម្មភាពនេះនៅមុនពេលសិស្សអនុវត្តសកម្មភាពវិធីវិទ្យាសាស្ត្រ។ វត្ថុបំណងគឺដើម្បីស្វែងយល់អំពី ចំណេះដឹងមានស្រាប់របស់សិស្សអំពីវិធីវិទ្យាសាស្ត្រ។ សកម្មភាពនេះអាចពិបាកពេកសម្រាប់សិស្សដែលមិនធ្លាប់ដឹងអំពីវិទ្យាសាស្ត្រពិតឬមិនធ្លាប់ដឹងពីរបៀបធ្វើការរបស់អ្នកវិទ្យាសាស្ត្រ។ក្នុងករណីនេះ គ្រូគួរអនុវត្តសកម្មភាពនេះនៅចុងបញ្ចប់នៃការបញ្ចូលវិធីវិទ្យាសាស្ត្រក្នុងមេរៀន។ ការធ្វើបែបនេះជួយឱ្យគ្រូអាចវាយតម្លៃនិងឆ្លុះបញ្ចាំងអំពីសកម្មភាពដែលបានប្រើនៅក្នុងម៉ោងបង្រៀន។



## 1.5. ដំណើរការ



គ្រូអានប្រយោគមួយៗ។ ក្រោយពីគិតមួយភ្លែតមក សិស្សលើកបណ្ណដែលបញ្ជាក់ថាគេយល់ស្រប ឬមិនយល់ស្របចំពោះប្រយោគនេះ។ សិស្សគួរតែលើកបណ្ណព្រមៗគ្នាក្នុងពេលតែមួយ ដោយមិនយកតាមការលើកបណ្ណរបស់សិស្សផ្សេងទៀតឡើយ គឺលើកបណ្ណភ្លាមពេលគ្រូឱ្យសញ្ញា។

បណ្ណពណ៌បៃតង = យល់ស្រប<br>
បណ្ណពណ៌លឿង = មានចម្ងល់<br>
បណ្ណពណ៌ក្រហម = មិនយល់ស្រប

### ប្រយោគស្តីអំពីវិធីវិទ្យាសាស្ត្រ

ក ) កម្មវត្ថុនៃវិទ្យាសាស្ត្រមិនអាចធ្វើទៅបានទេព្រោះអ្នកវិទ្យាសាស្ត្រទាំងអស់រងឥទ្ធិពលនៃទស្សនៈរបស់ខ្លួន។

ខ ) ដោយប្រើវិធីវិទ្យាសាស្ត្រអ្នកអាចអះអាងអ្វីៗគ្រប់យ៉ាង ដោះស្រាយបានគ្រប់បញ្ហាឬឆ្លើយបានគ្រប់សំណួរទាំងអស់។

គ ) អ្នកវិទ្យាសាស្ត្រដែលពូកែបំផុត ជាអ្នកដែលគោរពតាមជំហានទាំងអស់នៃវិធីវិទ្យាសាស្ត្រ។

ឃ ) ពិសោធន៍មួយមិនអាចអះអាងថាអ្វីមួយត្រឹមត្រូវនោះទេ វាអាចត្រឹមតែអះអាងថាអ្វីមួយមិនខុសប៉ុណ្ណោះ។

ប្រសិនបើសិស្សភាគច្រើនលើកបណ្ណដែលមានពណ៌ដូចគ្នា ( ក្រហមឬបៃតង ) បញ្ជាក់ថាមានការយល់ឃើញរួមគ្នា។ ប្រសិនបើមានសិស្សលើកបណ្ណពណ៌លឿងច្រើន គ្រូចាំបាច់ត្រូវពន្យល់ប្រយោគនេះឡើងវិញឱ្យបានច្បាស់។ ប្រសិនបើសិស្សលើកបណ្ណជាល្បាយនៃពណ៌ទាំងបី មានន័យថាសិស្សមានការយល់ឃើញខុសៗគ្នា ដែលអាចឱ្យយើងរៀបចំការពិភាក្សាដ៏គួរឱ្យចាប់អារម្មណ៍ ( ឧទាហរណ៍ សកម្មភាពព្យុះគំនិតឬភ្លៀងគំនិត ) ទោះជាលទ្ធផលលើកបណ្ណបែបណាក៏ដោយ គ្រូនៅតែគប្បីសួរសំណួរពិភាក្សាដូចជា “ហេតុអ្វីបានជាអ្នកយល់ស្រប ( ឬមិនយល់ស្រប ) ?” “ហេតុអ្វីបានជាអ្នកនៅមិនទាន់យល់ច្បាស់?”

គួរធ្វើឱ្យប្រាកដថាសិស្សស្តាប់អំណះអំណាងគ្នាទៅវិញទៅមក ហើយការពិភាក្សាមានគោលបំណងបញ្ជាក់ឱ្យកាន់តែច្បាស់នូវប្រយោគនីមួយៗ។ ក្រោយការពិភាក្សាចប់ គ្រូអាចឱ្យសិស្សលើកបណ្ណម្តងទៀត និងសុំឱ្យសិស្សដែលប្តូរពណ៌បណ្ណប្រាប់ហេតុផលរបស់ខ្លួន។

គ្រូអាចរៀបចំក្រុមពិភាក្សាដែលមានសិស្សដែលលើកបណ្ណពណ៌ខុសគ្នាដើម្បីពិភាក្សាចម្លើយរបស់ពួកគេ។ ក្នុងពេលពិភាក្សា គ្រូអាចចល័តដើម្បីស្តាប់និងកត់ត្រាអំណះអំណាងល្អៗនិងការយល់ឃើញមិនត្រឹមត្រូវរបស់សិស្ស។ ចំពោះក្រុមណាដែលការពិភាក្សាមិនអាចឈានទៅមុខរួច គ្រូអាចផ្តល់គន្លឹះសម្រាប់បំផុសការពិភាក្សាបន្ថែមទៀត។





## 1.6. សំណួមពរ



បណ្ណភ្លើងសញ្ញាចរាចរគឺជាសកម្មភាពដ៏មានប្រសិទ្ធិភាពមួយដើម្បីទទួលបានព័ត៌មានត្រឡប់ភ្លាមៗពីសិស្សអំពីការបង្រៀនរបស់អ្នក។ ក្រោយពីបង្រៀនផ្នែកមួយនៃមេរៀនហើយ អ្នកអាចអង្កេតសិស្សដើម្បីវាយតម្លៃការយល់ដឹងរបស់ពួកគេ និងធ្វើការលើកបណ្ណ។

- បណ្ណពណ៌ក្រហមមានន័យថា: ខ្ញុំមិនយល់មេរៀននេះទេ
- បណ្ណពណ៌លឿងមានន័យថា: ខ្ញុំនៅមានចម្ងល់ខ្លះ
- បណ្ណពណ៌បៃតងមានន័យថា: ខ្ញុំយល់មេរៀននេះហើយ អ្នកអាចបន្តទៅចំណុចបន្ទាប់បាន



គប្បីបញ្ជាក់ឱ្យប្រាកដថាសិស្សដែលលើកបណ្ណពណ៌បៃតងពិតជាយល់មេរៀននេះមែន។ គ្រូអាចសួរសំណួរឬសុំឱ្យសិស្សពន្យល់ចំណុចដែលគ្រូទើបតែបង្រៀនទៅកាន់សិស្សផ្សេងៗទៀត។



## 1.7. ដំបូន្មានសំខាន់ៗ



ធ្វើឱ្យប្រាកដថា ការពិភាក្សាមិនចាកប្រធាន។ ការចូលរួមរបស់គ្រូគួរមានកម្រិតត្រឹមដឹកនាំការពិភាក្សាប៉ុណ្ណោះ ( សួរសំណួរបន្ថែម សង្ខេបគំនិតរបស់សិស្ស និងបញ្ចប់ការពិភាក្សា )។ វត្ថុបំណងសំខាន់គឺស្វែងរកការយល់ឃើញផ្ទាល់ខ្លួនរបស់សិស្សអំពីវិធីវិទ្យាសាស្ត្រ មិនមែនរកចម្លើយត្រឹមត្រូវនោះទេ។ ប្រយោគភាគច្រើនអាចទទួលបានចម្លើយផ្សេងៗគ្នា អាស្រ័យលើភាពសមហេតុផលនៃអំណះអំណាងរបស់សិស្ស។















# 2.សកម្មភាពទី2: វិធីព្យុះគំនិត

## 2.1. សេចក្តីផ្តើម



ព្យុះគំនិតគឺជាសកម្មភាពសម្រាប់ដោះស្រាយបញ្ហាជាក្រុមដ៏មានប្រយោជន៍និងមានប្រសិទ្ធិភាពដោយមានការចូលរួមគំនិតជាច្រើនពីសមាជិកក្រុម។ អ្នកវិទ្យាសាស្ត្រតែងមានការប្រជុំដោយប្រើសកម្មភាពព្យុះគំនិតយ៉ាងទៀងទាត់។ ជានិច្ចកាលមតិឬគំនិតផ្តល់ដោយសមាជិកក្រុមម្នាក់អាចជួយឱ្យសមាជិកផ្សេងៗទៀតនឹកឃើញគំនិតថ្មីៗជាបន្តបន្ទាប់។



## 2.2. វត្ថុបំណង



- ប្រមូលចំណេះដឹងមានស្រាប់របស់សិស្សដែលទាក់ទងជាមួយមេរៀនថ្មី
- បំផុសភាពច្នៃប្រឌិត
- ប្រែក្លាយការចង់ចេះចង់ដឹងទៅជាការចោទសំណួរវិទ្យាសាស្ត្រ
- ស្វែងរកចម្លើយឬដំណោះស្រាយ
- បង្កើតគំនិតឱ្យបានច្រើនបំផុតក្នុងរយៈពេលដ៏ខ្លី

## 2.3. ពេលវេលា



ព្យុះគំនិតអាចអនុវត្តបាននៅក្នុងដំណាក់ផ្សេងៗនៃវិធីវិទ្យាសាស្ត្រ (សូមមើលវត្ថុបំណងខុសៗគ្នា):

- នៅដើមវិធីវិទ្យាសាស្ត្រ ព្យុះគំនិតជួយឱ្យយើងស្វែងយល់ពីទិដ្ឋភាពទូទៅនៃបញ្ហា ស្វែងយល់អំពីចំណេះដឹងមានស្រាប់របស់សិស្ស និងដើម្បីបង្កើតសំណួរស្រាវជ្រាវ។ នៅក្នុងលំនាំវិទ្យាសាស្ត្រដ៏ល្អមួយ សិស្សអង្កេតសំណួរស្រាវជ្រាវទាំងនេះដោយខ្លួនឯងនៅក្នុងជំហានបន្ទាប់នៃវិធីវិទ្យាសាស្ត្រ។ ប្រភេទសំណួរបើកបែបនេះជំរុញទឹកចិត្តសិស្សឱ្យចង់ស្វែងរកចម្លើយ។ ក្រុមនីមួយៗជ្រើសរើសសំណួរស្រាវជ្រាវផ្សេងៗគ្នាដើម្បីអង្កេត។
- ព្យុះគំនិតក៏អាចជួយរកដំណោះស្រាយចំពោះបញ្ហាលំបាកៗនិងបង្កើតសម្មតិកម្មដែលអាចដាក់បញ្ចូលសម្រាប់ការអង្កេតពិសោធន៍ដើម្បីផ្ទៀងផ្ទាត់សម្មតិកម្មទាំងនោះ។

ជាធម្មតាអ្នកនឹងអនុវត្តសកម្មភាពនេះនៅក្នុងជំហានទី3នៃម៉ោងសិក្សា។

## 2.4. ដំណើរការ



ការណែនាំច្បាស់លាស់ពីការអនុវត្តមួយជំហានម្តងៗ មានសារសំខាន់ណាស់។

គ្រូអាចអនុវត្តតាមគោលការណ៍ណែនាំដូចតទៅ:

- លើកទឹកចិត្តសិស្សឱ្យគិត: សរសេរពាក្យគន្លឹះឬសំណួរគន្លឹះមួយនៅលើក្តារខៀន។ ជួនកាល ការធ្វើបង្ហាញងាយមួយក៏អាចជួយឱ្យសិស្សគិតដែរ។ ប្រសិនបើសិស្សមិនធ្លាប់ដឹងអំពីមេរៀននេះពីមុនមកទេ គួរផ្តល់ព័ត៌មានបន្ថែមឱ្យសិស្សដោយការបង្រៀនខ្លីមួយ។
- ចែកសិស្សជាក្រុមតូចៗ។ សិស្សម្នាក់ក្នុងក្រុមនីមួយៗត្រូវធ្វើជាអ្នកកត់ត្រារាល់គំនិតទាំងឡាយរបស់ក្រុម។
- កំណត់ពេលវេលាជាក់លាក់សម្រាប់សកម្មភាពព្យុះគំនិត ( ឧទាហរណ៍ អតិបរមា 5នាទី )។
- ដើម្បីធានាចំនួនគំនិតដែលសិស្សអាចរកបាន អ្នកអាចកំណត់ចំនួនគំនិតអប្បបរមាដែលគេត្រូវរក។
- បន្ទាប់ពីសិស្សធ្វើព្យុះគំនិតចប់ ទុកពេលឱ្យក្រុមនីមួយៗតម្រៀបគំនិតទាំងនោះតាមលំដាប់នៃភាពសំខាន់។



## 2.5. សំណូមពរ



អ្នកអាចបញ្ចូលនូវបែបបទមួយចំនួនបន្ថែមទៀតទៅក្នុងលំនាំព្យុះគំនិតដើម្បីធានាថាអ្នកចូលរួមទាំងអស់មានឱកាសបញ្ចេញមតិស្មើៗគ្នា ហើយអាចប្រើដើម្បីបង្កើតជាបញ្ជីផ្តល់ពិន្ទុចំពោះគំនិតនីមួយៗ។ សមាជិកក្រុមម្នាក់ៗត្រូវសរសេរគំនិតរបស់គេចូលក្នុងក្រដាសរៀងៗខ្លួន។ បន្ទាប់មកសមាជិកក្រុមម្នាក់ដែលមាននាទីជាអ្នកសម្របសម្រួលសុំឱ្យសមាជិកក្រុមម្នាក់ៗអានគំនិតមួយក្នុងចំនោមគំនិតដែលគេបានសរសេរ។ អ្នកសម្របសម្រួលសរសេរគំនិតរបស់សមាជិកក្រុមម្នាក់ៗនៅលើក្រដាសផ្ទាំងធំ។ បន្ទាប់មកសមាជិកក្រុមចម្លងបញ្ជីគំនិតចុងក្រោយរបស់ក្រុមចូលក្នុងក្រដាសមួយសន្លឹករៀងៗខ្លួនដោយផ្តល់ពិន្ទុឱ្យគំនិតនីមួយៗ។ ក្រដាសនីមួយៗនឹងត្រូវប្រមូលពីសមាជិកក្រុម ហើយធ្វើការបូកសរុបពិន្ទុ បង្កើតបានជាបញ្ជីពិន្ទុមួយ។ បន្ទាប់មក សមាជិកក្រុមអាចពិភាក្សាអំពីបញ្ជីពិន្ទុនេះ រហូតឈានដល់ការព្រមព្រៀងគ្នាចុងក្រោយ។

## 2.6. កម្មវិធីសិក្សា



**វិធីប្រើសំណួរបើកនិងវិធីរិះរកអំពីប្លាស្មា ( ស្វ៊ែរ ) ( រូបវិទ្យា )**

( 1 ) ចាប់ផ្តើមមេរៀន

ក ) ព្យុះគំនិត: បង្កើតទំនាក់ទំនងជាមួយពាក្យប្លាស្មា និងប្រមូលគំនិតមានស្រាប់របស់សិស្ស:
គ្រូសួរសំណួរទូទៅទៅសិស្សដើម្បី ស្វែងយល់ថាតើសិស្សដឹងអ្វីខ្លះអំពីប្លាស្មា។ ចម្លើយនិងការយល់ឃើញរបស់សិស្សអាចយកមកពិភាក្សាជាមួយសិស្សទាំងអស់គ្នា ( មិនមែនពិភាក្សាជាក្រុមទេ )





















សំណួរទាំងនោះអាចជា:
តើអ្វីទៅជាប្លាស្មា ? តើអ្នកគិតពីអ្វីពេលអ្នកឮពាក្យថាប្លាស្មា ?
តើអ្នកដឹងអ្វីខ្លះអំពីប្លាស្មា ? តើអ្នកចង់ដឹងអ្វីខ្លះអំពីប្លាស្មា ?

ខ) ការបង្រៀនខ្លីមួយអំពីលក្ខណៈសម្គាល់សំខាន់ៗនៃប្លាស្មា: គ្រូនិងសិស្សមិនសូវដឹងអំពីប្លាស្មាឡើយ។ យ៉ាងណាមិញ ប្លាស្មាកើតមានឡើងច្រើនក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដូចជា:

- ប្លាស្មាក្នុងបច្ចេកវិទ្យាពន្លឺ:
  - ស្វ៊ែរប្លាស្មា
  - ទូរទស្សន៍
  - អំពូល ( ភ្លុយអររ៉េសង់ )
  - ផ្លាកសញ្ញាអំពូលនេអុង










ឯកសារយោង: wikipedia

- ប្លាស្មាក្នុងការស្រាវជ្រាវប្រតិកម្មនុយក្លេអ៊ែរ: ដោយហេតុថាប្លាស្មាអាចកម្ដៅរហូតដល់សីតុណ្ហភាពខ្ពស់ខ្លាំង វាអាចប្រើជាឥន្ធនៈក្នុងពិសោធន៍ប្រតិកម្មនុយក្លេអ៊ែរ។

- ប្លាស្មាក្នុងធម្មជាតិ
  - ព្រះអាទិត្យ
  - ពន្លឺប៉ូល
  - ផ្លេកបន្ទោរ
  - ភ្លើងទៀន





ឯកសារយោង: www.nasa.gov

ប្លាស្មាក៏ត្រូវបានហៅថាភាវៈទីបួននៃការប្រមូលផ្ដុំដែរ។

ព័ត៌មាននេះផ្ដល់ឱ្យសិស្សនូវចំណេះដឹងអំពីសារសំខាន់នៃប្លាស្មាក្នុងមុខវិជ្ជារូបវិទ្យា (បច្ចេកវិទ្យា ធម្មជាតិ។ល។) ប៉ុន្តែចំណុចដែលសំខាន់ជាងនេះទៅទៀតនោះគឺ វាបំផុសការគិតបន្ថែមទៀតអំពីប្លាស្មា។

គ) ចោទសំណួរនិងលើកគំនិតសំខាន់ៗអំពីប្លាស្មាសិស្សត្រូវបង្កើតសំណួរឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន អំពីអ្វីដែលពួកគេចង់ដឹងអំពីប្លាស្មា។ បើចាំបាច់ គ្រូគួរយោងទៅលើបាតុភូតដែលពិពណ៌នាខាងលើ។ សិស្សធ្វើការជាក្រុមតូចៗ ហើយអ្នករាយការណ៍ម្នាក់ត្រូវកត់ត្រាសំណួរទាំងអស់។ គ្រប់សំណួរដែលទាក់ទងនឹងមេរៀននេះ សុទ្ធតែជាសំណួរល្អ



ទោះជាមិនអាចឆ្លើយបានក៏ដោយ។

សិស្សត្រូវបង្កើតសំណួរដោយខ្លួនឯង (មិនមែនគ្រូទេ)។ សំណួរទាំងនោះអាចជា:

| | | |
|---|---|---|
| ពន្លឺប៉ូល: ហេតុអ្វីមាននៅតែប៉ូល? | តើអ្នកអាចប៉ះឬមើលឃើញប្លាស្មាឬទេ? | តើប្លាស្មាមានពណ៌អ្វី? |
| ភាវៈនៃរូបធាតុ: ហេតុអ្វីទីបួន? | តើអាចបង្កើតប្លាស្មាបានដោយរបៀបណា? | តើប្លាស្មាគ្រោះថ្នាក់ឬទេ? តើគេអាចប្រើវាក្នុងផ្លូវខុសឬទេ? |
| តើប្លាស្មានិងទូរទស្សន៍ទាក់ទងគ្នាយ៉ាងដូចម្តេច? | ហេតុអ្វីបានជាប្លាស្មាបញ្ចេញពន្លឺ? | តើប្លាស្មាផ្សំឡើងពីអ្វី? |
| វាអាចរងឥទ្ធិពលពីអ្វី? | ហេតុអ្វីបានជាវាមានចលនា? តើអាចឈប់ស្ងៀមបានទេ? | តើប្លាស្មាមានសីតុណ្ហភាពប៉ុន្មាន? |
| ហេតុអ្វីបានជាមានពណ៌ប្លែកៗគ្នា? | ហេតុអ្វីបានជាប្លាស្មាស្ថិតនៅខាងក្នុងស្វ៊ែរ? | តើស្វ៊ែរប្លាស្មាដំណើរការយ៉ាងដូចម្តេច? |
| តើប្លាស្មាអាចទៅដល់គ្រប់ទីកន្លែងឬទេ? | តើគេអាចរក្សាប្លាស្មាទុកដោយរបៀបណា? | តើអ្នកអាចប៉ះប្លាស្មាបានទេ? |

សិស្សអាចបង្កើតសំណួរប្លែកៗគ្នាជាច្រើនដែលត្រូវចំណាយពេលច្រើននិងពិបាកឆ្លើយ។ ទោះជាយ៉ាងនេះក្តី គ្រូគួរប្រមូលសំណួរទាំងអស់នេះ កែសម្រួលនិងវាយតម្លៃនៅពេលក្រោយ។ សំណួរបើកទាំងនេះគប្បីត្រូវឆ្លើយនៅក្នុងការបង្រៀនរបស់គ្រូ ប៉ុន្តែមិនមែនភ្លាមៗទេ។ គោលគំនិតនៃការប្រើប្រាស់សំណួរបើកគឺអ្នកចូលរួមសហការគ្នាដើម្បីឆ្លើយសំណួររបស់គេដោយខ្លួនឯងនៅក្នុងសិក្ខាសាលា (សូមមើលសកម្មភាពបន្ថែមទៀត)។

ឧទាហរណ៍នៃសំណួរផ្តើម:

ជីវវិទ្យា:

- តើយើងអាចការពារខ្លួនទល់នឹងជម្ងឺឆ្លងយ៉ាងដូចម្តេច? (ថ្នាក់ទី11 ជំពូកទី8 មេរៀនទី1 ឆ្នាំ2009)
- តើយើងអាចអភិរក្សធនធានជាតិយើងយ៉ាងដូចម្តេច? (ថ្នាក់ទី9 ជំពូកទី5 មេរៀនទី 1&2 ឆ្នាំ2011)
- តើយើងអាចកែលម្អបរិស្ថានសាលារៀនយើងយ៉ាងដូចម្តេច?
- ហេតុអ្វីបានជាទឹកទន្លេក្នុងតំបន់របស់អ្នកត្រូវបានធ្វើឱ្យកខ្វក់? សូមរកមូលហេតុឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន។
(ថ្នាក់ទី11 ជំពូកទី6 មេរៀនទី3)
- សូមសរសេរជាចំណុចៗនូវអ្វីៗដែលអ្នកដឹងអំពីថ្នាំសម្លាប់សត្វល្អិតចង្រៃ។
(ថ្នាក់ទី8 ជំពូកទី1 មេរៀនទី2 ឆ្នាំ2010)

គីមីវិទ្យា:

សូមរំឭកឡើងវិញនូវអ្វីដែលអ្នកដឹងអំពីអាស៊ីតនិងបាស។
(ថ្នាក់ទី9 ជំពូកទី3 មេរៀនទី2-3 ឆ្នាំ2011)
(ថ្នាក់ទី12 ជំពូកទី3 មេរៀនទី1-4 ឆ្នាំ2010)

ផែនដី និងបរិស្ថានវិទ្យា:

- សូមរំឭកឡើងវិញនូវអ្វីដែលអ្នកដឹងអំពីព្រះអាទិត្យ។
(ថ្នាក់ទី7 ជំពូក1 មេរៀនទី2 ឆ្នាំ2009)
- តើយើងអាចពិសោធន៍សាកល្បងយ៉ាងដូចម្តេចដើម្បីបញ្ជាក់ថាមានប្រេងនៅនៅក្រោមផ្ទៃផែនដី?
(ថ្នាក់ទី12 ជំពូកទី4 មេរៀនទី2 ឆ្នាំ2011)
- សូមបង្កើតការប្រៀបប្រដូចមួយដើម្បីពន្យល់សិស្សអំពីការរីកនៃសាកល។
(ថ្នាក់ទី12 ជំពូកទី3 មេរៀនទី4 ឆ្នាំ2011)
- តើយើងអាចបង្កើតធនធានថាមពលកកើតឡើងវិញក្នុងប្រទេសកម្ពុជាយ៉ាងដូចម្តេច?
(ថ្នាក់ទី12 ជំពូកទី4 មេរៀនទី3&4 ឆ្នាំ2011)

រូបវិទ្យា

- សូមរំឭកឡើងវិញនូវអ្វីដែលអ្នកដឹងអំពីកម្តៅ។ (ថ្នាក់ទី7 ជំពូកទី1 មេរៀនទី3 ឆ្នាំ2009)
- តើអ្នកចង់ដឹងអ្វីខ្លះអំពីទឹកកក? (ថ្នាក់ទី10 ជំពូកទី2 មេរៀនទី3 ឆ្នាំ2009)
- សូមរកឧទាហរណ៍ឱ្យបានច្រើនអំពីច្បាប់ទីបីញូតុន។
(ថ្នាក់ទី8 ជំពូកទី2 មេរៀនទី3 ឆ្នាំ2010)

























## 2.7. ដំបូន្មានសំខាន់ៗ



គំនិតដែលទទួលបានពីព្យុះគំនិតមិនត្រូវវាយតម្លៃដោយយោងទៅលើភាពសមគួរអាចធ្វើទៅបាននោះទេ។ ដូចនេះគ្រូត្រូវផ្តល់ឱ្យសិស្សនូវគោលការណ៍ណែនាំមួយចំនួននៅពេលអនុវត្តសកម្មភាពព្យុះគំនិត:

- គួរកុំពិភាក្សាឬវាយតម្លៃគំនិតរហូតដល់ដំណាក់កាលព្យុះគំនិតត្រូវបានបញ្ចប់។
- ផ្តោតតែទៅលើបរិមាណជាជាងគុណភាព។ គំនិតកាន់តែច្រើន ឱកាសទទួលបានគំនិតល្អៗក៏មានកាន់តែច្រើនដែរ។
- រក្សាបរិយាកាសមួយដែលមិនមានការរិះគន់។ លើកទឹកចិត្តការបញ្ចេញយោបល់ ទោះជាគំនិតយោបល់នោះហាក់មិនសមហេតុផល ឬមិនអាចយកជាការបានក៏ដោយ។
- ផ្តើមចេញពីគំនិតរបស់អ្នកដទៃ រួមបញ្ចូលឬកែតម្រូវគំនិតមួយចំនួនដែលត្រូវបានលើកឡើងរួចហើយ។

ចំណុចសំខាន់ក្នុងការធ្វើព្យុះគំនិតគឺបំផុសឱ្យសិស្សគិត។ បើសិស្សមិនសូវមានការយល់ដឹងច្រើនអំពីមេរៀន សកម្មភាពព្យុះគំនិតនឹងចប់យ៉ាងរហ័ស។ អាស្រ័យហេតុនេះ ទាមទារឱ្យគ្រូធ្វើសកម្មភាពបន្ថែម (ឧទាហរណ៍បាតុភូត ការបង្រៀនបន្ថែមអំពីមេរៀននោះ បង្ហាញរូបភាព។ល។)។

សិស្សចូលរួមសកម្មនៅពេលដែលគេមានអារម្មណ៍ថាពួកគេកំពុងចូលរួមគិតអំពីសំណួរដែលសំខាន់ចំពោះពួកគេ។ លើកទឹកចិត្តសិស្សទាំងអស់ឱ្យចូលរួមយោបល់នៅក្នុងការសន្ទនានៃសកម្មភាពព្យុះគំនិត។

សូមមើលសកម្មភាពភ្លៀងគំនិតសម្រាប់ដំបូន្មានល្អៗក្នុងការបង្កើតសំណួរព្យុះគំនិតល្អៗ។





# 3. សកម្មភាពទី3: វិធីធ្វើចំណែកថ្នាក់ (ចំណាត់ថ្នាក់បណ្ណ)

## 3.1. សេចក្ដីផ្ដើម



សិស្សតែងយល់ច្រឡំថាចំណេះដឹងវិទ្យាសាស្ត្រជាអ្វីដែលគេស្រាវជ្រាវ "រកឃើញ" ហើយជាចំណេះដឹងមួយមិនអាចកែប្រែបាន។ យ៉ាងណាមិញអ្នកវិទ្យាសាស្ត្របានខិតខំប្រឹងប្រែងជាច្រើនលើកច្រើនសារដើម្បីរៀបចំព័ត៌មានដ៏ច្រើនសម្បើមនោះឱ្យមានសណ្ដាប់ធ្នាប់។ តួយ៉ាងដូចជាប្រព័ន្ធចំណែកថ្នាក់ ត្រូវបានបង្កើតឡើងដើម្បីរៀបចំវត្ថុនិងជីវិតដែលមានភាពចម្រុះយ៉ាងសម្បូរបែបឱ្យមានសណ្ដាប់ធ្នាប់។ អ្នកវិទ្យាសាស្ត្រធ្វើចំណែកថ្នាក់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលគេបានព្រមព្រៀងគ្នា។ យ៉ាងណាមិញ លក្ខណៈវិនិច្ឆ័យខុសគ្នាអាចបណ្ដាលឱ្យមានការធ្វើចំណែកថ្នាក់ខុសគ្នាដែរ។

សិស្សអាចប្រើបំណិនដូចគ្នានេះដើម្បីរៀបចំគំនិតនិងសំណួរនៅក្នុងជំហានដំបូងនៃវិធីវិទ្យាសាស្ត្រ។ ពួកគេស្វាបស្ទង់ព័ត៌មានដែលអាចរកបាន ហើយព្យាយាមពិភាក្សានៅក្នុងក្រុមដើម្បីឯកភាពគ្នាអំពីលក្ខណៈវិនិច្ឆ័យសម្រាប់ចែកថ្នាក់ព័ត៌មានដែលគេមាន។

ឧទាហរណ៍មួយដែលត្រូវបានលើកមកសិក្សាគឺ "សកម្មភាពចំណាត់ថ្នាក់បណ្ណ"។ សិស្សអាចយល់ថាសកម្មភាពចំណាត់ថ្នាក់បណ្ណជាបទពិសោធន៍មួយផ្សេង ដែលមិនផ្លូវការហើយផ្ដល់ភាពសប្បាយរីករាយ។ សកម្មភាពនេះជួយឱ្យសិស្សត្រៀមខ្លួនរួចជាស្រេចដើម្បីសិក្សាឬរំឭកមេរៀនមួយឡើងវិញ។

## 3.2. វត្ថុបំណង



- ពន្យល់ថាវត្ថុមួយចំនួនក្នុងវិទ្យាសាស្ត្រមិនស្ថិតនៅក្នុងក្រុមណាមួយច្បាស់លាស់ទេ
- បកស្រាយថាការធ្វើចំណែកថ្នាក់ជាសកម្មភាពមនុស្សដោយពឹងផ្អែកលើលក្ខណៈវិនិច្ឆ័យដែលមនុស្សព្រមព្រៀងគ្នាប៉ុន្តែអាចកែប្រែបាន
- រៀបចំចំណេះដឹងឱ្យមានរចនាសម្ពន្ធត្រឹមត្រូវ
- រៀបចំព័ត៌មានឬសំណួរវិទ្យាសាស្ត្រជាក្រុម (ធ្វើចំណែកថ្នាក់)
- ទំលាប់រៀនសូត្រពីគ្នាទៅវិញទៅមកនៅក្នុងក្រុម



## 3.3. ពេលវេលា



សកម្មភាពនេះអាចប្រើសម្រាប់រៀបចំគំនិតឬសំណួរជាច្រើនដែលទទួលបានក្រោយសកម្មភាពព្យុះគំនិតជាក្រុម។















យ៉ាងណាមិញ វិធីធ្វើចំណែកថ្នាក់ក៏មានសារសំខាន់នៅក្នុងដំណាក់កាលផ្សេងៗទៀតនៃវិធីវិទ្យាសាស្ត្រដែរ។ ឧទាហរណ៍ការធ្វើចំណាត់ក្រុមនូវការសង្កេតបាតុភូតភាវរស់និងវត្ថុ (សូមមើលឧទាហរណ៍ក្នុងកម្មវិធីសិក្សា)។

ជាញឹកញាប់ ការធ្វើចំណាត់ថ្នាក់បណ្ណត្រូវប្រើក្នុងជំហានទី3នៃម៉ោងបង្រៀន។



## 3.4. ដំណើរការ



សកម្មភាពបង្រៀនមួយដែលអាចធ្វើបានគឺ “ការធ្វើចំណាត់ថ្នាក់បណ្ណ”។ ការណែនាំអំពីជំហាននៃការអនុវត្តមានដូចតទៅ:



- គ្រូចែកសិស្សជាក្រុមតូចៗ។
- គ្រូផ្តល់បណ្ណមួយឈុតដល់ក្រុមនីមួយៗ។
- សិស្សព្យាយាមចែកបណ្ណទាំងនោះជាក្រុម និងសរសេរលក្ខណៈវិនិច្ឆ័យនៃការចែកក្រុមផង។ ទន្ទឹមនឹងនោះគ្រូចល័តដើម្បីជួយសម្របសម្រួលសិស្សនៅពេលដែលចាំបាច់។
- ក្រោយពីតម្រៀបបណ្ណជាក្រុមរួចហើយ គ្រូពន្យល់ពីលក្ខណៈវិនិច្ឆ័យដែលអ្នកវិទ្យាសាស្ត្រប្រើដើម្បីធ្វើចំណែកថ្នាក់ក្នុងមេរៀននេះ។
- ក្រោយការពន្យល់ចប់សិស្សព្យាយាមធ្វើចំណាត់ថ្នាក់បណ្ណជាថ្មីដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរបស់អ្នកវិទ្យាសាស្ត្រ។
- គ្រូធ្វើសេចក្តីសន្និដ្ឋាន។



## 3.5. សំណូមពរ





ជំនួសបណ្ណ គ្រូអាចប្រើវត្ថុជាក់ស្តែង (ដុំថ្ម រ៉ែ ស្លឹកឈើ ល្បាយ) ពាក្យឬសំណួរដែលសរសេរលើក្តារខៀនក៏បាន។

គ្រូអាចផ្តល់ឱ្យសិស្សជាមុននូវចំណងជើងក្រុមនីមួយៗឬឱ្យសិស្សជាអ្នកបង្កើតចំណងជើងក្រុមដោយខ្លួនឯង។

គ្រូអាចផ្តល់បណ្ណមិនទាន់សរសេរឱ្យសិស្សសរសេរបន្ថែមគំនិតដែលគេនឹកឃើញ។

## 3.6. កម្មវិធីសិក្សា



សកម្មភាពសំណួរបើកនិងវិធីវិភាគអំពីប្លាស្មា (ស្ទើរ):

(2) ចែកសំណួរជាក្រុម:

ដោយប្រើបញ្ជីសំណួរដែលបានលើកឡើងក្នុងសកម្មភាពព្យុះគំនិត (សូមមើលចំណុច (1)) ការធ្វើចំណាត់ថ្នាក់នឹងត្រូវធ្វើជាមួយសិស្ស។ នេះមានន័យថាសំណួរត្រូវបានប្រមូលបញ្ចូលគ្នាក្រោមប្រធានបទតែមួយ។

មេរៀនដែលអាចអនុវត្តសកម្មភាពនេះបានមានដូចជាមេរៀនកម្តៅ ពន្លឺ រូបធាតុ គ្រោះថ្នាក់។ល។

នៅទីបញ្ចប់ យើងទទួលបានក្រុមសំណួរផ្សេងៗគ្នា។ គ្រូបន្ថែមគំនិតនិងសំណួរដើម្បីទាញទៅរកវត្ថុបំណងមេរៀន។

បន្ទាប់មក សិស្សចូលទៅតាមក្រុមដែលពិភាក្សាអំពីក្រុមសំណួរនីមួយៗ។

ផែនដី និងបរិស្ថានវិទ្យា

ភពនៃប្រព័ន្ធព្រះអាទិត្យ (ថ្នាក់ទី7 ជំពូកទី1 មេរៀនទី4 ឆ្នាំ2009)
កាឡាក់ស៊ី (ថ្នាក់ទី10 ជំពូកទី4 មេរៀនទី3 ឆ្នាំ2011 និង ថ្នាក់ទី12 ជំពូកទី3 មេរៀនទី3 ឆ្នាំ2011)



ការណែនាំសម្រាប់សិស្ស:

- សង្កេតរូបភាពភពទាំងឡាយនៃប្រព័ន្ធព្រះអាទិត្យនិង រូបភាពកាឡាក់ស៊ី។
- ធ្វើចំណែកថ្នាក់ផ្អែកលើលក្ខណៈវិនិច្ឆ័យរបស់អ្នក។
- អះអាងការជ្រើសរើសរបស់អ្នក។
- ប្រៀបធៀបការធ្វើចំណែកថ្នាក់របស់អ្នកជាមួយការធ្វើចំណែកថ្នាក់បែបវិទ្យាសាស្ត្រ។





គីមីវិទ្យា:
ចំណែកថ្នាក់រូបធាតុ (ថ្នាក់ទី7 ជំពូកទី1 មេរៀនទី2 ឆ្នាំ2009)

- សង្កេតរូបភាពនៃសារធាតុផ្សេងៗគ្នាមួយចំនួន
- ធ្វើចំណែកថ្នាក់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរបស់អ្នក
- ផ្តល់អំណះអំណាងនៃការធ្វើចំណែកថ្នាក់របស់អ្នក
- ចូរប្រៀបធៀបការធ្វើចំណែកថ្នាក់របស់អ្នកជាមួយដ្យាក្រាមខាងក្រោម




ឯកសារយោង: http://www.middleschoolscience.com

| 2. ទឹកដោះ |
|---|
| **សមាសភាពគីមី:**<br>ខ្លាញ់ឆ្អែត ប្រូតេអ៊ីន កាល់ស្យូម និងវីតាមីន C<br>**រូបរាង:** អង្គធាតុរាវពណ៌ស<br>**ដង់ស៊ីតេ:** 1.03g/cm$^3$ |
| ទឹកដោះគឺជាប្រភពធម្មជាតិនៃសារធាតុចិញ្ចឹមសម្រាប់កូនថនិកសត្វ។ ទឹកដោះរបស់សត្វមួយចំនួនប្រើជាអាហាររបស់មនុស្ស។ |


















ជីវវិទ្យា:
ចំណែកថ្នាក់សត្វឆ្អឹងកង ( ថ្នាក់ទី10 ជំពូកទី1 មេរៀនទី6 ឆ្នាំ2008 )

- សង្កេតរូបភាពសត្វឆ្អឹងកងមួយចំនួន។
- ធ្វើចំណែកថ្នាក់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរបស់អ្នក
- ផ្តល់អំណះអំណាងចំពោះការធ្វើចំណែកថ្នាក់របស់អ្នក។
- ប្រៀបធៀបការធ្វើចំណែកថ្នាក់របស់អ្នកជាមួយការធ្វើចំណែកថ្នាក់ដែលអ្នកវិទ្យាសាស្ត្រប្រើ។


ឯកសារយោង: wikipedia

រូបវិទ្យា
ឥន្ធនៈ ( ថ្នាក់ទី12 ជំពូកទី2 មេរៀនទី2 )
( ថ្នាក់ទី7 ជំពូកទី1 មេរៀនទី3 ឆ្នាំ2009 )

សិស្សពិភាក្សាពាក្យមួយចំនួនខាងក្រោម ហើយចែកចេញជាបីក្រុមគឺ ឥន្ធនៈ មិនមែនឥន្ធនៈ និង “មិនច្បាស់”។ សិស្សសរសេរឱ្យបានត្រឹមត្រូវនូវហេតុផលដែលគេដាក់ធាតុនីមួយៗនៅក្នុងក្រុមជាក់លាក់មួយ។




ផែនដី និងបរិស្ថានវិទ្យា:
តំបន់ធាតុអាកាស និងអាកាសធាតុ

សិស្សធ្វើចំណាត់ថ្នាក់បណ្ណដោយប្រើតារាងអាកាសធាតុដែលត្រូវគ្នានឹងរូបភាពមួយចំនួននៃតំបន់ធម្មជាតិ ( ថ្នាក់ទី11 ជំពូកទី4 មេរៀនទី2 )។ សកម្មភាពនេះត្រូវបានពណ៌នាលម្អិតនៅក្នុងឯកសារសកម្មភាពផែនដី និងបរិស្ថានវិទ្យា។

## 3.7. ដំបូន្មានសំខាន់ៗ



- វិធីសមស្របបំផុតសម្រាប់អនុវត្ត សកម្មភាពចំណាត់ថ្នាក់បណ្ណគឺធ្វើជាក្រុមតូចៗដើម្បីលើកទឹកចិត្តសិស្សឱ្យជជែកអំពីគំនិតរបស់គេ។
- បណ្ណនីមួយៗគប្បីមានទំហំធំល្មមសិស្សអាចអានបានដោយងាយ។
- សិស្សពិភាក្សាអំពីបណ្ណឬសំណួរនីមួយៗដើម្បីឈានដល់ការឯកភាពមួយអំពីក្រុមដែលត្រូវបញ្ចូលសំណួរនោះមុននឹងពិភាក្សាបណ្ណថ្មីមួយទៀត។ ជៀសវាងសិស្សដាក់បញ្ចូលបណ្ណទៅក្នុងក្រុមភ្លាមៗដោយមិនបានពិភាក្សាគ្នាច្បាស់លាស់។
- យើងអាចបន្ថែមឈ្មោះក្រុមមួយដោយដាក់ឈ្មោះថា “អាស្រ័យលើហេតុផល” ឬ “មិនច្បាស់”។
- លើកទឹកចិត្តសិស្សឱ្យបង្កើត“វិន័យ”មួយ ដែលត្រូវប្រើសម្រាប់កំណត់ក្រុម។




# 4. សកម្មភាពទី4: វិធីពិសោធន៍ព្រឹត្តិការណ៍ប្លែកៗ

## 4.1. សេចក្តីផ្តើម



ព្រឹត្តិការណ៍ប្លែកៗជាធម្មតាគឺជាការបង្ហាញខ្លីៗរបស់គ្រូ ឬសិស្សជាអ្នកធ្វើសកម្មភាព។ ដោយសារ លទ្ធផលមិននឹកស្មានដល់និងផ្ទុយពីការគិត ព្រឹត្តិការណ៍ប្លែកៗបំផុសចំណាប់អារម្មណ៍និងការចង់ដឹងរបស់សិស្ស និងបង្រៀនពួកគេឱ្យសួរសំណួរ បង្កើតសម្មតិកម្ម និងទស្សន៍ទាយលទ្ធផល។



## 4.2. វត្ថុបំណង



- បកស្រាយដោយប្រើជំនឿនិងចំណេះដឹងមានស្រាប់
- បង្កើនការចូលរួមសកម្មរបស់សិស្សនិងបង្កើតការចង់ចេះចង់ដឹង
- អភិវឌ្ឍបំណិនដោះស្រាយបញ្ហានិងគិតពិចារណា
- បកស្រាយអំពីគំនិតវិទ្យាសាស្ត្រជំនួសការគ្រាន់តែរំឭកវាឡើងវិញ
- ជុសខាត់បំណិនសង្កេត ទស្សន៍ទាយ ប្រមូលទិន្នន័យ និងពិសោធន៍

## 4.3. ពេលវេលា



សកម្មភាពនេះអាចអនុវត្តបានក្នុងជំហានទី3 អាស្រ័យលើវត្ថុបំណង:

- ដើម្បីចាប់ផ្តើមមេរៀនថ្មីតាមវិធីដែលទាក់ទាញចំណាប់អារម្មណ៍ (ត្រៀម)។
- សាកល្បងសមត្ថភាពសិស្សក្នុងការទស្សន៍ទាយលទ្ធផលនៃពិសោធន៍មួយ។
- ដើម្បីធ្វើការសង្កេតនិងបង្កើតសម្មតិកម្ម។



## 4.4. ដំណើរការ



បង្ហាញការពិសោធន៍មុនចាប់ផ្តើមមេរៀន។ ធ្វើយ៉ាងណាឱ្យសិស្សទាំងអស់គ្នាអាចមើលឃើញការបង្ហាញនេះយ៉ាងច្បាស់។ សិស្សទស្សន៍ទាយលទ្ធផលហើយគ្រូស្នើឱ្យពួកគេពន្យល់ចម្លើយរបស់ពួកគេក្រោយការបង្ហាញចប់។ ទុកពេលយ៉ាងហោចណាស់ 3វិនាទីឱ្យសិស្សឆ្លើយតបនឹងសំណួរ។ គប្បីប្រើសំណួរបើកដើម្បីឱ្យសិស្សយកបទពិសោធន៍និងចំណេះដឹងមានស្រាប់របស់គេមកប្រើនិងដើម្បីដឹកនាំពួកគេឈានទៅរកឃើញហេតុផលនៃការប្រើពិសោធន៍ព្រឹត្តិការណ៍ប្លែកៗនោះ។ នៅទីបញ្ចប់ផ្សារភ្ជាប់ព្រឹត្តិការណ៍ប្លែកៗទៅនឹងមេរៀន។ អ្នកអាចរង់ចាំពន្យល់ពីព្រឹត្តិការណ៍ប្លែកៗហើយចាត់ឱ្យសិស្សជាអ្នកអនុវត្តនៅចុងម៉ោងបង្រៀនក្រោយពេលទទួលបានការណែនាំ។



















## 4.5. កម្មវិធីសិក្សា: សូមមើលនៅក្នុងឯកសារពិសោធន៍



នៅក្នុងឯកសារពិសោធន៍ មានការពិសោធន៍ខ្លីៗជាច្រើនដែលមានលទ្ធផលផ្ទុយពីការគិតរបស់សិស្ស ដែលអាចយកទៅប្រើជាព្រឹត្តិការណ៍ប្លែកៗ។ សូមចងចាំថាគំនូរ សំណួរឬរឿងនិទានមួយក៏អាចប្រើជាព្រឹត្តិការណ៍ប្លែកៗបានដែរ។ យ៉ាងណាមិញ ជានិច្ចកាលពិសោធន៍ខ្លីៗសក្តិសមបំផុតសម្រាប់ប្រើជាព្រឹត្តិការណ៍ប្លែកៗ។

**ការឈរនៅលើម្ជូរក្រដាស (ឯកសារពិសោធន៍រូបវិទ្យាអំពីសម្ពាធ)**

ដំបូងទុកឱ្យសិស្សទាយថា តើគេត្រូវការរមូរក្រដាសចំនួនប៉ុន្មានទើបអាចទ្រទម្ងន់មនុស្សម្នាក់បាន។ ជាទូទៅសិស្សតែងតែទាយចំនួនច្រើនហួសការពិតដែលអាចធ្វើទៅបាន។ បន្ទាប់មក គ្រូឈរ (ឬទុកឱ្យសិស្សម្នាក់ឈរ)នៅលើរមូរក្រដាស ខណៈដែលសិស្សម្នាក់ដករមូរក្រដាសចេញមួយម្តងៗ។ ជាទូទៅ គេត្រូវការរមូរក្រដាសតែបីប៉ុណ្ណោះដើម្បីទ្រទម្ងន់មនុស្សម្នាក់។ បន្ទាប់មកលើកទឹកចិត្តឱ្យសិស្សពន្យល់អំពីអ្វីដែលគេបានឃើញ ប៉ុន្តែមិនទាន់ប្រាប់ចម្លើយត្រឹមត្រូវទៅសិស្សនៅឡើយទេ។



គ្រូអាចបន្តមេរៀនអំពីភាពខុសគ្នារវាងសម្ពាធនិងកម្លាំង ដោយប្រើការធ្វើបង្ហាញឬពិសោធន៍ផ្សេងទៀត។ នៅជិតចុងបញ្ចប់នៃមេរៀន រំឭកឡើងវិញនូវព្រឹត្តិការណ៍ប្លែកៗដែលបានធ្វើ ហើយលើកទឹកចិត្តសិស្សឱ្យព្យាយាមពន្យល់អ្វីដែលគេសង្កេតឃើញម្តងទៀត។ លំនាំនេះជួយឱ្យគ្រូអាចដឹងថាសិស្សយល់មេរៀនហើយឬនៅ រីឯចំពោះសិស្សវិញ លំនាំនេះជួយឱ្យសិស្សដឹងដោយខ្លួនឯងថាគេបានរៀនចេះអ្វីមួយហើយ។



## 4.6. ដំបូន្មានសំខាន់ៗ



ព្រឹត្តិការណ៍ប្លែកៗជានិច្ចកាលមានទំនាក់ទំនងទៅនឹងគំនិតភាន់ច្រឡំដែលសិស្សមាន។ គ្រូត្រូវធ្វើឱ្យប្រាកដថា គំនិតភាន់ច្រឡំរបស់សិស្សត្រូវបានកែតម្រូវនៅក្រោយពេលអនុវត្ត សកម្មភាពនេះរួច។





ក្រសួងអប់រំ យុវជន និងកីឡា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ
# តាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល

## ជំពូកទី 4 បំណិនឆ្លុះបញ្ចាំងគំនិតភាន់ច្រឡំ







នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ 2012

# 1. សេចក្ដីផ្ដើម



## *ព័ត៌មានទូទៅអំពីឯកសារនេះ*

ឯកសារនេះបង្ហាញជូននូវការប្រើប្រាស់គំនូរតុក្កតាគំនិតនិងលំហាត់តេស្ដគំនិតសម្រាប់ជាឧបករណ៍របស់គ្រូឧទ្ទេស។ ឧបករណ៍ទាំងពីរប្រភេទនេះទាមទារការគិតរៀងៗខ្លួននិងការពិភាក្សាក្រុម ហើយលើកទឹកចិត្តសិស្សឱ្យបង្ហាញការយល់ឃើញរបស់គេអំពីមេរៀនវិទ្យាសាស្ត្រទៅកាន់សិស្សផ្សេងទៀត។ ឧបករណ៍ទាំងពីរនេះផ្ដោតលើការយល់ដឹងនិងការអនុវត្តចំណេះដឹងវិទ្យាសាស្ត្រក្នុងស្ថានភាពមួយថ្មី។ តាមរយៈសកម្មភាពសិស្សចូលរួមបង្កើតគំនូរតុក្កតាគំនិតនិងលំហាត់តេស្តគំនិតដោយខ្លួនឯង សិស្សកំពុងអនុវត្តការគិតឈានដល់កម្រិតមួយកាន់តែខ្ពស់ហើយធ្វើឱ្យគំនិតច្នៃប្រឌិតរបស់គេរីកចម្រើន។

ឧបករណ៍ទាំងពីរប្រភេទនេះអាចយកទៅប្រើតាមវិធីផ្សេងៗគ្នាអាស្រ័យទៅលើវត្ថុបំណងរបស់មេរៀន ចំណេះដឹងមានស្រាប់របស់សិស្ស និងពេលវេលា។ ឯកសារនេះនឹងបង្ហាញជូននូវឧទាហរណ៍នៃការប្រើប្រាស់រូបគំនូរតុក្កតាគំនិតនិងលំហាត់តេស្ដគំនិតនៅក្នុងមេរៀនផ្សេងៗគ្នា និងដោយប្រើវិធីសាស្ត្រខុសៗគ្នាដើម្បីបញ្ចូលឧបករណ៍ទាំងពីរប្រភេទនេះនៅក្នុងកិច្ចតែងការបង្រៀនរបស់អ្នក។

រូបគំនូរតុក្កតាគំនិតទំហំ A4 ទាំងអស់ដែលត្រូវបានអ៊ុតផ្លាស្ទិចរឹង ជួយឱ្យឯកសារនេះកាន់តែមានលក្ខណៈពេញលេញ។ មិនតែប៉ុណ្ណោះ សំណៅឌីជីថលនៃរូបគំនូរតុក្កតាទាំងនេះក៏ត្រូវបានបញ្ចូលទៅក្នុងគេហទំព័រ krou.money.gov.kh ផងដែរ។

ឯកសារនេះត្រូវបានចងក្រងដោយអនុលោមតាមស្នាដៃរបស់ Naylor និង Keogh និងសាលា Arteveldehogeschool នៃទីក្រុង Ghent ប្រទេសបែលហ្ស៊ិក។ រូបគំនូរតុក្កតាទាំងអស់ត្រូវបានគូរឡើងវិញដើម្បីកែសម្រួលតាមបរិបទប្រទេសកម្ពុជាដោយកិច្ចសហការរវាងអង្គការ VVOB និងក្រុមហ៊ុនបោះពុម្ព Invent Design & Printing។

## *គំនិតភាន់ច្រឡំរបស់សិស្ស*

ចំណុចសំខាន់មួយដែលត្រូវយកចិត្តទុកដាក់នៅពេលប្រើរូបគំនូរតុក្កតាគំនិតនិងលំហាត់តេស្ដគំនិតគឺគំនិតភាន់ច្រឡំរបស់សិស្ស។

សិស្សមានចំណេះដឹងមានស្រាប់របស់ខ្លួនទាក់ទងនឹងមេរៀននីមួយៗ។ ពួកគេទទួលបានចំណេះដឹងទាំងនេះតាមរយៈការមើលទូរទស្សន៍ ពីគ្រួសារ តាមរយៈការអានសៀវភៅ ពីវប្បធម៌ ឬពីមេរៀនមុនៗដែលគេបានសិក្សា។ ជួនកាលចំណេះដឹងមានស្រាប់របស់សិស្សនៅមិនទាន់ពេញលេញ ឬមិនត្រឹមត្រូវ។ ជួនកាលសិស្សមានអារម្មណ៍ថាចំណេះដឹងនេះត្រឹមត្រូវព្រោះ ចំណេះដឹងនេះដូចការគិតរបស់គេ ឬដោយសារគេបានស៊ាំនឹងចំណេះដឹងនេះជាយូរណាស់មកហើយ។

សូមលើកយកច្បាប់ទីមួយញូតុនមកធ្វើជាឧទាហរណ៍។ ពេលកំពុងសង្កេតវត្ថុមួយនៅនឹងថ្កល់នៅលើតុ សិស្សមានទំនោរនឹងសន្មតថាមិនមានកម្លាំងណាមួយមានអំពើទៅលើវត្ថុនេះទេ ជាជាងការទទួលស្គាល់ថាមានកម្លាំងជាច្រើនដែលមានលំនឹងនឹងគ្នា។ ច្បាប់ទីមួយញូតុនផ្ទុយពីការគិតដោយសារវត្ថុមានរបស់កម្លាំងទប់នៃខ្យល់។

គ្រូចាំបាច់ត្រូវយកចិត្តទុកដាក់ត្រួតពិនិត្យចំណេះដឹងមានស្រាប់របស់សិស្ស និងគិតរកយុទ្ធវិធីបង្រៀនដើម្បីស្វែងចេញនិងកែប្រែចំណេះដឹងមានស្រាប់ទាំងនោះ។ គ្រាន់តែប្រាប់សិស្សថាការយល់ឃើញរបស់គេមិនត្រឹមត្រូវ មិនប្រាកដថាអាចកែប្រែការគិតរបស់គេឡើយ ប៉ុន្តែបែរជាបង្កើតនូវភាពខុសគ្នារវាងការយល់ឃើញរបស់គេនៅក្នុងសាលារៀននិងការយល់ឃើញនៅក្រៅសាលារៀន។ ក្នុងថ្នាក់រៀន គេនឹងទទួលយល់ស្របតាមច្បាប់ទីមួយញូតុន ប៉ុន្តែនៅក្រៅថ្នាក់រៀន គេត្រលប់ទៅរកការយល់ឃើញដើមរបស់ខ្លួនវិញ។

ពាក្យគន្លឹះមួយចំនួនត្រូវបានប្រើដើម្បីពណ៌នាចំណេះដឹងមានស្រាប់ដែលមិនត្រឹមត្រូវ ដូចជាគំនិតភាន់ច្រឡំ គំនិតមានស្រាប់ និងចំណេះដឹងខ្វះបទពិសោធន៍។ នៅក្នុងឯកសារនេះ យើងនឹងប្រើពាក្យគំនិតភាន់ច្រឡំព្រោះពាក្យនេះបញ្ជាក់យ៉ាងច្បាស់នូវភាពមិនត្រឹមត្រូវនៃចំណេះដឹងនោះ។




















# 1: រូបគំនូរតុក្កតាគំនិត















## តើអ្វីទៅជាគំនូរតុក្កតាគំនិត?

គំនូរតុក្កតាគំនិតជាគំនូរសាមញ្ញដែលបង្ហាញគោលគំនិតមួយចំនួនអំពីវិទ្យាសាស្ត្រទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។

ឧទាហរណ៍ខាងក្រោមបង្ហាញការពិសោធមួយអំពីស្រមោល។ តួអង្គតុក្កតា 4នាក់ព្យាយាមទស្សន៍ទាយលទ្ធផលពិសោធន៍តាមរយៈការយល់ឃើញរបស់គេរៀងៗខ្លួនទាក់ទងនឹងស្រមោល។ ចម្លើយទស្សន៍ទាយទាំងនេះអាចជាគំនិតភាន់ច្រឡំដែលសិស្សភាគច្រើនមាន។ នៅពេលដែលសិស្សបានឃើញគំនិតរបស់តួអង្គតុក្កតា គេអាចចាប់អារម្មណ៍ថាគំនិតរបស់តួអង្គណាមួយដូចគ្នានឹងការយល់ឃើញរបស់គេ។

គំនូរតុក្កតាគំនិតមានវត្ថុបំណងសំខាន់ដើម្បីបំផុសសិស្សឱ្យគិត ពិភាក្សា សួរសំណួរថ្មីៗ អង្កេត និងវែកញែកហេតុផល។

រូបគំនូរតុក្កតាគំនិតមិនមែនត្រឹមតែជាសំណួរពហុជ្រើសរើសប៉ុណ្ណោះទេ ប៉ុន្តែជាឧបករណ៍សម្រាប់ជំរុញឱ្យសិស្សចូលរួម គិតនិងសិក្សាស្រាវជ្រាវ។ ចម្លើយទាំងអស់តំណាងឱ្យគំនិតភាន់ច្រឡំដែលសិស្សតែងតែមាន ដូចនេះគ្រូត្រូវយកចិត្តទុកដាក់ក្នុងពេលបង្រៀនដោយប្រើសកម្មភាពនេះ។

ចូរកត់ចំណាំថារាល់ចម្លើយទាំងអស់នៅក្នុងគំនូរតុក្កតាមានភាពសំខាន់ស្មើៗគ្នាដូចនេះសិស្សត្រូវព្យាយាមជ្រើសរើសនិងបញ្ជាក់ឱ្យបានច្បាស់ចំៗនូវគំនិតដែលត្រឹមត្រូវបំផុតសម្រាប់ស្ថានភាពនៅក្នុងគំនូរតុក្កតានោះ។ ដំណើរការដែលមានគំនិតច្រើនមិនស្របគ្នាបែបនេះមាននាទីសំខាន់ក្នុងការទទួលបានចំណេះដឹងវិទ្យាសាស្ត្រ។ អាស្រ័យហេតុនេះសកម្មភាពនេះសមស្របសម្រាប់ការបង្រៀនបែបស្ថាបនា (សិស្សមជ្ឈមណ្ឌល)។




















## 2. វត្ថុបំណង



គ្រូអាចសម្រេចវត្ថុបំណងខុសៗគ្នាអាស្រ័យលើរបៀបដែលគ្រូប្រើគំនូរតុក្កតាគំនិតនៅក្នុងថ្នាក់រៀនដូចជា:

- ប្រាប់បានកាន់តែច្បាស់អំពីការយល់ឃើញរបស់សិស្សទាក់ទងនឹងគំនិតភាន់ច្រឡំ
- គិតនិងអភិវឌ្ឍការយល់ដឹង
- ពិភាក្សានិងបកស្រាយការយល់ឃើញផ្សេងៗគ្នា
- សួរសំណួរវិទ្យាសាស្ត្រដែលបង្កើតដោយខ្លួនឯង
- ពិសោធន៍ដើម្បីផ្ទៀងផ្ទាត់ការយល់ឃើញផ្សេងៗគ្នា
- បកស្រាយចំណេះដឹងវិទ្យាសាស្ត្រដែលទើបតែទទួលបាន

## 3. សម្ភារ



គ្រូចាំបាច់ត្រូវបង្ហាញគំនូរតុក្កតាទៅកាន់សិស្សឱ្យបានច្បាស់។ ម៉ាស៊ីនបញ្ចាំងជាជំនួយដ៏ប្រសើរ ប៉ុន្តែក្នុងករណីមិនមានម៉ាស៊ីនបញ្ចាំងទេគ្រូអាចបោះពុម្ពផ្ទាំងរូបភាពតុក្កតាគំនិតឬគូររូបតុក្កតាទាំងនោះនៅលើក្តារខៀនបង្ហាញសិស្សក៏បាន។

គ្រូអាចនឹងត្រូវការសម្ភារបន្ថែមមួយចំនួនអាស្រ័យលើផ្ទាំងរូបភាពតុក្កតានិងរបៀបដែលគ្រូប្រើផ្ទាំងរូបភាពនោះ។ សម្ភារបន្ថែមទាំងនោះអាចជា:

- ក្រដាសទំនេរ ( សម្រាប់សិស្សកត់ត្រា )
- សម្ភារពិសោធន៍ចាំបាច់សម្រាប់ការអង្កេត ( សូមមើលខ្លឹមសារនៃគំនូរតុក្កតានីមួយៗ )

## 4. ដំណើរការ



គ្រូអាចប្រើគំនូរតុក្កតាគំនិតក្នុងការបង្រៀនរបស់គាត់បានដោយប្រើរួមជាមួយសកម្មភាពសិស្សមជ្ឈមណ្ឌលផ្សេងៗគ្នា។

វិធីប្រើគំនូរតុក្កតាគំនិតក្នុងថ្នាក់រៀនទាំង 4 វិធីខាងក្រោមនេះត្រូវបានពណ៌នាយ៉ាងលម្អិតដោយប្រើឧទាហរណ៍ចំនួន4ក្នុងមេរៀនអំពី “ស្រមោល”។ វិធីនីមួយៗប្រើប្រាស់គំនូរតុក្កតាគំនិតតាមបែបសិស្សមជ្ឈមណ្ឌល។

សូមសាកល្បងប្រើគំនូរតុក្កតាគំនិតផ្សេងៗទៀតដោយអនុវត្តតាមឧទាហរណ៍នៃគំនូរតុក្កតាគំនិតអំពីស្រមោលដូចខាងក្រោម:



# 4.1. សកម្មភាពទី1: វិធីគិតជាបុគ្គល

## សេចក្ដីផ្ដើម



គ្រូអាចប្រើគំនូរតុក្កតានិងលំហាត់តេស្តគំនិតជាមួយសិស្សតាមរយៈវិធីគិតជាបុគ្គល។ វិធីនេះចំណាយពេលតិចប៉ុន្តែមិនមានសកម្មភាពពិភាក្សាជាក្រុមដែលមានអត្ថប្រយោជន៍ជួយជំរុញការចូលរួមរបស់សិស្សដែលមិនសូវចូលរួមក្នុងពេលពិភាក្សារួមនោះទេ។




## វត្ថុបំណង



- បំផុសការពិភាក្សារបស់សិស្សអំពីគំនិតវិទ្យាសាស្ត្រ
- ជំរុញការប្រើប្រាស់ចំណេះដឹងមានស្រាប់របស់សិស្ស
- ដើម្បីរកឱ្យឃើញនិងកែតម្រូវគំនិតភាន់ច្រឡំរបស់សិស្ស

## សម្ភារ



- គំនូរតុក្កតាគំនិត (បោះពុម្ពលើក្រដាសទំហំA4 ឬបញ្ចាំងនៅលើអេក្រង់)
- ម៉ាស៊ីនបញ្ចាំងឬពិលប្រើជាប្រភពពន្លឺសម្រាប់ការរិះរកនិងផ្ទៀងផ្ទាត់។

## ដំណើរការ



1. គ្រូបង្ហាញគំនូរតុក្កតាគំនិតដល់សិស្សនិងពន្យល់អំពីស្ថានភាព។
2. ទុកពេលវេលាខ្លីមួយឱ្យសិស្សម្នាក់ៗឆ្លុះបញ្ចាំងការយល់ឃើញរៀងៗខ្លួនដែលសិស្សម្នាក់ៗអានគោលគំនិតទាំងអស់ក្នុងគំនូរតុក្កតាគំនិតនិងព្យាយាមឆ្លើយសំណួរខាងក្រោម:
   ក. តើអ្នកយល់ស្របនឹងគំនិតឬផ្នែកណាមួយ ?
   ខ. តើអាចមានគំនិតត្រឹមត្រូវលើសពីមួយឬទេ ?
   *ហេតុអ្វីបានជាសំណួរនេះសំខាន់ ? សិស្សចាំបាច់ត្រូវគិតពីមូលហេតុដែលនាំឱ្យចម្លើយណាមួយត្រូវឬខុស។ ជួនកាល គោលគំនិតមួយអាចត្រឹមត្រូវដោយផ្នែកប៉ុណ្ណោះ។ ពេលវេលាឆ្លុះបញ្ចាំងនេះអាចមានពិសោធន៍វិទ្យាសាស្ត្រតូចៗអមជាមួយផង។*
   គ. សិស្សព្យាយាមគិតរកនិយមន័យនៃពាក្យស្រមោល។
3. គ្រូអាចត្រួតពិនិត្យការគិតរបស់សិស្សភ្លាមៗ (ដូចជាតាមរយៈការលើកដៃឬប្រើបណ្ណសម្រាប់បោះឆ្នោត)។
4. សួរសិស្សក្នុងថ្នាក់រៀនអំពីចម្លើយរបស់គេ។ ចម្លើយទាំងអស់ត្រូវបានពិភាក្សា។ប្រើសំណួរខាងក្រោមដើម្បីជួយសិស្សក្នុងការអះអាងហេតុផលបានត្រឹមត្រូវ:
   ក. តើនិងមានអ្វីកើតឡើងបើយើងបង្វិតដៃរបស់យើងទៅជិតប្រភពពន្លឺមួយ ?
   ខ. តើនឹងនៅមានស្រមោលទៀតទេប្រសិនបើអ្នកគ្របប្រភពពន្លឺជិត ?
   គ. តើអ្នកអាចគិតឃើញស្ថានភាពមួយដែលទំហំស្រមោលមិនប្រែប្រួលដែរឬទេ ?
   ឃ.តើអ្នកអាចពន្យល់ពីមូលហេតុបានដែរឬទេ ?
   ង. តើទំហំនៃស្រមោលដែលបង្កើតដោយពន្លឺព្រះអាទិត្យអាចប្រែប្រួលយ៉ាងដូចម្ដេច ?


















## ការបកស្រាយ



1. ស្រមោលរបស់ខ្ញុំធំបំផុតពេលដែលខ្ញុំស្ថិតនៅជិតអេក្រង់
2. ស្រមោលរបស់អ្នកធំបំផុតពេលដែលអ្នកស្ថិតនៅជិតចង្កៀង

ចម្លើយទាំងពីរនេះចាំបាច់ត្រូវយកមកពិភាក្សារួមគ្នាព្រោះជាគោលគំនិតពីរដែលយល់ឃើញផ្ទុយគ្នា។សិស្សមិនអាចនឹងមានគំនិតទាំងពីរនេះក្នុងពេលតែមួយនោះទេ។

ផ្តល់ឱកាសឱ្យសិស្សរៀបចំផែនការដើម្បីត្រួតពិនិត្យថាតើចម្លើយណាមួយដែលត្រឹមត្រូវ។ គេអាចរកឃើញចម្លើយត្រឹមត្រូវតាមរយៈការពិសោធន៍និងទ្រឹស្តីនិងការបញ្ជាក់ហេតុផល។ ពិសោធន៍ដ៏ខ្លីមួយដោយប្រើម៉ាស៊ីនបញ្ចាំងនិងប្រអប់ដែបង្ហាញភ្លាមៗថាស្រមោលរីកធំប្រសិនបើវត្ថុខិតទៅជិតប្រភពពន្លឺ។ សិស្សក៏អាចពន្យល់ថាពន្លឺដាលជាបន្ទាត់ត្រង់ហើយប្រភពពន្លឺមួយញែកបាច់ពន្លឺទៅគ្រប់ទិសទី។



ឯកសារយោង: Wikipedia

វត្ថុស្ថិតនៅកាន់តែជិតប្រភពពន្លឺ ស្រមោលកាន់តែធំ

3. ទំហំស្រមោលមិនប្រែប្រួលទេទោះជាអ្នកឈរនៅត្រង់ណាក៏ដោយ

ដោយប្រើប្រភពពន្លឺមួយអ្នកអាចបង្ហាញថាការយល់ឃើញនេះមិនត្រឹមត្រូវទេ។ ប្រសិនបើអ្នកចល័តប្រអប់ដែរបស់អ្នកទំហំស្រមោលប្តូរជានិច្ច។ សិស្សអាចកត់សម្គាល់បានត្រឹមត្រូវថាទំហំនៃស្រមោលមួយមិនប្រែប្រួលទេប្រសិនបើអ្នកចល័តនៅក្រោមពន្លឺព្រះអាទិត្យ។ ព្រះអាទិត្យជាប្រភពពន្លឺមួយដែលស្ថិតនៅឆ្ងាយសែនឆ្ងាយ។ បាច់ពន្លឺដែលដាលពីប្រភពពន្លឺដ៏ឆ្ងាយដាលស្របគ្នា។ ដោយប្រើរូបដូចករណីមុនដែរប៉ុន្តែលើកនេះប្រើបាច់ពន្លឺស្របគ្នាវិញម្តងអ្នកអាចបង្ហាញថាទំហំស្រមោលមិនប្រែប្រួលទេ។



ឯកសារយោង: Wikipedia

ស្រមោលមិនប្រែប្រួលដោយសារប្រភពពន្លឺដែលនៅឆ្ងាយសែនឆ្ងាយ

4. ស្រមោលរបស់អ្នកនិងបាត់ពេលដែលអ្នកស្ថិតនៅជិតចង្កៀង

ពេលដែលអ្នកគ្របប្រភពពន្លឺជិតស្រមោលរីកសាយពាសពេញជញ្ជាំងឬថ្នាក់រៀនទាំងមូល។ ស្រមោលមិនបានបាត់ទេប៉ុន្តែគ្រប់ទីកន្លែងគ្របដណ្តប់ដោយស្រមោលទាំងអស់។ សិស្សខ្លះអាចគិតថាស្រមោលលែងមានទៀតហើយព្រោះមិនឃើញមានព្រំដែនរវាងពន្លឺនិងស្រមោល។ ដោយប្រើគោលគំនិតទី4នេះគ្រូអាចចាប់ផ្តើមការពិភាក្សាស៊ីជម្រៅអំពីនិយមន័យនៃពាក្យស្រមោលបាន។

គ្រូអាចផ្តើមការពិភាក្សារបស់សិស្សដោយសួរសំណួរដូចតទៅ:

“តើមានភាពខុសគ្នាយ៉ាងដូចម្តេចរវាងការគ្របប្រភពពន្លឺជិតនិងការពន្លត់ចង្កៀង ?”

តាមការពិតស្ថានភាពទាំងពីរនេះមានផលដូចគ្នា។ ក្នុងស្ថានភាពទីមួយយើងនិយាយអំពីស្រមោលប៉ុន្តែក្នុងស្ថានភាពទីពីរយើងមិននិយាយពីស្រមោលទេ។ ចំណុចនេះចាប់ផ្តើមការពិភាក្សាអំពីធម្មជាតិនៃស្រមោល:

- តើនៅពេលណាដែលយើងហៅភាពងងឹតថាជាស្រមោល ?
- ហេតុអ្វីបានជាយើងមិនចាត់ទុករាល់ភាពងងឹតទាំងអស់ថាជាស្រមោល ?





## សន្និដ្ឋាន



តុក្កតាគំនិតបង្ហាញថាយើងត្រូវការការពិពណ៌នាឬនិយមន័យដ៏ល្អមួយនៃពាក្យស្រមោល។ លើសពីនេះទៅទៀត សិស្សត្រូវបានលើកទឹកចិត្តឱ្យគិតអំពីគំនិតវិទ្យាសាស្ត្រ និងរបៀបផ្ទៀងផ្ទាត់សម្មតិកម្មរបស់គេ។

សេចក្តីសន្និដ្ឋានទីមួយគឺដើម្បីឱ្យមានស្រមោលបានអ្នកត្រូវការប្រភពពន្លឺមួយនិងវត្ថុមួយ។ សេចក្តីសន្និដ្ឋានទីពីរគឺស្រមោលជាទីកន្លែងដែលមិនមានពន្លឺពីប្រភពពន្លឺ។ ចំណុចសកម្មភាពបង្ហាញថារាល់គោលគំនិតរបស់តួអង្គក្នុងផ្ទាំងគំនូរតុក្កតាគំនិតចាំបាច់ត្រូវយកមកពិភាក្សាទាំងអស់រួមទាំងគោលគំនិតដែលមិនត្រឹមត្រូវផង។ គ្រូចាំបាច់ត្រូវលើកទឹកចិត្តឱ្យសិស្សគិតអំពីគោលគំនិតទាំងអស់នោះ វែកញែករកហេតុផលដែលគំនិតទាំងនោះត្រឹមត្រូវឬមិនត្រឹមត្រូវ ព្យាយាមរៀបចំការពិសោធន៍ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃគោលគំនិតនីមួយៗនិងបង្កើតជានិយមន័យនៃគោលគំនិតរួមដោយខ្លួនឯង។













# 4.2. សកម្មភាពទី2: វិធីពិភាក្សាក្រុម

## សេចក្ដីផ្ដើម



អ្នកអាចទទួលបានប្រសិទ្ធិភាពខ្ពស់បំផុតនៃការប្រើរូបគំនូរតុក្កតាគំនិតនិងលំហាត់តេស្ដគំនិត តាមរយៈការផ្ដល់ឱកាសឱ្យសិស្សពិភាក្សាជាក្រុម។ សកម្មភាពនេះអនុញ្ញាតឱ្យសិស្សពិភាក្សាការយល់ឃើញរបស់គេជាមួយសមាជិកក្រុម។ ពួកគេអាចរៀនសូត្របកស្រាយហេតុផលនិងស្ដាប់ការយល់ឃើញរបស់អ្នកដទៃ។ ការរៀនសូត្រតាមបែបសហការប្រភេទនេះ គឺជាបទពិសោធន៍មួយដ៏មានអត្ថប្រយោជន៍។ យើងនិងពិភាក្សាអំពីសកម្មភាពនេះ ដោយប្រើឧទាហរណ៍ក្នុងមេរៀនអំពីស្រមោលដូចគ្នា។




## វត្ថុបំណង



- រកគំនិតភាន់ច្រឡំរបស់សិស្ស។ គំនិតភាន់ច្រឡំមួយចំនួនក្នុងមេរៀនអំពីស្រមោលដែលសិស្សតែងមានគឺ:
  - ស្រមោលជាវត្ថុពិត។
  - ពេលដែលមិនមានពន្លឺក៏មិនអាចមានស្រមោលដែរ។
- បកស្រាយពីហេតុផលនៃគំរូចំណេះដឹងផ្សេងៗគ្នានិងការពិតដែលគំរូមួយចំនួនអាចត្រឹមត្រូវអាស្រ័យលើកាលៈទេសៈ
- បកស្រាយចំណេះដឹងកាន់តែស៊ីជំរៅ
- ទំលាប់ស្ដាប់ហេតុផលរបស់អ្នកដទៃ

## សម្ភារ



- គំនូរតុក្កតាគំនិត (បោះពុម្ពលើក្រដាស A3 ឬA4 ឬបញ្ចាំងនៅលើអេក្រង់)
- សម្ភារបន្ទាប់បន្សំមួយចំនួនរួមមាន:
  - ប្រភពពន្លឺដូចជាពិលឬអំពូលពងមាន់ចំនួនពី 2 ទៅ 6
  - ម៉ាស៊ីនបញ្ចាំងមួយជាប្រភពពន្លឺដ៏សមស្របសម្រាប់ការគិតជាបុគ្គល



## ដំណើរការ



1. ចែកសិស្សជាក្រុមតូចៗហើយចែកផ្ទាំងគំនូរតុក្កតាគំនិតដល់ក្រុមនីមួយៗ។
2. ទុកពេលខ្លីឱ្យសិស្សគិតរៀងៗខ្លួនថាគោលគំនិតមួយណាដែលត្រូវនឹងការយល់ឃើញរបស់គេ។
3. លើកទឹកចិត្តឱ្យពួកគេពិភាក្សាគ្នាដើម្បីស្វែងរកគំនិតយល់ឃើញរួម។ ប្រសិនបើការពិភាក្សារបស់ពួកគេអាចឈានដល់ការយល់ស្របគ្នាយ៉ាងឆាប់រហ័ស សិស្សត្រូវរកហេតុផលដែលនាំឱ្យសិស្សផ្សេងទៀតមានការយល់ឃើញផ្សេងពីក្រុមខ្លួន។ បើមិនដូច្នោះទេគ្រូអាចបន្ថែមសំណួរពិភាក្សាមួយចំនួនទៀតឱ្យក្រុមនេះដូចជាប្រាប់ឱ្យសិស្សញែកសម្គាល់ភាពខុសគ្នារវាងយប់ងងឹតដែលមានពពកច្រើននិងយប់ដែលផ្ទៃមេឃស្រឡះហើយព្រះចន្ទពេញបូណ៌មី (ប្រហែល10នាទី)។
4. សួរសិស្សឱ្យឆ្លើយនូវការយល់ឃើញខ្លីៗដើម្បីស្វែងយល់ពីការយល់ឃើញរបស់សិស្សទាំងអស់ក្នុងថ្នាក់។ គ្រូអាចឱ្យសិស្សបោះឆ្នោត(ដោយការលើកដៃឬដោយការលើកបណ្ណ)។
5. ផ្តល់ឱកាសឱ្យក្រុមដែលមានការយល់ឃើញផ្សេងៗពីគ្នាប្រាប់ពីហេតុផលរបស់គេរៀងខ្លួននឹងចូលរួមពិភាក្សាទាំងអស់គ្នាដើម្បីរកយោបល់មួយចំនួនដែលសមហេតុផលជាងគេនិងព័ត៌មានបន្ថែមដែលត្រូវការដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃការយល់ឃើញទាំងនោះ។
6. គ្រូប្រមូលគំនិតផ្សេងៗទាំងឡាយបញ្ចូលគ្នានិងផ្តល់ជាសេចក្តីសង្ខេបដ៏ច្បាស់លាស់មួយអំពីចំណោទខាងដើម។ សួរសិស្សក្រែងគេចង់ផ្លាស់ប្តូរការយល់ឃើញពីដំបូងរបស់ខ្លួន។

## ការបកស្រាយការយល់ឃើញនីមួយៗ



1. ពេលយប់មានស្រមោលប៉ុន្តែអ្នកមិនអាចមើលវាឃើញទេ។
   សិស្សតែងមានការយល់ឃើញបែបនេះព្រោះពួកគេគិតថាស្រមោលគឺជាវត្ថុមានរូបរាងពិតប្រាកដ។ យើងអាចមើលឃើញស្រមោលពេលដែលមានពន្លឺបន្ថែមដូចវត្ថុផ្សេងៗទៀតដែរ។
2. ពេលយប់មិនមានស្រមោលទេ។
   ស្រមោលមានទំនាក់ទំនងជាមួយអវត្តមាននៃពន្លឺនៅទីតាំងជាក់លាក់មួយ។ ប្រសិនបើមិនមានពន្លឺទេក៏មិនមានស្រមោលដែរ។
3. នៅពេលយប់អ្វីៗគ្រប់យ៉ាងសុទ្ធតែជាស្រមោល។
   រូបភាពចន្ទគ្រាសបង្ហាញនូវការយល់ឃើញមួយផ្សេងទៀតអំពីពេលយប់។ មួយផ្នែកនៃផែនដីមិនទទួលបានពន្លឺនៅពេលយប់ព្រោះផ្នែកនេះស្ថិតនៅក្នុងតំបន់ស្រមោលនៃប្រព័ន្ធផែនដីនិងព្រះអាទិត្យ។ ពេលដែលអ្នកគិតអំពីពេលយប់ដោយហេតុផលខាងលើនេះ ពេលយប់អាចចាត់ទុកជាស្រមោលដ៏ធំមួយ។ មនុស្សភាគច្រើនមិនយល់ឃើញបែបនេះទេព្រោះគេគិតថាស្រមោលជាអង្គវត្ថុមួយដាច់ដោយឡែក។




ឯកសារយោង: Wikipedia


















4. ស្រមោលកាន់តែងងឹតនៅពេលយប់។

ប្រសិនបើមានប្រភពពន្លឺនៅពេលយប់ (ឧទាហរណ៍ពន្លឺព្រះចន្ទ) នោះនាំឱ្យមានស្រមោល។ បើយើងសង្កេតឱ្យកាន់តែជិតឃើញថាស្រមោលទាំងនោះងងឹតជាងស្រមោលនៅពេលថ្ងៃ។ ពេលថ្ងៃមានពន្លឺមិនផ្ទាល់ច្រើនជាង (ពន្លឺដែលត្រូវបានបំផ្លាតលើវត្ថុផ្សេងៗនិងពន្លឺដែលបាចសាចក្នុងស្រទាប់បរិយាកាសជុំវិញផែនដី) ចូលទៅដល់តំបន់ ស្រមោល។

## សន្និដ្ឋាន



1. គំនិតដែលហាក់ដូចជាមិនសមហេតុផលពីដំបូងអាចនឹងប្រែជាសមហេតុផល និងអាចយកជាការបានទៅវិញនៅពេលក្រោយ។
2. សេចក្តីសន្និដ្ឋានដែលយើងបានធ្វើបន្ទាប់ពីរូបតុក្កតាមុននៅតែត្រឹមត្រូវទោះជាយើងពិចារណាអំពីប្រព័ន្ធផែនដីនិងព្រះអាទិត្យក៏ដោយ។
3. ភាពងងឹតនៃស្រមោលមួយរងឥទ្ធិពលនៃប្រភពពន្លឺទីពីរ។





# 4.3. សកម្មភាពទី3: វិធីអង្កេតពិសោធន៍



## សេចក្ដីផ្ដើម

វិធីពីរខាងដើមបានបង្ហាញពីតម្លៃនៃការពិភាក្សាអំពីវិទ្យាសាស្ត្រ។ ការជំរុញលើកទឹកចិត្តសិស្សឱ្យពិភាក្សាអំពីការយល់ឃើញរបស់គេ បង្កើតនូវមជ្ឈដ្ឋានសិក្សាមួយដ៏មានអត្ថប្រយោជន៍។ ចំពោះគុក្កតាមួយចំនួនគេអាចបញ្ចូលការពិភាក្សាជាមួយការពិសោធន៍។ ការពិភាក្សាអំពីវិទ្យាសាស្ត្រនាំឱ្យមានការបង្កើតសម្មតិកម្មស្រាវជ្រាវមួយដែលក្រោយមកត្រូវផ្ទៀងផ្ទាត់ដោយការពិសោធន៍។ ក្រោយការពិភាក្សា សិស្សអាចធ្វើពិសោធន៍ជាក្រុមឬគ្រូធ្វើពិសោធន៍មួយបង្ហាញសិស្ស។




## វត្ថុបំណង



- ប្រាប់បានពីគំនិតភាន់ច្រឡំរបស់សិស្សចំពោះរូបគំនូរតុក្កតាគំនិតអំពីស្រមោលសិស្សអាចគិតថាស្រមោលនឹងកាន់តែងងឹតនៅពេលដែលមានស្រមោល 2 ត្រួតលើគ្នា។
- អនុវត្តការពិសោធន៍ដើម្បីប្រាប់តាមស្ថានភាពនៅក្នុងគំនូរតុក្កតា
- ផ្ទៀងផ្ទាត់គោលគំនិតទាំងឡាយក្នុងតុក្កតាតាមរយៈការអង្កេតពិសោធន៍ និងទាញសេចក្ដីសន្និដ្ឋានត្រឹមត្រូវមួយ
- ទំលាប់យកចំណេះដឹងរបស់ខ្លួនអំពីស្រមោលមកអនុវត្តក្នុងស្ថានភាពដែលមានស្រមោល2ត្រួតស៊ីគ្នា:
  - សម្រាប់វត្ថុស្រអាប់: ផ្នែកដែលត្រួតស៊ីគ្នាងងឹតដូចគ្នានឹងផ្នែកផ្សេងទៀតនៃស្រមោលដែរ។
  - សម្រាប់វត្ថុថ្លា:ផ្នែកដែលត្រួតស៊ីគ្នាងងឹតជាងបន្តិច។

## សម្ភារ



- គំនូរតុក្កតាគំនិត
- សម្ភារពិសោធន៍សម្រាប់ឧទាហរណ៍អំពីស្រមោលរួមមាន:
  - ប្រភពពន្លឺដូចជាពិលឬអំពូលពងមាន់ចំនួន ពី 2 ទៅ 6
  - សម្ភារដែលស្រអាប់
  - ក្រដាសស្តើងដែលអាចមើលឃើញវត្ថុខាងក្រោយបានឬមុង
  - ម៉ាស៊ីនបញ្ចាំង LCD ជាការប្រសើរគប្បីមានសម្ភារគ្រប់គ្រាន់សម្រាប់ក្រុមនីមួយៗធ្វើពិសោធន៍




















## ដំណើរការ



1. គ្រូបង្ហាញចំណងជើងមេរៀន។
2. ទុកពេលខ្លីឱ្យសិស្សគិតរៀងៗខ្លួនអំពីគោលគំនិតនៅក្នុងគំនូរតុក្កតា។ បន្ទាប់មកសួរសិស្សរកប្រយោគដែលគេយល់ស្របតាម។ ( ឧទាហរណ៍: បោះឆ្នោតដោយលើកដៃឬដោយលើកបណ្ណ )។
3. ចាត់សិស្សឱ្យធ្វើការអង្កេតជាក្រុមអំពីស្រមោលដែលត្រួតស៊ីគ្នា។ សិស្សគប្បីគ្រាប់តាមស្ថានភាពទាំងពីរគឺវត្ថុថ្លានិងវត្ថុស្រអាប់។
4. ក្រុមនីមួយៗបង្ហាញលទ្ធផលដល់សិស្សផ្សេងៗទៀត។
5. សិស្សទាំងអស់ចូលរួមពិភាក្សាទាំងអស់គ្នាអំពីស្រមោល។ ដោយសារស្ថានភាពសាំញ៉ាំ និយមន័យនៃពាក្យស្រមោលខាងដើមអាចនឹងត្រូវពិចារណាឡើងវិញ និងបន្ថែមន័យឱ្យកាន់តែទូលាយថែមទៀត។

## ការបកស្រាយ



នៅក្នុងរូបតុក្កតាគំនិតមួយនេះគេចាំបាច់ត្រូវញែកសម្គាល់ភាពខុសគ្នារវាងស្ថានភាពទាំងពីរ។

*1. ស្រមោលងងឹតជាងមុនទ្វេដងត្រង់តំបន់ដែលស្រមោលត្រួតស៊ីគ្នា*

ពេលដែលសិស្សជ្រើសរើសគោលគំនិតនេះពួកគេចាត់ទុកថាស្រមោលជាវត្ថុពិតមួយ។ ពេលដែលមានស្រមោល2ត្រួតគ្នាគេគិតថាទទួលបានស្រមោលថ្មីមួយដែលងងឹតជាងមុនទ្វេដង។ពួកគេភ្លេចអត្ថន័យនៃស្រមោលមួយដែលគ្រាន់តែមានន័យថា ( ស្ទើរតែ ) មិនមានពន្លឺនៅក្នុងលំហនោះប៉ុណ្ណោះ។ យើងប្រើពាក្យថា “ស្ទើរតែ” មិនមានពន្លឺព្រោះជានិច្ចកាលមានពន្លឺមិនផ្ទាល់ដែលយើងចាំបាច់ត្រូវយកមកពិចារណា។

*2. តំបន់ដែលស្រមោលត្រួតស៊ីគ្នាងងឹតដូចផ្នែកផ្សេងទៀតនៃស្រមោលដែរ*

ប្រសិនបើនិយមន័យរបស់ស្រមោលគឺជាអវត្តមាននៃពន្លឺពីប្រភពពន្លឺមួយ ជាក់ស្តែងណាស់ថាអ្នកអាចយកពន្លឺចេញពីប្រភពពន្លឺនោះបានតែម្តងគត់។ ប្រសិនបើពន្លឺត្រូវបានយកចេញពីប្រភពពន្លឺហើយអ្នកមិនអាចយកពន្លឺអ្វីផ្សេងទៀតចេញពីប្រភពពន្លឺនេះទេ។ ដូចនេះតំបន់ដែលមានស្រមោលពីរត្រួតស៊ីគ្នាងងឹតស្មើគ្នានឹងស្រមោលផ្សេងៗទៀតដែរ។ ពិសោធន៍នេះអាចបញ្ជាក់ស្ថានភាពនេះច្បាស់បានដរាបណាស្រមោលដែលត្រួតគ្នានោះជាស្រមោលនៃវត្ថុពីរដែលស្រអាប់។

*3. ស្រមោលត្រង់តំបន់ត្រួតស៊ីគ្នាងងឹតជាងតែមិនដល់ទ្វេដងនោះទេ*

សិស្សដែលជ្រើសរើសយកចម្លើយនេះគិតក្នុងស្ថានភាពមួយកាន់តែសាំញ៉ាំជាងមុនទៅទៀត។ ស្ថានភាពដែលគូរនៅក្នុងរូបតុក្កតានេះមានរូបដើមឈើ។ ដើមឈើមានផ្នែកខ្លះដែលពន្លឺឆ្លងកាត់បានអាស្រ័យលើដង់ស៊ីតេនិងទីតាំងនៃស្លឹកឈើ។ ត្រង់តំបន់ដែលស្រមោលដើមឈើពីរដើមត្រួតស៊ីគ្នាស្រមោលនោះនឹងងងឹតជាងស្រមោលធម្មតាបន្តិច។ ស្លឹកនៃដើមឈើទីមួយទប់តែពន្លឺមួយផ្នែកប៉ុណ្ណោះ។ ពន្លឺមួយចំនួនអាចឆ្លងកាត់វាបានប៉ុន្តែត្រូវបានស្លឹកនៃដើមឈើទីពីរទប់ជាប់។ ដោយស្រមោលដែលត្រួតស៊ីគ្នានោះកើតឡើងពីចំនួនស្លឹកនៃដើមឈើពីរនាំឱ្យស្រមោលនេះងងឹតជាងស្រមោលធម្មតាបន្តិច។ ប្រសិនបើពិសោធន៍ក្នុងចម្លើយទី2ត្រូវបានធ្វើឡើងវិញប៉ុន្តែប្រើវត្ថុថ្លាដូចជាក្រដាសស្តើងឬក្រណាត់មុងមួយចម្រៀកជំនួសវិញនោះយើងនឹងមើលឃើញស្ថានភាពនេះច្បាស់។

## សន្និដ្ឋាន



និយមន័យមុននៃពាក្យស្រមោលត្រូវតែកែតម្រូវ។ ស្រមោលកើតមានឡើងពេលដែលពន្លឺពីប្រភពពន្លឺមួយត្រូវបានស្ទាក់ទាំងស្រុងឬដោយផ្នែកដោយវត្ថុមួយ។ ក្នុងរូបតុក្កតានេះពាក្យពន្លឺនិងស្រមោលត្រូវបានយកមកប្រើរួមគ្នាជាលើកដំបូង។ នៅក្នុងពិសោធន៍មុនគ្រូអាចសួរសិស្សនូវសំណួរត្រិះរិះដូចជា: “តើយើងហៅតំបន់ដែលនៅពីក្រោយវត្ថុថ្លាមួយថាជាអ្វី ? តើជាពន្លឺឬជាស្រមោល ?”

# 4.4.សកម្មភាពទី4: វិធីពិភាក្សាក្រុមរួមជាមួយអង្កេតពិសោធន៍

## សេចក្ដីផ្ដើម



សកម្មភាពនេះផ្ដល់ឱកាសកាន់តែច្រើនឱ្យសិស្សសិក្សាដោយឯករាជ្យ។ ពួកគេពិភាក្សាអំពីរូបគំនូរតុក្កតា រៀបចំផែនការអង្កេតពិសោធន៍ ធ្វើពិសោធន៍នោះហើយរាយការណ៍លទ្ធផល និងសេចក្ដីសន្និដ្ឋាន។ សកម្មភាពនេះផ្ដល់ឱ្យសិស្សនូវបទពិសោធន៍សិក្សាជាក់ស្ដែង និងជំរុញឱ្យសិស្សសិក្សាដោយសហការគ្នា។




## វត្ថុបំណង



- ប្រាប់បានពីគំនិតភាន់ច្រឡំរបស់សិស្ស។ ទាក់ទងនឹងមេរៀនអំពីស្រមោលសិស្សអាច:
  - គិតថាស្រមោលតែងតែមានពណ៌ខ្មៅជានិច្ច។
  - យល់ច្រឡំរវាងស្រមោលនិងពន្លឺ។
- បកស្រាយបានពីតម្លៃនៃការយល់ឃើញផ្សេងៗគ្នា
- អង្កេតពិសោធន៍ដើម្បីឆ្លើយសំណួរវិទ្យាសាស្ត្រនិងទទួលបាននូវសេចក្ដីសន្និដ្ឋានមួយដ៏មានប្រយោជន៍
- បង្កើតនិយមន័យនៃពាក្យស្រមោលដោយខ្លួនឯង
- បណ្ដុះស្មារតីយល់ឃើញថាស្រមោលនិងពន្លឺមានភាពខុសប្លែកគ្នាតែបន្តិចប៉ុណ្ណោះ

## សម្ភារ



- គំនូរតុក្កតាគំនិត
- សម្ភារបន្ទាប់បន្សំមួយចំនួន (សម្រាប់រូបគំនូរតុក្កតានេះ):
  - ប្រភពពន្លឺដូចជាពិលឬអំពូលពងមាន់ពី2ទៅ6
  - ម៉ាស៊ីនបញ្ចាំងជាប្រភពពន្លឺមួយសមស្រប។
  - សិស្សអាចប្រើសម្ភារសាមញ្ញមួយចំនួនដូចជាផ្លាស្ទិចក្រដាសពណ៌។ល។

















## ដំណើរការ



1. បង្ហាញចំណាងជើងមេរៀនព្រមទាំងផ្ទាំងរូបភាពតុក្កតាគំនិត។ ផ្តល់ពេលវេលាខ្លីមួយឱ្យសិស្សគិតរៀងៗខ្លួនពេលដែលសិស្សទាំងអស់កំពុងអានគោលគំនិតនីមួយៗក្នុងផ្ទាំងរូបភាព។សួរសិស្សរកគោលគំនិតណាមួយដែលគេយល់ស្របតាម (ឧទាហរណ៍: បោះឆ្នោតដោយលើកដៃឬដោយលើកបណ្ណ)។
2. លើកទឹកចិត្តការពិភាក្សាជាក្រុមតូចៗ(ដែលមានគ្នាពី 2 ទៅ 5 នាក់) និងជំរុញឱ្យឈានដល់ទទួលបានការយល់ឃើញរួម។ ប្រសិនបើរហ័សឈានដល់ការយល់ឃើញរួមគ្នាប្រាប់ក្រុមនេះថាគោលគំនិតផ្សេងទៀតក៏អាចត្រឹមត្រូវក្នុងស្ថានភាពផ្សេងដែរ។ សិស្សព្យាយាមគិតរកស្ថានភាពដែលគោលគំនិតនីមួយៗអាចនឹងត្រឹមត្រូវ។ សួរសិស្សឱ្យឆ្លើយចម្លើយខ្លីៗអំពីការយល់ឃើញរួមរបស់ក្រុមខ្លួន។ គ្រូអាចឱ្យសិស្សបោះឆ្នោតគាំទ្រការយល់ឃើញមួយចំនួន។
3. សិស្សទាំងអស់ក្នុងថ្នាក់ពិភាក្សារួមគ្នាអំពីរបៀបរកឱ្យឃើញថាការយល់ឃើញមួយណាដែលត្រឹមត្រូវហើយត្រឹមត្រូវក្នុងល័ក្ខខ័ណ្ឌអ្វីខ្លះ។ បើចាំបាច់គ្រូអាចប្រើសំណួរខាងក្រោមដើម្បីបំផុសការពិភាក្សា:
   - តើស្រមោលមាននិយមន័យថាយ៉ាងដូចម្តេច? តើនិយមន័យនេះអាចយកទៅអនុវត្តបានចំពោះស្រមោលក្នុងជីវភាពប្រចាំថ្ងៃដែរឬទេ? តើយើងអាចធ្វើឱ្យនិយមន័យនេះកាន់តែមានភាពទូទៅបានដែរឬទេ?
   - តើស្រមោលរបស់មនុស្សម្នាក់មកលើផ្ទៃខាងក្រោយដែលមានពណ៌ (ដូចជាស្មៅ) មានពណ៌ខ្មៅឬ?
   - ពេលដែលមានតែពន្លឺពណ៌ក្រហមនៅក្នុងបន្ទប់មួយតើស្រមោលមានពណ៌ក្រហមដែរឬទេ?
   - តើអ្នកយល់ទេថាហេតុអ្វីបានជាស្រមោលដែលចោលទៅលើព្រិលសមើលទៅមានពណ៌ខៀវ?
4. ការរិះរកជាក្រុមតូចៗ:សិស្សសហការគ្នាជាក្រុមតូចៗដើម្បីរៀបចំពិសោធន៍នឹងផ្ទៀងផ្ទាត់គោលគំនិតនីមួយៗ។សិស្សកត់ត្រាការពិសោធន៍សង្កេតនិងសន្និដ្ឋាន។ក្រោយមកសិស្សបង្ហាញលទ្ធផលដល់សិស្សផ្សេងទៀតក្នុងថ្នាក់ដែលបញ្ជាក់ថាគោលគំនិតណាមួយដែលសមហេតុផលនិងព័ត៌មានបន្ថែមអ្វីផ្សេងទៀតដែលយើងអាចនឹងត្រូវការដើម្បីបញ្ជាក់គោលគំនិតនោះឱ្យកាន់តែច្បាស់។
5. គ្រូប្រមូលគំនិតទាំងអស់បញ្ចូលគ្នាហើយផ្តល់នូវសេចក្តីសំយោគចំពោះចំណោទឬបញ្ហាខាងដើម ការរិះរក លទ្ធផល និងចំណេះដឹងដែលទទួលបាន។

## ការបកស្រាយ



1. *ស្រមោលតែងតែមានពណ៌ខ្មៅជានិច្ច*

   គោលគំនិតនេះត្រឹមត្រូវតែនៅពេលដែលមានប្រភពពន្លឺតែមួយមិនមានពន្លឺមិនផ្ទាល់។
2. *មានស្រមោលពណ៌ទឹកក្រូចនៅពីក្រោយបណ្ណពណ៌ទឹកក្រូច*

   ការយល់ឃើញបែបនេះទាក់ទងនឹងការយល់ច្រឡំអំពីស្រមោល និងពន្លឺ។ស្រមោលអាចបង្កើតម្លប់ពណ៌ទឹកក្រូចពេលដែលមានពន្លឺមិនផ្ទាល់គ្រប់គ្រាន់។បន្ទាប់មកពន្លឺដែលផ្លាតលើបណ្ណពណ៌ទឹកក្រូចអាចទៅដល់តំបន់ស្រមោល។
3. *កែវពណ៌ទឹកក្រូចមានស្រមោលពណ៌ទឹកក្រូច*

   ការយល់ឃើញនេះត្រឹមត្រូវប្រសិនបើវាមានន័យថាតំបន់ពណ៌ទឹកក្រូចគឺជាស្រមោលនៃប្រេកង់ពន្លឺទាំងអស់ដែលមិនមែនពណ៌ទឹកក្រូច។
4. *មិនមានស្រមោលនៅពីក្រោយកែវទេមានតែពន្លឺប៉ុណ្ណោះ*

   ការយល់ឃើញនេះត្រឹមត្រូវបើអ្នកផ្តោតតែទៅលើគំនិតអំពីពន្លឺ។ តម្រងពន្លឺអាចឱ្យប្រេកង់ពណ៌ទឹកក្រូចនៃពន្លឺឆ្លងកាត់បានបង្កើតជាតំបន់ពន្លឺមួយ។

## សន្និដ្ឋាន



ជានិច្ចកាល ស្រមោលត្រូវបានឱ្យនិយមន័យថាជាតំបន់ដែលពន្លឺផ្ទាល់ពីប្រភពពន្លឺមួយមិនអាចទៅដល់។ ដោយយើងផ្តោតតែទៅលើប្រភពពន្លឺតែមួយការកត់សម្គាល់ថាស្រមោលមានពណ៌ខ្មៅត្រូវបានទទួលយកយ៉ាងទូលំទូលាយ។

យ៉ាងណាមិញស្ថានភាពដែលស្ទើរតែមិនមានពន្លឺទៅដល់តំបន់ស្រមោលកម្រកើតមានណាស់។សូមមើលស្រមោលនៅជុំវិញខ្លួនអ្នកអ្នកនឹងឃើញពណ៌នៃផ្ទៃដែលរងស្រមោល (ឧទាហរណ៍ស្រមោលពណ៌បៃតងស្រអាប់នៅលើស្មៅ)។ មានន័យថានៅតែមានពន្លឺចូលទៅដល់តំបន់ស្រមោលដដែលដែលពន្លឺទាំងនេះអាចជាពន្លឺចេញពីចំណាំងផ្លាតផ្សេងៗជាច្រើន (សូម្បីតែពន្លឺពណ៌ខៀវផ្លាតពីមេឃ) ឬពីប្រភពពន្លឺផ្សេងៗទៀត។



មនុស្សភាគច្រើននឹងនិយាយថា “តំបន់” ពណ៌ទឹកក្រូចនៅពីក្រោយតម្រងពន្លឺពណ៌ទឹកក្រូចមិនមែនជាស្រមោលមានពណ៌នោះទេប៉ុន្តែជាពន្លឺដែលមានពណ៌។ ការយល់ឃើញនេះមានភាពត្រឹមត្រូវដោយផ្នែកប៉ុណ្ណោះព្រោះការយល់ឃើញថាជាស្រមោលក៏សមហេតុផលដែរ។ តម្រងពន្លឺទប់ស្កាត់រាល់ប្រេកង់ទាំងអស់នៃពន្លឺលើកលែងតែប្រេកង់នៃពន្លឺពណ៌ទឹកក្រូចទើបបង្កើតជាស្រមោលរបស់ប្រេកង់ពន្លឺផ្សេងៗក្រៅពីពន្លឺពណ៌ទឹកក្រូច។ ដូចនេះស្រមោលអាចជាពន្លឺហើយពន្លឺក៏អាចជាស្រមោលដែរ។

សម្រាប់រូបគំនូរតុក្កតាគំនិតទាំងអស់បានពិពណ៌នាលម្អិតអំពីរបៀបប្រើប្រាស់ដូចជា: វត្ថុបំណង សម្ភារ សកម្មភាព និងលទ្ធផលរំពឹងទុក។ វិធីដែលប្រើនៅក្នុងមេរៀនស្រមោលនឹងផ្តល់ជាគំនិតដល់អ្នកក្នុងការអនុវត្តប្រើប្រាស់ផ្ទាំងរូបភាពតុក្កតាគំនិតផ្សេងៗទៀត (**សូមមើលចំណុចកម្មវិធីសិក្សា**)។

## 5. ពេលវេលា



លោកគ្រូអ្នកគ្រូអាចប្រើគំនូរតុក្កតាគំនិតនៅពេលចាប់ផ្តើមមេរៀនថ្មីដើម្បីបំផុសការពិភាក្សានិងលើកជាសំណួរអំពីសកម្មភាពដែលត្រូវធ្វើបន្តដើម្បីស្វែងយល់បន្ថែមទៀត។ សកម្មភាពនេះអាចជួយសិស្សកំណត់ចំណុចចាប់ផ្តើមការរិះរកនិងការសិក្សាបន្ថែម។

គ្រូក៏អាចប្រើគំនូរតុក្កតាគំនិតនៅជិតចុងបញ្ចប់នៃការបង្រៀនមេរៀនមួយ។ បន្ទាប់មកជាការផ្តោតសំខាន់ទៅលើការរំលឹកនឹងសំយោគចំណេះដឹង។ ការប្រើប្រាស់គំនូរតុក្កតាគំនិតនឹងផ្តល់ឱកាសឱ្យសិស្សបានអនុវត្តនូវរាល់ចំណេះដឹងដែលគេទទួលបានក្នុងស្ថានភាពជីវភាពរស់នៅជាក់ស្តែង។

## 6. កម្មវិធីសិក្សា



### 6.1. រូបវិទ្យា

យើងបានជ្រើសរើសរូបភាពតុក្កតាគំនិតចំនួន14ពីខ្លឹមសារមេរៀនមួយចំនួនធំក្នុងកម្មវិធីសិក្សា។

| អុបទិច | មេកានិច | កម្តៅ | សន្ទនីយ៍ | អគ្គិសនី |
|---|---|---|---|---|
| 1. វ៉ែនតាខ្មៅ<br>2. ស្បូវគ្រាស<br>3. ពិល | 4. ការធ្លាក់<br>5. បាល់ទាត់<br>6. រ៉ុកកែតអវកាស<br>7. យន្តហោះលឿន | 8. ទឹកពុះ<br>9. ប៉ាន់តែ | 10. ប៉ោងប៉ោង | 11. កុងតាក់<br>12. រំហូរចរន្ត<br>13. ខ្សែចម្លងធំ<br>14. អេឡិចត្រូមេដែក |

រូបភាពតុក្កតានីមួយៗបានពិពណ៌នាលម្អិតក្នុងឧបសម្ពន្ធទី1។























## 6.2. ជីវវិទ្យា

យើងបានជ្រើសរើសរូបភាពតុក្កតាគំនិតចំនួន3អំពីខ្លឹមសារមេរៀនក្នុងកម្មវិធីសិក្សា។

| រុក្ខជាតិ | សារពាង្គកាយមនុស្ស | ការវិវត្ត និងការបន្តពូជ |
|---|---|---|
| 1. ផ្លែប៉ោមរលួយ | 2. អង់ទីប្យូទិច | 3. ជីវិតក្នុងត្រពាំង |

រូបភាពតុក្កតានីមួយៗបានពិពណ៌នាលម្អិតក្នុងឧបសម្ពន្ធទី2។

## 6.3. ផែនដីនិងបរិស្ថានវិទ្យា

សម្រាប់មុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យាយើងបានបញ្ចូលគំរូតុក្កតាគំនិតចំនួន 2 អំពីខ្លឹមសារមេរៀនក្នុងកម្មវិធីសិក្សា។

| ប្រព័ន្ធព្រះអាទិត្យនិងសកល | ផែនដីនិងបរិស្ថាន |
|---|---|
| 1. ចន្ទគ្រាស | 2. ហេតុអ្វីមួយថ្ងៃមាន24ម៉ោង ? |

រូបភាពតុក្កតានីមួយៗបានពិពណ៌នាលម្អិតក្នុងឧបសម្ពន្ធ3។

## 6.4. គីមីវិទ្យា

សម្រាប់មុខវិជ្ជាគីមីវិទ្យាយើងបានបញ្ចូលគំរូតុក្កតាគំនិតចំនួន7អំពីខ្លឹមសារមេរៀនក្នុងកម្មវិធីសិក្សា។

| ល្បាយសមាសធាតុ លក្ខណៈរូបធាតុ | ប្រតិកម្មគីមី |
|---|---|
| 1. អង្គធាតុរាវ<br>2. ទឹកល្អក់<br>3. កំណរជាញើស<br>4. តៃផ្អែម ( ការរលាយ )<br>5. ទឹកកករលាយ | 6. ដែកគោលច្រែះ<br>7. ទៀនកំពុងឆេះ |

តុក្កតានីមួយៗត្រូវបានពណ៌នាលម្អិតក្នុងឧបសម្ពន្ធ4។

## 7. សំណូមពរ



មានវិធីផ្សេងៗមួយចំនួនទៀតដែលគ្រូអាចប្រើរូបគំនូរតុក្កតាគំនិតក្នុងការបង្រៀនដូចជា:

- លុបពាក្យសម្ដីរបស់តួអង្គខ្លះចេញហើយឱ្យសិស្សបំពេញ។
- គ្រូបង្កើតរូបភាពតុក្កតាគំនិតដោយប្រើគំនិតរបស់សិស្ស។
- សិស្សធ្វើការជាក្រុមដើម្បីបង្កើតរូបភាពតុក្កតាដោយខ្លួនឯង ដែលបង្ហាញពីការយល់ឃើញនៅក្នុងក្រុមរបស់គេ។
- សិស្សពូកែបង្កើតរូបភាពតុក្កតារបស់គេដើម្បីបង្ហាញពីប្រភពនៃការភាន់ច្រឡំអំពីមេរៀនមួយ។





- រូបភាពតុក្កតាអាចប្រើជាប្រយោគផ្ដើមដើម្បីអនុវត្តសកម្មភាពបំណិនបកស្រាយបែបវិទ្យាសាស្ត្រដូចជា*វង្វង់ព្រម-មិនព្រមឬវេទិកាពិភាក្សា* (*សូមមើលជំពូកអំពីបំណិនបកស្រាយបែបវិទ្យាសាស្ត្រ*)។ សិស្សគាំទ្រតួអង្គតុក្កតាមួយហើយពន្យល់ហេតុផលដែលការយល់ឃើញរបស់តួអង្គនោះត្រឹមត្រូវ។
- គ្រូអាចរៀបចំជាការប្រកួតបង្កើតរូបភាពតុក្កតាគំនិតនៅចុងមេរៀន។ សិស្សព្យាយាមរចនាជារូបភាពតុក្កតាគំនិតដែលគួរឱ្យចាប់អារម្មណ៍ជាងគេ។

## 8. ដំបូន្មានសំខាន់ៗ



រូបភាពតុក្កតាគំនិតនីមួយៗមិនមែនតម្រូវថាមានចម្លើយត្រឹមត្រូវតែមួយនោះទេ។ ក្នុងករណីភាគច្រើនសេចក្ដីសន្និដ្ឋានចុងក្រោយដែលសមហេតុផលគឺច្រើនផ្ដើមដោយប្រយោគ “ **វាអាស្រ័យលើ**......”។ សូម្បីតែស្ថានភាពដែលមើលទៅងាយក៏អាចមានកត្តាដែលនាំឱ្យសាំញុំាមួយចំនួនពេលដែលយើងពិនិត្យពិច័យល្អិតល្អន់។ ជានិច្ចកាល ដូចក្នុងវិទ្យាសាស្ត្រពិតដែរ ចំណោទវិទ្យាសាស្ត្រមិនមានចម្លើយត្រឹមត្រូវតែមួយនោះទេ។នេះជាគោលដៅដ៏សំខាន់មួយដែលយើងចង់ឱ្យសិស្សយល់។

គ្រូបង្រៀនជាច្រើនជួបការលំបាកក្នុងការអនុវត្តវិធីបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ។ ពួកគាត់គិតថាស្ថានភាពក្នុងរូបភាពតុក្កតាគួរតែបញ្ជាក់ឱ្យច្បាស់ដើម្បីឱ្យមានចម្លើយត្រឹមត្រូវតែមួយគត់។ រូបភាពតុក្កតាគំនិតមានវត្ថុបំណងសំខាន់មួយគឺសិស្សរៀនបង្ហាញការយល់ឃើញរបស់ខ្លួនអំពីគំនិតទាំងឡាយក្នុងតុក្កតា។ គ្រូចាំបាច់ត្រូវបំផុសឱ្យសិស្សបកស្រាយហេតុផលនិងពិភាក្សាអំពីវិទ្យាសាស្ត្រជាជាងការផ្ដល់ចម្លើយត្រឹមត្រូវភ្លាមៗតែម្ដង។

ដូចនេះគ្រូគួរប៉ាន់ស្មានទុកជាមុននូវចម្លើយដែលសិស្សអាចនឹងឆ្លើយទើបគាត់អាចអនុវត្តបានល្អ។

















# ឧបសម្ពន្ធ1: គំរូតុក្កតាគំនិតសម្រាប់មុខវិជ្ជារូបវិទ្យា

(ឯកសារយោង "រូបភាពតុក្កតាគំនិតក្នុងការអប់រំវិទ្យាសាស្ត្រ" នៃគម្រោង ConCISE ដោយ Stuart Naylor និង Brenda Keogh រោងពុម្ពMilgate House )

## សេចក្តីផ្តើម



នៅក្នុងរូបភាពតុក្កតានីមួយៗទស្សនៈវិទ្យាសាស្ត្រត្រឹមត្រូវនិងគំនិតភាន់ច្រឡំត្រូវបានយកមកពិពណ៌នា។ការពិសោធន៍និងអង្កេតបែបវិទ្យាសាស្ត្រដើម្បីបំភ្លឺគោលគំនិតទាំងនោះក៏ត្រូវបានលើកមកបង្ហាញដែរ។រូបភាពតុក្កតាក្នុងមុខវិជ្ជារូបវិទ្យាត្រូវបានបែងចែកទៅតាមប្រធានបទសំខាន់ៗដូចជាអុបទិច កម្តៅ សន្ទនីយ៍ មេកានិច និងអគ្គិសនី។





# អុបទិច










## 1. វ៉ែនតាខ្មៅ

កម្មវិធីសិក្សា: ថ្នាក់ទី9 ជំពូកទី5 មេរៀនទី2-3 (ឆ្នាំ2011)




## ការបកស្រាយ



មនុស្សដែលនៅលើឆ្នេរខ្សាច់អាចនឹងភ្ញាក់ផ្អើលដែលស្បែករបស់ពួកគេឡើងខ្មៅដោយងាយដោយសារពន្លឺព្រះអាទិត្យដែលផ្លាតមកពីដីខ្សាច់។ ចំណាំងផ្លាតពីខ្សាច់បង្កើនបរិមាណសរុបនៃពន្លឺព្រះអាទិត្យដែលជះមកលើរាងកាយដូចនេះការលាបក្រែមការពារកម្ដៅថ្ងៃ និងពាក់វ៉ែនតាខ្មៅមាននាទីសំខាន់ណាស់។ យ៉ាងណាមិញពន្លឺទាំងអស់គឺបញ្ចេញមកពីព្រះអាទិត្យ។ ដីខ្សាច់មិនបង្កើតឬរក្សាទុកពន្លឺឡើយ ប៉ុន្តែគ្រាន់តែបំផ្លាតពន្លឺព្រះអាទិត្យប៉ុណ្ណោះ។ ព្រិល និងខ្សាច់បំផ្លាតពន្លឺបានល្អជាងដី និងស្មៅ។

## 2. សូរ្យគ្រាស

កម្មវិធីសិក្សា: ថ្នាក់ទី9 ជំពូកទី5 មេរៀនទី2-3 (ឆ្នាំ2011)




## ការបកស្រាយ



សូរ្យគ្រាសកើតមាននៅពេលដែលព្រះចន្ទឆ្លងកាត់ចន្លោះផែនដីនិងព្រះអាទិត្យទើបព្រះចន្ទបាំងពន្លឺព្រះអាទិត្យជិតហើយផែនដីស្ថិតនៅក្នុងស្រមោលរបស់ព្រះចន្ទ។ បាតុភូតខាងលើនេះកម្រកើតឡើងណាស់ព្រោះវាទាមទារឱ្យអង្គទាំងបីខាងលើស្ថិតលើបន្ទាត់តែមួយយ៉ាងជាក់លាក់។ សូរ្យគ្រាសអាចកើតឡើងបានតែជាមួយស្រមោលរបស់ព្រះចន្ទមួយគត់ព្រោះមិនមានអង្គភពណាមួយផ្សេងទៀតដែលអាចស្ថិតនៅជិតផែនដីល្មមអាចបាំងជិតពន្លឺព្រះអាទិត្យឡើយ។ សូរ្យគ្រាសខុសពីចន្ទគ្រាសជាបាតុភូតដែលកើតមានពេលស្រមោលរបស់ផែនដីជះទៅលើព្រះចន្ទនាំឱ្យព្រះចន្ទមិនអាចបំផ្លាតពន្លឺរបស់ព្រះអាទិត្យបាន។

ការបញ្ជាក់បាតុភូតនេះតាមរយៈការពិសោធន៍មិនមែនជាការងាយស្រួលទេ។ យើងអាចបង្កើនការយល់ដឹងរបស់យើងតាមរយៈរូបភាពគំរូ។ សិស្សអាចបង្កើតគំរូតំណាងបាតុភូតនេះបានដោយប្រើភូគោល ប្រភពដែលមានពន្លឺភ្លឺខ្លាំងនិងកូនបាល់តូចមួយដើម្បីតំណាងព្រះចន្ទ។













## 3. ពិល

កម្មវិធីសិក្សា: ថ្នាក់ទី9 ជំពូកទី5 មេរៀនទី2-3 ( ឆ្នាំ2011 )




## ការបកស្រាយ



ការយល់ឃើញភាន់ច្រឡំមួយដែលច្រើនកើតមានគឺថាចម្ងាយដែលពន្លឺដាលអាស្រ័យលើភាពភ្លឺនៃប្រភពពន្លឺ។ តាមការពិតនៅក្នុងមជ្ឈដ្ឋានតែមួយពន្លឺតែងតែដាលដោយល្បឿនស្មើគ្នាដូចនេះវានឹងដាលបានចម្ងាយស្មើគ្នា។ អ្វីដែលប្រែប្រួលគឺភាពភ្លឺនិងក្រឡាផ្ទៃដែលត្រូវបានបំភ្លឺ។

ពិលធំអាចបំភ្លឺបានផ្ទៃធំជាងឬបំភ្លឺផ្ទៃមួយបានភ្លឺជាងឬទាំងពីរ។ ការវាស់ល្បឿនដែលពន្លឺដាលពិតជារឿងមួយដ៏លំបាក។ ការរិះរកដែលប្រសើរជាងនេះគឺការសង្កេតផ្ទៃដែលទទួលបានពន្លឺនិងភាពភ្លឺនៃការបំភ្លឺនោះដោយប្រើប្រភពពន្លឺផ្សេងៗគ្នា។ ការរិះរកក៏អាចបញ្ចូលពិសោធន៍សន្មត ("តើនឹងមានហេតុការណ៍អ្វីកើតឡើងប្រសិនបើ............?" )




# មេកានិច













## 4. ការធ្លាក់

កម្មវិធីសិក្សា: ថ្នាក់ទី8 ជំពូកទី2 មេរៀនទី3 ( ឆ្នាំ2010 )




## ការបកស្រាយ



រូបភាពតុក្កតានេះទាក់ទងជាមួយរូបភាពតុក្កតាមុនដែលនិយាយអំពីការលោតចងជើង។ ទម្ងន់និងទំហំមិនមានឥទ្ធិពលដោយផ្ទាល់ទៅលើល្បឿននៃការធ្លាក់ទេ។ ស្លាបបក្សីនិងក្រដាសធ្លាក់យឺតៗដោយសារក្រឡាផ្ទៃរាខ្យល់របស់វាធំបង្កើតជាកម្លាំងទប់នៃខ្យល់ខ្លាំងពេលវាធ្លាក់។ ក្នុងការអង្កេតយើងអាចរកវិធីធ្វើឱ្យក្រដាសធ្លាក់កាន់តែលឿនដូចជាមូរវាឱ្យតូចឬបត់។ យើងក៏អាចរកវិធីផ្សេងទៀតដើម្បីកែប្រែល្បឿនធ្លាក់របស់ស្លាបបក្សីដោយកែប្រែស្ថានភាពរោមដែលមាននៅលើស្លាបបក្សីឬទម្លាក់ស្លាបនោះដោយរបៀបផ្សេងៗគ្នា។ ការបញ្ចាំងវីដេអូស្តីអំពីសកម្មភាពរបស់អវកាសយានិកទៅឋានព្រះចន្ទមុនគេបង្អស់ដែលបានទម្លាក់ញញួរមួយនិងស្លាបបក្សីមួយនៅលើឋានព្រះចន្ទ ( ដែលមិនមានបរិយាកាស ) មានប្រយោជន៍បង្កើនការយល់ដឹងរបស់សិស្ស។

## 5. បាល់ទាត់

កម្មវិធីសិក្សា: ថ្នាក់ទី8 ជំពូកទី2 មេរៀនទី3 ( ឆ្នាំ2010 )




## ការបកស្រាយ



មនុស្សភាគច្រើនយល់ច្រឡំថាវត្ថុដែលកំពុងផ្លាស់ទីមានកម្លាំងមួយដែលមានអំពើទៅលើវាក្នុងទិសដៅដូចទិសដៅនៃចលនា។ ចំពោះបាល់កម្លាំងដែលមានអំពើទៅលើវាពេលវាស្ថិតនៅផុតពីដីគឺកម្លាំងទំនាញផែនដីនិងកម្លាំងដ៏តូចមួយគឺកម្លាំងទប់នៃខ្យល់។នៅក្នុងទ្រឹស្តីបាល់អាចនឹងមិនធ្លាក់ចុះមកដីវិញទេប្រសិនបើគេអាចទាត់វាដោយកម្លាំងខ្លាំងល្មម ( ដូចជាផ្កាយរណបដែលអាចស្ថិតនៅជាអចិន្ត្រៃយ៍ខាងក្រៅផែនដី ) ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែងវិញស្ថានភាពនេះមិនអាចកើតឡើងបានទេ។

ការវាស់ដោយផ្ទាល់នូវកម្លាំងដែលមានអំពើលើបាល់ដែលកំពុងហោះមិនមែនជាការងាយស្រួលនោះទេ។ មិនធ្លាប់មានការអង្កេតជាក់ស្តែងត្រូវបានធ្វើឡើងដើម្បីបញ្ជាក់ស្ថានភាពក្នុងតុក្កតានៅឡើយ។ ការពិភាក្សាមានទំនោរនឹងផ្តោតទៅលើគំរូតាងធាតុមួយចំនួនក្នុងស្ថានភាពខាងលើ ( ឧទាហរណ៍ពិនិត្យមើលកម្លាំងដែលមានអំពើតាមខ្សែដេក )។

















## 6. រ៉ុកកែត

កម្មវិធីសិក្សា: ថ្នាក់ទី8 ជំពូកទី2 មេរៀនទី3 (ឆ្នាំ2010)




## ការបកស្រាយ



ថ្វីបើនៅលើផែនដីកម្លាំងកកិតបន្ថយល្បឿនវត្ថុដែលកំពុងផ្លាស់ទី នៅក្នុងលំហអវកាសមិនមានបរិយាកាសទើបនាំឱ្យមិនមានកម្លាំងកកិតដែរ។ កាំជ្រួចអវកាសនិងបន្តផ្លាស់ទីជានិច្ចដោយរក្សាទិសដៅដដែលពេលវាអស់ឥន្ទនៈ។ បើវាស្ថិតនៅជិតនឹងតារាឬភពណាមួយល្មមអាចរងឥទ្ធិពលនៃកម្លាំងទំនាញនៃតារាឬភពនោះវាអាចនឹងធ្លាក់បន្តិចម្តងៗទៅរកតារាឬភពនោះ។

មានល័ក្ខខ័ណ្ឌមួយចំនួនដែលនាំឱ្យស្ថានភាពនេះស្រដៀងគ្នានឹងស្ថានភាពបន្ទះក្តាររអិលខាងលើខុសគ្នាតែមិនមានអំពើនៃកម្លាំងកកិត។ យើងមិនអាចអង្កេតស្ថានភាពនេះដោយផ្ទាល់បានទេប៉ុន្តែដើម្បីរិះរកយើងអាចប្រើវិធីមួយចំនួនដូចជាពិសោធន៍សន្មត ("តើនិងមានហេតុការណ៍អ្វីកើតឡើងប្រសិនបើ...... ?") ការទស្សន៍ទាយនិងធ្វើគំរូតាងផ្នែកផ្សេងៗនៃស្ថានភាពនេះឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន (ឧទាហរណ៍ចលនាដូចស្ថានភាពខាងលើនៅខ្សែដេកដែលមានកម្លាំងកកិតតូច)។

## 7. យន្តហោះលឿន

កម្មវិធីសិក្សា: ថ្នាក់ទី8 ជំពូកទី1 មេរៀនទី2 (ឆ្នាំ2010)




## ការបកស្រាយ



ការពិភាក្សានៅក្នុងរូបភាពតុក្កតានេះគឺជាទំនាក់ទំនងរវាង សំទុះ ល្បឿន និងថេរវេលាចរ។ ថេរវេលាចរអាស្រ័យនឹងល្បឿនមធ្យមមិនអាស្រ័យនឹងសំទុះទេ។ ថ្វីបើសំទុះធំជួយឱ្យយន្តហោះបង្កើនល្បឿនដល់ល្បឿនហោះហើរធម្មតារបស់វាយ៉ាងឆាប់រហ័សក៏ដោយចំពោះចម្ងាយចរខ្លីវាមិនសូវមានភាពខុសប្លែកគ្នាចំពោះថេរវេលាចរនោះទេ។មានសំទុះធំមិនមែនមានន័យថាមានល្បឿនខ្ពស់បំផុតធំឬមានថេរវេលាចរថយចុះខ្លាំងនោះទេ។

នៅក្នុងការរិះរកយើងអាចអនុវត្តសកម្មភាពមួយចំនួនដូចជាគណនាថេរវេលាក្នុងស្ថានភាពផ្សេងៗគ្នា គូសក្រាបតាងទំនាក់ទំនងរវាងថេរវេលាចរនិងចម្ងាយចរនិងការប្រើប្រាស់កម្មវិធីគ្រាប់តាមនៅក្នុងកុំព្យូទ័រ។



# កម្តៅ










## 8. ទឹកពុះ

កម្មវិធីសិក្សា: ថ្នាក់ទី7 ជំពូកទី1 មេរៀនទី1-3 ( ឆ្នាំ2009 )




## ការបកស្រាយ



មនុស្សច្រើនមានគំនិតយល់ច្រឡំមួយថាអង្គធាតុរាវដែលមានបរិមាណតិចនឹងពុះនៅសីតុណ្ហភាពទាបជាងអង្គធាតុរាវដែលមានបរិមាណច្រើន។ បរិមាណតិចនៃអង្គធាតុរាវត្រូវការថាមពលតិចដើម្បីឈានដល់ចំណុចរំពុះហេតុនេះហើយទើបវាឆាប់ពុះប៉ុន្តែសីតុណ្ហភាពរំពុះគឺដូចគ្នា។

យើងអាចអង្កេតស្ថានភាពនេះបានដោយប្រើឆ្នាំងដាំទឹកមួយ។ យើងអាចប្រៀបធៀបរយៈពេលដាំទឹកឱ្យពុះនិងសីតុណ្ហភាពរំពុះនៃបរិមាណទឹកផ្សេងគ្នា។ យើងក៏អាចវាស់ផលនៃការផ្ដល់កម្ដៅឱ្យទឹកកាន់តែច្រើនផងដែរ។ វិធីដ៏ត្រឹមត្រូវដើម្បីកម្ដៅអង្គធាតុរាវគឺការប្រើឧបករណ៍កម្ដៅតូចមួយព្រោះយើងពិបាកតាមដានបរិមាណថាមពលដែលត្រូវបានផ្ដល់ឱ្យប្រសិនបើយើងប្រើឆ្នាំង។ វិធីអង្កេតដ៏មានប្រយោជន៍មួយបែបផ្សេងទៀតគឺប្រៀបធៀបរយៈពេលដាំនិងសីតុណ្ហភាពរំពុះនៃអង្គធាតុរាវផ្សេងទៀតដូចជាសូលុយស្យុងអំបិលឬទឹកដោះគោ។

## 9. ប៉ាន់តែ

កម្មវិធីសិក្សា: ថ្នាក់ទី7 ជំពូកទី2 មេរៀនទី1 ( ឆ្នាំ2009 )




## ការបកស្រាយ



ប្រធានបទសំខាន់នៃការពិភាក្សាក្នុងរូបភាពតុក្កតានេះគឺរយៈពេលដែលថាមពលកម្ដៅឆ្លងកាត់ឬបាត់បង់ពីវត្ថុមួយចំនួន។ ការបាត់បង់ថាមពលពីប៉ាន់តែអាស្រ័យលើកម្រាស់របស់ប៉ាន់ (ប៉ាន់តែកាន់តែក្រាស់ត្រូវការថាមពលកាន់តែច្រើនដើម្បីកម្ដៅ) ធម្មជាតិនៃវត្ថុធាតុដើម (លោហៈចម្លងថាមពលបានល្អ) ពណ៌ (ពណ៌ស្រអាប់បាត់បង់ថាមពលឆាប់ជាង) និងផ្ទៃនៃប៉ាន់ (ផ្ទៃគ្រើមបាត់បង់ថាមពលឆាប់ជាង)។ យើងពិបាកនឹងទស្សន៍ទាយអន្តរកម្មរវាងកត្តាផ្សេងៗជាច្រើនឱ្យបានត្រឹមត្រូវណាស់។

យើងអាចអង្កេតស្ថានភាពខាងលើជាក់ស្ដែងដោយប្រើប៉ាន់តែដែលមានទឹកក្ដៅពេញដែលយើងវាស់ល្បឿនចុះត្រជាក់ដោយប្រើទែរម៉ូម៉ែត្រ។ យើងអាចបង្កើតគំរូតាងបែបនេះដោយប្រើវត្ថុផលិតពីវត្ថុធាតុដើមផ្សេងៗទៀតដាក់ទឹកក្ដៅពេញដែលអាចឱ្យយើងវិភាគឥទ្ធិពលនៃកត្តានីមួយៗដាច់ដោយឡែកពីគ្នា។ ឯកសារពិសោធន៍រូបវិទ្យា ពិពណ៌នាអំពីពិសោធន៍ដ៏មានប្រយោជន៍មួយដែលសិស្សសហការគ្នាបង្កើតដបអ៊ីសូឡង់ដែលល្អជាងគេបំផុត។







# សន្ទនីយ៍













## 10. ប៉ោងប៉ោង

កម្មវិធីសិក្សា: ថ្នាក់ទី7 ជំពូកទី4 មេរៀនទី4 (ឆ្នាំ2009)




## ការបកស្រាយ



មនុស្សភាគច្រើនយល់ថាខ្យល់មិនមានទម្ងន់ឬមានទម្ងន់ជាតម្លៃអវិជ្ជមាន។ ដូចសារធាតុផ្សេងៗទៀតដែរខ្យល់ផ្សំឡើងពីភាគល្អិតទោះជាភាគល្អិតទាំងនោះមានទំហំតូចក៏ដោយក៏មានទម្ងន់បន្តិចបន្តួចដែរ។ ព្រោះខ្យល់មានទម្ងន់ ការបញ្ចូលខ្យល់ចូលក្នុងប៉ោងប៉ោងនិងបន្ថែមទម្ងន់ឱ្យប៉ោងប៉ោង។ ប៉ោងប៉ោងផ្ទុកខ្យល់កាន់តែច្រើនកាន់តែធ្ងន់។








# អគ្គិសនី













## 11. កុងតាក់

កម្មវិធីសិក្សា: ថ្នាក់ទី7 ជំពូកទី3 មេរៀនទី6 (ឆ្នាំ2009)




## ការបកស្រាយ



ការយល់ឃើញភាន់ច្រឡំមួយគឺថាអគ្គិសនីចាប់ផ្តើមកើតមាននៅលើថ្មពិលបន្ទាប់មកឆ្លងកាត់ធាតុនីមួយៗនៃសៀគ្វីមួយម្តងៗដូចនេះកុងតាក់ចាំបាច់ត្រូវស្ថិតនៅខាងវិជ្ជមាននៃអំពូលដើម្បីបើកឬបិទអំពូល។ តាមការពិតចរន្តអគ្គិសនីរត់នៅគ្រប់ផ្នែកនៃសៀគ្វីក្នុងពេលតែមួយដូចនេះមិនថាកុងតាក់ស្ថិតនៅត្រង់ចំណុចណានៃសៀគ្វីក៏អាចបើកឬបិទអំពូលបានដូចគ្នា។

ចំណោទដែលបង្ហាញក្នុងសៀគ្វីនេះអាចអង្កេតបានដោយប្រើសម្ភារងាយៗ។ ដោយគ្រាន់តែភ្ជាប់កុងតាក់នៅទីតាំងខុសៗគ្នាក្នុងសៀគ្វីងាយមួយគឺគ្រប់គ្រាន់ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីផលនៃការប្តូរទីតាំងកុងតាក់។

## 12. រំហូរចរន្ត

កម្មវិធីសិក្សា: ថ្នាក់ទី7 ជំពូកទី3 មេរៀនទី2 (ឆ្នាំ2009)




## ការបកស្រាយ



ដោយថ្មពិលអស់ថាមពលច្បាស់ជាមានអ្វីម្យ៉ាងត្រូវបានប្រើអស់នៅក្នុងសៀគ្វីអគ្គិសនី។ ដូចនេះយើងអាចនឹងសន្មតថានឹងមានចរន្តអគ្គិសនីចូលទៅចង្កៀងច្រើនជាងចេញពីចង្កៀង។ ការពិតដែលចរន្តអគ្គិសនីស្មើគ្នាឆ្លងកាត់ខ្សែចម្លងទាំងពីរហាក់ដូចជាផ្ទុយពីការគិតរបស់យើង។ ការស្វែងយល់អាចមានភាពសាំញ៉ាំប្រសិនបើយើងសិក្សាអំពីចរន្តអគ្គិសនីដោយមិនញែកវាឱ្យដាច់ស្រឡះពីថាមពលអគ្គិសនី។ ចរន្តអគ្គិសនីជំរុញឱ្យកើតមានបន្ទេរថាមពលហើយទោះជាចរន្តអគ្គិសនីមានតម្លៃថេរគ្រប់ចំណុចនៃសៀគ្វីក៏ដោយថាមពលអគ្គិសនីមិនដូច្នោះទេ។

ប្រសិនបើមានអំពែរម៉ែត្រ យើងអាចវាស់អាំងតង់ស៊ីតេចរន្តអគ្គិសនីនៅចំណុចផ្សេងៗគ្នាជុំវិញសៀគ្វីដើម្បីបញ្ជាក់ថាវាមានតម្លៃថេរ។ការប្រៀបប្រដូច (សូមមើលជំពូកស្តីពីការប្រៀបប្រដូចនិងគំរូតាង) អាចជួយសិស្សញែកសម្គាល់ភាពខុសគ្នារវាងលំហូរចរន្តនិងបន្ទេរថាមពល។ ការសិក្សាបន្ថែមទៀតអំពីប្រតិកម្មគីមីដែលកើតមានខាងក្នុងថ្មពិលក៏មានប្រយោជន៍សម្រាប់ការស្វែងយល់ចំណុចខាងលើដែរ។











## 13. ខ្សែចម្លងធំ

កម្មវិធីសិក្សា: ថ្នាក់ទី7 ជំពូកទី3 មេរៀនទី4 ( ឆ្នាំ2009 )




## ការបកស្រាយ



សិស្សភាគច្រើនគិតថាបើយើងប្រើខ្សែចម្លងកាន់តែធំនឹងមានចរន្តអគ្គិសនីកាន់តែច្រើនរត់កាត់ខ្សែចម្លងហើយអំពូលនឹងភ្លឺកាន់តែខ្លាំង។ យ៉ាងណាមិញការប្រើខ្សែកាន់តែធំក្នុងសៀគ្វីមួយមិនបានជួយឱ្យអំពូលភ្លឺកាន់តែខ្លាំងនោះទេ។ ភាពភ្លឺនៃអំពូលអាស្រ័យលើរ៉េស៊ីស្តង់នៃលំហូរចរន្តអគ្គិសនីឆ្លងកាត់សៀគ្វី។ ដូចនេះកត្តាដែលកម្រិតលំហូរនៃចរន្តអគ្គិសនីគឺកម្រាស់នៃសរសៃឆ្មារៗនៅក្នុងអំពូល។

ស្ថានភាពនេះអាចអង្កេតបានដោយរៀបចំសៀគ្វីងាយមួយដោយឆ្លាស់គ្នាប្រើខ្សែចម្លងតូចនិងខ្សែចម្លងធំភ្ជាប់ពីថ្មពិលទៅអំពូល។ ជាមួយខ្សែរចម្លងតូចគេអាចកត់សម្គាល់ឃើញថាលំហូរចរន្តថយចុះអំពូលមិនសូវភ្លឺរីឯខ្សែរចម្លងធំក៏មិនបណ្ដាលឱ្យមានផលអ្វីប្លែកគ្នាដែរ។ ការពិភាក្សានេះអាចប្រើជាសេចក្ដីផ្ដើមនៃមេរៀនរ៉េស៊ីស្តង់និងដើម្បីស្វែងយល់អំពីរបៀបត្រួតពិនិត្យលម្ហូរចរន្តឆ្លងកាត់សៀគ្វី។

## 14. អេឡិចត្រូមេដែក

កម្មវិធីសិក្សា: ថ្នាក់ទី7 ជំពូកទី5 មេរៀនទី3




## ការបកស្រាយ



ផលម៉ាញ៉េទិចនៃលំហូរចរន្តអគ្គិសនីមានសារៈសំខាន់ណាស់នៅក្នុងយុគសម័យអេឡិចត្រូនិចរបស់យើងនេះ។ ថ្វីបើការពិសោធន៍ដោយប្រើដែកគោលមួយឬវត្ថុដែលផ្សំឡើងពីដែកសម្រាប់ជាស្នូលម៉ាញ៉េទិចគ្រប់គ្រាន់ដើម្បីបញ្ជាក់រួចទៅហើយក៏ដោយក៏ការពិសោធន៍នេះមិនមែនបញ្ជាក់ត្រឹមតែផលម៉ាញ៉េទិចប៉ុណ្ណោះទេ។

ដោយរៀបចំជាសៀគ្វីដូចក្នុងរូបភាពខាងលើអាចឱ្យយើងអង្កេតបាននូវចម្ងល់មួយចំនួន។ យើងអាចពិនិត្យផលម៉ាញ៉េទិចដោយពិនិត្យទ្រនិចត្រីវិស័យឬកម្រិតស្រូបទាញដែលវាមានទៅលើវត្ថុមួយចំនួនដូចជាប្រដាប់កៀបក្រដាស។ ការសិក្សាអំពីផលម៉ាញ៉េទិចនៃរង្វេលខ្សែចម្លងដោយគ្មានដែកគោលបង្ហាញថាផលម៉ាញ៉េទិចកើតឡើងពីចរន្តអគ្គិសនីហើយមិនមែនកើតដោយវត្តមាននៃដែកគោលនោះទេ។



# ឧបសម្ព័ន្ធ2: គំរូតុក្កតាគំនិតសម្រាប់មុខវិជ្ជាជីវវិទ្យា





## សេចក្តីផ្តើម





នៅក្នុងរូបភាពតុក្កតានីមួយៗការយល់ឃើញត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រ និងការយល់ឃើញបែបភាន់ច្រឡំត្រូវបានពិពណ៌នា។មិនតែប៉ុណ្ណោះពិសោធន៍ និងសកម្មភាពសិស្សមជ្ឈមណ្ឌលមួយចំនួនដើម្បីបង្រៀនមេរៀនទាំងនេះក៏ត្រូវបានយកមកបកស្រាយផងដែរ។







# រុក្ខជាតិ








## 1. ផ្លែប៉ោមរលួយ

កម្មវិធីសិក្សា: ថ្នាក់ទី10 ជំពូកទី1 មេរៀនទី2 ( ឆ្នាំ2008 )




## ការបកស្រាយ



មនុស្សភាគច្រើនយល់ច្រឡំថាផ្លែឈើរលួយបណ្តាលមកពីល័ក្ខខ័ណ្ឌមជ្ឈដ្ឋានមិនអនុគ្រោះដែលមានអំពើទៅលើសារធាតុសរីរាង្គ។ ជាទូទៅសិស្សមួយចំនួនអាចចង្អុលបង្ហាញនូវហេតុការណ៍ដែលកើតឡើងពេលផ្លែឈើរលួយ។ តាមការពិតសារធាតុសរីរាង្គរលួយដោយសារមីក្រុប ( មីក្រូសារពាង្គកាយដូចជាបាក់តេរី ) ស៊ីផ្លែឈើនោះជាអាហារ។ យើងមិនអាចមើលឃើញស្ថានភាពនេះជាក់ស្តែងទេព្រោះយើងមិនអាចមើលឃើញមីក្រុបដោយភ្នែកទទេបានឡើយ។ យ៉ាងណាមិញបរិមាណសំណើម សីតុណ្ហភាព និងកម្រិតអាស៊ីតសុទ្ធតែអាចមានឥទ្ធិពលទៅលើល្បឿនដែលមីក្រុបស៊ីផ្លែប៉ោមនិងធ្វើឱ្យផ្លែប៉ោមនេះរលួយ។ ល្បឿនដែលផ្លែប៉ោមមួយរលួយអាចអង្កេតបានដោយទុកផ្លែប៉ោមមួយចោលលើដីប្រភេទខុសៗគ្នាក្នុងល័ក្ខខ័ណ្ឌខុសៗគ្នា។ សកម្មភាពមីក្រុបអាចចៀសវាងបានដោយប្រើដំណោះស្រាយថ្នាំសម្លាប់សត្វល្អិតឬថ្នាំបាញ់សម្លាប់បាក់តេរីដើម្បីរំងាប់មីក្រុបនៅលើផ្លែប៉ោមរៀងរាល់2-3ថ្ងៃម្តង។














# សារពាង្គកាយមនុស្ស



## 2. អង់ទីប៊្យូទិច

កម្មវិធីសិក្សា: ថ្នាក់ទី11 ជំពូកទី3 មេរៀនទី2 ( ឆ្នាំ2009 )




## ការបកស្រាយ



នេះជាប្រធានបទដែលសិស្សធ្លាប់ឮនៅផ្ទះ ហើយអាចគិតថាពួកគេយល់។ ចម្លើយរបស់តួអង្គ C ត្រឹមត្រូវ។ បាក់តេរីទាំងអស់មិនអាចទទួលបានភាពធន់ឡើយ ហើយមនុស្សមិនអាចធន់នឹងអង់ទីប៊្យូទិចឡើយ (ទោះជាបាក់តេរីនៅក្នុងខ្លួនពួកគេអាចធន់ក៏ដោយ)។ គំនូរតុក្កតានេះពន្យល់ហេតុផលដែលត្រូវលេបអង់ទីប៊្យូទិចឱ្យគ្រប់តាមពេលវេលាកំណត់នៅពេលដែលអ្នកឈឺ។ ប្រសិនបើអ្នកឈប់លេបឆាប់ពេក បាក់តេរីមិនងាប់ទាំងអស់ទេ។ បាក់តេរីដែលនៅសល់អាចប្រែជាធន់ ហើយនឹងត្រូវចម្លងទៅមនុស្សផ្សេងទៀត ដែលអ្នកទាំងនោះនឹងមិនអាចព្យាបាលជាដោយប្រើអង់ទីប៊្យូទិចដដែលបានឡើយ។







# ការវិវត្តនិងការបន្តពូជ













## 3. ជីវិតក្នុងត្រពាំង

កម្មវិធីសិក្សា: ថ្នាក់ទី10 ជំពូកទី1 មេរៀនទី6 ( ឆ្នាំ2008 )




## ការបកស្រាយ



ប្រសិនបើមិនស្ថិតក្នុងស្ថានភាពមួយដែលមិនប្រក្រតីទេត្រីទំនងជាមិនអាចប្រើប្រាស់អស់អុកស៊ីសែននៅក្នុងត្រពាំងហើយងាប់នោះទេ។ ត្រីបាននឹងកំពុងរស់នៅក្នុងបឹងនិងត្រពាំងអស់ជាច្រើនឆ្នាំមកហើយដោយមិនធ្លាប់ជួបនឹងបញ្ហាអស់អុកស៊ីសែនហើយងាប់នោះទេដូចនេះត្រីទាំងនោះច្បាស់ជាទទួលបានអុកស៊ីសែនពីប្រភពណាមួយផ្សេងទៀត។ ត្រីទទួលបានអុកស៊ីសែនបន្ថែមពីខ្យល់ដែលរលាយក្នុងទឹក។ ត្រីក៏អាចទទួលបានអុកស៊ីសែនពីរុក្ខជាតិដែលបញ្ចេញអុកស៊ីសែនទៅក្នុងទឹកតាមលំនាំរស្មីសំយោគ។ នេះជាស្ថានភាពមួយដែលពិបាកអង្កេតដោយសកម្មភាពពិសោធន៍ជាក់ស្តែង។ យើងអាចប្រៀបប្រដូចនឹងស្ថានភាពមួយទៀតដែលរុក្ខជាតិទឹកទទួលបានឧស្ម័នកាបូនិចសម្រាប់លំនាំរស្មីសំយោគពីឧស្ម័នកាបូនិចដែលរលាយក្នុងទឹក។










# ឧបសម្ព័ន្ធ3: គំរូតុក្កតាគំនិតសម្រាប់មុខវិជ្ជា ផែនដី និង បរិស្ថានវិទ្យា

## សេចក្តីផ្តើម



នៅក្នុងរូបភាពតុក្កតានីមួយៗការយល់ឃើញត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រនិងការយល់ឃើញបែបភាន់ច្រឡំត្រូវបានពិពណ៌នា។ មិនតែប៉ុណ្ណោះសកម្មភាពអង្កេតបែបវិទ្យាសាស្ត្រនិងពិសោធន៍ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀតក៏ត្រូវបានយកមកបកស្រាយផងដែរ។











# ប្រព័ន្ធព្រះអាទិត្យនិងសកល













## 1. ចន្ទគ្រាស

កម្មវិធីសិក្សា: ថ្នាក់ទី8 ជំពូកទី3 មេរៀនទី3 ( ឆ្នាំ2010 )




## ការបកស្រាយ



ចន្ទគ្រាសកើតមានឡើងពេលដែលស្រមោលរបស់ផែនដីចាំងចំលើព្រះចន្ទ ធ្វើឱ្យព្រះចន្ទមិនអាចបំភ្លាតពន្លឺពីព្រះអាទិត្យតទៅទៀតបាន។

អ្នកអាចជួយឱ្យសិស្សយល់បាតុភូតនេះបានតាមរយៈការប្រើគំរូតាងនិងរូបភាពជីវចលតំណាងដោយប្រើគំរូតាងដែលមានភូគោលមួយនិងប្រភពពន្លឺដ៏ខ្លាំងមួយ និងកូនបាល់តូចមួយសម្រាប់តំណាងព្រះចន្ទ។ ចូរប្រៀបធៀបបាតុភូតចន្ទគ្រាស និងសូរ្យគ្រាស។ បំផុសការគិតរបស់សិស្សដោយសួរសំណួរមួយថាហេតុអ្វីបានជាមិនមានបាតុភូតចន្ទគ្រាសកើតឡើងរៀងរាល់ខែ ?










# ផែនដីនិងបរិស្ថាន















## 2. ហេតុអ្វីបានជាមួយថ្ងៃមាន24ម៉ោង?

កម្មវិធីសិក្សា: ថ្នាក់ទី7 ជំពូកទី2 មេរៀនទី1-2 (ឆ្នាំ2009)




## ការបកស្រាយ



ថ្ងៃនិងយប់កើតឡើងពីចលនារង្វិលខ្វាល់របស់ផែនដីជុំវិញអ័ក្សរង្វិលរបស់ខ្លួន ទើបបណ្ដាលឱ្យទីតាំងជាក់ស្ដែងរបស់ព្រះអាទិត្យនៅលើមេឃមើលទៅដូចជាប្រែប្រួល។ ចលនារង្វិលខ្វាល់ប្រព្រឹត្តទៅបានមួយជុំរៀងរាល់24ម៉ោងម្ដង បង្កើតជាវដ្ដពេល24ម៉ោងនៃភាពភ្លឺនឹងងងឹតដែលយើងបានដឹងរួចមកហើយ។ ថ្វីបើយើងមើលទៅដូចជាព្រះអាទិត្យធ្វើចលនាផ្លាស់ទីនៅលើមេឃ នេះបណ្ដាលមកពីយើងមិនដឹងអំពីចលនារង្វិលខ្វាល់របស់ផែនដីទើបយើងគិតថាបម្លាស់ប្ដូរទីតាំងរបស់ព្រះអាទិត្យបណ្ដាលមកពីព្រះអាទិត្យធ្វើចលនាជាជាងគិតថាផែនដីធ្វើចលនា។

វានឹងមិនងាយស្រួលក្នុងការអះអាងដោយប្រើពិសោធន៍ដែលបញ្ជាក់ថាផែនដីវិលជុំវិញខ្លួនឯងមួយជុំរៀងរាល់24ម៉ោងម្ដង មិនមែនព្រះអាទិត្យផ្លាស់ទីទេ។ យើងអាចបង្កើតគំរូតាងស្ថានភាពនេះបានដោយប្រើភូគោលមួយនឹងប្រភពពន្លឺដែលភ្លឺខ្លាំងមួយ។ ពិសោធន៍សន្មតនិងការទស្សន៍ទាយអាចភ្ជាប់ទំនាក់ទំនងជាមួយបទពិសោធន៍ប្រចាំថ្ងៃអំពីថ្ងៃនិងយប់។













# ឧបសម្ពន្ធ4: គំរូតុក្កតាគំនិតសម្រាប់មុខវិជ្ជាគីមីវិទ្យា







## សេចក្តីផ្តើម



នៅក្នុងរូបគំនូរតុក្កតានីមួយៗ យើងបានពិពណ៌នាអំពីការយល់ឃើញត្រឹមត្រូវតាមបែបវិទ្យាសាស្ត្រនិងគំនិតភាន់ច្រឡំដែលសិស្សអាចមាន។ លើសពីនេះទៅទៀត យើងក៏បានបញ្ចូលនូវគំនិតសម្រាប់ការអង្កេត ការពិសោធន៍ឬសកម្មភាពសិស្សមជ្ឈមណ្ឌលផ្សេងៗទៀតដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់នូវបញ្ញត្តិនៃមេរៀននីមួយៗ។



# ល្បាយ សមាសធាតុ និងលក្ខណៈនៃរូបធាតុ













## 1. *អង្គធាតុរាវ*

កម្មវិធីសិក្សា: ថ្នាក់ទី7 ជំពូកទី1 មេរៀនទី1 (ឆ្នាំ2009)




## ការបកស្រាយ



ប្រធានបទសំខាន់នៃការពិភាក្សាក្នុងរូបភាពនេះគឺធម្មជាតិនៃអង្គធាតុរាវ។ តាមលក្ខណៈវិទ្យាសាស្ត្រ វត្ថុរាវមានមាឌថេរតែមានរូបរាងប្រែប្រួល ដូចនេះវានឹងមានរូបរាងតាមវត្ថុដែលផ្ទុកវា។ ថ្វីបើដីឥដ្ឋអាចប្រែប្រួលរូបរាងបានក៏ពិតមែនតែវានឹងរក្សារូបរាងរបស់វារហូតដល់វារងអំពើណាមួយដែលបណ្ដាលឱ្យវាប្រែប្រួលរូបរាង។ ចំពោះ "វត្ថុរឹងម៉ដ្ឋដែលអាចហូរបាន" ដូចជាខ្សាច់ឬអំបិលហាក់ដូចជាគ្រាប់តាមលក្ខណៈរបស់វត្ថុរាវដែលមានរូបរាងដូចវត្ថុដែលផ្ទុកវា។

យ៉ាងណាមិញ គ្រាប់អំបិលឬគ្រាប់ខ្សាច់មិនប្រែប្រួលរូបរាងដូចវត្ថុរាវទេ។ គ្រាប់នីមួយៗជាវត្ថុរឹងតូចមួយ។ បទពិសោធន៍ពីការសិក្សាទៅលើសារធាតុផ្សេងៗគ្នាច្រើន (រួមបញ្ចូលទាំងសារធាតុដែលពិបាកនឹងធ្វើចំណាត់ថ្នាក់ក្រុម) ការពិភាក្សានិងការឆ្លុះបញ្ចាំងចាំបាច់ដើម្បីឱ្យសិស្សយល់។ ការញែកសម្គាល់ភាពខុសគ្នារវាងសារធាតុសុទ្ធដែលអាចធ្វើចំណាត់ថ្នាក់ក្រុមបានងាយនិងល្បាយដែលសាំញ៉ាំមានប្រយោជន៍សម្រាប់ការសិក្សាស្ថានភាពខាងលើ។ ល្បាយមានទំនោរនឹងមានលក្ខណៈលាយឡំគ្នារបស់អង្គធាតុរាវ រឹងនិងឧស្ម័ន។ គ្រូអាចប្រើរូបភាពតុក្កតានេះរួមជាមួយសកម្មភាពចំណាត់ថ្នាក់បណ្ណដែលសិស្សព្យាយាមចែកសារធាតុជាក្រុមទៅតាមលក្ខណៈវិនិច្ឆ័យដែលគេបានពិភាក្សាគ្នា។













## 2. ទឹកល្អក់

កម្មវិធីសិក្សា: ថ្នាក់ទី8 ជំពូកទី2 មេរៀនទី2 (ឆ្នាំ2010)




## ការបកស្រាយ



ប្រធានបទនៃការពិភាក្សាក្នុងរូបភាពតុក្កតានេះគឺ តើតម្រងអាចត្រងជាប់សារធាតុដែលរលាយនិងសារធាតុដែលមិនរលាយបានដែរឬទេ?ជាទូទៅសារធាតុដែលរលាយអាចឆ្លងកាត់តម្រងបានដោយងាយ។ សំណួរមួយផ្សេងទៀតដែលទាក់ទងនឹងសំណួរនេះដែរគឺ "តើទឹកដែលយើងមើលឃើញថាស្អាត ពិតជាទឹកសុទ្ធដែលអាចបរិភោគបានដោយសុវត្ថិភាពដែរឬទេ?" យើងអាចអង្កេតប្រសិទ្ធិភាពនៃតម្រងផ្សេងៗគ្នាដោយប្រៀបធៀបរូបសម្បត្តិរបស់វត្ថុរាវដែលឆ្លងកាត់តម្រង។ ដោយប្រើតម្រងដូចជាសំឡី ប្រដាប់ច្រោះដែលមានក្រឡាល្អិតនិងក្រដាសច្រោះដែលមានកម្រាស់ខុសៗគ្នានឹងផ្តល់ជាមូលដ្ឋានសម្រាប់ការប្រៀបធៀប។ ទឹកដែលយើងមើលឃើញថាស្អាតអាចយកទៅបង្អួតឱ្យអស់ដើម្បីបង្ហាញថាសារធាតុផ្សេងៗគ្នាអាចស្ថិតនៅក្នុងទឹកដោយមិនធ្វើឱ្យប៉ះពាល់រូបសម្បត្តិរបស់ទឹកទេ។ អ្នកអាចភ្ជាប់ទំនាក់ទំនងរូបគំនូរតុក្កតានេះជាមួយមេរៀនការកង្វក់ទឹក។ តើទឹកភ្លៀងជាទឹកដែលមានសុវត្ថិភាពអាចផឹកបានដែរឬទេ? តើយើងគួរធ្វើយ៉ាងដូចម្តេចដើម្បីឱ្យទឹកភ្លៀងក្លាយជាទឹកមានសុវត្ថិភាពអាចផឹកបាន?

## 3. កំណជាញើស

កម្មវិធីសិក្សា: ថ្នាក់ទី7 ជំពូកទី2 មេរៀនទី1 (ឆ្នាំ2009)




## ការបកស្រាយ



ថ្វីបើកំណជាញើសជាបទពិសោធន៍ដ៏សាមញ្ញមួយដែលមនុស្សទូទៅតែងជួបប្រទះក្នុងជីវភាពរស់នៅប្រចាំថ្ងៃក៏ដោយ យើងនៅមិនទាន់យល់អំពីប្រភពដែលញើសទាំងនោះចេញមកនៅឡើយទេ។ ជាធម្មតា ចំហាយទឹកស្ថិតនៅក្នុងបរិយាកាសប៉ុន្តែយើងមិនអាចមើលឃើញទេ។ នៅសីតុណ្ហភាពខ្ពស់ចំហាយទឹកស្ថិតនៅជាឧស្ម័នប៉ុន្តែនៅសីតុណ្ហភាពទាបចំហាយទឹករងកំណជាញើសក្លាយជាដំណក់ទឹក។ កែវមួយដែលមានផ្ទុកទឹកកក ជាធម្មតាមានសីតុណ្ហភាពត្រជាក់ល្មម អាចឱ្យចំហាយទឹកក្នុងបរិយាកាសប្រែក្លាយជាដំណក់ទឹកជាប់នៅផ្ទៃខាងក្រៅនៃកែវ។




គ្រូអាចអនុវត្តសកម្មភាពមួយចំនួនដើម្បីជួយឱ្យសិស្សយល់អំពីស្ថានភាពនេះ។ ការយកកែវដ៏ត្រជាក់មួយចេញពីទូទឹកកកបង្ហាញថាយើងមិនចាំបាច់ត្រូវដាក់ទឹកកកនៅក្នុងកែវទើបអាចកើតមានលំនាំកំណជាញើសនោះទេ ហើយក៏មិនមានទឹកលិចចេញពីកែវមកដែរ។ ដោយប្រៀបធៀបបរិមាណកំណជាញើសក្នុងខ្យល់នឹងខ្យល់បក់ខ្យល់ក្ដៅ និងខ្យល់សើមជួយឱ្យយើងភ្ជាប់ទំនាក់ទំនងជាមួយភស្តុតាងអំពីវត្តមានចំហាយទឹកនៅក្នុងខ្យល់។ ការសិក្សាអំពីពេលវេលានិងទីកន្លែងដែលកើតមានលំនាំកំណជាញើសជាវិធីមួយដ៏មានប្រយោជន៍សម្រាប់អនុវត្តចំណេះដឹងអំពីលំនាំកំណជាញើស។

## 4. ការរលាយ

កម្មវិធីសិក្សា: ថ្នាក់ទី8 ជំពូកទី3 មេរៀនទី3 ( ឆ្នាំ2010 )




## ការបកស្រាយ



មនុស្សទូទៅច្រើនមានការភាន់ច្រឡំថា ពេលដែលសារធាតុទាំងឡាយរលាយ សារធាតុទាំងនោះបាត់បង់ហើយលែងមានវត្តមានតទៅទៀត។ ថ្វីបើយើងមើលស្ករមិនឃើញពេលវារលាយ ទម្ងន់សរុបនៃសារធាតុដែលមានក្នុងទឹកតែនិងស្ករមិនប្រែប្រួលទេ។ ដោយមូលហេតុនេះហើយទើបទឹកតែនេះមានរសជាតិផ្អែម ព្រោះស្ករនៅតែមាន គ្រាន់តែយើងមើលវាមិនឃើញប៉ុណ្ណោះ។

ការថ្លឹងទម្ងន់របស់ទឹកតែនិងស្ករនៅមុននឹងក្រោយពេលស្កររលាយ ជាសកម្មភាពមួយងាយស្រួលនិងបញ្ជាក់យ៉ាងច្បាស់លាស់ថាតើទម្ងន់មានប្រែប្រួលឬទេ។ ជញ្ជីងមានដងធម្មតាអាចប្រើជំនួសបានប្រសិនបើមិនមានជញ្ជីងដែលមានភាពរួសកម្រិតខ្ពស់ទេ។ យើងអាចថ្លឹងតែនិងស្ករដាច់ដោយឡែកពីគ្នា បន្ទាប់មកកូរស្ករក្នុងទឹកតែរួចថ្លឹងម្ដងទៀតដើម្បីពិនិត្យថាមានបម្រែបម្រួលឬទេ។

ដោយបង្ហូតទឹកចេញឱ្យអស់ពីទឹកតែដែលមានរសជាតិផ្អែម យើងនឹងឃើញថាស្ករនៅតែមានវត្តមានក្នុងទឹកតែដដែល។

















## • ទឹកកករលាយ ( ដូចរូបភាពរូបវិទ្យា )

កម្មវិធីសិក្សា: ថ្នាក់ទី7 ជំពូកទី2 មេរៀនទី1 ( ឆ្នាំ2009 )




## ការបកស្រាយ



រូបភាពតុក្កតានេះបង្ហាញការភាន់ច្រឡំដែលច្រើនកើតមានរវាងទម្ងន់និងដង់ស៊ីតេ។ ទឹកកកមានដង់ស៊ីតេទាបជាងទឹក ហេតុនេះហើយទើបវាអណ្តែតលើទឹក។ ពេលទឹកកករលាយទម្ងន់របស់វាមិនប្រែប្រួលទេ។ ទឹកកក10ក្រាមរលាយបានជាទឹក 10ក្រាមដែរ។ យ៉ាងណាមិញ មាឌប្រែប្រួលពេលទឹកកករលាយ។ ទឹក10ក្រាមមានមាឌតូចជាងទឹកកក10ក្រាម ដូចនេះទឹកកកមានដង់ស៊ីតេទាបជាងដង់ស៊ីតេរបស់ទឹក។ យើងងាយនឹងភាន់ច្រឡំត្រង់ចំណុចនេះណាស់។ ទឹកនិងទឹកកកជាករណីពិសេសព្រោះស្ទើរតែគ្រប់សារធាតុទាំងអស់មានដង់ស៊ីតេកើនឡើងពេលវាកករឹង។ យើងអាចថ្លឹងទម្ងន់ទឹកកកដែលមានបរិមាណជាក់លាក់មួយនៅមុន និងក្រោយពេលរលាយ ដើម្បីបញ្ជាក់ថាតើទម្ងន់មានប្រែប្រួលឬទេ។ ការសិក្សាអំពីបម្រែបម្រួលដង់ស៊ីតេពេលសីតុណ្ហភាពប្រែប្រួលកាន់តែគួរឱ្យចាប់អារម្មណ៍ជាងនេះទៅទៀត ហើយអាចផ្តល់ឱកាសឱ្យសិស្សបានប្រើប្រាស់ចំណេះដឹងរបស់ខ្លួនរកហេតុផលដែលនាំឱ្យផ្ទាំងទឹកកកធំៗអណ្តែតនិងទីតាំងដែលទឹកកកកើតមានឡើងពេលដែលទឹកមានសីតុណ្ហភាពត្រជាក់ខ្លាំង។

# ប្រតិកម្មគីមី













## 6. ដែកគោលច្រែះ

កម្មវិធីសិក្សា: ថ្នាក់ទី11 ជំពូកទី2  មេរៀនទី1 ( ឆ្នាំ2009 )




### ការបកស្រាយ



លំនាំឡើងច្រែះអាចកើតឡើងបានត្រូវការវត្ថុមានខ្យល់និងទឹក ដូចនេះដែកគោលសើមតែងតែឡើងច្រែះយ៉ាងរហ័ស។ ទោះជាដែកគោលស្ថិតនៅលិចក្នុងទឹកក៏ការឡើងច្រែះនៅតែកើតឡើងដដែលព្រោះជាធម្មតានៅក្នុងទឹកមានខ្យល់រលាយ។ យ៉ាងណាមិញ លំនាំនេះនឹងប្រព្រឹត្តទៅយឺតជាង ព្រោះនៅក្នុងទឹកមានបរិមាណអុកស៊ីសែនរលាយទាបជាង។ លក្ខខណ្ឌសីតុណ្ហភាពត្រជាក់នឹងពន្យឺតល្បឿនលំនាំឡើងច្រែះ ព្រោះខ្យល់ត្រជាក់មានបរិមាណចំហាយទឹកតិច។ ថ្វីបើច្រែះមើលទៅដូចជាជំងឺម្យ៉ាង តាមការពិតវាមិនមែនដូច្នោះទេ ដូចនេះវត្តមាននៃដែកគោលដែលមានច្រែះ មិនបណ្ដាលឱ្យដែកគោលផ្សេងទៀតឡើងច្រែះឡើយ។ អ្នកអាចដាក់កិច្ចការឱ្យសិស្សអង្កេតស្ថានភាពនេះដោយរៀបចំនូវបន្សំនៃកត្តាមួយចំនួនដែលអាចបណ្ដាលឱ្យឡើងច្រែះ( ដំបូង ទុកឱ្យសិស្សធ្វើព្យាករណ៍ គំនិតរកកត្តាទាំងនេះដោយខ្លួនឯង )។ ការបំបាត់វត្តមានខ្យល់ទាំងស្រុងជាបន្សំមួយដែលពិបាកសម្រេចបានបំផុតក្នុងបន្សំនៃកត្តាទាំងឡាយ។ ស្រទាប់ប្រេងឬថ្នាំលាបអាចបំបាត់វត្តមានខ្យល់ ប៉ុន្តែវាក៏ទប់ស្កាត់សំណើមមិនឱ្យចូលទៅដល់ដែកគោលដែរ។ ដាំទឹកហើយទុកឱ្យពុះមួយរយៈដើម្បីឱ្យអស់ខ្យល់ បន្ទាប់មកដាក់ដែកគោលចូលក្នុងទឹកពុះក្នុងផើងឬកែវមួយបិទជិត អាចមានវត្តមានទឹកប៉ុន្តែមិនមានខ្យល់។ ត្រូវឱ្យសិស្សផ្ទៀងផ្ទាត់ម្ដងមួយអថេរហើយត្រូវរៀបចំពិសោធន៍ត្រួតពិនិត្យដែរ។

## 7. ទៀនកំពុងឆេះ

កម្មវិធីសិក្សា: ថ្នាក់ទី9 ជំពូកទី2 មេរៀនទី2 ( ឆ្នាំ2011 )




### ការបកស្រាយ



ថ្វីបើការសម្លឹងមើលទៀនកំពុងឆេះជាបទពិសោធន៍សាមញ្ញមួយ ការស្វែងយល់អំពីបាតុភូតដែលកើតមានឡើងពេលដែលទៀនកំពុងឆេះនៅមិនទាន់មានភាពជាក់ស្ដែងនៅឡើយ។ ការភាន់ច្រឡំមួយដែលតែងតែកើតមានគឺថាប្រឆេះទៀនកំពុងឆេះរីឯក្រមួនគ្រាន់តែមាននាទីទប់ប្រឆេះនេះប៉ុណ្ណោះ។ តាមការពិតទាំងប្រឆេះនិងក្រមួនសុទ្ធតែឆេះទាំងអស់។ យើងអាចមើលឃើញការរលាយរបស់ក្រមួន តែមើលមិនឃើញរំហួតនិងចំហេះរបស់ក្រមួនទេ។ ការសង្កេតទៀនកំពុងឆេះយ៉ាងប្រុងប្រយ័ត្ននាំឱ្យយើងកើតចម្ងល់ថាតើបាត់ក្រមួនទៅណា។ វិធីរិះរកដ៏មានប្រយោជន៍មួយគឺរកវិធីផ្សេងទៀតដើម្បីដុតក្រមួនដូចជាប្រើឈើគូសឬក្រដាសមួយចំរៀកតូចនៅក្នុងក្រមួនជំនួសប្រឆេះ។









# 2: តេស្តគំនិត និងការបង្រៀនទៅវិញទៅមក

























## 1. សេចក្តីផ្តើមៈ តើអ្វីទៅជាតេស្តគំនិត?



### តើអ្វីទៅជាតេស្តគំនិត?

តេស្តគំនិត គឺជាប្រភេទសំណួរពហុជ្រើសរើសដ៏គួរឱ្យចាប់អារម្មណ៍ដែលផ្តោតលើការយល់ដឹងអំពីបញ្ញត្តិនៃមេរៀនមួយ។ វិធីសាស្ត្រនេះបណ្តុះបំណិនដោះស្រាយចំណោទ បញ្ហាក់និងរែកញែកហេតុផល។

ឯកសារបំប៉ននេះយោងតាមស្នាដៃរបស់សាស្ត្រាចារ្យ Eric Mazur ជាសាស្ត្រាចារ្យរូបវិទ្យានៃសាកលវិទ្យាល័យ Harvard នៅសហរដ្ឋអាមេរិច។

### ហេតុអ្វីបានជាត្រូវប្រើតេស្តគំនិត?

ការស្រាវជ្រាវជាច្រើនបានបង្ហាញថាវិធីបង្រៀនបែបបុរាណមិនទទួលបានជោគជ័យក្នុងការជំរុញសិស្សឱ្យស្ថាបនាបែបផែនចំណេះដឹងអំពីបញ្ញត្តិនៃមេរៀនមួយបានត្រឹមត្រូវនោះទេ។ ជានិច្ចកាល វិធីបង្រៀនបែបបុរាណមិនបានកែប្រែគំនិតភាន់ច្រឡំរបស់សិស្សឡើយ។ សិស្សទន្ទេញរូបមន្ត និងហ្វឹកហាត់វិធីដោះស្រាយចំណោទ ប៉ុន្តែជានិច្ចកាលសិស្សមិនអាចឆ្លើយសំណួរងាយៗដែលទាក់ទងនឹងបញ្ញត្តិនៃមេរៀនមួយបានទេ នេះបញ្ជាក់ថាសិស្សគ្រាន់តែទន្ទេញចាំមាត់ប៉ុណ្ណោះ តែមិនទទួលបានការយល់ដឹងដល់កម្រិតមួយខ្ពស់ជាងនេះទេ ដូចដែលមានពណ៌នាក្នុងប្លូមតាក់សូណូមី (Bloom's Taxonomy)។

### ហេតុអ្វីបានជាត្រូវប្រើការបង្រៀនបែបការណែនាំទៅវិញទៅមក?

ការបង្រៀនបែបណែនាំទៅវិញទៅមកជាសកម្មភាពគោលវិធីសិស្សមជ្ឈមណ្ឌលមួយសម្រាប់អនុវត្តវិធីតេស្តគំនិតនៅក្នុងថ្នាក់រៀន។ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសចម្លើយលើកទីមួយ សិស្សពិភាក្សាអំពីសំណួរដែលគ្រូដាក់ឱ្យជាក្រុមតូច (ជួនកាលគេហៅសកម្មភាពនេះថា "សួរសិស្សដែលអង្គុយក្បែរអ្នក")។ ហេតុផលសម្រាប់ការអនុវត្តសកម្មភាពនេះគឺ:

- ព្រោះសិស្សដឹងច្បាស់ពីការលំបាកក្នុងការយល់បញ្ញត្តិមួយ ជានិច្ចកាលការផ្តល់ឱកាសឱ្យសិស្សពន្យល់គំនិតមួយមានប្រសិទ្ធិភាពជាងគ្រូជាអ្នកពន្យល់។
- ព្រោះសកម្មភាពនេះផ្តល់ឱកាសឱ្យសិស្សគិតពិចារណាស៊ីជម្រៅ ឆ្លងកាត់ពេលវេលាដែលគេកំពុងពិភាក្សារែកញែក។
- សិស្សដែលអាចពន្យល់បញ្ញត្តិមួយបាន នឹងយល់បញ្ញត្តិបានល្អជាង និងចងចាំបានយូរជាងសិស្សផ្សេងៗទៀត។
- ជានិច្ចកាលសិស្សមានការខិតខំប្រឹងប្រែងរៀនសូត្រពីគ្នាទៅវិញទៅមក។
- សិស្សពង្រឹងបំណិនទំនាក់ទំនងនិងបំណិនធ្វើកិច្ចការជាក្រុម។
- សិស្សទទួលបានបទពិសោធន៍ក្នុងការប្រើប្រាស់ពាក្យបច្ចេកទេសនិងបញ្ញត្តិវិទ្យាសាស្ត្រ។
- គ្រូទទួលបានព័ត៌មានត្រឡប់ភ្លាមៗអំពីកម្រិតយល់ដឹងនិងគំនិតភាន់ច្រឡំរបស់សិស្ស។

ឈ្មោះមួយទៀតរបស់វិធីបង្រៀនដោយការណែនាំទៅវិញទៅមក គឺ **គិត-ពិភាក្សាក្រុម-ចែករំលែក**។ ដំបូងសិស្សគិតអំពីចម្លើយ បន្ទាប់មកពិភាក្សាជាមួយក្រុមអំពីការយល់ឃើញរៀងៗខ្លួន និងជាចុងក្រោយគេឡើងបង្ហាញដល់សិស្សផ្សេងទៀតនៅក្នុងថ្នាក់។

### តើវិធីសាស្ត្របង្រៀនតាមរយៈការណែនាំទៅវិញទៅមកមានគុណសម្បត្តិដូចម្តេចខ្លះបើប្រៀបធៀបនឹងវិធីសួរឱ្យសិស្សលើកដៃឆ្លើយ?

1. សិស្សគ្រប់ៗគ្នាមានឱកាសហ្វឹកហាត់ឆ្លើយចម្លើយរបស់គេ (ផ្ទាល់មាត់) ទៅកាន់ដៃគូពិភាក្សារបស់គេ មុននឹងឆ្លើយសំណួរនេះទៅសិស្សទាំងអស់ក្នុងថ្នាក់។
2. ក្រោយពីសកម្មភាពនេះមក នឹងមានសិស្សកាន់តែច្រើនចង់លើកដៃដើម្បីឆ្លើយសំណួរ។
3. តើនឹងមានសិស្សប៉ុន្មាននាក់ដែលអាក់អន់ស្រពន់ចិត្ត នៅពេលដែលខ្លួនលើកដៃសុំឆ្លើយសំណួរ ហើយគ្រូបែរជាជ្រើសរើសសិស្សផ្សេងទៀតឱ្យឆ្លើយទៅវិញនោះ? ឥឡូវនេះ ពួកគេអាចបែរទៅរកដៃគូពិភាក្សារបស់គេដើម្បីប្រាប់ចម្លើយ។
4. ការហ្វឹកហាត់ឆ្លើយមានន័យថាពួកគេអាចប្រៀបធៀបការយល់ឃើញរបស់ខ្លួនជាមួយការយល់ឃើញរបស់ដៃគូ។ ប្រសិនបើគេមិនយល់មេរៀន គេនឹងដឹង ហើយគេអាចព្យាយាមកែតម្រូវគំនិតភាន់ច្រឡំរបស់ខ្លួន។



## 2. វត្ថុបំណង



វត្ថុបំណងនៃការប្រើប្រាស់តេស្តគំនិតគឺស្រដៀងគ្នានឹងវត្ថុបំណងនៃការប្រើប្រាស់រូបគំនូរតុក្កតាគំនិតដែរ។ តេស្តគំនិតមានវត្ថុបំណងជំរុញឱ្យសិស្សផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ញត្តិដែលបង្កប់ក្នុងមេរៀនមួយ។ សូមមើលកថាខ័ណ្ឌស្តីអំពី “ហេតុអ្វីត្រូវប្រើការបង្រៀនតាមបែបការណែនាំទៅវិញទៅមក?”

## 3. សម្ភារ



តេស្តគំនិតមិនទាមទារសម្ភារអ្វីទេ។ សកម្មភាពនេះអាចអមដោយ សន្លឹកកិច្ចការ ការអង្កេត រូបភាពជីវចលនិងខ្សែភាពយន្តខ្លីៗ។

គ្រូអាចសរសេរសំណួរតេស្តគំនិតនៅលើក្តារខៀនឬនៅលើក្រដាសផ្ទាំងធំមួយសន្លឹក។ អ្នកក៏អាចសរសេរសំណួរនៅលើក្រដាសមួយសន្លឹកនិងថតចម្លង សម្រាប់កិច្ចការជាក្រុម។ក្រដាសសំណួរអ៊ុតផ្លាស្ទិចរឹងអាចប្រើបានច្រើនឆ្នាំ។

គ្រូអាចចែកឱ្យសិស្សនូវបណ្ណសម្រាប់បោះឆ្នោតជ្រើសរើសចម្លើយ។ ការជ្រើសរើសចម្លើយដោយការលើកបណ្ណជួយឱ្យគ្រូអាចស្វែងយល់បានភ្លាមៗនូវទិដ្ឋភាពទូទៅនៃការយល់ឃើញរបស់សិស្សទាំងអស់នៅក្នុងថ្នាក់។

## 4. របៀបប្រើសំណួរតេស្តគំនិត



**មុននឹងចាប់ផ្តើមមេរៀន** ចូរកំណត់បញ្ញត្តិសំខាន់ៗនៃមេរៀនឱ្យរួចស្រេច។ ចូរបែងចែកមេរៀនរបស់អ្នកជាផ្នែកតូចៗ (អ្នកអាចអនុវត្តសកម្មភាពគោលវិធីសិស្សមជ្ឈមណ្ឌលផ្សេងៗទៀត) និងការបង្ហាញសំណួរតេស្តគំនិត។ ដើម្បីរៀបចំសំណួរតេស្តគំនិតបានល្អ ទាមទារការខិតខំប្រឹងប្រែង។ យ៉ាងណាមិញ ពេលដែលអ្នកមានបញ្ជីសំណួរដ៏ល្អមួយរួចរាល់ហើយអ្នកនឹងមិនត្រូវការពេលវេលារៀបចំច្រើនទេ ព្រោះពេលវេលាមួយចំនួននៃម៉ោងសិក្សាត្រូវបានប្រើសម្រាប់ការពិភាក្សាក្រុមរបស់សិស្សទៅហើយ។

**ពេលកំពុងបង្រៀន** គ្រូបង្ហាញសំណួរមួយឬពីរអមដោយចម្លើយមួយចំនួន។ គ្រូគួរបញ្ជាក់ ឱ្យបានច្បាស់នូវចំនួនចម្លើយត្រឹមត្រូវថាមានតែមួយឬអាចមានច្រើនជាងមួយ។ សិស្សគិតមួយនាទីអំពីសំណួរតេស្តគំនិតនីមួយៗ បន្ទាប់មកបោះឆ្នោតជ្រើសរើសចម្លើយដោយប្រើបណ្ណឬដោយលើកដៃ។ លទ្ធផលនៃការជ្រើសរើសចម្លើយរបស់សិស្ស កំណត់សកម្មភាពបន្ទាប់ដែលគ្រូគួរអនុវត្ត។





ប្រសិនបើមានសិស្សភាគច្រើន (ច្រើនជាង90%) ជ្រើសរើសចម្លើយត្រឹមត្រូវ គ្រូអាចប្រើពេលវេលាខ្លីសួរបញ្ជាក់ហេតុផលទើបបង្រៀនបន្តទៀត។ វិធីមួយផ្សេងទៀតគឺគ្រូ ជ្រើសរើសសិស្សម្នាក់ឱ្យពន្យល់ចម្លើយដែលត្រឹមត្រូវ។ បើសិស្សភាគច្រើនមិនអាចជ្រើសរើសចម្លើយត្រឹមត្រូវទេ គ្រូផ្តល់ពេលឱ្យសិស្ស2នាទីដើម្បីពិភាក្សារកចំណុចយល់ស្របជាមួយសិស្សដែលអង្គុយក្បែរគេ។ បន្ទាប់មក គ្រូសួរសំណួរដដែលម្តងទៀតដើម្បីត្រួតពិនិត្យការវិវត្តនៃការយល់ដឹងរបស់សិស្ស។



បើអាចធ្វើទៅបាន គ្រូគួរកត់ត្រាភាគរយ (ប្រហាក់ប្រហែល) សិស្សដែលជ្រើសរើសចម្លើយនីមួយៗ។ការធ្វើបែបនេះជួយផ្តល់ព័ត៌មានមានប្រយោជន៍ដល់គ្រូដើម្បីកែលម្អនិងត្រួតពិនិត្យតាមដានការបង្រៀនរបស់ខ្លួន។

ពេលវេលាពន្យល់ណែនាំគ្នាទៅវិញទៅមកតែងតែជួយបង្កើនភាគរយនៃការជ្រើសរើសចម្លើយត្រឹមត្រូវនិងជួយបង្កើនទំនុកចិត្ត (កម្រិតនៃភាពច្បាស់លាស់ចំពោះចម្លើយ) របស់សិស្ស។ការរីកចម្រើនដែលប្រសើរបំផុត ជាធម្មតាអាចសង្កេតឃើញនៅពេលដែលសិស្សពាក់កណ្តាលអាចជ្រើសរើសចម្លើយត្រឹមត្រូវតាំងពីដំបូង។បន្ទាប់មក អាចនឹងកើនបាន40%បន្ថែមទៀត។ យ៉ាងណាមិញ ជួនកាលសិស្សអាចនឹងងាកទៅជ្រើសរើសចម្លើយមិនត្រឹមត្រូវ បញ្ជាក់ថាគេយល់ច្រឡំដូចសិស្សដែលអង្គុយក្បែរគេដែរ។



ប្រសិនបើក្រោយពីការបោះឆ្នោតជ្រើសរើសចម្លើយលើកទីពីរហើយ អ្នកមិនសូវពេញចិត្តនឹងលទ្ធផលនៃការជ្រើសរើសចម្លើយរបស់សិស្ស អ្នកចាំបាច់ត្រូវបន្ថយល្បឿននិងពន្យល់បន្ថែម។ប្រសិនបើអាច គ្រូគួរវាយតម្លៃការយល់ដឹងរបស់សិស្សម្តងទៀត ដោយប្រើតេស្តគំនិតទីពីរ។ បើលទ្ធផលបញ្ជាក់ថាសិស្សយល់បញ្ញត្តិនេះហើយ គ្រូអាចពន្យល់សំណួរនេះដោយសង្ខេប ហើយបន្តទៅមេរៀនបន្ទាប់ទៀត។















ពេលសិស្សកំពុងពិភាក្សា គ្រូចល័តទៅមកក្នុងថ្នាក់ដើម្បីស្តាប់បទសន្ទនារបស់សិស្ស។ គ្រូចងចាំទុកក្នុងចិត្តនូវអ្វីដែលសិស្សបកស្រាយខុស ប៉ុន្តែមិនត្រូវអន្តរាគមន៍រំខានការពិភាក្សាទេ។ បំណកស្រាយខុសរបស់សិស្សអាចផ្តល់ជាគំនិតសម្រាប់គ្រូបង្កើតតេស្តគំនិតលើកក្រោយ។

**ក្រោយពេលបង្រៀនចប់** គ្រូរំឭកឡើងវិញនូវសំណួរនិងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសចម្លើយ។ គ្រូវិភាគក្រុមចម្លើយណាមួយដែលសិស្សជ្រើសរើស និងលទ្ធភាពនៃការកែលម្អការបង្រៀនរបស់គាត់ឱ្យកាន់តែប្រសើរ។ គ្រូលុបចោល ឬក៏សម្រួលក្រុមចម្លើយដែលសិស្សមិនជ្រើសរើស។



ប្រែសម្រួលពី : Mazur, 1997

## 5. ពេលវេលា



សិស្សត្រូវមានបទពិសោធន៍ខ្លះៗក្នុងការអនុវត្តសកម្មភាពនេះតាមរយៈ**ការអនុវត្តយ៉ាងទៀងទាត់**ក្នុងថ្នាក់រៀន ដែលជួយឱ្យសិស្សស៊ាំនឹងសកម្មភាពនេះ។ គ្រូគួរអនុវត្តសកម្មភាពនេះនៅក្នុងជំហានទីបី។សកម្មភាពអនុវត្តតេស្តគំនិត ពុំគប្បីដាក់ពិន្ទុទេ ដើម្បីធានាថាសិស្សផ្តល់ចម្លើយស្មោះត្រង់និងដើម្បីលើកទឹកចិត្តសិស្សឱ្យចូលរួមដោយសេរី។

**ការធ្វើបង្ហាញ**អាចអនុវត្តរួមជាមួយវិធីតេស្តគំនិត។ បន្សំនេះអាចប្រើដើម្បីដាក់សំណួរដែលចម្លើយជំរុញឱ្យសិស្សគិតអំពីអ្វីដែលគេបានសង្កេត។ការធ្វើបង្ហាញក៏អាចប្រើដើម្បីឆ្លើយសំណួរតេស្តគំនិតដែរ។ ដោយប្រើតេស្តនេះ សិស្សនឹងយកចិត្តទុកដាក់លើការបង្ហាញកាន់តែខ្លាំងឡើង។ ពួកគេចង់ដឹងថាតើចម្លើយរបស់គេត្រូវឬខុស។គ្រូក៏អាចបង្កើតតេស្តគំនិតដោយប្រើ**គំនូរជីវចលឬខ្សែភាពយន្តខ្លីៗ**ផងដែរ។

គ្រូត្រូវមានភាពបត់បែន ពេលអនុវត្តតេស្តគំនិត។អាស្រ័យទៅលើលទ្ធផល គ្រូអាចត្រូវ បញ្ចូលការបង្រៀនបន្ថែមទៀតដូចជាការពិសោធន៍ឬលំហាត់។ ក្នុងម៉ោងបង្រៀនធម្មតាមួយ គ្រូអាចនឹងអនុវត្តពី1ទៅ5សំណួរតេស្តគំនិត។

## 6. កម្មវិធីសិក្សា



យើងបានបញ្ចូលឧទាហរណ៍ចំនួន23 ដែលដកស្រង់ចេញពីមេរៀនមួយចំនួនក្នុងកម្មវិធីសិក្សា។ ឧទាហរណ៍ជាច្រើនទៀត អាចរកបានក្នុងបណ្តាញអ៊ីនធើនែត ឬក្នុងបណ្ណាល័យ ( សូមមើលប្រភពឯកសារនៅខាងក្រោយឯកសារនេះ )។ យ៉ាងណាមិញ យើងត្រូវកត់សម្គាល់ថាឧទាហរណ៍ទាំងនេះគ្រាន់តែជា**ចំណុចចាប់ផ្តើម**ប៉ុណ្ណោះ។ គ្រូចាំបាច់ត្រូវធ្វើការវាយតម្លៃសំណួរតេស្តគំនិតនីមួយៗក្រោយពីសាកល្បងអនុវត្តវារួចមក។ ចម្លើយដែលសិស្សមិនជ្រើសរើសគួរលុបចេញ រីឯចម្លើយរបស់សិស្សដែលបញ្ជាក់ពីគំនិតភាន់ច្រឡំគួរបន្ថែមចូល។ គ្រូគួរលើកទឹកចិត្តមិត្តរួមការងាររបស់គាត់ឱ្យអនុវត្តសកម្មភាពតេស្តគំនិតក្នុងការបង្រៀនរបស់គាត់ ហើយអ្នកអាចចែករំលែកតេស្តដែលអ្នកបង្កើតជាមួយគ្នាទៅវិញទៅមកបាន។



## ឧទាហរណ៍ទី1: ហេតុអ្វីបានជាពេលយប់ងងឹត?

កម្មវិធីសិក្សា:
ថ្នាក់ទី8 ជំពូកទី3 មេរៀនទី1 (ឆ្នាំ2010)

មិត្តភក្តិ6នាក់កំពុងឆ្ងល់ពីមូលហេតុដែលមេឃនៅពេលយប់ងងឹត។
ពួកគេនិយាយថា:

ក. ពពកអណ្តែតចូលមកនៅពេលយប់បាំងព្រះអាទិត្យជិត។
ខ. ផែនដីវិលជុំវិញខ្លួនឯងមួយជុំក្នុងមួយថ្ងៃ។
គ. ព្រះអាទិត្យធ្វើដំណើរជុំវិញផែនដីមួយជុំក្នុងមួយថ្ងៃ។
ឃ. ផែនដីវិលជុំវិញព្រះអាទិត្យមួយជុំក្នុងមួយថ្ងៃ។
ង. ព្រះអាទិត្យធ្វើដំណើរនៅខាងក្រោមផែនដីនៅពេលយប់។
ច. ព្រះអាទិត្យមិនបញ្ចេញពន្លឺនៅពេលយប់។

*មូលហេតុដែលនាំឱ្យមានវដ្តថ្ងៃនិងយប់គឺផែនដីវិលជុំវិញអ័ក្សរង្វិលរបស់វាបានមួយជុំរៀងរាល់រយៈពេលប្រហែល24ម៉ោង(ចម្លើយ ខ)។ ពេលដែលទីតាំងរបស់យើងនៅលើផែនដីងាកចេញពីព្រះអាទិត្យយើងស្ថិតក្នុងពេលយប់(ងងឹត)។ ពេលដែលទីតាំងរបស់យើងនៅលើផែនដីងាកទៅរកព្រះអាទិត្យយើងស្ថិតនៅក្នុងពេលថ្ងៃ (មានពន្លឺថ្ងៃ)។*

## ឧទាហរណ៍ទី2: រដូវនៅលើផែនដី

កម្មវិធីសិក្សាមុខវិជ្ជាផែនដី និងបរិស្ថានវិទ្យា:
ថ្នាក់ទី8 ជំពូកទី3 មេរៀនទី1 (ឆ្នាំ2010)

មិត្តភក្តិ6នាក់ពិភាក្សាគ្នាពីមូលហេតុដែលនាំឱ្យមានរដូវនៅលើផែនដី។
ចម្លើយរបស់ពួកគេគឺ:

ក. នៅរដូវក្តៅផែនដីស្ថិតនៅកាន់តែជិតព្រះអាទិត្យ។
ខ. នៅរដូវក្តៅចុងខាងជើងនៃអ័ក្សរបស់ផែនដីទ្រេតទៅរកព្រះអាទិត្យ។
គ. នៅរដូវក្តៅព្រះអាទិត្យបញ្ចេញថាមពលកាន់តែច្រើន។
ឃ. នៅរដូវក្តៅព្រះអាទិត្យបញ្ចេញពន្លឺបានយូរជាង។
ង. នៅរដូវក្តៅព្រះអាទិត្យស្ថិតនៅចំពីលើក្បាលយើងនៅពេលថ្ងៃត្រង់។
ច. នៅរដូវក្តៅពន្លឺព្រះអាទិត្យកោងបណ្តាលឱ្យវាចាំងផ្ទាល់កាន់តែខ្លាំងមកលើផែនដី។

*ចម្លើយដែលត្រឹមត្រូវបំផុតគឺចម្លើយ ខ។ អ័ក្សរង្វិលទ្រេតរបស់ផែនដីបណ្តាលឱ្យផ្នែកខ្លះនៃផែនដីទទួលបានពន្លឺថ្ងៃច្រើនជាងផ្នែកផ្សេងៗទៀត។ចម្លើយ ឃ និង ង ជាលទ្ធផលនៃអ័ក្សទ្រេតរបស់ផែនដី។ ចម្ងាយខុសគ្នាបន្តិចបន្តួចទៅព្រះអាទិត្យមិនមានឥទ្ធិពលទៅលើរដូវក៏មិនធ្វើឱ្យមានបម្រែបម្រួលចំពោះថាមពលឬពន្លឺដែលបញ្ចេញដោយព្រះអាទិត្យដែរ។*

## ឧទាហរណ៍ទី3: សូរ្យគ្រាស

កម្មវិធីសិក្សាមុខវិជ្ជាផែនដី និងបរិស្ថានវិទ្យា:
ថ្នាក់ទី8 ជំពូកទី3 មេរៀនទី3 (ឆ្នាំ2010)

ពេលកំពុងមានសូរ្យគ្រាសផ្នែកមួយចំនួននៃផែនដីស្ថិតក្នុងភាពងងឹតមួយរយៈពេលខ្លីនៅពេលថ្ងៃ។ ជាយូរលង់មកហើយមនុស្សមានការយល់ឃើញខុសៗគ្នាអំពីបាតុភូតដែលកើតមានឡើងពេលកំពុងមានសូរ្យគ្រាស:

ក. ព្រះអាទិត្យឆ្លងកាត់ចន្លោះផែនដីនិងព្រះចន្ទ។
ខ. ផែនដីឆ្លងកាត់ចន្លោះព្រះអាទិត្យនិងព្រះចន្ទ។
គ. ពពកបាំងព្រះអាទិត្យជិត។
ឃ. ស្រមោលរបស់ផែនដីចាំងលើព្រះអាទិត្យ។
ង. ស្រមោលព្រះចន្ទចាំងលើផែនដី។
ច. ព្រះអាទិត្យបិទពន្លឺមួយរយៈខ្លី។
ឆ. ព្រះអាទិត្យវិលទៅនៅពីក្រោយផែនដីមួយរយៈពេលខ្លីបន្ទាប់មកទើបចេញមកម្តងទៀត។

*ចម្លើយដែលត្រឹមត្រូវបំផុតគឺចម្លើយ ង។ សូរ្យគ្រាសកើតមានឡើងនៅក្នុងអំឡុងខែដើមខ្នើត ពេលដែលព្រះចន្ទស្ថិតក្នុងបន្ទាត់តែមួយជាមួយព្រះអាទិត្យនិងផែនដី។ ព្រោះព្រះចន្ទបាំងពន្លឺព្រះអាទិត្យ វាបង្កើតជាស្រមោលដែលចាំងលើផែនដី។ ប្រើគំរូតាងឬផ្ទាំងរូបភាពមួយដើម្បីពន្យល់ពីដំណើរការនៃបាតុភូតសូរ្យគ្រាស។*

## ឧទាហរណ៍ទី4: វដ្តទឹក/រំហួត

កម្មវិធីសិក្សាមុខវិជ្ជាផែនដី និងបរិស្ថានវិទ្យា:
ថ្នាក់ទី9 ជំពូកទី2 មេរៀនទី1
កម្មវិធីសិក្សាមុខវិជ្ជារូបវិទ្យា:
ថ្នាក់ទី7 ជំពូកទី2 មេរៀនទី1 (ឆ្នាំ2011)


















ថ្នាក់ទី10 ជំពូកទី2 មេរៀនទី3 (ឆ្នាំ2009)

ក្រោយពីបោកគក់ខោរបស់អ្នករួច អ្នកហាលវានៅខាងក្រៅផ្ទះដើម្បីឱ្យវាស្ងួត។ ប៉ុន្មានម៉ោងក្រោយមកខោរបស់អ្នកស្ងួត។ តើចម្លើយណាមួយដែលពណ៌នាបានល្អបំផុតអំពីអ្វីដែលបានកើតឡើងចំពោះទឹកដែលសើមជាប់នឹងខោរបស់អ្នកនៅប៉ុន្មានម៉ោងចុងក្រោយនោះ?

ក. វាជ្រាបចូលទៅក្នុងដី។

ខ. វាបានបាត់បង់ទៅ ហើយមិនស្ថិតនៅទៀតទេ។

គ. វាស្ថិតនៅក្នុងខ្យល់ក្នុងទម្រង់មួយដែលយើងមើលមិនឃើញ។

ឃ. វារសាត់ឡើងទៅរកពពក។

ង. វាមានបម្រែបម្រួលគីមីទៅជាសារធាតុថ្មីមួយផ្សេងទៀត។

ច. វាបំបែកទៅជាអាតូមអ៊ីដ្រូសែននិងអុកស៊ីសែន។

*ចម្លើយដែលត្រឹមត្រូវបំផុតគឺចម្លើយ គ ។ ទម្រង់ដែលមើលមិនឃើញគឺចំហាយទឹក។ផ្ទុយពីដ្យាក្រាមវដ្តទឹកជាច្រើន ទឹកមិនប្រែក្លាយទៅជាពពកភ្លាមៗនោះទេ។ ទឹកនៅផ្ទៃខាងក្រៅនៃកែវត្រជាក់មួយដែលមានទឹក បញ្ជាក់ថាទឹកស្ថិតនៅក្នុងបរិយាកាសជុំវិញខ្លួនយើង។ ច្បាប់រក្សាម៉ាសបដិសេធចោលនូវចម្លើយ ខ។ សារធាតុទាំងពីរគឺទឹករាវនិងចំហាយទឹកនៅតែមានទម្រង់គីមីដូចគ្នាដដែល។ វាមិនបានប្រែទៅជាសារធាតុមួយថ្មី ឬបំបែកទៅជាអាតូមអ៊ីដ្រូសែនឬអុកស៊ីសែនទេ។*

## ឧទាហរណ៍ទី5: ដើមកំណើតនៃប្រេង

កម្មវិធីសិក្សាមុខវិជ្ជាផែនដី និងបរិស្ថានវិទ្យា:
ថ្នាក់ទី9 ជំពូកទី2 មេរៀនទី5 (ឆ្នាំ2011)
កម្មវិធីសិក្សាមុខវិជ្ជាគីមីវិទ្យា:
ថ្នាក់ទី10 ជំពូកទី4 មេរៀនទី1 (ឆ្នាំ2008)

មិត្តភក្តិមួយក្រុមកំពុងជជែកវែកញែកគ្នាអំពីដើមកំណើតនៃប្រេង។ នេះជាអ្វីដែលពួកគេនិយាយ:

ក. វាមានប្រភពមកពីបាណង្គជាតិយក្សនិងរុក្ខជាតិដែលមានជីវិតតាំងពីរាប់លានឆ្នាំកន្លងមកហើយ។

ខ. វាកើតចេញពីផ្នែកខាងក្នុងនៃសិលាបុរាណដែលប្រែប្រួលទៅជាប្រេងក្រោយរយៈពេលរាប់លានឆ្នាំ។

គ. វាកើតចេញពីទឹកនៃមហាសមុទ្ររាក់ៗដែលប្រែក្លាយទៅជាប្រេងកាលពីរាប់លានឆ្នាំមុន។

ឃ. វាកើតចេញពីមីក្រូសារពាង្គកាយនិងសារពាង្គកាយក្នុងមហាសមុទ្រផ្សេងៗទៀតកាលពីរាប់លានឆ្នាំមុន។

ង. វាកើតចេញពីភក់ ខ្សាច់ និងដីកាលពីបុរាណដែលផ្លាស់ប្តូរបន្តិចម្តងៗទៅជាអង្គធាតុរាវកាលពីរាប់លានឆ្នាំមុន។

ច. វាកើតចេញពីប្រេងសាំងដែលត្រូវបានបង្ខាំងជាប់ក្នុងសម្បកផែនដីអស់រយៈពេលរាប់លានឆ្នាំកន្លងមកហើយ។

*ចម្លើយដែលត្រឹមត្រូវបំផុតគឺចម្លើយ ឃ។ ប្រេងកើតមកពីផូស៊ីលដែលបន្សល់ទុកដោយសារពាង្គកាយតូចៗក្នុងសមុទ្រ (ប្លង់តុង)។ ពេលដែលសារពាង្គកាយទាំងនោះងាប់ វាប្រមូលផ្តុំនៅលើបាតសមុទ្រហើយត្រូវកប់បន្តិចម្តងៗក្រោមស្រទាប់កម្ទេចកំណ។កាកសំណល់នៃសារពាង្គកាយទាំងនោះរងបម្រែបម្រួលគីមីបន្តិចម្តងៗឆ្លងកាត់រយៈពេលរាប់លានឆ្នាំទៅជាប្រេង។ ធ្យូងថ្មមានដើមកំណើតដំបូងមកពីរុក្ខជាតិគោក (ចម្លើយ ក)។ ប្រេងសាំងគឺជាផលិតផលនៃប្រេងហើយមិនអាចរកបានដោយធម្មជាតិនៅក្នុងផែនដីដូចប្រេងឡើយ។*

## ឧទាហរណ៍ទី6: រស្មីសំយោគ

កម្មវិធីសិក្សាមុខវិជ្ជាជីវវិទ្យា:
ថ្នាក់ទី8 ជំពូកទី1 មេរៀនទី1-3 (ឆ្នាំ2011)

សូមក្រឡេកមើលទៅដើមឈើនៅខាងក្រៅ។តើរូបធាតុភាគច្រើនដែលចូលរួមផ្សំជាឈើនិងស្លឹកនៃដើមឈើទាំងនោះមានប្រភពចេញមកពីណា?

ក. ពន្លឺព្រះអាទិត្យ

ខ. ទឹក

គ. ដី

ឃ. កាបូនឌីអុកស៊ីត

ង. អុកស៊ីសែន

ច. រ៉ែ

ឆ. ក្លរ៉ូភីល

*ចម្លើយដែលត្រឹមត្រូវបំផុតគឺចម្លើយ ឃ ប៉ុន្តែចម្លើយ ខ ក៏ត្រឹមត្រូវមួយផ្នែកដែរ។ តេស្តគំនិតនេះត្រូវមានបង្កើតឡើងដើម្បីបញ្ជាក់ថាតើសិស្សដឹងថាឧស្ម័នមួយនៃខ្យល់ ($CO_2$) ចូលផ្សំជាមួយទឹកនិងប្រែក្លាយទៅជាសារធាតុថ្មីដែលផ្សំជាផ្នែក*



*ផ្សេងៗនៃដើមឈើឬទេ។ ម៉ាសដែលចូលផ្សំដោយ $CO_2$មានច្រើនជាងម៉ាស ដែលចូលផ្សំដោយទឹក។*

## ឧទាហរណ៍ទី7: ប្រដាប់រំលាយអាហារ

កម្មវិធីសិក្សាមុខវិជ្ជាជីវវិទ្យា:
ថ្នាក់ទី7 ជំពូកទី4 មេរៀនទី1-4 (ឆ្នាំ2009)
ថ្នាក់ទី11 ជំពូកទី4 មេរៀនទី2 (ឆ្នាំ2009)

សិស្សមួយក្រុមកំពុងពិភាក្សាគ្នាអំពីមុខងារចម្បងនៃប្រដាប់រំលាយអាហារ។ តើការយល់ឃើញណាមួយដែលត្រូវនឹងគំនិតរបស់អ្នកបំផុត?

ក. មុខងារចម្បងគឺបញ្ចេញថាមពលពីអាហារ។
ខ. មុខងារចម្បងគឺជួយឱ្យយើងដកដង្ហើម។
គ. មុខងារចម្បងគឺដើម្បីបំបែកអាហារជាម៉ូលេគុលតូចៗដែលអាចស្រូបដោយកោសិកា។
ឃ. មុខងារចម្បងគឺបំបែកអាហារនៅក្នុងក្រពះជាបំណែកអាហារតូចៗដែលអាចត្រូវបានប្រើប្រាស់ដោយសារពាង្គកាយ។
ង. មុខងារចម្បងគឺដឹកនាំបំណែកតូចៗនៃអាហារនិងសារធាតុចិញ្ចឹមទៅផ្នែកផ្សេងៗនៃសារពាង្គកាយរបស់យើង។
ច. មុខងារចម្បងគឺរក្សាទុកអាហារដើម្បីឱ្យយើងអាចទទួលបានថាមពលពេលដែលយើងត្រូវការ។

*ចម្លើយដែលត្រឹមត្រូវបំផុតគឺចម្លើយ គ។ ប្រដាប់រំលាយអាហារមានមុខងារសំខាន់ៗពីរគឺ បំបែកអាហារនិងរៀបចំសារធាតុចិញ្ចឹមសម្រាប់ការស្រូបយកដោយកោសិកា។ប្រដាប់រំលាយអាហារបំពេញតួនាទីមូលដ្ឋាន6គឺចាប់យកអាហារ (ស្រូបយកអាហារ) ការបញ្ចេញចលនានៃអាហារនិងសំណល់បំបែកអាហារសម្រួបពីផ្លូវក្រពះពោះវៀនទៅកោសិកានិងបញ្ចេញសំណល់។ ចម្លើយ ក និង ឃ ត្រឹមត្រូវមួយផ្នែក។ ចម្លើយ ងមិនត្រឹមត្រូវទេព្រោះប្រដាប់រំលាយអាហារមិនចល័តអាហារនិងសារធាតុចិញ្ចឹមឆ្លងកាត់ផ្នែកផ្សេងនៃសារពាង្គកាយឡើយ។ នេះគឺជាមុខងារនៃប្រដាប់របត់ឈាម។*

## ឧទាហរណ៍ទី8: ប្រព័ន្ធប្រសាទ

កម្មវិធីសិក្សាមុខវិជ្ជាជីវវិទ្យា:
ថ្នាក់ទី9 ជំពូកទី2 មេរៀនទី1-3 (ឆ្នាំ2011)

សិស្សមួយក្រុមកំពុងពិភាក្សាគ្នាអំពីមុខងារនៃខួរក្បាលនៅក្នុងសកម្មភាពផ្សេងៗគ្នា។ ខាងក្រោមនេះគឺជាពាក្យសម្ដីរបស់ពួកគេ:

ក. ខួរក្បាលចាំបាច់ណាស់ចំពោះសកម្មភាពផ្លូវចិត្តដូចជាការគិតជាដើម ប៉ុន្តែវាមិនចាំបាច់ចំពោះសកម្មភាពផ្លូវកាយដូចជាការលេងកីឡានោះទេ។
ខ. ខួរក្បាលចាំបាច់ទាំងចំពោះសកម្មភាពផ្លូវកាយនិងផ្លូវចិត្ត ប៉ុន្តែយើងមិនប្រើខួរក្បាលទេពេលដែលយើងកំពុងគេងលក់។
គ. យើងប្រើប្រាស់ខួរក្បាលចំពោះគ្រប់សកម្មភាពទាំងអស់។ សូម្បីតែនៅពេលកំពុងគេងលក់ ក៏ខួរក្បាលយើងនៅតែដំណើរការដែរ។

*ចម្លើយដែលត្រឹមត្រូវគឺចម្លើយ គ។ ចម្លើយ ក និងខ ឆ្លើយតបទៅនឹងគំនិតភាន់ច្រឡំដែលសិស្សភាគច្រើនមាន គឺការយល់ច្រឡំថាខួរក្បាលត្រូវបានប្រើប្រាស់តែចំពោះសកម្មភាពមួយចំនួនប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបានប្រើប្រាស់ចំពោះសកម្មភាពដែលកើតឡើងដោយមិនដឹងខ្លួនដូចជា ការក្អក ស្ថានភាពកំពុងគេងលក់ និងការមិចភ្នែកជាដើម។*

## ឧទាហរណ៍ទី9: ការរលាយ

កម្មវិធីសិក្សាមុខវិជ្ជាគីមីវិទ្យា:
ថ្នាក់ទី8 ជំពូកទី3 មេរៀនទី3 (ឆ្នាំ2010)

ពេលដែលយើងកូរស្ករសមួយស្លាបព្រាកាហ្វេក្នុងកែវមួយដែលមានទឹកក្ដៅឧណ្ឌៗ ស្ករសរលាយទាំងអស់។ តើប្រយោគណាមួយខាងក្រោមដែលត្រឹមត្រូវ (អាចមានចម្លើយត្រឹមត្រូវច្រើនជាងមួយ)?

ក. ស្ករសរលាយ។
ខ. ស្ករសបាត់បង់ម៉ាស។
គ. ស្ករសប្រែក្លាយទៅជាម៉ូលេគុលទឹក។
ឃ. ស្ករសបង្កើតជាល្បាយមួយជាមួយទឹក។
ង. ស្ករសអាចញែកចេញពីទឹកបាន។
ច. ស្ករសបាត់រូបរាង ហើយមិនស្ថិតនៅទៀតទេ។
ឆ. ម៉ូលេគុលនៃស្ករសស្ថិតនៅរាយប៉ាយលាយឡំនឹងម៉ូលេគុលទឹក។
ជ. ស្ករសបំបែកទៅជាអាតូម។









ឈ. ស្ករសចូលផ្សំតាមវិធីគីមីជាមួយទឹកបង្កើតបានជាសារធាតុថ្មីមួយទៀត។

*ចម្លើយដែលត្រឹមត្រូវបំផុតគឺចម្លើយ ឃ ង និង ឆ។ ពេលដែលស្ករសត្រូវបានចាក់ចូលទៅក្នុងទឹកវាបង្កើតបានជាល្បាយមួយហៅថាសូលុយស្យុង។ ម៉ូលេគុលស្ករសត្រូវបានរុំព័ទ្ធដោយម៉ូលេគុលទឹកប៉ូលែ។ ពេលស្កររលាយវាចូលផ្សំជាមួយទឹកតាមលំនាំរូបមិនមែនលំនាំគីមីទេដូចនេះវាមិន*



*បង្កើតជាសមាសធាតុថ្មីឡើយ។ ការរលាយក្នុងអង្គធាតុរាវខុសពីការរលាយដោយកម្ដៅព្រោះការរលាយដោយកម្ដៅសំដៅលើបម្រែបម្រួលភាពរូបហើយមិនទាមទារឱ្យមានអន្តរអំពើរវាងសារធាតុពីរដូចការរលាយក្នុងអង្គធាតុរាវទេ។ តាមច្បាប់រក្សាម៉ាសម៉ាសរបស់ស្ករសរក្សានៅដដែលទោះជាយើងមិនអាចមើលវាឃើញនៅក្នុងសូលុយស្យុងក៏ដោយ។*

## ឧទាហរណ៍ទី10: ទម្រង់អាតូម

កម្មវិធីសិក្សា:

ថ្នាក់ទី8 ជំពូកទី1 មេរៀនទី1 (ឆ្នាំ2008)



មិត្តភក្តិមួយក្រុមកំពុងពិនិត្យមើលក្រាមអំបិលដោយប្រើកែវពង្រីក។ ពួកគេកំពុងឆ្ងល់ថាតើពួកគេនឹងមើលឃើញអ្វីប្រសិនបើគេមានឧបករណ៍ ដែលមានសមត្ថភាពគ្រប់គ្រាន់អាចមើលឃើញអាតូម។ទាំងនេះគឺជាចម្លើយរបស់ពួកគេ:

ក. អាតូមទាំងឡាយនឹងតម្រៀបជាប់ៗគ្នាយ៉ាងណែន។ អាតូមទាំងនោះនឹងមើលទៅដូចជាអង្គធាតុរឹងមួយដែលមិនមានចន្លោះទំនេររវាងអាតូមឡើយ។



ខ. ខ្ញុំនឹងឃើញអាតូមញ័រតម្រៀបគ្នាយ៉ាងមានសណ្ដាប់ធ្នាប់ដោយមានចន្លោះរវាងអាតូមទាំងនោះ។ មិនមានអ្វីនៅក្នុងចន្លោះនោះក្រៅពីខ្យល់ឡើយ។

គ. ខ្ញុំនឹងមើលឃើញអាតូមទាំងឡាយនៅស្ងៀមនិងតម្រៀបគ្នាយ៉ាងមានសណ្ដាប់ធ្នាប់។ យើងនឹងឃើញមានចន្លោះរវាងអាតូមទាំងនោះដែលចន្លោះទាំងនោះមានខ្យល់។



ឃ. ខ្ញុំគិតថាខ្ញុំនឹងឃើញអាតូមទាំងឡាយដែលមានរាងជាគូបតូចៗ។ គូបតូចៗទាំងនេះនឹងចូលផ្សំគ្នាបង្កើតបានជាគូបអំបិលធំមួយ។

ង. ខ្ញុំគិតថាខ្ញុំនឹងឃើញអាតូមញ័រជាច្រើនដែលភ្ជាប់គ្នាដោយខ្សែឆ្នារជាច្រើន។ ខ្សែឆ្នារៗទាំងនេះភ្ជាប់អាតូមទាំងឡាយបង្កើតជារូបរាងគូបច្បាស់លាស់មួយ។

ច. ខ្ញុំគិតថាខ្ញុំនឹងឃើញអាតូមនីមួយៗចល័តពីទីតាំងមួយទៅទីតាំងមួយផ្សេងទៀត។ អាតូមទាំងនោះចល័តចុះឡើងពាសពេញក្នុងទម្រង់ក្រាមមួយ។

*ចម្លើយ ខ ត្រឹមត្រូវ។ អំបិលគឺជាឧទាហរណ៍មួយនៃបណ្ដាញអ៊ីយ៉ុងក្រាម។ ក្រាមអំបិលមួយកើតឡើងពីរចនាសម្ពន្ធមួយនៃអ៊ីយ៉ុងសូដ្យូមនិងក្លរតម្រៀបឆ្លាស់គ្នាជាច្រើនជាន់យ៉ាងមានសណ្ដាប់ធ្នាប់។ រចនាសម្ពន្ធនេះកើតឡើងពីទំនាញអេឡិចត្រូស្តាទិចរវាងអ៊ីយ៉ុងដែលមានបន្ទុកវិជ្ជមាននិងអវិជ្ជមានទើបធ្វើឱ្យក្រាមអំបិលមានរាងជាគូប។ អ៊ីយ៉ុងទាំងនេះត្រូវបានចងផ្ដោបគ្នាយ៉ាងណែននៅក្នុងទីតាំងមួយហើយអាចត្រឹមតែមានរំញ័រប៉ុណ្ណោះ។ មានចន្លោះទទេរវាងអាតូមទាំងឡាយនៅក្នុងក្រាមប៉ុន្តែមិនមានខ្យល់នៅក្នុងចន្លោះទាំងនោះទេ។ សារធាតុនេះជាអំបិលសុទ្ធមិនមែនជាល្បាយរវាងអំបិលនិងខ្យល់នោះទេ។ ខ្សែឆ្នារៗដែលជួនកាលត្រូវបានប្រើក្នុងគំនូរឬគំរូតាងមិនមែនជារចនាសម្ពន្ធរូបពិតប្រាកដទេប៉ុន្តែខ្សែទាំងនោះជាតំណាងឱ្យទំនាញរវាងអ៊ីយ៉ុង។*

## ឧទាហរណ៍ទី11: កម្លាំង

កម្មវិធីសិក្សាមុខវិជ្ជារូបវិទ្យា:

ថ្នាក់ទី8 ជំពូកទី2 មេរៀនទី1 (ឆ្នាំ2010)

មនុស្សម្នាក់ទាញប្រអប់មួយលើកម្រាលផ្ទះ។តើប្រយោគមួយណាដែលត្រឹមត្រូវ?

ក. ប្រអប់ចល័តទៅមុខព្រោះមនុស្សទាញទៅមុខដោយកម្លាំងខ្លាំងជាងបន្តិចបើធៀបនឹងកម្លាំងទាញត្រលប់ក្រោយដែលប្រអប់មានមកលើមនុស្សវិញ។

ខ. ដោយអំពើតែងតែស្មើនឹងប្រតិកម្មមនុស្សមិនអាចទាញប្រអប់នេះបានទេប្រអប់ទាញថយក្រោយដោយកម្លាំងស្មើគ្នានឹងមនុស្សទាញទៅមុខដែរដូចនេះប្រអប់មិនមានចលនាទេ។

គ. មនុស្សអាចធ្វើឱ្យប្រអប់ផ្លាស់ទីបានដោយប្រើការទាញដែលមានបរិមាណកម្លាំងធំជាងកម្លាំងដែលបង្កើតដោយប្រអប់មកលើមនុស្សវិញ។

ឃ. កម្លាំងរបស់មនុស្សដែលមានអំពើទៅលើប្រអប់ស្មើគ្នានឹងកម្លាំងដែលប្រអប់មានអំពើទៅលើមនុស្សប៉ុន្តែកម្លាំងកកិតដែលមានទៅលើមនុស្សមានទិសដៅឆ្ពោះទៅមុខនិងមានបរិមាណកម្លាំងធំខណៈដែលកម្លាំងកកិតដែលមានអំពើលើប្រអប់និងមានទិសដៅថយក្រោយមានបរិមាណកម្លាំងតូច។



*ចម្លើយ ឃ ត្រឹមត្រូវ។ កម្លាំងដែលកើតពីមនុស្សមានអំពើទៅលើប្រអប់ស្មើគ្នានឹងកម្លាំងដែលប្រអប់មានអំពើមកលើមនុស្សវិញ។ មនុស្សផ្លាស់ទីទៅមុខដោយសារកម្លាំងកកិតមានទិសដៅទៅមុខដែលកើតឡើងពីកម្រាលផ្ទះ។ កម្លាំងកកិតបង្កើតដោយកម្រាលផ្ទះមានអំពើទៅលើប្រអប់តូចជាងនេះច្រើនដង។*

## ឧទាហរណ៍ទី12: សន្ទនីយ៍ស្តាទិច

កម្មវិធីសិក្សាមុខវិជ្ជារូបវិទ្យា:

ថ្នាក់ទី7 ជំពូកទី4 មេរៀនទី3 ( ឆ្នាំ2009 )

បើគេចោះរន្ធមួយនៅចំហៀងឧបករណ៍ផ្ទុកទឹកមួយ ទឹកហូរចេញតាមគន្លងមួយមានរាងជាប៉ារ៉ាបូល។ តើនឹងមានអ្វីកើតឡើងចំពោះរំហូរនៃទឹក ប្រសិនបើឧបករណ៍ផ្ទុកនោះត្រូវបានគេទម្លាក់ដោយទន្លាក់សេរី? តើអ្នកយល់ថាយ៉ាងដូចម្តេច?

ក. រំហូរនៃទឹកថយចុះ។
ខ. ទឹកឈប់ហូរចេញពីឧបករណ៍ផ្ទុក។
គ. ទឹកហូរចេញជាបន្ទាត់ត្រង់។
ឃ. ទឹកហូរកោងឡើងលើ។
ង. ទឹកហូរចេញកាន់តែលឿន។

*ចម្លើយ ខ ត្រឹមត្រូវ។ពេលដែលឧបករណ៍ផ្ទុកនៅនឹងថ្កល់ មានសម្ពាធទៅលើផ្ទៃនៃឧបករណ៍ផ្ទុក ដោយសារទឹក។សម្ពាធអាស្រ័យនឹងជម្រៅទឹកហើយស្មើនឹង p.g.h ដែល p ជាដង់ស៊ីតេទឹក។ ពេលដែលឧបករណ៍ផ្ទុកមានចលនាទន្លាក់សេរីទាំងឧបករណ៍ផ្ទុកនឹងទឹកមានសំទុះស្មើសូន្យ មិនមែន g នៅក្នុងតំរុយឧបករណ៍ផ្ទុកទេ។ នៅក្នុងតំរុយនេះសម្ពាធនៃទឹកទៅលើផ្ទៃនៃឧបករណ៍ផ្ទុកស្មើសូន្យ ដូចនេះមិនមានទឹកហូរចេញទេ។*

## ឧទាហរណ៍ទី13: អគ្គិសនី

កម្មវិធីសិក្សាមុខវិជ្ជារូបវិទ្យា:

ថ្នាក់ទី7 ជំពូកទី3 មេរៀនទី6 ( ឆ្នាំ2009 )

អំពូលភ្លើងមូលទាំងបីនៅក្នុងសៀគ្វីមានរេស៊ីស្តង់ស្មើគ្នា។ ដោយភាពភ្លឺសមាមាត្រនឹងថាមពលដែលបាត់បង់ ភាពភ្លឺនៃអំពូល B និង C រួមគ្នា ប្រៀបធៀបនឹងអំពូល A គឺ:

ក. ភ្លឺជាង2ដង
ខ. ភ្លឺស្មើគ្នា
គ. ភ្លឺខ្សោយជាង2ដង

*ចម្លើយ គ ត្រឹមត្រូវ។ផលសងប៉ូតង់ស្យែលនៃអំពូល B និង C តជាស៊េរីស្មើនឹងផលសងប៉ូតង់ស្យែលនៃអំពូល A។ដោយថាមពលដែលបាត់បង់នៅក្នុងរ៉េស៊ីស្តរនៃរ៉េស៊ីស្តង់ R គឺ V2/R ដែល V គឺជាផលសងប៉ូតង់ស្យែលនៃរ៉េស៊ីស្តរ ថាមពលដែលប្រើប្រាស់ដោយបង្គុំស៊េរីស្មើនឹងពាក់កណ្តាលនៃថាមពលដែលប្រើប្រាស់ដោយរ៉េស៊ីស្តរនៃអំពូល A។*

## ឧទាហរណ៍ទី14: បម្រែបម្រួលភាពរូប

កម្មវិធីសិក្សាមុខវិជ្ជារូបវិទ្យា:

ថ្នាក់ទី7 ជំពូកទី2 មេរៀនទី1 ( ឆ្នាំ2009 )

ដាក់ទឹកកក5ដុំចូលក្នុងកែវមួយ។ ក្រោយរយៈពេល20នាទី ទឹកកកមួយភាគធំរលាយបង្កើតបានជាទឹកត្រជាក់។ យើងឃើញនៅសល់ដុំទឹកកកតូចៗអណ្តែតក្នុងទឹកនោះ។ វាស់ សីតុណ្ហភាពនៃទឹកត្រជាក់នេះ បន្ទាប់មកថែមទឹកកក5ដុំចូលទៅក្នុងកែវខាងលើទៀត។ 3នាទីក្រោយមក វាស់សីតុណ្ហភាពទឹកម្តងទៀត:

ក. សីតុណ្ហភាពនៃទឹកត្រជាក់នេះកើនឡើង
ខ. សីតុណ្ហភាពនៃទឹកត្រជាក់នេះថយចុះ
គ. សីតុណ្ហភាពនៃទឹកត្រជាក់នេះមិនប្រែប្រួលទេ

*ចម្លើយ គ ត្រឹមត្រូវ។សីតុណ្ហភាពនៃទឹកត្រជាក់នេះ រក្សានៅដដែល។ ពេលគេដាក់ទឹកកកមួយដុំមានសីតុណ្ហភាព -4ºC ទៅក្នុងពែងមួយនៅសីតុណ្ហភាពបន្ទប់ ផ្ទៃនៃដុំទឹកកកនេះស្រូបថាមពលកម្តៅពីមជ្ឈដ្ឋាន។ ថាមពលនេះត្រូវបានប្រើប្រាស់ដើម្បីយកឈ្នះលើកម្លាំងទំនាញរវាងម៉ូលេគុលទឹក។ ពេលស្រូបបានថាមពលគ្រប់គ្រាន់ ដុំទឹកកកចាប់ផ្តើមរលាយ។ ចំពោះទឹក បម្រែបម្រួលបែបនេះកើតមាននៅសីតុណ្ហភាព0ºC។ នៅក្នុងអំឡុងពេលបម្រែបម្រួលភាពរូប សីតុណ្ហភាពនឹងរក្សានៅតម្លៃថេរដរាបណាភាពរូបទាំងពីរនៅមានវត្តមាននៅឡើយ។ សីតុណ្ហភាពកម្តៅ និងថាមពលកម្តៅមានទំនាក់ទំនងគ្នា ប៉ុន្តែជាពាក្យខុសគ្នាដែលងាយឱ្យសិស្សភាន់ច្រឡំ។ គប្បីមានបម្រុងប្រយ័ត្នក្នុងការញែកសម្គាល់ពាក្យទាំងបីនេះឱ្យបានត្រឹមត្រូវ។*















## ឧទាហរណ៍ទី15: មេកានិច

កម្មវិធីសិក្សាមុខវិជ្ជារូបវិទ្យា:
ថ្នាក់ទី8 ជំពូកទី1 មេរៀនទី1&2 ( ឆ្នាំ2010 )

រថយន្តពីរដែលមួយមានទម្ងន់ធ្ងន់ជាងរថយន្តមួយទៀតទ្វេដង កំពុងស្ថិតនៅនឹងថ្កល់លើផ្លូវរាបមួយ ។ មនុស្សម្នាក់រុញរថយន្តទាំងពីររយៈពេលប្រាំវិនាទី។ ដោយមិនគិតកម្លាំងកកិត ហើយសន្មតថាកម្លាំងដែលមានអំពើទៅលើរថយន្តទាំងពីរស្មើគ្នា។ បរិមាណចលនានៃរថយន្តស្រាល បន្ទាប់ពីការរុញគឺ:



ក. តូចជាង
ខ. ស្មើនឹង
គ. ធំជាង

បរិមាណចលនានៃរថយន្តធ្ងន់។



ចម្លើយដែលត្រឹមត្រូវគឺចម្លើយ ខ។ បម្រែបម្រួលបរិមាណចលនាដែលបង្កើតដោយកម្លាំងថេរជាផលគុណរវាងកម្លាំងនិងថេរវេលា ($\Delta p = F. \Delta t$)។ ព្រោះថេរវេលា និងកម្លាំងដូចគ្នាចំពោះ រថយន្តទាំងពីរ បម្រែបម្រួលបរិមាណចលនាក៏ស្មើគ្នាដែរ។

## ឧទាហរណ៍ទី16: មេកានិច



កម្មវិធីសិក្សាមុខវិជ្ជារូបវិទ្យា:
ថ្នាក់ទី8 ជំពូកទី1 មេរៀនទី1&2 ( ឆ្នាំ2010 )

រថយន្តពីរដែលមួយមានទម្ងន់ធ្ងន់ជាងរថយន្តមួយទៀតទ្វេដង កំពុងស្ថិតនៅនឹងថ្កល់លើផ្លូវរាបមួយ ។ មនុស្សម្នាក់រុញរថយន្តទាំងពីររយៈពេលប្រាំវិនាទី។ ដោយមិនគិតកម្លាំងកកិត ហើយសន្មតថាកម្លាំងដែលមានអំពើទៅលើរថយន្តទាំងពីរស្មើគ្នា។ ថាមពលស៊ីនេទិចនៃរថយន្តស្រាល បន្ទាប់ពីការរុញគឺ:



ក. តូចជាង
ខ. ស្មើនឹង
គ. ធំជាង

ថាមពលស៊ីនេទិចនៃរថយន្តធ្ងន់។

ចម្លើយដែលត្រឹមត្រូវគឺចម្លើយ គ។ ដោយសារបរិមាណចលនារបស់រថយន្តទាំងពីរស្មើគ្នា រថយន្តដែលមានល្បឿនលឿនជាង ត្រូវមានថាមពលស៊ីនេទិចធំជាង។ នោះគឺរថយន្តស្រាល ព្រោះវាមាននិចលភាពតិចជាង វាមានសំទុះធំជាងសំទុះរថយន្តធ្ងន់។

## ឧទាហរណ៍ទី17: កើតផ្តាសាយ

កម្មវិធីសិក្សាមុខវិជ្ជាជីវវិទ្យា:
ថ្នាក់ទី9 ជំពូកទី4 មេរៀនទី2 ( ឆ្នាំ2011 )

សិស្សបួននាក់ពិភាក្សាគ្នាអំពីដើមហេតុដែលនាំឱ្យកើតផ្តាសាយ ( គ្រុន )។ ពួកគេគិតថា:

ក. អ្នកអាចកើតផ្តាសាយពេលដែលអ្នកគ្រុនក្តៅ។
ខ. អ្នកអាចកើតផ្តាសាយពេលដែលស្ថិតក្នុងស្ថានភាពត្រជាក់និងសើម។
គ. ជម្ងឺផ្តាសាយបង្កដោយមេរោគ (វីរុស)។
ឃ. ការគេងមិនបានគ្រប់គ្រាន់បណ្តាលឱ្យអ្នកកើតផ្តាសាយ។

*ចម្លើយ គ ត្រឹមត្រូវ។វីរុសនិងបាក់តេរីជាភ្នាក់ងារចម្លងជំងឺ។ គ្រុនក្តៅគឺជាការឆ្លើយតបនៃសារពាង្គកាយទៅនឹងជំងឺឆ្លង។ ស្ថិតក្នុងស្ថានភាពត្រជាក់និងសើម ឬការគេងមិនគ្រប់គ្រាន់ធ្វើឱ្យ ប្រព័ន្ធការពាររាងកាយចុះខ្សោយ ជាហេតុនាំឱ្យវីរុសងាយឆ្លងចូលក្នុងសារពាង្គកាយ។*



## 7. ដំបូន្មានសំខាន់ៗ



### តើអ្នកអាចបង្កើតតេស្តគំនិតដោយខ្លួនឯងយ៉ាងដូចម្តេច ?

មិនមានក្បួនច្បាប់ណាមួយជាក់លាក់សម្រាប់បង្កើតតេស្តគំនិតនោះទេ ប៉ុន្តែមានល័ក្ខខ័ណ្ឌមួយចំនួនដែលត្រូវបំពេញ:

- ផ្តោតទៅលើបញ្ញត្តិវិទ្យាសាស្ត្រតែមួយ។ បើមិនដូច្នោះទេ នឹងមានការលំបាកក្នុងការបកស្រាយចម្លើយដែលមិនត្រឹមត្រូវ។
- សំណួរមិនគួរពឹងផ្អែកតែទៅលើសមីការឬមេរៀនទន្ទេញដូចជាតួលេខឡើយ។
- ចម្លើយផ្សេងៗគួរតែឆ្លុះបញ្ចាំងពីគំនិតភាន់ច្រឡំដែលសិស្សតែងតែមាន។
- សំណួរគួរតែរៀបចំដោយប្រើពាក្យពេចន៍មិនច្បាស់លាស់។
- សំណួរមិនគួរមានភាពងាយស្រួលពេកឬពិបាកពេក (ជាទូទៅបើសិស្សជ្រើសរើសចម្លើយត្រឹមត្រូវស្ថិតនៅចន្លោះ40% និង80% បញ្ជាក់ពីកម្រិតពិបាកដ៏ត្រឹមត្រូវ)

ជាទូទៅ គ្រូមានការលំបាកក្នុងការកំណត់គំនិតយល់ច្រឡំរបស់សិស្សដោយមិនមានការផ្តល់ចម្លើយរបស់សិស្ស។ គ្រូអាចទទួលបានព័ត៌មានពីប្រភពទាំងឡាយខាងក្រោម:

- លទ្ធផលបោះឆ្នោត។ ក្រុមចម្លើយដែលមិនធ្លាប់ត្រូវបានជ្រើសរើសគួរកែតម្រូវឬលុបចោល។
- ការពិភាក្សាជាក្រុមអាចសម្តែងចេញនូវគំនិតភាន់ច្រឡំ។
- ចម្លើយខុសដែលច្រើនលេចឡើងក្នុងការប្រឡងអាចយកមកប្រើក្នុងតេស្តគំនិតបាន។
- តេស្តគំនិតជាច្រើនត្រូវបានផ្សព្វផ្សាយនៅក្នុងបណ្តាញអ៊ីនធើណែត។ តេស្តគំនិតទាំងនោះជាចំណុចផ្តើមដ៏ល្អ ប៉ុន្តែគប្បីប្រើប្រភពព័ត៌មានខាងលើជាប់ជានិច្ចដើម្បីឆ្លុះបញ្ចាំងគំនិតភាន់ច្រឡំក្នុងថ្នាក់រៀនរបស់អ្នក។ គេហទំព័រមួយចំនួនក្នុងបណ្តាញអ៊ីនធើណែតត្រូវបានបញ្ចូលក្នុងឧបសម្ពន្ធ។
- ចម្លើយនៅខាងចុងមេរៀនក្នុងសៀវភៅសិក្សាជាច្រើន។

### តើគួរបកស្រាយលទ្ធផលតេស្តគំនិតដោយរបៀបណា ?

អ្នកអាចប្រើលទ្ធផលតេស្តគំនិតដើម្បីវាយតម្លៃលំនាំនៃការបង្រៀនរបស់អ្នកបាន។ ឧទាហរណ៍ បន្ទាប់ពីទទួលបានពិន្ទុទាបពីតេស្តគំនិតមួយអំពីច្បាប់ញូតុន អ្នកអាចនឹងសម្រេចចិត្តចំណាយពេលវេលាបន្ថែមទៀតដើម្បីបង្រៀនមេរៀននេះនៅឆ្នាំសិក្សាក្រោយ បន្ថែមពិសោធន៍មួយទៀត ឬធ្វើលំហាត់បន្ថែមទៀត។

## 1. ឧបសម្ពន្ធ: បង្កើតតេស្តគំនិតដោយខ្លួនឯង

អ្នកអាចដាក់កិច្ចការឱ្យសិស្សទាំងអស់គ្នា ដូចជាធ្វើព្យុះគំនិតដើម្បីបង្កើតចម្លើយឱ្យបានច្រើន។

ឧទាហរណ៍ អ្នកអាចដាក់កិច្ចការឱ្យសិស្សរកវត្ថុបីដែលគេគិតថាជាអាហាររបស់រុក្ខជាតិ។ ចូរប្រើចម្លើយមិនត្រឹមត្រូវដើម្បីបង្កើតជាតេស្តគំនិតមួយ។

ជាធម្មតាចម្លើយមានដូចជាពន្លឺព្រះអាទិត្យ ស្ករ កាបូនឌីអុកស៊ីត រ៉ែ ជី ដី ទឹក អុកស៊ីសែន វីតាមីន។ល។ ផ្សំចម្លើយ 5 ឬ 6 ដែលសិស្សនិយមឆ្លើយដើម្បីបង្កើតជាតេស្តគំនិតមួយ។

*ចម្លើយដែលត្រឹមត្រូវគឺស្ករ។ និយមន័យវិទ្យាសាស្ត្រនៃអាហារគឺជាសារធាតុសរីរាង្គដែលមានផ្ទុកកាបូអ៊ីដ្រាត ប្រូតេអ៊ីននិង/ឬខ្លាញ់ដែលបំពេញ តួនាទីជាឥន្ធនៈ និងសារធាតុសម្រាប់សាងសង់សារពាង្គកាយមួយ។ សារធាតុចិញ្ចឹមគឺជាសារធាតុសរីរាង្គឬអសរីរាង្គដែលសារពាង្គកាយត្រូវការដើម្បីរស់រានមានជីវិត។ ឧទាហរណ៍រួមមានទឹក វីតាមីននិងអំបិល។ យ៉ាងណាមិញ សារធាតុចិញ្ចឹមមិនមែនជាប្រភពថាមពលទេ ក៏មិនត្រូវបានប្រើប្រាស់ជាធាតុដែលមាននាទីបឋមសម្រាប់សាងសង់សារពាង្គកាយដែរ។ រុក្ខជាតិអាចផលិតអាហារដោយខ្លួនឯងបានពីទឹក និងកាបូនឌីអុកស៊ីតដោយប្រើថាមពលពីព្រះអាទិត្យ (រស្មីសំយោគ)។*

ឧទាហរណ៍ទី8 អំពីប្រព័ន្ធប្រសាទជាលទ្ធផលនៃសំណួរប្រឡងដែលគ្រូដាក់ឱ្យសិស្សធ្វើ។ គាត់បានកត់សម្គាល់ឃើញថាសិស្សភ្ជាប់តួនាទីខួរក្បាលតែទៅនឹងសកម្មភាពដោយចេតនា តែមិនគិតថាជាសកម្មភាពដែលកើតឡើងដោយមិនដឹងខ្លួនដូចជាពេលដេកលក់ឬការក្អកទេ។















## ឧទាហរណ៍សម្រាប់មុខវិជ្ជាផែនដី និងបរិស្ថានវិទ្យា:

រយៈពេលមួយថ្ងៃនៅលើភពសៅរ៍ស្មើនឹងប្រហែល10ម៉ោងនៃផែនដី។ តើអ្នកនឹងពន្យល់យ៉ាងដូចម្តេច ?ចម្លើយអាចមានដូចជា: ភពសៅរ៍មានដង់ស៊ីតេតូចជាងផែនដី ភពសៅរ៍ស្ថិតនៅឆ្ងាយពីព្រះអាទិត្យជាងផែនដី ភពសៅរ៍វិលជុំវិញខ្លួនឯងលឿនជាងផែនដី និងគន្លងរបស់ភពសៅរ៍មានភាពជាអេលីបជាងគន្លងរបស់ផែនដី។



*ចម្លើយដែលត្រឹមត្រូវគឺចម្លើយទី3។ថេរវេលានៃរយៈពេលមួយថ្ងៃគឺគ្រាន់តែកំណត់ដោយរយៈពេលនៃមួយរង្វិលខ្វាល់ជុំវិញអ័ក្សរង្វិលរបស់ភពនោះ។*

## ឧទាហរណ៍សម្រាប់មុខវិជ្ជារូបវិទ្យា:



ចូរស្រមៃថាសិស្សបោះបាល់មួយឡើងលើ។ សូមឱ្យពួកគេគូសវ៉ិចទ័រកម្លាំងនៅលើបាល់ ពេលដែលវាត្រូវបានគេបោះឡើងលើ ពេលវាឡើងដល់ចំណុចខ្ពស់បំផុត និងពេលដែលវាធ្លាក់ចុះ។ អ្នកអាចរកឃើញថាសិស្សជាច្រើនច្រឡំកម្លាំងនិងបរិមាណចលនា ហើយគូសវ៉ិចទ័រកម្លាំងពីរ មួយឡើងលើ មួយចុះក្រោម។ តាមការពិត មានតែកម្លាំងទំនាញផែនដីប៉ុណ្ណោះដែលមានអំពើទៅលើបាល់ពេលដែលវាត្រូវគេបោះឡើង។



បើគ្រូទទួលបានចម្លើយច្រើនចំពោះសំណួរនេះនៅពេលប្រឡងគ្រូអាចនឹងបង្កើតតេស្តគំនិត ឬសូម្បីតែតុក្កតាគំនិតក៏បានដែរ។







## 2. ឧបសម្ពន្ធ: បណ្ណសម្រាប់បោះឆ្នោតរើសចម្លើយ

| | | | |
|---|---|---|---|
| ក | គ | ង | ឆ |
| ខ | ឃ | ច | ជ |







ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ
# តាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល

ជំពូកទី 5

# ការប្រៀបប្រដូចនិងគំរូតាង







នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ 2012

# សេចក្ដីផ្ដើម













ការប្រៀបប្រដូចគឺជាទំនាក់ទំនងភាសារវាងវត្ថុពីរ ដែលហាក់ដូចជាមិនជាប់ទាក់ទងគ្នា។ ក្នុងការអប់រំការប្រៀបប្រដូចជានិច្ចកាលជាការភ្ជាប់ទំនាក់ទំនងរវាងបញ្ញត្តិថ្មីដែលសិស្សមិនធ្លាប់ដឹងទៅនឹងវត្ថុដែលសិស្សធ្លាប់ដឹងធ្លាប់ស្គាល់រួចមកហើយ។ ការភ្ជាប់ទំនាក់ទំនងប្រភេទនេះមានសារសំខាន់ណាស់សម្រាប់ការអប់រំវិទ្យាសាស្ត្រព្រោះមានចំណេះដឹងជាច្រើនដែលសិស្សមិនធ្លាប់បានជួបប្រទះដូចជា សែន ថាមពល និងអាតូមជាដើម។

ក្រៅពីអត្ថប្រយោជន៍ ក្នុងការពន្យល់បញ្ញត្តិពិបាកៗបានច្បាស់លាស់ ការប្រៀបប្រដូចក៏បំផុសបំណិនគិតកម្រិតខ្ពស់មួយចំនួនដូចជាបំណិនដោះស្រាយបញ្ហា និងការគិតប្រកបដោយភាពច្នៃប្រឌិតផងដែរ។ ការប្រៀបប្រដូចបង្កើតបរិយាកាសសប្បាយរីករាយក្នុងថ្នាក់រៀន ដែលជំរុញទឹកចិត្តសិស្សឱ្យចង់សិក្សា។

ការអនុវត្តន៍ការប្រៀបប្រដូចទទួលបានលទ្ធផលល្អបំផុតជាមួយការសិក្សារបស់សិស្ស ពេលដែលសិស្សត្រូវបានទាក់ទាញឱ្យចូលរួមពិភាក្សា ហើយបើកាន់តែប្រសើរជាងនេះទៅទៀត នោះគឺពេលដែលសិស្សអាចបង្កើតការប្រៀបប្រដូចបានដោយខ្លួនឯង។ យើងមិនគួរចាត់ទុកការប្រៀបប្រដូចត្រឹមតែជាការប្រៀបធៀបវត្ថុ 2ប៉ុណ្ណោះទេ ប៉ុន្តែគឺជាឱកាសដើម្បីពិភាក្សាឱ្យបានស៊ីជម្រៅអំពីបញ្ញត្តិផ្សេងៗ។

ជួនកាល ការប្រៀបប្រដូចប្រៀបបាននឹងអាវុធមុខពីរ។ បើតាមន័យវិជ្ជមាន ការប្រៀបប្រដូចផ្ដល់ឱកាសច្រើនសម្រាប់ការសិក្សាបែបសិស្សមជ្ឈមណ្ឌល។ ផ្ទុយទៅវិញប្រសិនបើមិនបានប្រើដោយប្រុងប្រយ័ត្នទេ ការប្រៀបប្រដូចអាចបង្កើតគំនិតភាន់ច្រឡំថ្មី ឬធ្វើឱ្យការភាន់ច្រឡំដែលមានស្រាប់កាន់តែភាន់ច្រឡំខ្លាំងឡើង។ គ្រប់ការប្រៀបប្រដូចទាំងអស់មានបញ្ហាត្រង់ចំណុចមួយ គឺចំណុចដែលការប្រៀបប្រដូចមិនអាចប្រើជាតំណាងនៃបញ្ញត្តិដែលយើងចង់ឱ្យសិស្សយល់។ គ្រូគួរប្រាប់ចំណុចនេះឱ្យសិស្សបានដឹងច្បាស់។ ឧទាហរណ៍ ពេលដែលគ្រូប្រៀបធៀបអង្គធាតុរឹងទៅនឹងសិស្សម្នាក់ដែលអង្គុយនៅតុរបស់គេក្នុងថ្នាក់ ហើយប្រៀបធៀបអង្គធាតុរាវទៅនឹងសិស្សដែលកំពុងធ្វើសកម្មភាពជាក្រុមនៅក្នុងថ្នាក់ សិស្សអាចទាញសន្និដ្ឋានច្រឡំថាភាគល្អិតនៃអាតូមប្រៀបបាននឹងភាវរស់តូចៗដែលមានសកម្មភាពដោយចេតនា។















# សេចក្តីផ្តើម



ឯកសារនេះបង្ហាញនូវការប្រៀបប្រដូចមួយចំនួនសម្រាប់ប្រើក្នុងមេរៀនជាច្រើននៃមុខវិជ្ជាវិទ្យាសាស្ត្រនីមួយៗ។ ក្រៅពីនេះ ឯកសារនេះក៏ប្រាប់វិធីដែលមានប្រសិទ្ធិភាព ប្រកបដោយភាពច្នៃប្រឌិត និងមានលក្ខណៈគោលវិធីសិស្សមជ្ឈមណ្ឌលសម្រាប់អនុវត្តការប្រៀបប្រដូចក្នុងការបង្រៀនរបស់អ្នក។ យ៉ាងណាមិញ សូមចាត់ទុកការប្រៀបប្រដូចទាំងនេះត្រឹមជាចំណុចចាប់ផ្តើមប៉ុណ្ណោះ។ សូមជួយកែសម្រួលឱ្យសមស្របនឹងការប្រើប្រាស់ជាក់ស្តែង និងធ្វើឱ្យឯកសារនេះកាន់តែប្រសើរឡើង។ អ្នកអាចធ្វើឱ្យកាន់តែប្រសើរជាងនេះទៅទៀត ដោយផ្តល់ឱកាសឱ្យសិស្សរបស់អ្នកបង្កើតការប្រៀបប្រដូចដោយខ្លួនឯង។

ដូចដែលបានរៀបរាប់ខាងលើសិស្សកាន់តែចូលរួមគិតនិងបង្កើតការប្រៀបប្រដូចបានសកម្មកម្រិតណា ការប្រៀបប្រដូចរបស់អ្នកក៏កាន់តែមានប្រសិទ្ធភាពកម្រិតនោះដែរ។





# សកម្មភាពសម្ដែងតួ

## សេចក្ដីផ្ដើម



ការសម្ដែងតួគឺជាការប្រៀបប្រដូចដ៏ពិសេសដែលជួយសិស្សឱ្យចេះប្រើរូបារម្មណ៍និងយល់បញ្ញត្តិពិបាកៗ។ បើសិស្សចូលរួមក្នុងការពន្យល់និងសម្ដែងតួកាន់តែសកម្ម ពួកគេកាន់តែងាយនឹងទទួលយកនូវចំណេះដឹងដែលគ្រូផ្ទេរឱ្យពួកគេ។ មិនតែប៉ុណ្ណោះ ភាពរីករាយដែលកើតមានក្នុងការសម្ដែងតួ បង្កើនការចងចាំរបស់សិស្សអំពីមេរៀនដែលទើបតែសិក្សា។



## វត្ថុបំណង



- សិក្សាបែបអរូបីអំពីអ្វីដែលគេដឹងជុំវិញបញ្ញត្តិមួយ
- ភ្ជាប់ចំណេះដឹងមានស្រាប់ជាមួយបញ្ញត្តិថ្មីៗប្រកបដោយលក្ខណៈច្នៃប្រឌិត
- សហការគ្នានិងពង្រឹងការយល់ដឹង
- ចូលរួមកាន់តែសកម្ម

## ដំណើរការ



លំដាប់លំដោយនៃជំហានក្នុងការអនុវត្តសកម្មភាពនេះប្រែប្រួលទៅតាមមេរៀន។ បញ្ជីរាយឈ្មោះការប្រៀបប្រដូចនៅខាងក្រោយឯកសារនេះ ផ្ដល់នូវគំនិតជាច្រើនសម្រាប់ការសម្ដែងតួ។ ជាទូទៅ អ្នកអាចអនុវត្តតាមជំហានដូចខាងក្រោម:

1. ចែកសិស្សជាក្រុមតូចៗ អាស្រ័យលើសាច់រឿង។ ជួនកាលក្រុមនីមួយៗ នឹងត្រូវ សម្ដែងសាច់រឿងតែមួយ ជួនកាលត្រូវសម្ដែងផ្នែកផ្សេងៗគ្នា ឧទាហរណ៍ដូចជាក្នុងលំនាំចំណែកកោសិកា( មុខវិជ្ជាជីវវិទ្យា )។
2. គ្រូពន្យល់អំពីគំនិតទូទៅ ប៉ុន្តែមិនពន្យល់លម្អិតទេ។
3. សិស្សសហការតាមក្រុមនីមួយៗដើម្បីបែងចែកតួនាទីសម្ដែងនិងកសាងសាច់រឿង។ ពួកគេកត់ត្រាសាច់រឿងរបស់ខ្លួន។
4. ក្រុមនីមួយៗសម្ដែងសាច់រឿងរបស់ពួកគេឱ្យសិស្សក្រុមផ្សេងៗទៀតទស្សនា។
5. សិស្សទាំងអស់គ្នាចូលរួមវាយតម្លៃការសម្ដែងនីមួយៗ ដោយពិភាក្សាអំពីចំណុចត្រឹមត្រូវនិងកំហុសឆ្គងក្នុងការសម្ដែងព្រមទាំងវិធីកែលម្អ។ ជួនកាលគេអាចត្រូវបន្ថែមសកម្មភាពឬធាតុផ្សេងៗទៅក្នុងការសម្ដែងដើម្បីពង្រឹងទំនាក់ទំនងរវាងបញ្ញត្តិនិងវត្ថុប្រដូច។

## សម្ភារ



តម្រូវការសម្ភារ អាស្រ័យលើស្ថានភាព។ ជានិច្ចកាល មានត្រឹមក្រដាសនិងប៊ិចគឺគ្រប់គ្រាន់ហើយ។

















## ពេលវេលា



- គ្រូអាចប្រើប្រាស់វិធីសម្តែងតួដើម្បីពង្រឹងការយល់ដឹងរបស់សិស្ស អំពីមេរៀន (ក្នុងជំហានទី3)។
- គ្រូអាចប្រើប្រាស់សកម្មភាពនេះដើម្បីពន្យល់អំពីបញ្ញត្តិដែលពិបាក និងអរូបី (ក្នុងជំហានទី3)។
- គ្រូអាចប្រើប្រាស់សកម្មភាពនេះដើម្បីរំឭកមេរៀនឡើងវិញក្រោយពេលបង្រៀនចប់មេរៀនមួយចំនួនដែលទាក់ទងគ្នា ឬនៅចុងឆមាស (ក្នុងជំហានទី4)។

## កម្មវិធីសិក្សា



ឧទាហរណ៍នៃការប្រៀបប្រដូចមួយចំនួនដែលសមស្របសម្រាប់សកម្មភាពសម្តែងតួត្រូវបានបញ្ចូលក្នុងឧបសម្ពន្ធ។ ឧទាហរណ៍ដែលមិនមាននៅក្នុងឧបសម្ពន្ធមានដូចខាងក្រោមៈ

### ជីវវិទ្យា



- មុខងារនិងរូបផ្គុំនៃភ្នាសកោសិកា (ថ្នាក់ទី7 ជំពូកទី3 ឆ្នាំ2009)
- ចំណែកកោសិកាៈ មីតូសនិងមេយ៉ូស
  ថ្នាក់ទី7 ជំពូកទី3 មេរៀនទី1 (ឆ្នាំ2009)
  ថ្នាក់ទី11 ជំពូកទី1 មេរៀនទី3 (ឆ្នាំ2009)
  ថ្នាក់ទី11 ជំពូកទី2 មេរៀនទី1 (ឆ្នាំ2009)
- ប្រដាប់រំលាយអាហារ ថ្នាក់ទី11 ជំពូកទី2 មេរៀនទី1 (ឆ្នាំ2009)

### គីមីវិទ្យា

- ប្រតិកម្មគីមីនៅក្នុងអគ្គិសនីវិភាគ
  ថ្នាក់ទី11 ជំពូកទី3 មេរៀនទី5 (ឆ្នាំ2009)

### ផែនដី និងបរិស្ថានវិទ្យា

- សូរ្យគ្រាសនិងចន្ទគ្រាស ថ្នាក់ទី8 ជំពូកទី3 មេរៀនទី3(ឆ្នាំ2010)
- ជំនោរសមុទ្រ ថ្នាក់ទី8 ជំពូកទី3 មេរៀនទី4 (ឆ្នាំ2010)
- ផលផ្ទះកញ្ចក់ៈ ហេតុអ្វីបានជាភពសុក្រមានកម្តៅក្តៅជាងផែនដីច្រើនដង? ថ្នាក់ទី9 ជំពូកទី3 មេរៀនទី3 (ឆ្នាំ2011)
- មុខងារនៃស្រទាប់អូសូន។ ប្រហោងនៃស្រទាប់អូសូន។ ថ្នាក់ទី12 ជំពូកទី4 មេរៀនទី8 (ឆ្នាំ2011)



### រូបវិទ្យា

- ប្រតិកម្មបង្កុំនិងបំបែកនុយក្លេអ៊ែរ ថ្នាក់ទី12 ជំពូកទី4 មេរៀនទី3 (ឆ្នាំ2011)
- សៀគ្វីអគ្គិសនី ថ្នាក់ទី7 ជំពូកទី3 មេរៀនទី6 (ឆ្នាំ2009)



## 1. ការសម្តែងតួអំពីជំនោរសមុទ្រ

កម្មវិធីសិក្សាៈ ថ្នាក់ទី៨ ជំពូកទី3 មេរៀនទី4 (ឆ្នាំ2010)

ជំនោរសមុទ្រគឺជាបាតុភូតដ៏ពិបាកយល់សម្រាប់សិស្ស។ ការសម្តែងតួអាចជួយឱ្យសិស្សយល់ពីឥទ្ធិពលនៃព្រះអាទិត្យនិងព្រះចន្ទដែលបង្កើតឱ្យមានជំនោរនិងលំនាចនៅលើផែនដី។

នៅពេលសម្តែងតួអំពីជំនោរនិងលំនាចសិស្សចាំបាច់ត្រូវរំឭកចំនុចផ្សេងៗមួយចំនួនអំពីព្រះអាទិត្យនិងព្រះចន្ទដូចជាៈ

- ព្រះចន្ទវិលជុំវិញផែនដីមួយជុំប្រើរយៈពេល 28ថ្ងៃ។
- ផែនដីវិលជុំវិញព្រះអាទិត្យមួយជុំប្រើរយៈពេលមួយឆ្នាំ។
- រង្វិលជុំនិងរង្វិលខ្វាល់របស់ព្រះចន្ទប្រើពេលស្មើគ្នា។ ហេតុនេះហើយទើបយើងមើលឃើញតែផ្នែកម្ខាងរបស់ព្រះចន្ទ។
- ព្រះចន្ទនៅជិតផែនដីជាងព្រះអាទិត្យ។



| ចំណុចដូចគ្នា (ចំណុចដូចគ្នារវាងវត្ថុប្រដូចនិងបញ្ញត្តិ) | |
|---|---|
| សិស្សបីនាក់ | ព្រះអាទិត្យ ផែនដីនិងព្រះចន្ទ |
| សិស្សម្នាក់ៗវិលជុំវិញខ្លួនឯងនិងវិលជុំវិញសិស្សម្នាក់ផ្សេងទៀត | ព្រះចន្ទ ព្រះអាទិត្យនិងផែនដីធ្វើរង្វិលជុំនិង/ឬរង្វិលខ្វាល់ |
| សិស្សទាញដៃគ្នាទៅវិញទៅមក | កម្លាំងទំនាញរវាងអង្គទាំងបី |
| សិស្សតំណាងផែនដីលាដៃទាំងពីរចេញទៅឆ្វេងនិងទៅស្តាំ | ជំនោរនៅផ្នែកទាំងពីរនៃផែនដី |
| សិស្សតំណាងផែនដីលាដៃទាំងពីរចេញឱ្យអស់ទៅឆ្វេងនិងទៅស្តាំ | ជំនោររួមនៅផ្នែកទាំងពីរនៃផែនដី |
| ទិសដៅផ្សេងទៀត (ខាងមុខនិងខាងខ្នងដែលមិនមានលាដៃ) | លំនាចនៅផ្នែកទាំងពីរនៃផែនដី |
| **ចំណុចមិនដូច (ចំណុចខុសគ្នារវាងវត្ថុប្រដូចនិងបញ្ញត្តិ)** | |
| ព្រះចន្ទនៅជិតផែនដីជាងព្រះអាទិត្យ 400ដង | |
| ព្រះអាទិត្យធំជាងព្រះចន្ទប្រហែល 400ដង | |


















## 2. ការសម្តែងតួតំណាងប្រតិកម្មគីមី

កម្មវិធីសិក្សា: ប្រតិកម្មគីមី អគ្គិសនីវិភាគ ថ្នាក់ទី11 ជំពូកទី3 មេរៀនទី5 (ឆ្នាំ2009)

គេអាចប្រឌិតរូបភាពតំណាងប្រតិកម្មគីមីតាមវិធីមួយដែលប្រកបដោយភាពសប្បាយរីករាយគឺការសម្តែងតួ។ ឧទាហរណ៍មួយគឺយោបកលោហៈទង់ដែងពីទង់ដែងកាបូណាតដែលពាក់ព័ន្ធនឹងអគ្គិសនីវិភាគទង់ដែងស៊ុលផាត។ លំនាំនេះមាន3ជំហាន:

- ការរលាយនៃទង់ដែងកាបូណាត
- ការកកើតនៃទង់ដែងស៊ុលផាត
- អគ្គិសនីវិភាគទង់ដែងស៊ុលផាត




ឯកសារយោង: Harrison and Coll, 2008

សមីការតាងប្រតិកម្ម

ប្រតិកម្មនៅខាងកាតូត $Cu^{2+}(aq) + 2e^- \Longrightarrow Cu(s)$

ប្រតិកម្មនៅខាងអាណូត $2H_2O(l) \Longrightarrow 4H^+ + O_2(g) + 4e^-$

សិស្សត្រូវបានកំណត់តួនាទីជាអាតូមឬអ៊ីយ៉ុងហើយត្រូវបង្កើតផ្លាកសម្គាល់។ សិស្ស5នាក់ ដើរតួរួមគ្នាជាទង់ដែងកាបូណាត ($CuCO_3$)។ សិស្សកាន់ដៃគ្នាតំណាងសម្ពន្ធកូវ៉ាឡង់នៅក្នុងអ៊ីយ៉ុងកុំផ្លិច និងសម្ពន្ធអ៊ីយ៉ូនិចមួយរវាងអ៊ីយ៉ុងទង់ដែងហើយអេឡិចត្រុងត្រូវបានតំណាងដោយសៀវភៅ2ក្បាលដែលសិស្សកាន់ក្នុងដៃហើយដាក់លើស្មា។ ដូចនេះមុនពេលរលាយក្នុងទឹក យើងមានសិស្សមួយក្រុមដែលមានគ្នា4នាក់កាន់ដៃគ្នា ដែលក្នុងនោះមានសិស្ស2នាក់កាន់សៀវភៅ (អ៊ីយ៉ុង $CO_3^{2-}$) ហើយសៀវភៅនៅលើស្មាសិស្សទី5 (អ៊ីយ៉ុង $Cu^{2+}$)។ ពេលដែលការរលាយចាប់ផ្តើម សិស្សទាំង4នាក់ផ្តាច់ខ្លួនចេញពីសិស្សទី5ដោយយកសៀវភៅមកតាមខ្លួនពួកគេ (អេឡិចត្រុងបង្ហាញថាអ៊ីយ៉ុង $CO_3^{2-}$ មានបន្ទុក)។

នៅក្នុងដំណាក់កាលទី2 សិស្សសម្តែងបង្ហាញ ការកកើតទង់ដែងស៊ុលផាត ($CuSO_4$)។ យើងត្រូវការសិស្ស6នាក់ ដែល5នាក់តំណាងអ៊ីយ៉ុងស៊ុលផាត ម្នាក់តំណាងអ៊ីយ៉ុងទង់ដែងនិងសៀវភៅ2ក្បាលតំណាងអេឡិចត្រុង។ នៅក្នុងប្រតិកម្មនេះអាស៊ីតស៊ុលផួរិចរាវ ($H_2SO_4$)មានប្រតិកម្មជាមួយទង់ដែងកាបូណាតដើម្បីបង្កើតជាទង់ដែងស៊ុលផាត ឧស្ម័នកាបូនិចនិងទឹក។

ជាចុងក្រោយ សម្រាប់លំនាំអគ្គិសនីវិភាគ យើងត្រូវការសិស្ស 2នាក់បន្ថែមទៀតដើម្បីតំណាងទឹកនិងកៅអីពីរតំណាងអេឡិចត្រូត។ សិស្សតំណាងអ៊ីយ៉ុងទង់ដែងដើរទៅកាន់កៅអីមួយទទួលសៀវភៅទាំងពីរក្បាល(អេឡិចត្រុង) ហើយចូលទៅអង្គុយលើកៅអីនោះបង្ហាញថាពួកគេត្រូវបានភ្ជាប់ទៅនឹងអេឡិចត្រូត (កាបូនក្រាភីត)។ អេឡិចត្រូតមួយទៀតក៏ធ្វើពីកាបូនក្រាភីតដែរ។ សិស្សតំណាងម៉ូលេគុលទឹកដើរទៅកាន់កៅអីផ្សេងទៀតហើយដាក់សៀវភៅ2ក្បាលលើកៅអីនោះ។ បន្ទាប់មកសិស្សពីរនាក់កាន់ដៃគ្នាទាំងពីរដើម្បីតំណាង 1ម៉ូលេគុលអុកស៊ីសែនដែលអាតូមទាំងពីរភ្ជាប់គ្នាដោយសម្ពន្ធ2ជាន់ ហើយធ្វើជាដើរវង្វេងចេញពីការសម្តែង (ឧស្ម័នបាត់បង់ពីក្នុងប្រព័ន្ធប្រតិកម្ម)។ សិស្សតំណាងអ៊ីយ៉ុងស៊ុលផាតចល័តដោយសេរី ធ្វើជាអ៊ីយ៉ុងទស្សនិច។






ការសម្តែងតួប្រភេទនេះក៏អាចធ្វើបានសម្រាប់ប្រតិកម្មគីមីផ្សេងៗទៀតដែរ។ គ្រូអាចបង្ហាញប្រតិកម្មគីមីផ្សេងៗគ្នា បន្ទាប់មកសិស្សអាចពិភាក្សាគ្នាជាក្រុមដើម្បីកំណត់តួនាទីដែលគេត្រូវសម្តែង ហើយឡើងសម្តែងតួឱ្យសិស្សផ្សេងៗទៀតមើល ដែលមានសិស្សម្នាក់មានតួនាទីជាអ្នកបង្ហាញ។

| ចំណុចដូច (ចំណុចដូចគ្នារវាងវត្ថុប្រដូចនិងបញ្ញត្តិ) | |
|---|---|
| សិស្ស | អាតូម |
| សិស្ស4នាក់កាន់ដៃគ្នា | អ៊ីយ៉ុងកំផ្លិច |
| សៀវភៅដាក់នៅលើស្មា (មនុស្ស) | អេឡិចត្រុង (អ៊ីយ៉ុង) |
| សិស្សឃ្លាតចេញពីគ្នា | ការរលាយ |
| ខ្យល់ | ទឹក |
| កាន់ដៃគ្នាតែមួយ | សម្ព័ន្ធមួយជាន់ |
| កាន់ដៃគ្នាទាំងពីរ | សម្ព័ន្ធពីរជាន់ |
| កៅអី | អេឡិចត្រូតវិជ្ជមាន |
| កៅអីដែលមានសៀវភៅ | អេឡិចត្រូតអវិជ្ជមាន |

| ចំណុចមិនដូច (ចំណុចខុសគ្នារវាងវត្ថុប្រដូចនិងបញ្ញត្តិ) |
|---|
| សិស្សនិងសៀវភៅមានទំហំធំជាងអាតូមឬអេឡិចត្រុងឆ្ងាយណាស់ |
| កម្លាំងដែលបង្កើតសម្ព័ន្ធភ្ជាប់អាតូមទាំងឡាយជាមួយគ្នាមានតម្លៃធំជាងកម្លាំងដែលប្រើក្នុងការកាន់ដៃគ្នា |
| អាតូមនិងអេឡិចត្រុងមានចំនួនច្រើនជាងចំនួនសិស្សនៅក្នុងថ្នាក់ទៅទៀត |
| រូបរាងរបស់អ៊ីយ៉ុងខុសប្លែកពីការរៀបចំទីតាំងរបស់សិស្ស |













ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ
# តាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល

## ជំពូកទី 6
## ល្បែងសិក្សា



នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ 2012

# សេចក្តីផ្តើម



ល្បែងសិក្សាគឺជាសកម្មភាពមួយដ៏មានប្រសិទ្ធភាពសម្រាប់ការបង្រៀននិងរៀន។ យើងអាចប្រើល្បែងសិក្សាក្នុងការបង្រៀនដើម្បីបំផុសសកម្មភាពសិក្សាបែបរិះរក ធ្វើឱ្យសិស្សស៊ាំជាមួយមេរៀនអរូបីនិងជំរុញឱ្យសិស្សគិតដល់កម្រិតមួយខ្ពស់ជាងមុន។ ការបង្រៀនដោយការលេងល្បែងសិក្សាបង្កើនការយល់ដឹងតាមរយៈការទាក់ទាញឱ្យសិស្សចូលរួមក្នុងសកម្មភាពសិក្សា។ ការលេងល្បែងសិក្សាក្នុងការបង្រៀនមានគោលបំណងដូចតទៅ:

ក. ដើម្បីរំឮកមេរៀន

ខ. ដើម្បីបង្កើតទំនាក់ទំនងថ្មីៗរវាងគោលការណ៍និងខ្លឹមសារនាំឱ្យការយល់ដឹងកាន់តែស៊ីជម្រៅ។

គ. ដើម្បីកំណត់ចំណុចខ្វះខាតនៃចំណេះដឹងឬបំណិន

ល្បែងសិក្សាមានគុណសម្បត្តិសំខាន់ៗដូចជាផ្តល់ឱកាសឱ្យសិស្សប្រើប្រាស់ចំណេះដឹងរបស់គេក្នុងស្ថានភាពមួយថ្មី។មិនតែប៉ុណ្ណោះល្បែងសិក្សាបំផុសសកម្មភាពរស់រវើករវាងសិស្សនិងគ្រូហើយបង្កើនចំណាប់អារម្មណ៍និងសេចក្តីឧស្សាហ៍ព្យាយាមរបស់សិស្ស។

ល្បែងសិក្សាដែលអាចយកទៅប្រើឱ្យមានប្រសិទ្ធភាពគប្បីមានលក្ខណៈសម្បត្តិដូចខាងក្រោម:

ក ). គប្បីកំណត់ថាឈ្នះតាមរយៈការបង្ហាញចំណេះដឹងនិងបំណិនប៉ុណ្ណោះ។ ល្បែងសិក្សាដែលពឹងផ្អែកតែទៅលើសំណាងឬយុទ្ធសាស្ត្រមិនសក្តិសមនឹងប្រើជាល្បែងសិក្សាឡើយ។

ខ ). ល្បែងសិក្សាគួរពិភាក្សាអំពីបញ្ញត្តិឬខ្លឹមសារសំខាន់ៗនៃមេរៀន។

គ ). វិន័យនៃការលេងល្បែងសិក្សាគប្បីសក្តិសមនឹងវ័យនិងកម្រិតលូតលាស់របស់សិស្ស។

ឃ ). មិនគប្បីដកពិន្ទុសិស្សពេលដែលគេឆ្លើយខុសឡើយ។

ង ). សិស្សដែលចូលរួមលេងទាំងអស់គ្នាអាចមានឱកាសឈ្នះដូចគ្នា។

នៅពេលអនុវត្តល្បែងសិក្សាក្នុងការបង្រៀនសូមយកចិត្តទុកដាក់សំណូមពរខាងក្រោម:

- បង្កើតក្រុមដែលមានកម្លាំងស្មើគ្នា
- នៅពេលរៀបចំល្បែងសូមគិតអំពីរបៀបដែលគ្រូអាចវាយតម្លៃការយល់ដឹងរបស់សិស្ស

















# សេចក្ដីផ្ដើម



តាមរយៈរចនាបថរបស់ល្បែង។

- ការតវ៉ាឬមិនអស់ចិត្តរបស់សិស្សគួរដោះស្រាយក្រោយលេងល្បែងចប់នៅក្រៅថ្នាក់ដើម្បីកុំឱ្យរំខានមេរៀន។
- វាយតម្លៃល្បែងសិក្សាក្រោយបង្រៀនចប់។ តើអ្នកបានសម្រេចវត្ថុបំណងនៃការលេងល្បែងនេះដែរឬទេ? តើសិស្សបានចូលរួមដែរឬទេ? គិតរកវិធីដែលអ្នកអាចកែលម្អល្បែងនេះឱ្យកាន់តែប្រសើរ។ អ្នកអាចស្នើសុំឱ្យសិស្សផ្ដល់យោបល់ឬសំណូមពររបស់គេចំពោះការកែលម្អល្បែងនេះដោយផ្ទាល់មាត់ឬដោយសំណេរ។

ល្បែងសិក្សាមានច្រើនប្រភេទ។ ល្បែងមួយចំនួនត្រូវបានដកស្រង់និងកែសម្រួលតាមល្បែងដែលមានប្រជាប្រិយភាពក្នុងទូរទស្សន៍ហើយល្បែងផ្សេងៗទៀតមានប្រភពពីល្បែងប្រជាប្រិយ។ ប្រភេទល្បែងសិក្សាមួយចំនួនមានដូចជា:

- ល្បែងប្រើក្ដារ
- ល្បែងប្រើបណ្ណ
- សំណួរ
- ការសម្ដែងតួ
- ចំណោទល្បងប្រាជ្ញា

នៅក្នុងឯកសារនេះអ្នកអាចសិក្សាឧទាហរណ៍ល្បែងសិក្សាមួយចំនួនដែលអ្នកអាចយកទៅប្រើក្នុងការបង្រៀនមេរៀនវិទ្យាសាស្ត្រ។ ឧទាហរណ៍នីមួយៗបង្ហាញល្បែងមួយប្រភេទដែលអ្នកក៏អាចយកទៅប្រើជាមួយមេរៀនផ្សេងៗទៀតបានដែរ។

សកម្មភាពសិក្សាដ៏មានប្រសិទ្ធភាពមួយផ្សេងទៀតគឺទុកឱ្យសិស្សជាអ្នកបង្កើតល្បែងសិក្សាដោយខ្លួនឯងជាកិច្ចការផ្ទះឬជាពិពណ៌វិទ្យាសាស្ត្រ។ ដើម្បីអាចធ្វើទៅបានមិនត្រឹមតែទាមទារឱ្យសិស្សយល់មេរៀនស៊ីជម្រៅប៉ុណ្ណោះទេពួកគេថែមទាំងត្រូវគិតរកវិធីផ្ទេរចំណេះដឹងទៅសិស្សផ្សេងទៀត និងរបៀបអនុវត្តជាក្រុម។

ការសម្ដែងតួត្រូវបានពិភាក្សាក្នុងឯកសារស្ដីអំពី ការប្រៀបប្រដូចនិងគំរូតាង។



# សកម្មភាព

## 1. សកម្មភាពទី1: ល្បែងលូប ( loop )

### 1.1. សេចក្ដីផ្ដើម



ល្បែងលូប ( loop ) ប្រើសម្រាប់រំឭកមេរៀន ហើយអាចលេងបានច្រើនរបៀប។

### 1.2. វត្ថុបំណង



- បង្កើនការយល់ដឹងអំពីមេរៀនដោយបង្ហាញមេរៀននោះក្នុងស្ថានភាពមួយថ្មី
- ស៊ាំនឹងគំនិតនៅក្នុងល្បែងនេះ

### 1.3. កម្មវិធីសិក្សា



ល្បែងនេះអាចប្រើបានក្នុងមេរៀនជាច្រើនសម្រាប់គ្រប់មុខវិជ្ជាវិទ្យាសាស្ត្រទាំងអស់។

### 1.4. ពេលវេលា



ជំហានទី4

### 1.5. សម្ភារ



រៀបចំបណ្ណឱ្យស្មើនឹងចំនួនសិស្ស។ អុតបណ្ណទាំងនោះដើម្បីឱ្យរឹងមាំប្រើបានយូរ។

### 1.6. ដំណើរការ



- សិស្សម្នាក់ៗទទួលបានបណ្ណមួយសន្លឹក។ បណ្ណនីមួយៗមានសំណួរមួយនិងចម្លើយមួយ ( ជាចម្លើយរបស់សំណួរផ្សេងទៀត )។
- សិស្សម្នាក់ចាប់ផ្ដើមអានសំណួររបស់គាត់ឮៗ។ សិស្សដែលគិតថាមានចម្លើយរបស់សំណួរនេះនៅលើបណ្ណរបស់ខ្លួន ក្រោកឈរហើយអានចម្លើយ។ ប្រសិនបើនោះជាចម្លើយត្រឹមត្រូវ សិស្សម្នាក់នេះបន្តដោយអានសំណួរនៅលើបណ្ណរបស់ខ្លួន។ សិស្សដែលមានចម្លើយត្រឹមត្រូវរបស់សំណួរនេះ ក្រោកឈរឡើងហើយអានចម្លើយនោះឮៗ និងធ្វើបែបនេះរហូតដល់អានអស់សំណួរ និងចម្លើយទាំងអស់។
- ប្រសិនបើនៅសល់ពេល អ្នកអាចលេងល្បែងនេះម្ដងទៀត។ លើកទឹកចិត្តសិស្សឱ្យប្រើពេលឱ្យកាន់តែតិចជាងការលេងលើកទីមួយ។

















## 1.7. ឧទាហរណ៍



សូមមើលឧទាហរណ៍នៃបណ្ណមួយឈុតនៅក្នុងឧបសម្ពន្ធសម្រាប់មុខវិជ្ជាគីមីវិទ្យា (អាតូម)។ សំណួរទាំងនេះសម្រាប់ជូនលោកគ្រូអ្នកគ្រូប្រើជាចំណុចចាប់ផ្តើម។ អ្នកអាចប្តូរសំណួរទៅតាមកម្រិតរបស់សិស្សនិងខ្លឹមសារមេរៀន។

សម្រាប់មុខវិជ្ជាជីវវិទ្យាអ្នកអាចបង្កើតល្បែងនេះសម្រាប់មេរៀនប្រដាប់រំលាយអាហារ។ រីឯមុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យាវិញ អ្នកអាចបង្កើតល្បែងនេះសម្រាប់មេរៀនប្រព័ន្ធព្រះអាទិត្យ។

## 1.8. ដំបូន្មានសំខាន់ៗ



គេអាចលេងល្បែងនេះជាក្រុមដែលមានគ្នាតិចក៏បាន។ នៅក្នុងឧបសម្ពន្ធអ្នកអាចឃើញបណ្ណមួយឈុតតម្រៀបតាមលំដាប់ត្រឹមត្រូវ។ សូមលាយច្របល់បណ្ណទាំងនោះហើយចែកឱ្យសិស្ស។ ពួកគេត្រូវផ្គូផ្គងសំណួរជាមួយចម្លើយដែលត្រឹមត្រូវហើយបង្កើតជារាងស៊ុមមួយ។ ទន្ទឹមនឹងនេះ គ្រូអាចចល័តទៅមកដើម្បីពិនិត្យភ្លាមៗថាសិស្សតម្រៀបបានត្រឹមត្រូវឬទេ។

# 2. សកម្មភាពទី2: ល្បែងប៊ីងហ្គោធាតុគីមី( គីមីវិទ្យា )

## 2.1. សេចក្តីផ្តើម



ល្បែងនេះប្រើសម្រាប់សិក្សាអំពីតារាងខួបនៃធាតុគីមី។ សិស្សលេងល្បែងនេះដូចគ្នានឹងល្បែងប៊ីងហ្គោធម្មតាដែរ ខុសគ្នាតែត្រង់ធាតុគីមីនៅលើសន្លឹកល្បែងនេះប៉ុណ្ណោះ។ យើងរំពឹងថាសិស្សនឹងទទួលបាននូវភាពរីករាយនិងចូលរួមយ៉ាងសកម្ម។



## 2.2. វត្ថុបំណង



បង្ហាញធាតុគីមីក្នុងតារាងខួបនៃធាតុគីមីដោយប្រើឈ្មោះនិងនិមិត្តសញ្ញានៃធាតុនោះ



## 2.3. កម្មវិធីសិក្សា



ថ្នាក់ទី9 ជំពូកទី1 មេរៀនទី1 (ឆ្នាំ2011)

## 2.4. ពេលវេលា



សម្រាប់បង្រៀនខ្លឹមសារថ្មីក្នុងជំហានទី3 និងពង្រឹងពុទ្ធិក្នុងជំហានទី4។

## 2.5. សម្ភារ



- បង្កើតបណ្ណប៊ីងហ្គោស្មើនឹងចំនួនសិស្សក្នុងថ្នាក់ (ក្នុងឧបសម្ពន្ធមានបណ្ណប៊ីងហ្គោចំនួន30បណ្ណប៉ុន្តែអ្នកអាចធ្វើបន្ថែមលើសនេះទៀតក៏បាន)។
- បង្កើតបញ្ជីរាយធាតុគីមីមួយសន្លឹកតាមលំដាប់ដែលអ្នកនឹងអានឮៗ ទៅកាន់សិស្ស។ អ្នកអាចប្រើបញ្ជីនេះដើម្បីត្រួតពិនិត្យថាសន្លឹកប៊ីងហ្គោរបស់សិស្សត្រឹមត្រូវ។ បើអ្នកគ្រោងនឹងលេងល្បែងនេះប៉ុន្មានលើក អ្នកក៏ត្រូវបង្កើតបញ្ជីនេះចំនួនប៉ុណ្ណោះដែរ។

## 2.6. ដំណើរការ



- ផ្តល់ឱ្យសិស្សម្នាក់ៗនូវបណ្ណមួយសន្លឹក (សូមមើលឧបសម្ពន្ធ)។ នេះជាសន្លឹកចម្លើយសម្រាប់ពួកគេ។
- សិស្សដាក់សន្លឹកកិច្ចការប៊ីងហ្គោនៅខាងមុខរៀងៗខ្លួន។ បន្ទាប់មកគ្រូហៅឈ្មោះធាតុគីមី។ សិស្សដាក់វត្ថុសម្គាល់នៅលើធាតុដែលត្រូវនឹងអ្វីដែលគ្រូបានហៅ។ សិស្សដែលទទួលបានធាតុប្រាំមុនគេតាមជួរឈរ ជួរដេក ឬបន្ទាត់បញ្ឆិត ជាអ្នកឈ្នះ។

## 2.7. ឧទាហរណ៍



ល្បែងនេះត្រូវបានរៀបចំសម្រាប់មេរៀនតារាងខួបនៃធាតុគីមី(ក្នុងមុខវិជ្ជាគីមី) ប៉ុន្តែអ្នកក៏អាចប្រើទម្រង់របស់ល្បែងប៊ីងហ្គោសម្រាប់មេរៀនក្នុងមុខវិជ្ជាផ្សេងទៀតដែរ។ ឧទាហរណ៍ ក្នុងមុខវិជ្ជាជីវវិទ្យាអ្នកអាចបង្កើតល្បែង ប៊ីងហ្គោសម្រាប់មេរៀនអំពីសារពាង្គកាយមនុស្ស។

## 2.8. ដំបូន្មានសំខាន់ៗ



សិស្សអាចលេងល្បែងនេះជាបុគ្គលជាដៃគូឬជាក្រុម។ជម្រើសល្អបំផុតគឺសិស្សលេងល្បែងនេះរៀងៗខ្លួនដើម្បីពង្រឹងការយល់ដឹងរបស់សិស្សអំពីធាតុគីមីនិងវិធីសិក្សារបស់សិស្សរៀងៗខ្លួនអំពីឈ្មោះនិងនិមិត្តសញ្ញារបស់ធាតុ។

ក្រៅពីការហៅឈ្មោះធាតុគីមីដោយខ្លួនឯង គ្រូក៏អាចឱ្យសិស្សអានឈ្មោះធាតុក្នុងបញ្ជីម្តងមួយៗ។

















## 3. សកម្មភាពទី3: ល្បែងថាប៊ូ ( Taboo )

### 3.1. សេចក្តីផ្តើម



ល្បែងនេះជួយឱ្យសិស្សយល់និងចងចាំពាក្យគន្លឹះក្នុងមេរៀន។ សិស្សព្យាយាមបង្កើតនិយមន័យនៃពាក្យគន្លឹះមួយដោយខ្លួនឯង។ សិស្សផ្សេងៗទៀតស្តាប់ហើយព្យាយាមទស្សន៍ទាយពាក្យគន្លឹះនោះ។ ល្បែងនេះអភិវឌ្ឍបំណិនត្រិះរិះរបស់សិស្ស។ សិស្សត្រូវទស្សន៍ទាយពាក្យនៅផ្នែកខាងលើនៃបណ្ណដោយមិននិយាយចេញនូវពាក្យណាមួយដែលស្ថិតនៅខាងក្រោមបន្ទាត់ឡើយ ព្រោះការនិយាយពាក្យទាំងនោះត្រូវបាន"ហាមឃាត់"។



ឧទាហរណ៍: ចូរពន្យល់ពាក្យ << ពងមាន់ >> ដោយមិនប្រើពាក្យ << មាន់ >>

### 3.2. វត្ថុបំណង



- រំឭកពាក្យគន្លឹះនិងពង្រឹងការយល់ដឹងអំពីពាក្យគន្លឹះ
- បំផុសបំណិនគិតរបស់សិស្ស

### 3.3. កម្មវិធីសិក្សា



គ្រូអាចប្រើល្បែងថាប៊ូក្នុងមេរៀនជាច្រើនសម្រាប់គ្រប់មុខវិជ្ជាវិទ្យាសាស្ត្រទាំងអស់។

### 3.4. ពេលវេលា



ប្រើក្នុងជំហានទី4

### 3.5. សម្ភារ



- ក្រដាសរឹងតូច
- ហ្វឺតពណ៌ ឬខ្មៅដៃពណ៌ ( មិនសូវចាំបាច់ )




## 3.6. ដំណើរការ



- ចែកសិស្សជាក្រុមហើយពន្យល់វិន័យក្នុងការលេងល្បែងនេះ។
- ជ្រើសរើសសិស្សម្នាក់ដើម្បីឃ្លាំមើលសិស្សដែលត្រូវឡើងមកពន្យល់និយមន័យរបស់ពាក្យគន្លឹះ។ តួនាទីរបស់អ្នកឃ្លាំមើលគឺតាមដានថាតើសិស្សដែលពន្យល់និយមន័យបានប្រើពាក្យដែលត្រូវបានហាមឃាត់ដែរឬទេ ?
- ជ្រើសរើសសិស្សម្នាក់ដើម្បីលេងល្បែងនេះ។ គាត់ត្រូវជ្រើសរើសយកបណ្ណមួយដែលមានសរសេរពាក្យគន្លឹះនៅលើនោះ។
- គាត់ត្រូវធ្វើយ៉ាងណាឱ្យសិស្សផ្សេងទៀតអាចទស្សន៍ទាយពាក្យគន្លឹះបានត្រឹមត្រូវដោយប្រើពេលខ្លីបំផុត។ បើគាត់និយាយចេញនូវពាក្យណាមួយដែលត្រូវបានហាមឃាត់ គាត់ត្រូវត្រលប់មកកន្លែងវិញ ហើយសិស្សម្នាក់ផ្សេងទៀតត្រូវឡើងមកជំនួស។
- ក្រុមដែលទស្សន៍ទាយត្រូវមួយពាក្យនឹងទទួលបានមួយពិន្ទុ។

វិន័យក្នុងការលេងល្បែងថាប៉ូ:

- មិនត្រូវនិយាយចេញនូវពាក្យណាមួយនៅលើបណ្ណឡើយ។
- មិនត្រូវធ្វើកាយវិការបង្ហាញឡើយ។
- មិនអនុញ្ញាតឱ្យប្រើពាក្យមួយចំនួនដូចជា "មានសូរដូចនឹង" ឬ "មានសូរច្នួនគ្នានឹង"
- ហាមប្រើពាក្យ ឬអក្សរកាត់ ប្រសិនបើមានពាក្យពេញនៅលើបណ្ណ

## 3.7. ឧទាហរណ៍



ជីវវិទ្យា: តំណពូជ

| ចូរពន្យល់ពាក្យខាងក្រោម | ដោយមិនប្រើពាក្យ....... |
|---|---|
| សែន | • ណែ្សយ៉ូ<br>• ក្រូម៉ូសូម |
| ក្រូម៉ូសូម | • កោសិកា<br>• ណែ្សយ៉ូ<br>• សែន |
| ការបង្កាត់ជ្រើស | • ការជ្រើសរើស<br>• លក្ខណៈ |
| ការក្លូន | • ដូចគ្នា<br>• ដោយឥតភេទ<br>• មេបា |





















### ជីវវិទ្យា: ទម្រង់កោសិកា

| ចូរពន្យល់ពាក្យខាងក្រោម | ដោយមិនប្រើពាក្យ....... |
|---|---|
| ភ្នាសគ្រោងកោសិកា | • រុក្ខជាតិ<br>• ទម្រង់<br>• រូបរាង |
| ភ្នាសកោសិកា | • រុក្ខជាតិ<br>• សត្វ<br>• ត្រួតពិនិត្យ |
| ណ្វៃយ៉ូកោសិកា | • ត្រួតពិនិត្យ<br>• ក្រូម៉ូសូម<br>• ADN |

### ផែនដី និងបរិស្ថានវិទ្យា

| ចូរពន្យល់ពាក្យខាងក្រោម | ដោយមិនប្រើពាក្យ....... |
|---|---|
| តេលេទស្សន៍ | • តារា<br>• មណ្ឌលសង្កេតតារា<br>• តារាវិទូ<br>• ភព |

### រូបវិទ្យា

| ចូរពន្យល់ពាក្យខាងក្រោម | ដោយមិនប្រើពាក្យ....... |
|---|---|
| ចរន្តវិលវល់ | • កម្តៅ<br>• ចលិតឡើងលើ<br>• ត្រជាក់<br>• ខាប់<br>• លិចចុះ |

## 3.8. ដំបូន្មានសំខាន់ៗ



អ្នកក៏អាចឱ្យសិស្សលេងល្បែងនេះជាក្រុមដែរ។ នៅក្នុងក្រុមដែលមានសមាជិកពី2-4នាក់ សិស្សអាចដាក់វេនគ្នាពន្យល់ពាក្យ។ សិស្សដែលឆ្លើយត្រូវពាក្យគន្លឹះរក្សាទុកបណ្ណនោះ។ បន្ទាប់មកអ្នកលេងបន្ទាប់ព្យាយាមពន្យល់ពាក្យ។

ល្បែងនេះអាចលេងទៅតាមពេលវេលាដែលមាន។ បើសល់តែ5នាទី សិស្សអាចលេងតែ2ជុំ តែបើសល់ពេលច្រើនជាងនេះ សិស្សអាចលេងបានកាន់តែច្រើនជុំ។

ផ្តល់ឱកាសឱ្យសិស្សបង្កើតបណ្ណថាប៉ូដោយខ្លួនឯង។ ផ្តល់ឱ្យសិស្សនូវបណ្ណទទេដូចរូបខាងក្រោម។ សិស្សប្រើខ្មៅដៃនិងហ្វឺតពណ៌ (បើមាន) ដើម្បីបង្កើតបណ្ណថាប៉ូ។




# 4. សកម្មភាពទី 4: ល្បែងក្ដារ

## 4.1. សេចក្ដីផ្ដើម



ល្បែងក្ដារជាល្បែងចត្រង្គ ដែលអ្នកលេងជាក្រុមត្រូវដើរកូនចត្រង្គនៅលើក្ដារនេះឱ្យបានឆាប់បំផុត។ ដើម្បីដើរនៅលើក្ដារនេះគេត្រូវបោះគ្រាប់ឡុកឡាក់និងឆ្លើយសំណួរ។ ចំណុចខ្លះទាមទារឱ្យសិស្សធ្វើសកម្មភាពមួយចំនួនដូចជាធ្វើសំណួរដែលទាមទារការគណនា ផ្លាស់ទីកូនចត្រង្គរបស់គូប្រកួត។ ការលេងល្បែងនេះទាមទាររយៈពេលយ៉ាងហោចណាស់1ម៉ោង អាស្រ័យលើចំនួនក្រុមនិងកម្រិតសំណួរពិបាកឬស្រួល។ យ៉ាងណាមិញ ការលេងល្បែងនេះជាសកម្មភាពរំឭកមេរៀនដ៏មានប្រយោជន៍។





## 4.2. វត្ថុបំណង



- បង្កើនការយល់ដឹងវិទ្យាសាស្ត្រ
- ទទួលស្គាល់អត្ថប្រយោជន៍នៃល្បែងសិក្សាក្នុងមេរៀនវិទ្យាសាស្ត្រ
- អនុវត្តល្បែងសិក្សាក្នុងការបង្រៀនវិទ្យាសាស្ត្រ

## 4.3. កម្មវិធីសិក្សា



ល្បែងនេះអាចលេងបានសម្រាប់គ្រប់មេរៀន។ ដោយល្បែងនេះត្រូវការពេលវេលាច្រើន វាសក្តិសមសម្រាប់សកម្មភាពរំឭកមេរៀន។ ល្បែងនេះអាចរំឭកមេរៀនច្រើនក្នុងពេលតែមួយ ដូចជាមេរៀនទាំងអស់ក្នុងមួយឆមាសឬក្នុងមួយឆ្នាំជាដើម។

## 4.4. ពេលវេលា



ល្បែងនេះត្រូវការពេលលេងពេញមួយម៉ោង ដូចនេះគប្បីលេងល្បែងនេះនៅពេលបង្រៀនមេរៀនមួយចំនួនចប់។





















## 4.5. សម្ភារ



- ក្តារចត្រង្គសម្រាប់លេងល្បែង
- គ្រាប់ឡុកឡាក់
- សំណួរ (នៅលើក្រដាស)
- ក្តារខៀន
- ហ្វីត

ប្រសិនបើអាច គប្បីភ្ជាប់បន្ទះចត្រង្គទៅនឹងបន្ទះមេដែក។ កូនចត្រង្គដែលជាមេដែក អាចចល័តបាន ប៉ុន្តែត្រូវបានស្រូបទាញជាប់នឹងបន្ទះចត្រង្គ។

## 4.6. ដំណើរការ



ការពិពណ៌នាអំពីបន្ទះចត្រង្គ

- លេខទាំងអស់មានប្រាំពណ៌ដែលពណ៌នីមួយៗតំណាងមេរៀនមួយ។ នៅក្នុងល្បែងដែលបានបង្កើត ពណ៌បៃតងតំណាងក្រុមសំណួរសម្រាប់មេរៀនមេកានិច ពណ៌លឿងតំណាងក្រុមសំណួរក្នុងមេរៀនអុបទិច ពណ៌ក្រហមតំណាងមេរៀនកម្ដៅ ពណ៌ត្នោតតំណាងមេរៀនអគ្គិសនីនិងម៉ាញ៉េទិច និងពណ៌ទឹកក្រូចតំណាងមេរៀនសម្ពាធ។




- បន្ទះចត្រង្គនេះមានកាំពិសេសៗមួយចំនួន។ ពេលដែលសិស្សដើរកូនចត្រង្គមកដល់ទីតាំងទាំងនេះគេត្រូវធ្វើលំហាត់មួយ។ក្រោយពេលធ្វើចប់ គេសុំឱ្យគ្រូពិនិត្យមើលចម្លើយរបស់គេ។ លេខនេះហៅថា "លេខរំលងមួយវេន" ប៉ុន្តែបើសិស្សធ្វើបានលឿន ពួកគេអាចរួចខ្លួនពីការរំលងមួយវេន។ គេក៏អាចជួបនឹងការរំលង2វេនដែរ ដែលនេះជាការរំលងអតិបរមា។
- អ្នកអាចបញ្ចូលទីតាំងពិសេសផ្សេងទៀតក្នុងបន្ទះចត្រង្គរបស់អ្នក ឧទាហរណ៍ដូចជា អនុញ្ញាតឱ្យអ្នកលេងដើរកូនចត្រង្គទៅមុខ5កាំ ឬបញ្ជាឱ្យដើរថយក្រោយ5កាំ។




- នៅក្នុងគំរូដែលបានបង្កើតរួចមកហើយ យើងបានបញ្ចូលទីតាំងមួយដែលបញ្ជាថា "ប្តូរ" (ដូចក្នុងរូបខាងក្រោម)។ បើក្រុមណាមួយដើរមកឈប់ត្រឹមទីតាំងនេះ គេមានសិទ្ធិអាចប្តូរទីតាំងជាមួយកូនចត្រង្គរបស់ក្រុមផ្សេងទៀត (ជាទូទៅ គេប្តូរជាមួយក្រុមដែលដើរលឿនជាងគេ)។ ចំណុចនេះបញ្ជាក់ថាលេងល្បែងនេះក៏ត្រូវការសំណាងដែរ។

**វិន័យក្នុងការលេងល្បែង**

- ចែកសិស្សជាក្រុមដែលមានសមាជិកច្រើនបំផុត4នាក់។ គ្រូអាចជ្រើសរើសចំនួនក្រុមដែលត្រូវចូលរួមលេងដោយខ្លួនឯង ប៉ុន្តែល្អបំផុតមិនគួរលើសពី5-6ក្រុមឡើយ។ ក្រុមនីមួយៗមានគ្រាប់ឡុកឡាក់មួយសម្រាប់បោះ។
- អ្នកអាចជ្រើសរើសសិស្សម្នាក់ធ្វើជាជំនួយការដើម្បីផ្លាស់ទីកូនចត្រង្គ។
- គ្រូអាចព្យួរបន្ទះចត្រង្គនៅខាងមុខដើម្បីឱ្យសិស្សបានឃើញច្បាស់ទាំងអស់គ្នា។ ក្រុមនីមួយៗចាប់ផ្តើមបោះគ្រាប់ឡុកឡាក់ ដោយក្រុមដែលបោះបានចំនួនច្រើនជាងគេ ចាប់ផ្តើមដើរចំនួនជំហានត្រូវនឹងចំនួនដែលខ្លួនបោះបាន។
- អានសំណួរក្នុងមេរៀនដែលត្រូវនឹងពណ៌ដែលកូនចត្រង្គស្ថិតនៅ។ គ្រូផ្តល់ពេលខ្លីសម្រាប់ពិភាក្សានិងឆ្លើយ។ មានតែសមាជិកក្រុមដែលដល់វេនឆ្លើយទើបអាចឆ្លើយបាន។ គ្រូក៏អាចជ្រើសរើសសិស្សម្នាក់ជាតំណាងក្រុមសម្រាប់ឆ្លើយសំណួរ។
- បើឆ្លើយត្រូវ កូនចត្រង្គស្ថិតនៅទីតាំងដែលបោះបាន ប៉ុន្តែបើឆ្លើយខុសត្រូវដើរកូនចត្រង្គថយក្រោយចំនួន2កាំ។
- ក្រុមដែលដើរដល់ទីបញ្ចប់មុនគេជាអ្នកឈ្នះ



សំណួរ

អ្នកអាចប្រើប្រភេទសំណួរខុសៗគ្នា។ អ្នកអាចកំណត់ឱ្យសិស្សគូររូបនៅលើក្តារខៀន ប្រើប្រភេទសំណួរខុសឬត្រូវ សំណួរពហុជ្រើសរើស ឬចំណោទខ្លីៗ។

## 4.7. ឧទាហរណ៍






នៅក្នុងឧបសម្ព័ន្ធ អ្នកអាចរកបានឧទាហរណ៍នៃសំណួរមួយចំនួនសម្រាប់ល្បែងដែលយើងបានបង្កើតសម្រាប់មុខវិជ្ជារូបវិទ្យា។ សម្រាប់មុខវិជ្ជាជីវវិទ្យា អ្នកអាចបង្កើតល្បែងមួយដែលពណ៌នីមួយៗតំណាងឱ្យផ្នែកផ្សេងៗនៃសារពាង្គកាយមនុស្ស។

ចំពោះមុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យា អ្នកអាចប្រើល្បែងនេះដើម្បីត្រួតពិនិត្យចំណេះដឹងរបស់សិស្សដែលទទួលបានពីការសិក្សាមេរៀនតារាវិទ្យា។ ឧទាហរណ៍:

ពណ៌ក្រហម: សំណួរអំពីភពនៃប្រព័ន្ធព្រះអាទិត្យ
ពណ៌លឿង: សំណួរអំពីព្រះអាទិត្យ
ពណ៌ខៀវ: សំណួរអំពីផែនដី
ពណ៌ប្រផេះ: សំណួរអំពីព្រះចន្ទ
ពណ៌បៃតង: សំណួរអំពីសកល


















## 4.8. ដំបូន្មានសំខាន់ៗ



ក្រោយពីលេងចប់ គ្រូអាចសួរសិស្សទាំងអស់គ្នាដើម្បីវាយតម្លៃល្បែងនេះ។ តើគេនឹងធ្វើយ៉ាងណាដើម្បីកែលម្អល្បែងនេះឱ្យកាន់តែប្រសើរ ? តើគេយល់ថាការលេងល្បែងនេះជាសកម្មភាពរំឭកមេរៀនដ៏មានប្រយោជន៍ដែរឬទេ ? តើគេទទួលបានចំណេះដឹងតាមរយៈការលេងល្បែងនេះដែរឬទេ ?





# ឯកសារយោង

## គោលវិធីសិស្សមជ្ឈមណ្ឌល

## សៀវភៅ


- Angelo, T.A. & Cross, K.P. (1993) Classroom Assessment Techniques, Jossey Bass, - Wiley & Sons, San Francisco, California, USA.
- Churchill, E.R. et al. (1997) 365 Simple Science Experiments with Everyday Materials, Black Dog & Leventhal Publishers, New York.
- Driver, R. et al. (1994) Making Sense of Secondary Science: Research into Children's Ideas, Routledge.
- Harrison, A.G. & Coll, R.K. (2008) Using Analogies in Middle and Secondary Science Classrooms, Corwin Press, Thousand Oaks, California, USA.
- Harrison, A.G. and Coll, R. K (2007) Using analogies in middle and secondary science classrooms: The FAR Guide, Sage.
- Harrison, A.G. and Treagust, D.F. (1993) Teaching with Analogies: A Case Study in Grade-10 Optics, Journal Of Research In Science Teaching, Vol. 30, No. 10, pp. 1291-1307
- Herr, N. (2008) The Sourcebook for Teaching Science, Jossey Bass, - Wiley & Sons, San Francisco, California, USA.
- Keeley, P. (2008) Science Formative Assessment, NSTA Press – Corwin Press, Thousand Oaks, Californa, USA.
- Keeley, P. et al. (2005) Uncovering Student Ideas in Science: 25 Formative Assessment Probes, Vol. 1, NSTA Press.
- Keeley, P. et al. (2007) Uncovering Student Ideas in Science: 25 Formative Assessment Probes, Vol. 2, NSTA Press.
- Keeley, P. et al. (2009) Uncovering Student Ideas in Science: 25 Formative Assessment Probes, Vol. 4, NSTA Press.
- Mazur, E. (1997) Peer Instruction: A User's Manual, Prentice Hall.
- McDaniel, M.A. and Donnelly, C.M. (1996) Learning with Analogy and Elaborative Interrogation.
- Naylor, S., Downing, B. and Keogh, B. (2001) An empirical study of argumentation in primary science, using Concept Cartoons as the stimulus. Third International Conference of the European Science Education Research Association. Thessaloniki, Greece.
- Naylor, S. and Keogh, B. (2000) Concept Cartoons in Science Education, Millgate House Publishers.
- Tweed, A. (2009) Designing Effective Science Instruction, NSTA press, Arlington, Virginia, USA.






















# គេហទំព័រ

**រូបវិទ្យា:**

- http://galileo.harvard.edu

**គីមីវិទ្យា:**

- http://www.chem.wisc.edu/~concept/
- http://www.chemcollective.org/find.php

**ផែនដីនិងបរិស្ថានវិទ្យា:**

- http://serc.carleton.edu/resources/1302.html: Assessment and Active Learning Strategies for Introductory Geology Courses
- http://serc.carleton.edu/resources/21699.html: Using ConcepTests to Assess and Improve Student Conceptual Understanding in Introductory Geoscience Courses
- http://serc.carleton.edu/introgeo/interactive/ctestexm.html: Concept Tests for many earth science topics.













vvob
education for development

With the support of
THE BELGIAN
DEVELOPMENT COOPERATION

With the support of
the government of Flanders